គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និង
ការពារសិទ្ធិស្ត្រី និងកុមារ (ACWC)

# សៀវភៅមគ្គុទេសក៍

## ស្តីពីការពិនិត្យតាមដាន ការអនុវត្តអភិក្រមឆ្លើយតបចំពោះ អំពើជួញដូរមនុស្ស ដែលផ្តោតលើ ជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ



asean

Australian Aid | ASEAN-Australia Counter Trafficking

ខែកញ្ញា ឆ្នាំ ២០២៣

សេចក្តីបដិសេធ៖ សៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបចំឡើងដោយគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) គាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ។ ទស្សនៈដែលបានបង្ហាញ នៅក្នុងសៀវភៅមគ្គុទេសក៍នេះ គឺជាទស្សនៈយល់ឃើញរបស់អ្នកនិពន្ធតែឯង និងមិនមែនជាទស្សនៈយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលីនោះឡើយ។

# មាតិកា


| | | |
|---|---|---|
| ១. | **អារម្ភកថារបស់ប្រធាន ACWC** | ៥ |
| ២. | **អក្សរកាត់ និងពាក្យកាត់** | ៧ |
| ៣. | **វាក្យសព្ទគន្លឹះ** | ៨ |
| ៤. | **សារបាន** | ១៣ |
| ៥. | **អំពីសៀវភៅមគ្គទេសក៍នេះ** | ១៤ |
| ៦. | **តើសៀវភៅមគ្គទេសក៍នេះ ត្រូវបានរៀបចំឡើងដោយរបៀបណា** | ១៦ |
| ៧. | **ក្រុមគោលដៅ** | ២០ |
| ៨. | របៀបប្រើប្រាស់សៀវភៅមគ្គទេសក៍នេះ | ២១ |
| ១៣. | **ការបង្កើនការយល់ដឹង និងការទប់ស្កាត់អំពើជួញដូរមនុស្ស** | ២៦ |
| ១៤. | ឧទាហរណ៍អំពីការអនុវត្តល្អពាក់ព័ន្ធនឹងការបង្កើនការយល់ដឹង និងការទប់ស្កាត់អំពើជួញដូរមនុស្ស. | ៣៥ |
| ១៥. | **ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ** | ៣៦ |
| ១៦. | ឧទាហរណ៍បង្ហាញពីការអនុវត្តល្អ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ | ៥៤ |
| ១៧. | **ការស្តារឡើងវិញ ការឆ្លុះបញ្ចាំង និងជម្រកសុវត្ថិភាព** | ៥៥ |
| ១៨. | ឧទាហរណ៍ បង្ហាញពីការអនុវត្តល្អពាក់ព័ន្ធនឹងការស្តារឡើងវិញ ការឆ្លុះបញ្ចាំង និងជម្រកសុវត្ថិភាព | ៦៣ |
| ១៩. | **ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម** | ៦៤ |
| ២០. | ឧទាហរណ៍ ដែលបង្ហាញពីការអនុវត្តល្អពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម | ៧១ |
| ២១. | **ការថែទាំវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត** | ៧២ |
| ២២. | ឧទាហរណ៍អំពីការអនុវត្តល្អពាក់ព័ន្ធនឹងការផ្តល់សេវាវេជ្ជសាស្ត្រនិងសេវាថែទាំសុខភាពផ្លូវចិត្ត.. | ៧៩ |
| ២៣. | **ដំណើរការយុត្តិធម៌** | ៨០ |
| ២៤. | ឧទាហរណ៍បង្ហាញពីការអនុវត្តល្អពាក់ព័ន្ធនឹងដំណើរការយុត្តិធម៌ | ១០៥ |
| ២៥. | **ឧបសម្ព័ន្ធទី១៖ សូចនាករជាតុចេញ** | ១០៦ |
| ២៦. | **ឧបសម្ព័ន្ធទី២៖ ការប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្សផ្អែកតាមយេនឌ័រពិការភាពនិងបរិយាបន្ននៃមនុស្សពេញវ័យដែលងាយរងគ្រោះ** | ១០៨ |

# អារម្ភកថារបស់ប្រធាន ACWC

កន្លងមក មានការសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើន ក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើជួញដូរមនុស្ស (TIP) ដែលជាការប្តេជ្ញាចិត្តមួយ ក្នុងចំណោមការប្តេជ្ញាចិត្តសំខាន់ៗ ដែលបានទទួលការឯកភាពរួមគ្នាពីប្រទេសជាសមាជិកអាស៊ាន។ ការអនុម័តអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ហៅកាត់ថា ACTIP) កាលពីឆ្នាំ ២០១៥ ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិកអាស៊ានទាំងអស់ ដោយគ្មានការជំទាស់ពីរដ្ឋជាសមាជិកណាមួយឡើយ និងជាសមិទ្ធផលដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រអាស៊ាន ដែលមានឯកសារចងកាតព្វកិច្ចតាមផ្លូវច្បាប់បែបនេះ។ ទោះជាយ៉ាងនេះក្តី អំពើជួញដូរមនុស្សនៅតែបន្តកើតមានឡើង ជាពិសេស អំពើជួញដូរស្ត្រី និងកុមារ ហើយអំពើទាំងនេះបន្តមានការវិវឌ្ឍឥតឈប់ឈរ។

ជាផ្នែកមួយនៃបេសកកម្មលើកកម្ពស់សិទ្ធិស្ត្រី និងកុមារ ក្នុងតំបន់ទាំងមូល គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធស្ត្រី និងកុមារ (ហៅកាត់ថា ACWC) បន្តជំរុញឱ្យមានការគោរពសិទ្ធិស្ត្រី និងកុមារ និងលុបបំបាត់អំពើជួញដូរមនុស្ស។ ដោយសហការជាមួយវិស័យសំខាន់ៗ ACWC បានរៀបចំគោលការណ៍ណែនាំ និងក្របខ័ណ្ឌជាច្រើន ដើម្បីពង្រឹង សមត្ថភាពគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ នៅក្នុងបរិបទនៃការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំនៅថ្នាក់តំបន់ជាច្រើន ត្រូវបានរៀបចំឡើង។ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំទាំងនេះ រួមមាន មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ ក្នុងការការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ សម្រាប់ឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគោលការណ៍ណែនាំស្តីពីការធ្វើការងារជាមួយស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ។ គោលការណ៍ណែនាំទាំងនេះ មានគោលបំណងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ដើម្បីផ្តល់ការការពារប្រកបដោយអត្ថន័យ ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងផ្តល់ការគាំទ្រដល់ជនរងគ្រោះទាំងនេះ តាមរយៈការអនុវត្តអភិក្រមផ្តោតលើជនរងគ្រោះ និងឆ្លើយតបចំពោះយេនឌ័រ។

ACWC ទទួលស្គាល់ពីភាពចាំបាច់ក្នុងការវាស់វែងវឌ្ឍនភាពដែលសម្រេចបាន ព្រមទាំងវិសាលភាពនៃការអនុវត្តអភិក្រមផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ដើម្បីបង្ហាញឱ្យឃើញពីផលជះនៃអភិក្រមទាំងនេះ និងកំណត់ពីចំណុចដែលត្រូវធ្វើការកែលម្អបន្ថែម។ ដោយសហការជាមួយកម្មវិធីប្រឆាំងការជួញដូរមនុស្សអាស៊ាន-អូស្ត្រាលី (ASEAN-ACT) សៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ការពិនិត្យតាមដានការអនុវត្តអភិក្រមផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។ រដ្ឋជាសមាជិកអាស៊ានទាំងអស់ ស្ថាប័នតាមវិស័យរបស់អាស៊ាន ព្រមទាំងតួអង្គពាក់ព័ន្ធដែលចូលរួមក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់ អាចប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ ដើម្បីប្រមូលទិន្នន័យឱ្យមានសង្គតិភាព និងធ្វើការវាយតម្លៃ ក៏ដូចជាឆ្លុះបញ្ចាំងថាតើខ្លួនបានគោរពតាមគោលការណ៍អភិក្រមផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ក្នុងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងកម្រិតណា។

ACWC ជឿថា តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្ស គឺជាគន្លឹះសម្រាប់ការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញា ACTIP ប្រកបដោយប្រសិទ្ធភាព។ តម្លាភាព និងគណនេយ្យភាព អាចសម្រេចទៅបាននៅពេលដែលគេមានទិន្នន័យ ដែលងាយស្រួលប្រើប្រាស់ និងត្រូវបានប្រើប្រាស់សម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងមានឥទ្ធិពលលើការរៀបចំច្បាប់ គោលនយោបាយ និងការអនុវត្តនានា។ សៀវភៅមគ្គុទេសក៍នេះ ផ្តល់នូវក្របខណ្ឌ និងឧបករណ៍សម្រាប់ឱ្យស្ថាប័ននានា យកទៅប្រើប្រាស់ ដើម្បីប្រមូលទិន្នន័យស្តីពីការអនុវត្តអភិក្រមឆ្លើយតបចំពោះការជួញដូរមនុស្ស ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ប្រកបដោយប្រសិទ្ធភាព។ គេអាចកំណត់ និងឆ្លើយតបចំពោះចំណុចខ្វះខាតនៅក្នុងការអនុវត្ត ចងក្រងឯកសារអំពីវឌ្ឍនភាពដែលសម្រេចបាន ហើយស្ថាប័ននានាអាចប្រើប្រាស់សមិទ្ធផលដែលសម្រេចបានកន្លងមកជាមូលដ្ឋានសម្រាប់ការធ្វើសកម្មភាពនាពេលអនាគត។ ការធ្វើបែបនេះមិនត្រឹមតែធានាថា ការឆ្លើយតបចំពោះការជួញដូរមនុស្ស អាចផ្តល់ការគាំទ្រគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងការពារសិទ្ធិជនរងគ្រោះទាំងអស់ ដើម្បីឱ្យពួកគេមានភាពអង់អាចក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងទទួលបានយុត្តិធម៌។

នៅក្នុងដំណើរការរៀបចំសៀវភៅមគ្គុទេសក៍នេះ មានការពិគ្រោះយោបល់ជាច្រើនលើកច្រើនសា ជាមួយអ្នកជំនាញ និងអ្នកអនុវត្តការងារប្រឆាំងអំពើជួញដូរមនុស្ស មកពីទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងរដ្ឋជាសមាជិកអាស៊ាន បន្ថែមលើការសុំការណែនាំ និងយោបល់ពីអ្នកជំនាញ ដែលជាតំណាង ACWC ក៏ដូចជា ក្រុមថ្នាក់ដឹកនាំ និងក្រុមការងារប្រចាំប្រទេសនៃកម្មវិធី ASEAN-ACT។ ដូច្នេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតំណាង ACWC ដែលបានចូលរួមក្នុងការរៀបចំ និងពិនិត្យលើសៀវភៅមគ្គុទេសក៍នេះ ជាពិសេសដល់សមាជិកក្រុមការងារបច្ចេកទេសរបស់គម្រោងពហុឆ្នាំ ក្រុមការងារបច្ចេកទេស និងអ្នកដែលបានដឹកនាំការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញថ្នាក់ជាតិ នៅប្រទេសឥណ្ឌូនេស៊ី ថៃ និងវៀតណាម។ ACWC សូមថ្លែងអំណរគុណចំពោះកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងអំពើជួញដូរមនុស្ស ដែលទទួលបានថវិកាគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី និងចំពោះ Dr Anne Stephens និងលោកស្រី Jill Thomas មកពីក្រុមហ៊ុន Ethos of Engagement Consulting ដែលបានផ្តល់មតិយោបល់បច្ចេកទេសដ៏មានតម្លៃ និងដែលបានចូលរួមចំណែក ធ្វើឱ្យការរៀបចំសៀវភៅមគ្គុទេសក៍នេះទទួលបានជោគជ័យ។ នៅក្នុងការបន្តដំណើររបស់យើង ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ការបន្តកិច្ចសហការ និងការប្តេជ្ញាចិត្តឥតងាករេ របស់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ នៅតែមានសារៈសំខាន់ចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើង ក្នុងតំបន់អាស៊ានទាំងមូល។

# អក្សរកាត់ និងពាក្យកាត់

| | | |
|---|---|---|
| **ACWC** | ASEAN Commission on the Promotion and Protection of the Rights of Women and Children | គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ |
| **ASEAN-ACT** | ASEAN-Australia Counter Trafficking | កម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងអំពើជួញដូរមនុស្ស |
| **ACTIP** | ASEAN Convention Against Trafficking in Persons, Especially Women and Children | អនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| **ASEAN** | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ |
| **CSO** | Civil society organisation | អង្គការសង្គមស៊ីវិល |
| **CTIP** | Counter-trafficking in persons | ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| **EoE** | Ethos of Engagement Consulting | ក្រុមហ៊ុន Ethos of Engagement Consulting |
| **EPO** | End-of-program outcomes | លទ្ធផលចុងកម្មវិធី |
| **DFAT** | Australian Government's Department of Foreign Affairs and Trade | ក្រសួងការបរទេស និងពាណិជ្ជកម្មនៃរដ្ឋាភិបាលអូស្ត្រាលី |
| **GEDSI** | Gender, Equity, Disability and Social Inclusion | យេនឌ័រ សមធម៌ ពិការភាព និងបរិយាបន្នសង្គម |
| **GEMs** | Gender Equality, Environments and Marginalised voices | សមភាពយេនឌ័រ បរិយាកាស និងសំឡេងរបស់ក្រុមដែលមានឱកាសតិចតួច |
| **KII** | Key informant interview | ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ |
| **KPI** | Key performance indicator | សូចនាករសមិទ្ធកម្មគន្លឹះ |
| **M&E** | Monitoring and evaluation | ការតាមដាន និងការវាយតម្លៃ |
| **MEL** | Monitoring, evaluation, and learning | ការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ |
| **MOU** | Memorandum of Understanding | អនុស្សរណៈស្តីពីការយោគយល់គ្នា |
| **PWD** | Persons with disability | ជនមានពិការភាព |
| **SOP** | Standard Operating Procedure | នីតិវិធីប្រតិបត្តិការស្តង់ដារ |
| **TIP** | Trafficking in persons | អំពើជួញដូរមនុស្ស |
| **TOR** | Terms of Reference | លក្ខខណ្ឌប្រតិបត្តិ |
| **TWG** | Technical Working Group of the ACWC | ក្រុមការងារបច្ចេកទេសនៃ ACWC |
| **UNODC** | United Nations Office on Drugs and Crime | ការិយាល័យប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ |

# វាក្យសព្ទគន្លឹះ

| | |
|---|---|
| **សកម្មភាព** | សកម្មភាពដែលធ្វើឡើង ឬការងារដែលត្រូវបានអនុវត្ត តាមរយៈការកៀរគរធាតុចូល ដូចជា មូលនិធិ ជំនួយបច្ចេកទេស ព្រមទាំងប្រភេទធនធានផ្សេងទៀត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកជាក់លាក់។ |
| **ការយល់ព្រមពី អនីតិជន (Affirmative assent)** | ការយល់ព្រមពីអនីតិជន គឺជាការបញ្ជាក់យល់ព្រមរបស់កុមារណាម្នាក់ ដើម្បីចូលរួមក្នុងការស្រាវជ្រាវ។ បញ្ញត្តិស្តីពីការយល់ព្រមពីអនីតិជន ទទួលស្គាល់ពីសមត្ថភាពរបស់កុមារដែលមានការវិវឌ្ឍជាបន្តបន្ទាប់ បើទោះជាកុមារមិនទាន់មានសមត្ថភាពពេញលេញក្នុងការផ្តល់ការយល់ព្រម ផ្អែកលើព័ត៌មានដែលផ្តល់ឱ្យពួកគេក៏ដោយ។ ជាទូទៅកុមារដែលមានអាយុចាប់ពី ៧ ឆ្នាំឡើង អាចផ្តល់ការយល់ព្រមបាន។[១] |
| **កុមារ** | បើតាមអនុសញ្ញា ACTIP កុមារសំដៅលើមនុស្សអាយុក្រោម ១៨ ឆ្នាំ លើកលែងតែអាយុនីតិភាពត្រូវបានកំណត់ក្រោមអាយុដែលកំណត់នៅក្នុងអនុសញ្ញា ACTIP ក្នុងច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ។[២] |
| **សំណង** | ការផ្តល់សំណងចំពោះការខូចខាតជាទ្រព្យសម្បត្តិសម្ភារៈ និងផ្លូវចិត្ត ដែលជនរងគ្រោះនៃអំពើជួញដូរមនុស្សបានទទួលរង។[៣] |
| **ឧបករណ៍ប្រមូលទិន្នន័យ** | វិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីកំណត់រកប្រភពព័ត៌មាន និងប្រមូលព័ត៌មានក្នុងអំឡុងពេលពិនិត្យតាមដាន ឬក្នុងអំឡុងពេលវាយតម្លៃ។ ឧទាហរណ៍ រួមមាន ការអង្កេតក្រៅផ្លូវការ និងផ្លូវការ ការសង្កេតផ្ទាល់ដោយមានការចូលរួម ការសម្ភាសសហគមន៍ ការសម្ភាសជាក្រុម ការសុំយោបល់ពីអ្នកជំនាញ និងករណីសិក្សា។ |
| **ការសង្គ្រោះ និងឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះមហន្តរាយ** | សកម្មភាពទាំងឡាយដែលធ្វើឡើងដោយផ្ទាល់ នៅមុនពេល ក្នុងអំឡុងពេល ឬភ្លាមៗក្រោយគ្រោះមហន្តរាយកើតមានឡើង ដើម្បីសង្គ្រោះជីវិត កាត់បន្ថយផលប៉ះពាល់មកលើសុខភាព ជានាសុវត្ថិភាពសាធារណៈ និងឆ្លើយតបចំពោះតម្រូវការនៃការរស់នៅជាមូលដ្ឋានរបស់ជនដែលរងផលប៉ះពាល់។[៤] |
| **ការវាយតម្លៃ** | ការវាយតម្លៃក្នុងលក្ខណៈជាប្រព័ន្ធនិងសត្យានុម័តលើគម្រោងកម្មវិធីឬគោលនយោបាយដែលកំពុងបន្តអនុវត្ត ឬគម្រោងដែលត្រូវបានបញ្ចប់ ដោយផ្តោតលើការរៀបចំ ការអនុវត្ត និងលទ្ធផលនៃគម្រោង កម្មវិធី ឬគោលនយោបាយនេះ។ ការវាយតម្លៃ មានគោលបំណង |

១ Santelli, J. Haerizadeh, S and McGovern, T (2017) Inclusion with Protection: Obtaining informed consent when conducting research with adolescents, Innocenti Research Briefs, no. 2017-05, UNICEF Office of Research, Innocenti, Florence.

២ United Nations Convention on the rights of the child, 1989, Article 1; ASEAN, ASEAN Convention Against Trafficking in Persons, Especially Women and Children, 2015,Article 2

៣ Cusveller J and Kleemans E (2018) 'Fair compensation for victims of human trafficking? A case study of the Dutch injured party claim', International Review of Victimology, 24(3):297-311. http://doi: 10.1177/0269758018758427.

៤ United Nations Office for Disaster Risk Reduction (UNDRR) (n.d.) Our Work, accessed 1 October 2023.

| | |
|---|---|
| | កំណត់ពីភាពឆ្លើយតបនឹងការសម្រេចគោលដៅ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ផលជះ និងនិរន្តរភាពនៃការអភិវឌ្ឍន៍។ ការវាយតម្លៃគួរផ្តល់នូវព័ត៌មានដែលអាចជឿទុកចិត្តបាន និងមានប្រយោជន៍ ដើម្បីឱ្យគេអាចបញ្ចូលមេរៀន បទពិសោធ ដែលទទួលបានទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ទាំងរបស់ស្ថាប័នទទួលជំនួយ និងស្ថាប័នផ្តល់ជំនួយ។ ការវាយតម្លៃ ក៏ជាដំណើរការ ដើម្បីកំណត់ពីតម្លៃ ឬសារៈសំខាន់នៃសកម្មភាព គោលនយោបាយ ឬកម្មវិធីណាមួយផងដែរ។ ការវាយតម្លៃលើអន្តរាគមន៍អភិវឌ្ឍន៍ ដែលត្រូវបានគ្រោងទុក កំពុងអនុវត្ត ឬត្រូវបានបញ្ចប់ ត្រូវធ្វើឡើងក្នុងលក្ខណៈជាប្រព័ន្ធ និងសត្យានុម័តបំផុតតាមដែលអាចធ្វើទៅបាន។ |
| **យេនឌ័រ** | សំដៅលើតួនាទី ឥរិយាបថ សកម្មភាព និងលក្ខណៈដែលកំណត់ដោយសង្គម ដោយធ្វើការពិចារណាពីលក្ខណៈ និងទំនាក់ទំនងរវាងស្ត្រីនិងបុរស។ សមភាពយេនឌ័រ រាប់បញ្ចូលទាំងឱកាស ការទទួលបាននិងការគ្រប់គ្រងលើធនធាន និងការធ្វើសេចក្តីសម្រេចចិត្ត ទទួលរងឥទ្ធិពលពីការយល់ឃើញរបស់សង្គម ចំពោះស្ត្រី និងបុរសនៅគ្រប់វ័យ។[៥] |
| **ការយកចិត្តទុកដាក់ចំពោះយេនឌ័រ** | អភិក្រមដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ ធ្វើការពិចារណាពីតម្រូវការរបស់មនុស្សគ្រប់រូប តាមយេនឌ័ររបស់ពួកគេ និងទៅតាមប្រភេទនៃគ្រោះថ្នាក់ និងការកេងប្រវ័ញ្ចដែលពួកគេទទួលរង។ អភិក្រមបែបនេះ ជួយឱ្យយើងក្នុងការរៀបចំ និងអនុវត្តការឆ្លើយតប និងអន្តរាគមន៍នានា ស្របតាមតម្រូវការរបស់អ្នកទាំងនេះ។ អភិក្រមនេះ ក៏បង្កើនសមត្ថភាពរបស់យើងក្នុងការឆ្លើយតបចំពោះភាពលម្អៀងនៃយេនឌ័រកំណត់អត្តសញ្ញាណជនរងគ្រោះដែល "មិនស្របតាមសាវតាររបស់អ្នកដែលសមជាជនរងគ្រោះ (non-ideal)" ជំរុញឱ្យមានការចូលរួមពីបុរស និងក្មេងប្រុស ក្នុងការឆ្លើយតបចំពោះការប្រកាន់ផ្នត់គំនិត ប្រកបដោយភាពរើសអើងលើភាពជាបុរស និងភាពជាស្ត្រី និងឆ្លើយតបចំពោះមូលហេតុដែលជាឫសគល់នាំឱ្យមានអំពើហិង្សាលើស្ត្រី និងក្មេងស្រី។[៦] |
| **សូចនាករ** | កត្តា ឬអថេរ បរិមាណវិស័យ គុណវិស័យ ដែលជាមធ្យោបាយដ៏សាមញ្ញ និងអាចជឿទុកចិត្តបាន សម្រាប់វាស់វែងលទ្ធផលដែលសម្រេចបាន ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ ដែលមានទំនាក់ទំនងជាមួយអន្តរាគមន៍ណាមួយ ឬជួយវាយតម្លៃលើលទ្ធផលដែលសម្រេចបានដោយតួអង្គអភិវឌ្ឍន៍ណាមួយ។ |
| **ការយល់ព្រមផ្អែកតាមព័ត៌មានត្រឹមត្រូវ** | ការសម្រេចចិត្តរបស់មនុស្សម្នាក់ ដែលធ្វើឡើងដោយស្ម័គ្រចិត្ត ដើម្បីយល់ព្រមចូលរួមក្នុងកិច្ចសម្ភាសន៍ ការព្យាបាល ការអនុវត្តនីតិវិធី ការផ្តល់ជំនួយ ឬអន្តរាគមន៍ផ្សេងទៀត។ ត្រូវមានការផ្តល់ព័ត៌មាន ច្បាស់លាស់ និងអាចយល់បានអំពីហានិភ័យ និងអត្ថប្រយោជន៍នៃអន្តរាគមន៍ដែលត្រូវបានស្នើឡើង ព្រមទាំងជម្រើសដែលមានដល់ជនរងគ្រោះ/បុគ្គលនោះ ដើម្បីឱ្យពួកគេអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ គួរមានផ្តល់អ្នកបកប្រែដើម្បីធានាថាបុគ្គលនោះអាចយល់ព័ត៌មានដែលកំពុងផ្តល់ដល់ពួកគេ។[៧] |

៥ ACWC, Do No Harm Guide for Frontline Responders, 2022.

៦ ACWC, Do No Harm Guide for Frontline Responders, 2022.

៧ ACWC, Do No Harm Guide for Frontline Responders, 2022.

| | |
|---|---|
| **ធាតុចូល** | ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានសម្ភារៈនានា ដែលត្រូវបានប្រើប្រាស់សម្រាប់អនុវត្តកិច្ចអន្តរាគមន៍អភិវឌ្ឍន៍។ |
| **ត្រូវបានធ្វើស្ថាបនីយកម្ម** | ត្រូវបានធ្វើស្ថាបនីយកម្ម មានន័យថាការផ្លាស់ប្តូរដែលគេចង់បាន បានក្លាយជាផ្នែកមួយនៃសកម្មភាពដែលអង្គការ ឬស្ថាប័នមួយកំពុងបន្តអនុវត្ត និងចូលមកជំនួសអ្វីដែលធ្លាប់មានកន្លងមក។[៨] |
| **ភាពប្រសព្វគ្នា** | របៀបដែលលក្ខណៈរបស់បុគ្គលម្នាក់មានទំនាក់ទំនងជាមួយគ្នា ដូចជា យេនឌ័រ អាយុ និងពិការភាពជាដើម។ ឧទាហរណ៍ មនុស្សម្នាក់អាចទទួលរងការរើសអើង ដោយសារតែយេនឌ័រ និងពិការភាពរបស់ពួកគេ។ នេះអាចនាំឱ្យបុគ្គលម្នាក់នោះ កាន់តែត្រូវបានគេផាត់ចេញ ឬកាន់តែប្រឈមនឹងហានិភ័យ។ ដូច្នេះ ទាមទារឱ្យមានការពិចារណាដោយប្រុងប្រយ័ត្ន។ ភាពប្រសព្វគ្នា គូសបញ្ជាក់ពីសារៈសំខាន់ នៃការមិនត្រឹមតែពិនិត្យលើលក្ខណៈអ្វីមួយដាច់ដោយឡែកពីគ្នាប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រើប្រាស់អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីលើកកម្ពស់បរិយាបន្នសង្គម។[៩] |
| **បញ្ជ្រាប** | ការអនុវត្តដែលឆ្លុះបញ្ចាំង ឬមានសមតិភាពជាមួយឥរិយាបថ និងគុណតម្លៃដែលមានជាទូទៅ។ |
| **ការពិនិត្យតាមដាន** | មុខងារបន្តអនុវត្តដោយប្រើប្រាស់ការប្រមូលទិន្នន័យក្នុងលក្ខណៈជាប្រព័ន្ធអំពីសូចនាករដែលត្រូវបានកំណត់ ដើម្បីផ្តល់ឱ្យអ្នកគ្រប់គ្រង និងអ្នកពាក់ព័ន្ធសំខាន់ៗ នូវព័ត៌មានដែលបង្ហាញពីវឌ្ឍនភាពដែលសម្រេចបាននៃកិច្ចអន្តរាគមន៍អភិវឌ្ឍន៍ ដែលកំពុងអនុវត្ត ព្រមទាំងអំពីការសម្រេចគោលដៅ និងវឌ្ឍនភាពក្នុងការប្រើប្រាស់ថវិកាត្រូវបានបែងចែក។ |
| **លទ្ធផលបន្ទាប់ (Outcome)** | ផលនៃលទ្ធផលរំពឹងទុក ឬធាតុចេញនៃអន្តរាគមន៍ណាមួយ ដែលទំនងជានឹងកើតមានឡើង ឬដែលកើតមានក្នុងទម្រង់ដែលជាលទ្ធផលអន្តរកាល ឬលទ្ធផលរយៈពេលមធ្យម។ |
| **លទ្ធផលរំពឹងទុក ឬធាតុចេញ (Outputs)** | ផលិតផល ទំនិញមូលធន និងសេវាកម្មដែលកើតចេញពីអន្តរាគមន៍នៃការអភិវឌ្ឍអ្វីមួយ និងអាចរាប់បញ្ចូលការផ្លាស់ប្តូរដែលកើតចេញពីអន្តរាគមន៍នោះ។ |
| **ជនមានពិការភាព** | ជនមានពិការភាព រួមមានជនដែលខ្សោយកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញាណដឹងក្នុងរយៈពេលវែង ដែលនៅពេលជួបប្រសព្វជាមួយនឹងឧបសគ្គនានា ធ្វើឱ្យរាំងស្ទះដល់ការចូលរួមពេញលេញប្រកបដោយប្រសិទ្ធភាពរបស់ពួកគេនៅក្នុងសង្គម ស្មើភាពនឹងអ្នកដទៃទៀត។[១០] |
| **ការធ្វើសមាហរណកម្ម** | ដំណើរការស្តារឡើងវិញ និងចូលរួមក្នុងសង្គម បន្ទាប់ពីត្រូវបានគេជួញដូរ។[១១] |

---

៨ Osman-Gani, A. M. and Jacobs, R. L. ( 2004 ). ˋInstitutionalization of Organizational Change: A Study of HRD Interventions in Singaporean, US, Japanese, and German Companiesˊ. Paper presented at the Academy of Human Resource Development International Conference ( AHRD ), Austin, TX, Mar 3-7, 2004, pp 482-489.

៩ ACWC, Do No Harm Guide for Frontline Responders, 2022.

១០ United Nations Convention on the Rights of Persons with Disabilities, 1989, Article 1; ASEAN, Enabling Masterplan 2025, Mainstreaming the Rights of Persons with Disabilities, February 2019.

១១ Surtees, R. M. Meshi, S, Tanellari, A. Lila and O. Hinaj ( 2022 ) Stages of recovery and reintegration of trafficking victims. A reintegration guide for practitioners. Tiranë: Different and Equal and Washington, D.C., NEXUS Institute.

| | |
|---|---|
| **សំណងបដិទាន** | គឺជារបៀបដែលប៉ះប៉ូវគ្រោះថ្នាក់ដែលបង្កឡើងចំពោះជនរងគ្រោះ និងដើម្បីឱ្យជនល្មើសមានការទទួលខុសត្រូវ ក្នុងន័យស្ថាបនាចំពោះសង្គម ហើយស្របពេលជាមួយគ្នាជួយស្តារនីតិសម្បទាបានជាអតិបរមា។ សំណងបដិទាន រួមមាន ការប្រគល់ត្រឡប់មកវិញនូវទ្រព្យសម្បត្តិ ឬការទូទាត់សងលើគ្រោះថ្នាក់ ឬការបាត់បង់ដែលទទួលរង ការសងចំណាយនានាដែលកើតឡើង ដោយសារការរងគ្រោះ ការផ្តល់សេវា និងការស្តារសិទ្ធិឡើងវិញ។[១២] |
| **ការទទួលរងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ** | ករណីដែលជនរងគ្រោះ ជួបសាជាថ្មីនូវការប៉ះទង្គិចផ្លូវចិត្ត ដែលពួកគេធ្លាប់ទទួលរងគ្រោះពីការជួញដូរមនុស្ស។[១៣] |
| **ការផ្តល់សេវា** | ដំណើរការនៃការបង្កើនសមត្ថភាព ឱកាស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលជួបការលំបាកដោយសារតែកត្តាយេនឌ័រ ពូជសាសន៍ ជាតិពន្ធុ សាសនា និន្នាការភេទ ពិការភាព ឬស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងសង្គម។[១៤] |
| **បរិយាបន្នសង្គម** | ដំណើរការនៃការបង្កើនសមត្ថភាព ឱកាស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលជួបការលំបាកដោយសារតែយេនឌ័រ ពូជសាសន៍ ជាតិពន្ធុ សាសនា និន្នាការភេទ ពិការភាព ឬស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងសង្គម។[១៥] |
| **នីតិវិធីប្រតិបត្តិការស្តង់ដារ** | វិធីសាស្ត្រដែលត្រូវបានដាក់ចេញ ឬកំណត់ឱ្យអនុវត្តតាមជាប្រចាំ សម្រាប់អនុវត្តកិច្ចប្រតិបត្តិការដែលត្រូវបានកំណត់ ឬនៅក្នុងស្ថានភាពដែលត្រូវបានកំណត់។ |
| **ការជួញដូរកុមារ** | ការជួញដូរកុមារ ដែលសំដៅលើបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ គឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រក ឬការទទួលយកកុមារ ដើម្បីគោលបំណងប្រព្រឹត្តអំពើកេងប្រវ័ញ្ច បើទោះជាមិនមានការប្រើប្រាស់មធ្យោបាយ ដូចដែលមានចែងនៅក្នុងនិយមន័យនៃអំពើជួញដូរមនុស្សក៏ដោយ។[១៦] |
| **អំពើជួញដូរមនុស្ស** | សំដៅលើការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រក ឬការទទួលយកមនុស្ស ដោយប្រើមធ្យោបាយគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬការបង្ខិតបង្ខំក្នុងទម្រង់ផ្សេងទៀត ដូចជា ការចាប់ពង្រត់ ការបន្លំ ការបោកបញ្ឆោត ការប្រើបំពានអំណាច ឬស្ថានភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលប្រាក់ ឬអត្ថប្រយោជន៍នានា ដើម្បីទទួលបានការយល់ព្រមពីមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ ពីរមនុស្សដែលមានសិទ្ធិគ្រប់គ្រងលើមនុស្សម្នាក់ផ្សេងទៀត ដើម្បីគោលបំណងប្រព្រឹត្តអំពើកេងប្រវ័ញ្ច។ អំពើកេងប្រវ័ញ្ច ត្រូវមានយ៉ាងហោចណាស់ការកេងប្រវ័ញ្ចប្រព្រឹត្តអំពើសច្ចាកម្មលើអ្នកដទៃទៀត ឬការកេងប្រវ័ញ្ចផ្លូវភេទក្នុងទម្រង់ផ្សេងទៀត ពលកម្ម ឬការផ្តល់សេវាដោយបង្ខំ អំពើទាសភាព ឬការអនុវត្តដែលស្រដៀងគ្នានឹងអំពើទាសភាព ការធ្វើជាបាវបម្រើដាច់ថ្លៃ ឬការដកយកសរីរាង្គជាដើម។[១៧] |

១២ ACWC, Do No Harm Guide for Frontline Responders, 2022.

១៣ ASEAN, GenderSensitive Guideline for Handling Women Victims of Trafficking in Persons, October 2016.

១៤ ASEAN, Gender-Sensitive Guideline for Handling Women Victims of Trafficking in Persons, October 2016.

១៥ ACWC, Do No Harm Guide for Frontline Responders, 2022.

១៦ United Nations Protocol to Prevent, Suppress and Punish Trafficking in Persons Especially Women and Children (The TIP Protocol), 2000, Article 3(c); ASEAN, ASEAN Convention Against Trafficking in Persons, Especially Women and Children, 2015, Article 2.

១៧ ASEAN, ASEAN Convention Against Trafficking in Persons, Especially Women and Children, 2015, Article 2(a).

| | |
|---|---|
| **ការប៉ះទង្គិចផ្លូវចិត្ត** | ការប៉ះទង្គិចផ្លូវចិត្ត កើតចេញពីការប៉ះពាល់នឹងឧប្បត្តិហេតុអ្វីមួយ ឬព្រឹត្តិការណ៍ដែលកើតមានជាស៊េរី ដែលបង្កការរំខានផ្លូវចិត្ត ឬគំរាមកំហែងដល់អាយុជីវិត ដែលបន្សល់ផលប៉ះពាល់អវិជ្ជមាន ក្នុងរយៈពេលវែងលើការបំពេញមុខងាររបស់បុគ្គល និងលើសុខមាលភាពផ្លូវចិត្ត ផ្លូវកាយ សង្គម អារម្មណ៍ និង/ឬស្មារតីរបស់បុគ្គលនោះ។[១៨] |
| **ការថែទាំផ្អែកលើបទពិសោធនៃការប៉ះទង្គិចផ្លូវចិត្ត** | ទទួលស្គាល់ពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត (ជាពិសេសអំពើហិង្សាផ្លូវកាយឬផ្លូវចិត្ត ដែលអាចមានដូចជា ការរំលោភបំពាន ដែលកើតឡើងនៅមុនពេល ឬក្នុងអំឡុងពេលនៃការជួញដូរមនុស្សជាក់ស្តែង) លើជីវិត និងឥរិយាបថរបស់បុគ្គលណាម្នាក់ លើការយល់ឃើញរបស់បុគ្គលនោះ ចំពោះខ្លួនឯង និងចំពោះរាងកាយរបស់ពួកគេ។ នៅក្នុងការថែទាំប្រភេទនេះ មានការទទួលស្គាល់ពីសញ្ញា និងរោគសញ្ញាដែលការប៉ះទង្គិចផ្លូវចិត្តមានលើជនរងគ្រោះដែលត្រូវបានជួញដូរ ស្រដៀងគ្នានឹងអភិក្រមផ្តោតលើជនរងគ្រោះដែរ ថែទាំប្រភេទនេះផ្តោតលើសុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះ និងបង្ការមិនឱ្យមានការអនុវត្តគោលនយោបាយ និងសកម្មភាពនានា ដែលធ្វើឱ្យជនរងគ្រោះទទួលរងការប៉ះទង្គិចផ្លូវចិត្ត។[១៩] |
| **អភិក្រមផ្តោតលើជនរងគ្រោះ** | អភិក្រមផ្តោតលើជនរងគ្រោះ គឺជាការយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធ លើតម្រូវការ និងក្តីបារម្ភរបស់ជនរងគ្រោះ ដើម្បីធានាឱ្យមានការផ្តល់សេវាដោយសមានចិត្ត និងយល់ពីសុខទុក្ខរបស់ជនរងគ្រោះ ដោយពុំមានការវិនិច្ឆ័យ។[២០] |
| **ជនរងគ្រោះ** | រូបវន្តបុគ្គលដែលជាកម្មវត្ថុនៃអំពើជួញដូរមនុស្ស ដូចដែលត្រូវបានឱ្យនិយមន័យក្នុងអនុសញ្ញា ACTIP។[២១] |
| **ក្រុមដែលងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស** | ក្រុមមនុស្សផ្សេងៗដែលប្រឈមមុខខ្ពស់ទៅនឹងអំពើជួញដូរមនុស្ស ដោយសារកត្តានានាដូចជា សញ្ជាតិ ស្ថានភាពអាពាហ៍ពិពាហ៍ យេនឌ័រ ជាតិពន្ធុ ពូជសាសន៍ សាសនា និន្នាការភេទ អាយុ ពិការភាព ឬស្ថានភាពទេសន្តប្រវេសន៍របស់ពួកគេ។[២២] |
| **សាក្សី** | បុគ្គលទាំងឡាយរាប់បញ្ចូលទាំងជនរងគ្រោះផង ដែលដឹងពីព្រឹត្តិការណ៍ពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស។[២៣] |

១៨ Trauma-Informed Care Implementation Resource Centre (2023) What is Trauma-Informed Care? Accessed 31 October 2023.

១៩ ACWC, Do No Harm Guide for Frontline Responders, 2022.

២០ ACWC, Do No Harm Guide for Frontline Responders, 2022.

២១ ASEAN, ASEAN Convention Against Trafficking in Persons, Especially Women and Children, 2015, Article 2(e); United Nations Convention against Transnational Organised Crime (UNTOC) 2001; Council of Europe Convention on Action against Trafficking in Human Beings, 2005.

២២ ACWC, Do No Harm Guide for Frontline Responders, 2022.

២៣ ASEAN, Gender-Sensitive Guideline for Handling Women Victims of Trafficking in Persons, October 2016.

# សារប្បាន

គណៈកម្មការអាស៊ាន គឺជាស្ថាប័នអន្តររដ្ឋាភិបាល និងជាផ្នែកមួយដ៏សំខាន់នៃរចនាសម្ព័ន្ធរបស់ស្ថាប័នអាស៊ាន។ គណៈកម្មការនេះត្រូវបានបង្កើតឡើងកាលពីឆ្នាំ ២០១០ ដើម្បីការពារសិទ្ធិស្ត្រី និងកុមារ។ ACWC បានសហការជាមួយនឹងកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងអំពើជួញដូរមនុស្ស (ASEAN-ACT) ដើម្បីជំរុញឱ្យមានការអនុវត្តអភិក្រមផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ក្នុងការអនុវត្តសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះករណីជួញដូរមនុស្ស។ កម្មវិធី ASEAN-ACT បន្តការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP) នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងកម្រិតស្ថាប័ន។

អាស៊ាន និង ACWC រួមជាមួយកម្មវិធី ASEAN-ACT ប្តេជ្ញាជំរុញឱ្យមានការប្រើប្រាស់អភិក្រមដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (TIP) ដើម្បីគាំទ្រដល់ការអនុវត្តអនុសញ្ញា ACTIP ដែលត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិកទាំងអស់របស់អាស៊ាន។ អនុសញ្ញា ACTIP លើកទឹកចិត្តឱ្យរដ្ឋជាសមាជិកអាស៊ានបន្តបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់គោលនយោបាយការផ្តល់សេវានិងកិច្ចសហប្រតិបត្តិការព្រមទាំងកាត់បន្ថយហានិភ័យ ដែលអាចបង្កគ្រោះថ្នាក់បន្ថែមទៀតដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សបានឱ្យនៅតិចតួចបំផុត។ ដើម្បីសម្រេចគោលដៅទាំងនេះ គោលការណ៍ណែនាំចំនួន ៣ ស្តីពីការឆ្លើយតបចំពោះករណីជួញដូរមនុស្សរបស់ ACWC ត្រូវបានរៀបចំឡើង៖

- គោលការណ៍ណែនាំថ្នាក់តំបន់ និងនីតិវិធី ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស[២៤]
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយយកចិត្តទុកដាក់ចំពោះយេនឌ័រ និង[២៥]
- មគ្គុទេសក៍អាស៊ានស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ៖ ការការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស។[២៦]

ឯកសារណែនាំទាំង ៣ នេះ លើកឡើងពីការអនុវត្តល្អ ជុំវិញការអនុវត្តអភិក្រមប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ទោះជាយ៉ាងនេះក្តី គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ ទិន្នន័យ និងព័ត៌មានអំពីការទទួលយក និងការអនុវត្តគោលការណ៍ណែនាំនេះ នៅមានកម្រិតនៅឡើយ។ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ ACWC ដែលមានការគាំទ្រពី ASEAN-ACT បានស្នើឱ្យក្រុមហ៊ុន Ethos of Engagement (EoE) រៀបចំបង្កើតនូវប្រព័ន្ធ និងឧបករណ៍តាមដាន និងវាយតម្លៃ (M&E) មួយ ដើម្បីជួយដល់អ្នកប្រើប្រាស់ និងតាមដានលើការអនុវត្តសៀវភៅមគ្គុទេសក៍ ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដែលត្រូវបានបង្កើតឡើង មានបញ្ចូលក្របខ័ណ្ឌលទ្ធផល និងសូចនាករផងដែរ។ សៀវភៅមគ្គុទេសក៍នេះ គឺជាឧបករណ៍ ដែលជួយដល់អ្នកពាក់ព័ន្ធក្នុងការអនុវត្តក្របខ័ណ្ឌពិនិត្យតាមដាន និងតាមដានលើការអនុវត្តអភិក្រមឆ្លើយតបចំពោះអំពើជួញដូរមនុស្ស ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។

---

២៤ ACWC, ASEAN Regional Guidelines and Procedures to Address the Needs of Victims of Trafficking in Persons, Especially Women and Children, 2018.

២៥ ASEAN, Gender-sensitive Guideline for Handling Women Victims of Trafficking in Persons, October 2016.

២៦ ACWC, Do No Harm Guide for Frontline Responders, 2022.

# អំពីសៀវភៅមគ្គុទេសក៍នេះ

ACWC បានសម្របសម្រួលរៀបចំសៀវភៅមគ្គុទេសក៍នេះឡើង ដើម្បីផ្តល់ឱ្យ ACWC រដ្ឋជាសមាជិកអាស៊ាន អង្គការ ស្ថាប័ន និងតួអង្គពាក់ព័ន្ធសំខាន់ៗក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដទៃទៀត នូវឧបករណ៍សម្រាប់ធ្វើស្វ័យវាយតម្លៃ និងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តឯកសារមគ្គុទេសក៍ ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័ររបស់ ACWC ។

សៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបរៀង និងបង្កើតឡើង ដើម្បីជួយដល់អ្នកប្រើប្រាស់ចុងក្រោយ ទាំងពីរក្រុម គឺ ACWC និងរដ្ឋជាសមាជិកអាស៊ាន ហើយការប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ ត្រូវបានលើកទឹកចិត្ត ប៉ុន្តែមិនតម្រូវជាកាតព្វកិច្ចនោះឡើយ។

សៀវភៅមគ្គុទេសក៍នេះ ផ្តោតលើលទ្ធផលរយៈពេលខ្លី ចំនួន ៤០ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដែលដកស្រង់ចេញពីឯកសារមគ្គុទេសក៍ ផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។ លទ្ធផលរយៈពេលខ្លីនីមួយៗត្រូវបានបរិយាយលម្អិត ១ ទំព័រ (សូមមើលរូបទី ១)។ លទ្ធផលរយៈពេលខ្លីនីមួយៗមានបង្ហាញពីការរំពឹងទុក និងកំណត់សម្គាល់ដែលបង្ហាញពីលទ្ធផលដែលគេចង់សម្រេច។ លទ្ធផលរយៈពេលមធ្យម និងលទ្ធផលរយៈពេលវែង ក៏ត្រូវបានលើកមកបង្ហាញផងដែរ ដើម្បីជួយឱ្យអ្នកប្រើប្រាស់មើលឃើញពីឱកាសបន្តធ្វើការកែលម្អក្នុងរយៈពេលវែង។

ក្របខ័ណ្ឌពេលវេលាសម្រាប់លទ្ធផលរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ត្រូវបានបង្ហាញក្នុងទម្រង់ដូចខាងក្រោម៖




ក្របខ័ណ្ឌពេលវេលាទាំងនេះ ត្រូវបានដែលធ្វើតេស្តសាកល្បង តាមរយៈកិច្ចពិគ្រោះយោបល់ និងឆ្លុះបញ្ចាំងពីរយៈពេលដែលគេអាចត្រូវការ ដើម្បីសម្រេចលទ្ធផលនីមួយៗ។ មានការទទួលស្គាល់ថា ក្របខ័ណ្ឌពេលវេលា ដើម្បីសម្រេចលទ្ធផលអាចមានការប្រែប្រួលទៅតាមបរិបទជាក់ស្តែង ព្រោះថាអាចមានការសម្រេចលទ្ធផលរយៈពេលខ្លីមួយចំនួនរួចទៅហើយ ហើយលទ្ធផលរយៈពេលខ្លីមួយចំនួនទៀត អាចត្រូវការពេលលើសពី ២ ឆ្នាំ ដើម្បីសម្រេច។

សៀវភៅមគ្គុទេសក៍នេះ ក៏មានបញ្ចូលឧបករណ៍ ដើម្បីជួយឱ្យអ្នកប្រើប្រាស់ ធ្វើស្វ័យវាយតម្លៃលើវឌ្ឍនភាព ដែលក្រុមការងារ ឬស្ថាប័នរបស់ខ្លួនសម្រេចបានពាក់ព័ន្ធនឹងលទ្ធផលរយៈពេលខ្លីនីមួយៗ។ ស្វ័យវាយតម្លៃនេះ អាចធ្វើឡើងដោយផ្ទាល់ ដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យលទ្ធផលរយៈពេលខ្លី (រូបទី ១) និងដាក់ពិន្ទុដោយប្រើប្រាស់គំរូ Building

Block Maturity (រូបទី ២០) សូចនាករនៅកម្រិតជាតុចេញក៏ត្រូវបានបង្ហាញជូនផងដែរ (សូមមើលឧបសម្ព័ន្ធទី ១) ដោយមានការកំណត់ពីប្រភេទទិន្នន័យដែលគេគួរប្រមូល និងរាយការណ៍ពាក់ព័ន្ធនឹងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្ស។ សូចនាករទាំងនេះ ត្រូវបានសរសេរសង្ខេបបង្ហាញពីស្ថានភាពជារួមពីកម្រិតខ្ពស់ទៅ និងអាចស្របទៅតាមការប្រមូល និងការរាយការណ៍ទិន្នន័យ ដែលមានស្រាប់ ក្នុងក្របខ័ណ្ឌ ACWC រដ្ឋជាសមាជិកអាស៊ាន អង្គការ ស្ថាប័ន និងតួអង្គពាក់ព័ន្ធសំខាន់ៗ ដែលធ្វើការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

គោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ត្រូវបានបញ្ចូលក្នុងសៀវភៅមគ្គុទេសក៍នេះ។ ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ ACWC និងអាស៊ាន លើការអនុវត្តអភិក្រមទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្ស ដោយផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។ នេះរួមមាន ការអនុវត្តដែលមិនរើសអើងលើក្រុមដែលងាយរងគ្រោះ ដោយសារតែកត្តាមួយ ឬច្រើន ដូចជា អាយុ សមត្ថភាព ជាតិពន្ធុ សាសនា អប់រំ សុខភាព ផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ (សូមមើលឧបសម្ព័ន្ធទី ២)។

# តើសៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបចំឡើង ដោយរបៀបណា

សៀវភៅមគ្គុទេសក៍ និងក្របខ័ណ្ឌពិនិត្យតាមដាននេះ ត្រូវបានបែងចែកជាសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្សចំនួន ៥ ផ្នែកសំខាន់ៗ។ ផ្នែកសំខាន់ៗទាំងនេះ ត្រូវបានដកស្រង់ចេញពីអនុសញ្ញា ACTIP ផែនការសកម្មភាពប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ាន និងឯកសារមគ្គុទេសក៍សម្រាប់អ្នកឆ្លើយតបជួរមុខរបស់*អាស៊ានស្តីពីការគោលការណ៍មិនបង្កគ្រោះថ្នាក់*[២៧]។ ផ្នែកនីមួយៗត្រូវបាន រៀបរាប់បង្ហាញជូន ដូចខាងក្រោម៖

## ១. ការយល់ដឹង និងការទប់ស្កាត់ករណីជួញដូរមនុស្ស

យុទ្ធសាស្ត្របង្កើនការយល់ដឹង និងទប់ស្កាត់អំពើជួញដូរមនុស្ស មានគោលបំណងទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងបង្ក្រាបអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារឱ្យមានប្រសិទ្ធភាព។ គំនិតផ្តួចផ្តើមទប់ស្កាត់អំពើជួញដូរមនុស្ស រួមមាន ការអប់រំផ្សព្វផ្សាយដល់សាធារណជន និងការកាត់បន្ថយភាពងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស។ នេះរួមមានជាអាទិ៍ អនុវត្តយុទ្ធនាការអប់រំផ្សព្វផ្សាយ ដើម្បីអប់រំប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម និងការបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងអំពើជួញដូរមនុស្ស និងការរំលោភបំពានសិទ្ធិមនុស្ស ដោយផ្តោតលើក្រុមដែលប្រឈមនឹងហានិភ័យជាងគេតាមរយៈការសហការជាមួយបណ្តាញផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធវិស័យឯកជន និងអ្នកដឹកនាំសហគមន៍ ដើម្បីលើកកម្ពស់សីលធម៌សង្គម សមភាព និងការកាត់បន្ថយភាពក្រីក្រ។ ការកែទម្រង់តាមវិស័យ ដូចជាមាគ៌ាសម្រាប់ធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព និងយន្តការរាយការណ៍ពីករណីជួញដូរមនុស្ស (ឧទាហរណ៍ ការប្រើប្រាស់បណ្តាញទូរស័ព្ទហតឡាញជាដើម)។ ការទប់ស្កាត់ និងការបង្កើនការយល់ដឹង ក៏សំដៅលើការអនុម័ត និងអនុវត្តផែនការសកម្មភាពជាតិ ដើម្បីកំណត់ និងចាត់អាទិភាពលើគោលនយោបាយ និងកម្មវិធីសំខាន់ៗ ដែលមានគោលបំណងទប់ស្កាត់អំពើជួញដូរមនុស្ស ព្រមទាំងពង្រឹងយន្តការអនុវត្ត សម្របសម្រួល និងពិនិត្យតាមដានលើផែនការទាំងនេះ។[២៨]

២៧ ACWC, Do No Harm Guide for Frontline Responders, 2022.

២៨ ASEAN, Plan of Action Against Trafficking in Persons, Especially Women and Children, 2015, pp 5-6.

## ២. ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ គឺជាដំណើរការដែលបុគ្គលម្នាក់ត្រូវបានគេអត្តសញ្ញាណថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលជួយឱ្យអ្នកទាំងនោះទទួលបានសិទ្ធិ និងទទួលបានសេវាផ្តល់ជំនួយ និងសេវាការពារនានា ដូចជាសេវាវេជ្ជសាស្ត្រ និងសេវាថែទាំសុខភាពដទៃទៀត កន្លែងស្នាក់ នៅម្ហូបអាហារ និងការបំពេញតម្រូវការជាមូលដ្ឋាន សេវាផ្តល់ប្រឹក្សា និងសេវាថែទាំចិត្តសង្គមជាដើម ។ល។ ការកំណត់អត្តសញ្ញាណឱ្យបានសុក្រឹត និងទាន់ពេលវេលា ជួយសម្រួលដល់ការសង្គ្រោះ និងការផ្តល់សេវាថែទាំដល់ជនរងគ្រោះឱ្យបានឆាប់រហ័ស។ ការកំណត់អត្តសញ្ញាណបែបនេះ ក៏បង្អាក់ដល់ដំណើរការជួញដូរមនុស្ស និងជួយដល់ការស៊ើបអង្កេត និងការចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សផងដែរ។[២៩]

## ៣. ការឆ្លុះបញ្ចាំង ការស្តារឡើងវិញ និងជម្រកសុវត្ថិភាព

រយៈពេលស្តារឡើងវិញ និងឆ្លុះបញ្ចាំង ទុកពេលឱ្យជនរងគ្រោះបានស្តារឡើងវិញពីអ្វីដែលពួកគេទទួលរង ដើម្បីជួយឱ្យពួកគេចាប់ផ្តើមកសាងសុខមាលភាពផ្លូវកាយ ផ្លូវចិត្ត ស្មារតី និងសង្គមរបស់ពួកគេជាថ្មី។ ជម្រកសុវត្ថិភាព ឬទីកន្លែងឱ្យស្នាក់នៅបណ្តោះអាសន្ន ដែលសមស្របទៅលើស្ថានភាពវប្បធម៌ ហើយដែលជនរងគ្រោះស្ម័គ្រចិត្តទទួលយក ផ្តល់ទីកន្លែងប្រកបដោយសុវត្ថិភាព និងសន្តិសុខ ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចទទួលបានសេវាចាំបាច់សំខាន់ៗ ដើម្បីឱ្យពួកគេអាចសះជា និងជួយក្នុងការអនុវត្តនីតិវិធីច្បាប់។ នៅក្នុងរយៈពេលនេះ ជនរងគ្រោះ អាចមានពេលវិភាគលើព័ត៌មាន និងគ្រប់ជម្រើសទាំងអស់ ដែលមានសម្រាប់ពួកគេ។[៣០]

## ៤. ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម

ជនរងគ្រោះដែលវិលត្រឡប់ទៅកាន់ស្រុកកំណើតរបស់ពួកគេវិញ គួរមានសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ និងត្រូវមានការគោរពឯកជនភាព និងមិនត្រូវមានការបង្ហាញពីអត្តសញ្ញាណរបស់ពួកគេនោះឡើយ។ ការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះ គួរធ្វើឡើងដោយដោយស្ម័គ្រចិត្ត ជនរងគ្រោះដែលមានបំណងចង់វិលត្រឡប់ទៅស្រុកកំណើតវិញ គួរទទួលបានជំនួយ ដើម្បីឱ្យពួកគេអាចវិលត្រឡប់ប្រកបដោយសុវត្ថិភាព និងពុំមានការពន្យារពេលដោយគ្មានមូលហេតុត្រឹមត្រូវនោះឡើយ។ សម្រាប់អ្នកដែលមិនអាចត្រឡប់ទៅស្រុកកំណើតវិញបាន ជាពិសេស ប្រសិនបើការវិលត្រឡប់បែបនេះបង្កគ្រោះថ្នាក់ដល់សុវត្ថិភាព និងសុខមាលភាពរបស់ពួកគេ គួរមានការរិះរកជម្រើសផ្សេងទៀតសម្រាប់ពួកគេ។[៣១]

---

២៩ ACWC, Do No Harm Guide for Frontline Responders, 2022.

៣០ ACWC, Do No Harm Guide for Frontline Responders, 2022.

៣១ ACWC, Do No Harm Guide for Frontline Responders, 2022.

## ៥. ការថែទាំវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត

សិទ្ធិទទួលបានសេវាថែទាំសុខភាព គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន។ សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ការទទួលបានសេវាថែទាំវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្តមានសារៈសំខាន់យ៉ាងខ្លាំង។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចមានបញ្ហាសុខភាពតិចតួច ឬធ្ងន់ធ្ងរ។ សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ អាចរងផលប៉ះពាល់ដោយសារតែការកេងប្រវ័ញ្ច ឬការបង្ករបួសស្នាមផ្ទាល់មកលើពួកគេ ដូចជា ការបង្ខំឱ្យប្រើគ្រឿងញៀន ដែលជាមធ្យោបាយត្រួតត្រាលើពួកគេជាដើម។ ពួកគេមួយចំនួនអាចមានជំងឺ ឬអាចធ្លាក់ខ្លួនពិការក្នុងអំឡុងពេលដែលត្រូវបានគេជួញដូរ។ ស្ត្រី និងក្មេងស្រី ដែលត្រូវបានគេយកទៅធ្វើអាជីវកម្មផ្លូវភេទ អាចឆ្លងជំងឺកាមរោគ និង/ឬមានផ្ទៃពោះ។[៣២]

## ៦. ដំណើរការយុត្តិធម៌

គោលការណ៍ណែនាំ និងផ្ដល់អនុសាសន៍ របស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស[៣៣] អំពាវនាវឱ្យរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស តាមរយៈការកំណត់អត្តសញ្ញាណពួកគេថាជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងធានាថា ពួកគេពុំត្រូវបានចាត់ទុកថាជាជនល្មើស និងជាប្រភពភស្តុតាងតែមួយគត់ នៅពេលដែលពួកគេចូលរួមក្នុងដំណើរការយុត្តិធម៌នោះឡើយ។ ជនរងគ្រោះមានជម្រើសចូលរួមក្នុងដំណើរការយុត្តិធម៌ក៏បាន មិនចូលរួមក៏បាន។ស្របតាមស្តង់ដារអន្តរជាតិគោលការណ៍ណែនាំនិងនីតិវិធីនៃតំបន់អាស៊ាន[៣៤]គួរបញ្ជាក់ថា ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ ដែលចូលរួមនៅក្នុងដំណើរការយុត្តិធម៌ គួរទទួលបាននូវការការពារ ការគាំទ្រ និងជំនួយដែលត្រូវបានកំណត់នៅក្នុងច្បាប់ឱ្យបានគ្រប់គ្រាន់ សម្រាប់រយៈពេលដែលពួកគេកំពុងចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ និងអាចសម្រេចចិត្ត លែងចូលរួមនៅពេលណាក៏បាន។

ជាកាតព្វកិច្ចមួយដែលមានចែងនៅក្នុងអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ានត្រូវពិចារណាអនុម័តវិធានការច្បាប់ ឬវិធានការសមស្របផ្សេងទៀត ដែលអនុញ្ញាតឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅបន្តស្ថិតនៅក្នុងដែនដីរបស់ខ្លួនជាបណ្ដោះអាសន្នក្ដី ឬជាអចិន្ត្រៃយ៍ក្ដី នៅក្នុងករណីដែលសមស្រប និងត្រូវពិចារណាផ្ដល់ការថែទាំ និងការគាំទ្របែបមនុស្សធម៌ និងដោយសមានចិត្តដល់ជនរងគ្រោះ ដូចជា ការ ធានាសុវត្ថិភាព ឯកជនភាព និងការរក្សាការសម្ងាត់ជាដើម។ រដ្ឋមិនត្រូវចោទប្រកាន់ជនរងគ្រោះនៃអំពើជួញដូរមនុស្សពីបទព្រហ្មទណ្ឌ ឬបទរដ្ឋបាលចំពោះអំពើខុសច្បាប់ដែលពួកគេប្រព្រឹត្ត

---

៣២ ACWC, Do No Harm Guide for Frontline Responders, 2022.

៣៣ United Nations High Commissioner for Human Rights (UNHCHR) Recommended Principles and Guidelines on Human Rights and Human Trafficking, 2002.

៣៤ ACWC, ASEAN Regional Guidelines and Procedures to Address the Needs of Victims of Trafficking in Persons, Especially Women and Children, 2018.

ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនោះឡើយ។ និងមិនត្រូវឃាត់ខ្លួនពួកគេដាក់នៅកន្លែងឃុំឃាំង ឬពន្ធនាគារ មុនពេល ក្នុងអំឡុងពេល ឬក្រោយពេលអនុវត្តនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលនោះឡើយ។

អនុសញ្ញា ACTIP ក៏បានបន្តអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ាន ធានាយ៉ាងណាឱ្យប្រព័ន្ធច្បាប់នៅក្នុងប្រទេសរបស់ខ្លួន មានបញ្ចូលនូវវិធានការ ដែលជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចទទួលបានសំណង ជំងឺចិត្ត និង/ឬសំណងបជិទាន ចំពោះការខូចខាតដែលពួកគេទទួលរង ដើម្បីជម្នះបញ្ហាប្រឈម ក្នុងការផ្តល់សំណងដល់ជនរងគ្រោះ និង/ឬការផ្តល់សំណងបជិទាន គួរផ្តល់ជំនួយផ្លូវច្បាប់ និងជំនួយជាសម្ភារៈដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេអាចសម្រេចបានសិទ្ធិរបស់ខ្លួន ក្នុងការទទួលបានដំណោះស្រាយសមស្រប និងគ្រប់គ្រាន់ ដូចជា ការបង្កើតមូលនិធិបរធនបាលរបស់ជាតិជាដើម។ វត្តមានរបស់អង្គភាពជំនាញប្រឆាំងអំពើជួញដូរមនុស្ស និងភាពជាដៃគូជាមួយស្ថាប័នដែលឋិតនៅក្រៅវិស័យយុត្តិធម៌ ដូចជា អង្គការសង្គមស៊ីវិលជាដើម ក៏ត្រូវបានចាត់ទុកថាមានសារៈសំខាន់ ដើម្បីលើកទឹកចិត្ត និងផ្តល់ភាពអង់អាចឱ្យជនដែលអាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬជនដែលត្រូវបានគេសន្មតថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌបាន។

ក្នុងករណីដែលអាចធ្វើទៅបាន សៀវភៅមគ្គុទេសក៍នេះ ប្រើប្រាស់ខ្លឹមសារ ភាសា និងរចនាសម្ព័ន្ធដកស្រង់ចេញពីធនធាន និងឯកសារបោះពុម្ពផ្សាយនានារបស់អាស៊ាន។ ឯកសារទាំងនេះ រួមមានអនុសញ្ញា ACTIP និងផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ានឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិរបស់ជនមានពិការភាព (Mainstreaming the Rights of Persons with Disabilities)[៣៥]។

មានការរៀបចំការពិគ្រោះយោបល់ជាច្រើនលើកជាច្រើនសា សម្រាប់ការរៀបចំសៀវភៅមគ្គុទេសក៍នេះ។ តាមរយៈការប្រើប្រាស់អភិក្រម ការវាយតម្លៃប្រកបដោយបរិយាបន្នក្នុងលក្ខណៈជាប្រព័ន្ធលើយេនឌ័រ បរិស្ថាន និងសំឡេងរបស់ក្រុមដែលមានឱកាសតិចតួច (ISE៤GEMs) របស់ UN Women សិក្ខាសាលាពិគ្រោះយោបល់ចំនួន ៤ លើក និងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) ត្រូវបានធ្វើឡើងជាមួយអ្នកជំនាញខាងប្រឆាំងអំពើជួញដូរមនុស្សជាង ២៧០ នាក់ មកពីរដ្ឋជាសមាជិកអាស៊ានសមាជិកនៃ ACWC ថ្នាក់ដឹកនាំ និងក្រុមការងារប្រចាំប្រទេសនៃកម្មវិធី ASEAN-ACT រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (CSOs)។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ចំនួន ៣ លើកជាមួយតំណាង ACWC និងសិក្ខាសាលាចំនួន ៦ លើក នៅថ្នាក់ជាតិ ត្រូវបានរៀបចំធ្វើឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី ថៃ និងវៀតណាម ដែលមានអ្នកចូលរួមចំនួនជាង ២០០ នាក់, ប្រុស ៥៨ នាក់ ស្រី ១៤៣ នាក់ និងមានអ្នកចូលរួមមួយនាក់ចាត់ទុកយេនឌ័ររបស់ខ្លួន ថាមិនមែនជាប្រុស ហើយក៏មិនមែនជាស្រីនោះដែរ (non-binary)។ មតិត្រឡប់ដែលទទួលបានពីសិក្ខាសាលា ការសម្ភាសជាលក្ខណៈបុគ្គល និងការសម្ភាសជាក្រុមទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីកែសម្រួល និងកែលម្អក្របខ័ណ្ឌ ខ្លឹមសារនៃសៀវភៅមគ្គុទេសក៍នេះ និងដើម្បីឱ្យសៀវភៅនេះកាន់តែផ្តល់ភាពងាយស្រួលដល់អ្នកពាក់ព័ន្ធនានា។

---

៣៥ ASEAN, Enabling Masterplan 2025, Mainstreaming the Rights of Persons with Disabilities, February 2019.

# ក្រុមគោលដៅ

ក្រុមគោលដៅរបស់សៀវភៅមគ្គុទ្ទេសក៍នេះ គឺ ACWC និងស្ថាប័នតាមវិស័យដែលពាក់ព័ន្ធ រដ្ឋជាសមាជិកអាស៊ាន អង្គការ ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជួយឱ្យស្ថាប័នទាំងនេះអាចតាមដានលើការអនុវត្តអភិក្រមឆ្លើយតបចំពោះអំពើជួញដូរមនុស្ស ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។

គេអាចប្រើប្រាស់សៀវភៅមគ្គុទ្ទេសក៍នេះ ប្រកបដោយភាពទន់ភ្លន់ អាស្រ័យលើវិស័យការងារ និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ពោលគឺពួកគេអាចប្រើប្រាស់ផ្នែកសំខាន់ៗមួយ ឬច្រើន នៅក្នុងសៀវភៅនេះ ទៅតាមភាពពាក់ព័ន្ធនឹងការងាររបស់ពួកគេ។ អាស្រ័យទៅតាមវិស័យការងាររបស់អង្គការ ឬស្ថាប័ន វិស័យការងារនេះអាចប្រែប្រួលខុសៗគ្នា ដូចជា ការងាររបស់អ្នកឆ្លើយតបជួរមុខ បុគ្គលិកដែលធ្វើរបាយការណ៍ ឬធ្វើការងារពាក់ព័ន្ធនឹងទិន្នន័យ និងអ្នកគ្រប់គ្រងជាដើម។

ប្រភេទអង្គការស្ថាប័ន និងអ្នកពាក់ព័ន្ធ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលអាចយកសៀវភៅមគ្គុទ្ទេសក៍នេះទៅប្រើប្រាស់ មានជាអាទិ៍៖

- **ទីភ្នាក់ងារអនុវត្តច្បាប់ និងបុគ្គលិកនៃទីភ្នាក់ងារទាំងនេះ**
- **តុលាការ និងបុគ្គលិករបស់តុលាការ**
- **ស្ថាប័នរដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ានដែលពាក់ព័ន្ធ**
- **អ្នកផ្តល់សេវាដែលពាក់ព័ន្ធ និងបុគ្គលិករបស់អ្នកផ្តល់សេវាទាំងនោះ (អ្នកផ្តល់សេវាផ្លូវច្បាប់ ជម្រកសុវត្ថិភាព វេជ្ជសាស្ត្រ ។ល។)**
- **អង្គការដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងបុគ្គលិករបស់អង្គការទាំងនោះ**
- **អ្នកធ្វើការខាងពិនិត្យតាមដាន និងវាយតម្លៃ**
- **ស្ថាប័នពាក់ព័ន្ធតាមវិស័យរបស់អាស៊ាន**
- **លេខាធិការដ្ឋានអាស៊ាន និង ACWC**

# របៀបប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ

សៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបចំឡើង ដើម្បីបង្កើនភាពងាយស្រួលក្នុងការប្រើប្រាស់ ដោយបានបញ្ចូលរាល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ អំពីលទ្ធផលរយៈពេលខ្លីនីមួយៗ ដាក់តែ ១ ទំព័រ (រូបទី ១)។ ទំព័រនីមួយៗមានបង្ហាញពី៖

- វិស័យការងារសំខាន់ៗ និងនិមិត្តសញ្ញាដែលសម្គាល់ពីវិស័យការងារនេះ
- លេខសម្គាល់លទ្ធផលរយៈពេលខ្លី
- លទ្ធផលរយៈពេលខ្លី
- ខ្លឹមសារពាក់ព័ន្ធនៅក្នុងឯកសារយោងរបស់អាស៊ាន ដែលលើកឡើងពីការយកចិត្តទុកដាក់ចំពោះយេនឌ័រ និងការផ្តោតលើជនរងគ្រោះ
- ការពិពណ៌នា និងសេចក្តីពន្យល់ពីលទ្ធផលរយៈពេលខ្លី
- វិសាលភាពនៃលទ្ធផលរយៈពេលខ្លី ដែលផ្តល់ព័ត៌មានកាន់តែស៊ីជម្រៅអំពីលទ្ធផលទាំងនេះ
- បញ្ជីត្រួតពិនិត្យដែលបង្ហាញដោយសង្ខេបនៃសេចក្តីពណ៌នា និងវិសាលភាព៖ អ្នកប្រើប្រាស់អាច ធីក ត្រង់ចំណុចដែលអង្គការរបស់ខ្លួនសម្រេចបានកន្លងមក។
- ក្របខ័ណ្ឌ Building Block Maturity៖ អ្នកប្រើប្រាស់អាចវាយតម្លៃលើការសម្រេចលទ្ធផលរយៈពេលខ្លីនីមួយៗរបស់ខ្លួន ទៅតាមដំណាក់កាលដែលបង្ហាញពីភាពជឿនលឿន ដូចជា មុនពេលសម្រេចបានវឌ្ឍនភាពដើមដំបូង (early)
- វឌ្ឍនភាពសម្រេចបានក្នុងកម្រិតបង្គួរ (intermediate) និងវឌ្ឍនភាពដែលសម្រេចបានក្នុងកម្រិតខ្ពស់ (advanced) ដែលជួយឱ្យពួកគេងាយកំណត់ពីចំណុចខ្លាំង និងឱកាសសម្រាប់ធ្វើការកែលម្អ (សូមមើលរូបទី ២)។
- លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) និងលទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) ជួយអ្នកប្រើប្រាស់ដឹងថាតើលទ្ធផលរយៈពេលខ្លី រួមចំណែកសម្រេចលទ្ធផលរយៈពេលវែងអ្វីខ្លះ។

*រូបទី ១ ឧទាហរណ៍នៃគេហទំព័រដែលបង្ហាញពីលទ្ធផលរយៈពេលខ្លីនៅក្នុងសៀវភៅមគ្គុទេសក៍នេះ*




លទ្ធផលនេះបញ្ចូលអ្វីខ្លះ។ បញ្ចូលព័ត៌មានអំពី GEDSI និងកំណត់សម្គាល់ដែលដកស្រង់ចេញពីគោលការណ៍ណែនាំ និងឯកសារដើម របស់ ACWC។

**ឧបករណ៍ស្វ័យវាយតម្លៃ។ លទ្ធផលរយៈពេលខ្លី គឺ៖**

- មិនដែលពាក់ព័ន្ធ (និងអង្គការស្ថាប័នរបស់អ្នក)
- មុនពេលសម្រេចបានវឌ្ឍនភាព៖ អង្គការរបស់អ្នកនៅមិនទាន់បានអនុវត្តសកម្មភាព ដែលសម្រេចលទ្ធផលនេះនៅឡើយ
- វឌ្ឍនភាពបង្គួរ៖ មានការធីកចំណុចមួយចំនួនក្នុងបញ្ជីត្រួតពិនិត្យ ដោយឆ្លុះបញ្ចាំងពីសកម្មភាពដែលបានអនុវត្ត
- វឌ្ឍនភាពកម្រិតខ្ពស់៖ គ្រប់ចំណុចទាំងអស់នៅក្នុងបញ្ជីត្រួតពិនិត្យត្រូវបានធីក

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
| --- | --- | --- |
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

*រូបទី ២ ក្របខ័ណ្ឌ Building Block Maturity*

**អនុម័ត**

ដើម្បីគាំទ្រដល់ការអនុម័តសៀវភៅមគ្គុទេសក៍នេះ គេអាចបញ្ចូលខ្លឹមសារវាទៅក្នុងគោលនយោបាយនិងនីតិវិធីដែលមានស្រាប់ ឬគោលនយោបាយ និងនីតិវិធីថ្មីៗ។ ភាពញឹកញាប់នៃការពិនិត្យតាមដានដោយប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ គួរស្របតាមវដ្តនៃការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ឬប្រចាំឆមាស និងត្រូវផ្តល់ព័ត៌មានដែលមានសារៈប្រយោជន៍សម្រាប់ក្រុមគោលដៅខាងក្នុង និងក្រុមគោលដៅខាងក្រៅ។

ជាអនុសាសន៍លទ្ធផលដែលទទួលបានពីស្វ័យវាយតម្លៃលើលទ្ធផលរយៈពេលខ្លី ដូចបង្ហាញជូនក្នុងសៀវភៅមគ្គុទេសក៍នេះ ត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ធ្វើការកែលម្អជាប្រចាំ ការប្រមូលព័ត៌មាន និង ការរាយការណ៍ពីសកម្មភាពនានា។

**កែសម្រួល**

រដ្ឋជាសមាជិកអាស៊ាននីមួយៗ ព្រមទាំងក្រុមគោលដៅនៅក្នុងប្រទេសនីមួយៗ អាចសម្រេចចិត្តប្រើប្រាស់សៀវភៅមគ្គុទេសក៍ជាភាសាអង់គ្លេសក៏បាន ឬជាកំណែបកប្រែក៏បាន។ ប្រសិនបើការប្រើប្រាស់កំណែបកប្រែ ត្រូវមានការពិនិត្យឱ្យបានការប្រុងប្រយ័ត្ន ដើម្បីធានាថាការបកប្រែពិតជាបានឆ្លុះបញ្ចាំងយ៉ាងសុក្រិត លើអត្ថន័យដែលគេចង់បានប្រាកដមែន។

ខ្លឹមសារលម្អិតនៃសៀវភៅមគ្គុទេសក៍នេះត្រូវបានរៀបរៀងឡើង ដើម្បីជួយឱ្យរដ្ឋជាសមាជិកអាស៊ាន អង្គការ ឬស្ថាប័ននីមួយៗ ធ្វើការបកស្រាយទៅតាមបរិបទរៀងៗខ្លួន។ ឧទាហរណ៍ អ្នកពាក់ព័ន្ធមួយចំនួនប្រហែលជាត្រូវជំនួសពាក្យមួយចំនួនចេញ ដោយប្រើប្រាស់វាក្យសព្ទដែលពាក់ព័ន្ធទៅនឹងបរិបទរបស់ពួកគេ។ តែសូមមានការប្រុងប្រយ័ត្ន ដើម្បីកុំឱ្យប្រាសចាកពីអត្ថន័យដើមនៃខ្លឹមសារក្នុងសៀវភៅមគ្គុទេសក៍នេះ។

**ស្វែងរកការគាំទ្រ**

ACWC ផ្តល់ការគាំទ្រសម្រាប់ការប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ ក៏ដូចជាឧបករណ៍រាយការណ៍ ទៅតាមការស្នើសុំ។

**រាយការណ៍**

ខាងក្រោមនេះ គឺជាជំហានដែលគួរអនុវត្តតាម ដើម្បីប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ ឱ្យមានប្រសិទ្ធភាពសម្រាប់ធ្វើការរាយការណ៍។

ជំហានទី ០១

## តែងតាំងអ្នកដែលត្រូវប្រើប្រាស់សៀវភៅមគ្គុទេសក៍នេះ

អ្នកគ្រប់គ្រងត្រូវតែងតាំងមន្ត្រីឱ្យទទួលខុសត្រូវ លើការរៀបចំរបាយការណ៍ តាងនាមតំណាងឱ្យអង្គការ ស្ថាប័ន តំបន់ ឬក្រុមការងាររបស់ខ្លួន។ នេះរួមមាន ការកំណត់ ថាតើអង្គការ ឬស្ថាប័ន និងមន្ត្រីទទួលខុសត្រូវនីមួយៗត្រូវធ្វើអ្វីខ្លះ ឬមិនត្រូវធ្វើអ្វីខ្លះ។ គេក៏អាចតែងតាំងមន្ត្រីផ្សេងៗឱ្យទទួលខុសត្រូវលើផ្នែកផ្សេងៗគ្នានៃសៀវភៅមគ្គុទេសក៍នេះផងដែរ។

**សម្គាល់៖ បង្ហាញពីចំណុចដែលស្ថិតនៅក្រៅវិសាលភាពនៃសៀវភៅមគ្គុទេសក៍នេះ តាមរយៈការធីកក្នុងប្រអប់ N/A។**

ជំហានទី ០២

## ស្វែងយល់ពីលទ្ធផលរយៈពេលខ្លី

មន្ត្រីដែលទទួលបន្ទុកត្រូវ៖

- ពិនិត្យលើលទ្ធផលរយៈពេលខ្លីដែលស្ថិតនៅក្នុងវិសាលភាពរបស់ខ្លួន
- សូមអានសេចក្តីពិពណ៌នា និងវិសាលភាព
- នៅពេលមានមន្ទិល សូមប្រើប្រាស់ឯកសារយោង ដើម្បីបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយនឹងបំណងនៃឯកសារដើម។

ជំហានទី ០៣

## ប្រមូលភ័ស្តុតាង

មន្ត្រីទទួលបន្ទុកត្រូវ៖

- ប្រមូលភស្តុតាង ឬស្រាវជ្រាវចំណុចដែលស្ថិតនៅក្នុងបញ្ជីត្រួតពិនិត្យ។

**សម្គាល់៖ នេះអាចរួមមានការប្រមូលទិន្នន័យបែបបរិមាណ និងគុណវិស័យ និងគ្រប់វិស័យ និងការពិនិត្យ ផ្ទៀងផ្ទាត់ជាមួយឱ្យបុគ្គលិកពាក់ព័ន្ធ ក៏ដូចជាធ្វើការពិភាក្សាពីការអនុវត្តនាពេលបច្ចុប្បន្ន។**

ជំហានទី ០៤

## បំពេញបញ្ជីត្រួតពិនិត្យ

មន្ត្រីទទួលបន្ទុកត្រូវ៖

- ប្រើប្រាស់ការវាយតម្លៃរបស់ខ្លួនលើចំណុចនីមួយៗនៅក្នុងបញ្ជីត្រួតពិនិត្យ និង ធីកចំណុចទាំងឡាយណាដែលត្រូវបានបង្ហាញ។

**សម្គាល់៖ មន្ត្រីទទួលបន្ទុកចាំបាច់ត្រូវប្រើប្រាស់ការវិនិច្ឆ័យផ្ទាល់ខ្លួននៅត្រង់ជំហាននេះ ផ្អែកតាមការបង្ហាញដ៏សមស្របអំពីចំណុចនីមួយៗនៅក្នុងបញ្ជីត្រួតពិនិត្យ។**

ជំហានទី ០៥

**កំណត់ពីវឌ្ឍនភាពនៃលទ្ធផលរយៈពេលខ្លីនីមួយៗ**

មន្ត្រីទទួលបន្ទុកត្រូវ៖

- ធ្វើការកំណត់ពីពិន្ទុដែលសមស្របបំផុតសម្រាប់ស្វ័យវាយតម្លៃ ដោយប្រើប្រាស់គំរូ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លីនីមួយៗ (មុនពេលសម្រេចបានវឌ្ឍនភាព, វឌ្ឍនភាពសម្រេចបានក្នុងកម្រិតបង្គួរ, ឬវឌ្ឍនភាពដែលសម្រេចបានក្នុងកម្រិតខ្ពស់) និងជ្រើសរើសប្រអប់ដែលពាក់ព័ន្ធនៅក្នុងសៀវភៅមគ្គុទេសក៍នេះ។

# ការបង្កើនការយល់ដឹង និង ការទប់ស្កាត់អំពើជួញដូរមនុស្ស

១

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

សកម្មភាពអប់រំ និងយុទ្ធនាការផ្សព្វផ្សាយនានា ផ្តោតលើការយល់ដឹងកម្រិតមូលដ្ឋានអំពីអំពើជួញដូរមនុស្ស និងក្របខ័ណ្ឌច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ព្រមទាំងភាពងាយរងគ្រោះ និងហានិភ័យ ក៏ដូចជា ផលវិបាកនៃអំពើជួញដូរមនុស្ស។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៤.៤។
- អនុសញ្ញា ACTIP មាត្រា ១១(២)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ញបសិទ្ធិជនមានពិការភាព APSC ២៣។

### សេចក្តីអធិប្បាយ និងការពន្យល់

ការអប់រំ និងការផ្សព្វផ្សាយដល់សាធារណជន រួមមាន ការរៀបចំសម្រាប់ការអនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន តាមប្រព័ន្ធផ្សព្វផ្សាយ និងគំនិតផ្តួចផ្តើមសង្គមសេដ្ឋកិច្ច ដើម្បីកសាងការយល់ដឹង ចំណេះដឹងអំពីការជួញដូរមនុស្ស និងការឃ្លាំមើល ដើម្បីទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងមិនលើកទឹកចិត្តឱ្យមានតម្រូវការ និងការផ្គត់ផ្គង់ ដែលជំរុញឱ្យមានការកេងប្រវ័ញ្ចលើមនុស្ស កាត់បន្ថយការមោក់ងាយ និងការការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

### វិសាលភាព

លទ្ធផលនេះ មានជាអាទិ៍៖

- សកម្មភាពអប់រំ និងឯកសារអប់រំផ្សព្វផ្សាយ ត្រូវបានរៀបចំឡើងផ្អែកលើភ័ស្តុតាង និងគោលការណ៍សិទ្ធិ ដើម្បីផ្សព្វផ្សាយដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងសហគមន៍អំពីអំពើជួញដូរមនុស្ស ក្របខ័ណ្ឌច្បាប់ គំនិតផ្តួចផ្តើមប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស កម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ព្រមទាំងអត្ថប្រយោជន៍នៃកម្មវិធីទាំងនេះ ក៏ដូចជា ភាពងាយរងគ្រោះរបស់ក្រុមប្រជាជនមួយចំនួនដោយសារអំពើជួញដូរមនុស្ស។
- សកម្មភាព និងឯកសារសម្ភារៈនានា គួររៀបចំឡើង និងអនុវត្តឱ្យសមស្របតាមអាយុ និងផ្តល់ភាពងាយស្រួលសម្រាប់ក្រុមគោលដៅ ទៅតាមទីកន្លែង វប្បធម៌ និងតម្រូវការជាមូលដ្ឋានរបស់ពួកគេ។
- គំនិតផ្តួចផ្តើមនានា ជំរុញឱ្យមានការចូលរួមពីប្រជាជនគ្រប់ស្រទាប់ វណ្ណៈនៅក្នុងសង្គម រួមទាំងអង្គការសង្គមស៊ីវិល វិស័យឯកជន ស្ថាប័នសិក្សាស្រាវជ្រាវ និងអ្នកដឹកនាំសហគមន៍ឱ្យសហការជាមួយរដ្ឋាភិបាលក្នុងការបង្ការទប់ស្កាត់ និងអប់រំផ្សព្វផ្សាយ។
- យុទ្ធនាការដឹកនាំដោយប្រជាជនបានយកចិត្តទុកដាក់ចំពោះយេនឌ័រផ្តោតលើជនរងគ្រោះ និងផ្តល់ភាពងាយស្រួលដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពបានចូលរួម។
- សម្ភារៈឯកសារនានា ដែលផលិតឡើងផ្អែកលើភស្តុតាង គឺជាឯកសារដែលងាយស្រួលយល់ និងរៀបចំគ្រប់ភាសា ព្រមទាំងផ្សព្វផ្សាយតាមថ្នាលបច្ចេកវិទ្យាមេឌា និងប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា វិទ្យុ ទូរទស្សន៍ សារព័ត៌មានបោះពុម្ព និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ សកម្មភាព និងយុទ្ធនាការអប់រំផ្សព្វផ្សាយអំពីអំពើជួញដូរមនុស្សផ្អែកលើភ័ស្តុតាងជាច្រើនប្រភេទត្រូវបានអនុវត្ត។
- ☐ សកម្មភាពអប់រំមានគោលបំណងអប់រំផ្សព្វផ្សាយដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ជាពិសេស ក្រុមងាយរងគ្រោះ ដូចជាស្ត្រី និងកុមារ និងជនមានពិការភាព អំពីគ្រោះថ្នាក់ដែលបង្កឡើងដោយសារអំពើជួញដូរមនុស្ស។
- ☐ យុទ្ធនាការដែលមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្តោតលើជនរងគ្រោះ ផ្តល់ព័ត៌មានដែលងាយស្រួលយល់ដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ជាពិសេស ក្រុមប្រជាជនងាយរងគ្រោះដោយសារអំពើជួញដូរមនុស្សជាងគេ។
- ☐ ឯកសារសម្ភារៈនានា ត្រូវបានដាក់តាំងបង្ហាញនៅទីតាំងដែលគេអាចមើលឃើញ និងតាមថ្នាលបច្ចេកវិទ្យាមេឌាសង្គម។
- ☐ សកម្មភាពនានា ត្រូវបានដាក់ឆ្លងការពិនិត្យជាបន្តបន្ទាប់ និងមានការកែលម្អជាប្រចាំ។

| លទ្ធផលរយៈពេលមធ្យម ( ២ ទៅ ៥ ឆ្នាំ ) | លទ្ធផលរយៈពេលវែង ( ចាប់ពី ៥ ឆ្នាំឡើងទៅ ) |
|---|---|
| ការយល់ដឹងកាន់តែច្រើនអំពីការអំពើជួញដូរមនុស្ស នាំឱ្យគេអាចឱ្យកាន់តែកំណត់ដឹងនិងរាយការណ៍ទាន់ពេលវេលាអំពីករណីជួញដូរមនុស្ស។ | ការយល់ដឹងនិងការរាយការណ៍ពីអំពើជួញដូរកាន់តែច្រើននាំឱ្យប្រេវ៉ាឡង់នៃអំពើជួញដូរមនុស្សមានការថយចុះ។ |

**ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី**

| | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ការបង្កើនការយល់ដឹង និងការទប់ស្កាត់ អំពើជួញដូរមនុស្ស

២

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

មាគ៌ាសម្រាប់ធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ត្រូវបានបង្កើតឡើង និង/ពង្រឹង និងលើកម្ពស់។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៤.៥, ៤.៩។
- អនុសញ្ញា ACTIP មាត្រា ១២(e)។

## សេចក្តីអធិប្បាយ និងការពន្យល់

ប្រទេសប្រភពដើមផ្តល់ឱកាស ដើម្បីឱ្យមានការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ ទទួលបានផលចំណេញ និងពុំមានការរើសអើង ដែលក្នុងនោះ យន្តការនិយ័តកម្ម និងត្រួតពិនិត្យត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីការពារសិទ្ធិ និងសុវត្ថិភាពរបស់ពលករទេសន្តរប្រវេសក៍ និងក្រុមជនងាយរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស។

## វិសាលភាព

លទ្ធផលនេះ រួមមាន យុទ្ធនាការអប់រំផ្សព្វផ្សាយដល់សាធារណជនអំពីអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ស្របច្បាប់ ដើម្បី៖

- ជួយឱ្យប្រជាពលរដ្ឋអាចផ្លាស់ទីដោយសេរី និងគោរពតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាធរអន្តោប្រវេសន៍។ រដ្ឋជាសមាជិកអាស៊ានផ្សព្វផ្សាយព័ត៌មានត្រឹមត្រូវអំពីជម្រើសទេសន្តរប្រវេសន៍ដែលស្របច្បាប់ មានសុវត្ថិភាព និងពុំមានការរើសអើង។
- ផ្តល់ព័ត៌មានដល់អ្នកដែលមានបំណងចង់ធ្វើចំណាកស្រុក ជាពិសេស ស្ត្រី អំពីហេតុផលប៉ះពាល់នៃទេសន្តរប្រវេសន៍ និងទេសន្តរប្រវេសន៍ខុសច្បាប់ ដូចជា ការកេងប្រវ័ញ្ច ការជាប់បំណុល បញ្ហាសុវត្ថិភាព និងបញ្ហាសុខភាព ដូចជា ការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ និងការជេកហូតសរីរាង្គ និងការរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយដល់សាធារណជន។
- ផ្តល់ឱកាសធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ប្រកបដោយសុវត្ថិភាព យុត្តិធម៌ និងគោរពតាមក្រមសីលធម៌ និងជំរុញឱ្យមានការអនុវត្តវិធានការគតិយុត្ត និងត្រួតពិនិត្យ ដែលការពារសិទ្ធិពលករទេសន្តរប្រវេសក៍។
- ផ្តល់ព័ត៌មានដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តោតលើជនរងគ្រោះ និងងាយស្រួលយល់សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពផងដែរ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

ប្រទេសប្រភពដើម និងប្រទេសគោលដៅ៖

- ☐ ជួយឱ្យប្រជាពលរដ្ឋអាចការផ្លាស់ទីដោយសេរី និងជានាឱ្យមានការគោរពតាមលក្ខខណ្ឌ សម្រាប់ការធ្វើអន្តោប្រវេសន៍។
- ☐ ផ្តល់ព័ត៌មានដល់អ្នកដែលមានបំណងចង់ធ្វើចំណាកស្រុក និងពលករចំណាកស្រុកដែលទើបមកដល់ អំពីហានិភ័យនៃអំពើជួញដូរមនុស្ស នៅក្នុងដំណើរការទេសន្តរប្រវេសន៍ស្របច្បាប់ និងមិនស្របច្បាប់។
- ☐ រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈអំពីអំពើជួញដូរមនុស្ស និងហានិភ័យនៃទេសន្តរប្រវេសន៍ និងទេសន្តរប្រវេសន៍ខុសច្បាប់។
- ☐ ជំរុញឱ្យមានការអនុវត្តវិធានការគតិយុត្តនិងវិធានការត្រួតពិនិត្យ ដើម្បីការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសក៍។
- ☐ ផ្សព្វផ្សាយព័ត៌មានដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តល់ដោយជនរងគ្រោះ និងងាយស្រួលយល់សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ការយល់ដឹងកាន់តែច្រើន អំពីការអំពើជួញដូរមនុស្ស នាំឱ្យគេអាចឱ្យកាន់តែកំណត់ដឹង និងរាយការណ៍ទាន់ពេលវេលាអំពីករណីជួញដូរមនុស្ស។ | ការយល់ដឹង និងការរាយការណ៍ពីអំពើជួញដូរកាន់តែច្រើន នាំឱ្យប្រេវ៉ាឡង់នៃអំពើជួញដូរមនុស្សមានការថយចុះ។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការបង្កើនការយល់ដឹង និងការទប់ស្កាត់ អំពើជួញដូរមនុស្ស

៣

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

មានការស្រាវជ្រាវ ប្រមូលទិន្នន័យ និងចងក្រងការអនុវត្តល្អអំពីករណីជួញដូរមនុស្ស និងបញ្ហាពាក់ព័ន្ធនានា។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៤.១, ៤.៨។
- អនុសញ្ញា ACTIP មាត្រា ១១(៤)។

## សេចក្តីអធិប្បាយ និងការពន្យល់

ប្រទេស និងអង្គការស្ថាប័ននានា ធ្វើការស្រាវជ្រាវ ការសិក្សា និងការវិភាគស្ថានភាពផ្លូវការ និងក្រៅផ្លូវការអំពីករណីជួញដូរមនុស្ស បញ្ហាដែលលេចឡើងថ្មីៗ ព្រមទាំងប្រធានបទដែលពាក់ព័ន្ធ។ ការប្រមូលទិន្នន័យស្តីពីអំពើជួញដូរមនុស្សបែងចែកតាម GEDSI ព្រមទាំងការអនុវត្តនានា អាចធ្វើឡើងដោយរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកជំនាញ ដើម្បីធ្វើការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្សឱ្យបានកាន់តែប្រសើរ។

## វិសាលភាព

ការស្រាវជ្រាវ ការសិក្សា និងការវិភាគស្ថានភាព ដែលធ្វើឡើងដោយរដ្ឋជាសមាជិកអាស៊ាន ឬអង្គការសង្គមស៊ីវិល ដើម្បី៖

- ផ្តល់ជាព័ត៌មាន ឬកែសម្រួលគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់
- ពង្រឹងការអនុវត្តវិធានការនានា
- លើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី និង
- ផ្តល់ជាព័ត៌មានសម្រាប់ធ្វើជាមូលដ្ឋានដែលធ្វើការសម្រេចចិត្តផ្ទៃក្នុងស្ថាប័ន

ប្រធានបទអាចមានជាអាទិ៍៖

- កត្តាដែលធ្វើឱ្យប្រជាពលរដ្ឋងាយត្រូវបានគេជួញដូរ ដូចជា ភាពក្រីក្រ ការអភិវឌ្ឍតិចតួច និងការមិនមានឱកាសស្មើភាពគ្នា ការរើសអើង និងការផាត់ចេញពីសង្គម
- និន្នាការនៃតម្រូវការ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដូចជាការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មប្រកបដោយការកេងប្រវ័ញ្ចការដកហូតសរីរាង្គ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបញ្ហាពាក់ព័ន្ធដទៃទៀត
- កត្តាអំណោយផល ដូចជា ច្បាប់ គោលនយោបាយ និងនីតិវិធី ដែលការអនុវត្តនៅខ្សោយ អំពើពុករលួយ ព្រមទាំងបញ្ហាដែលពាក់ព័ន្ធដទៃទៀត ការជួញដូរមនុស្ស ដើម្បីបង្ខំឱ្យប្រព្រឹត្តបទល្មើស និង
- ការអនុវត្តល្អពាក់ព័ន្ធនឹងការទប់ស្កាត់ និងការលុបបំបាត់អំពើជួញដូរមនុស្ស។

ការប្រមូលទិន្នន័យអាចមានជាអាទិ៍៖

- ការស្រាវជ្រាវផ្លូវការ ក្រៅផ្លូវការ និងការប្រមូលសរុបព័ត៌មានពីឯកសារ និងរបាយការណ៍ផ្សេងៗ ដើម្បីយកមកធ្វើការវិភាគ។

លទ្ធផល អាចផ្សព្វផ្សាយជាសាធារណៈ និងរៀបចំឱ្យស្រួលយល់ ហើយទន្ទឹមគ្នាត្រូវធ្វើការពិចារណាពីក្សាការសម្ងាត់ ឯកជនភាព និងអត្តសញ្ញាណផងដែរ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ការស្រាវជ្រាវត្រូវបានធ្វើឡើងផ្តោតលើកត្តា និងបញ្ហាថ្មីៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។
- ☐ អង្គការស្ថាប័ននានា ធ្វើការស្រាវជ្រាវជាលក្ខណៈផ្ទៃក្នុង
- ☐ អនុសាសន៍ និងលទ្ធផលរកឃើញ ដែលទទួលពីការស្រាវជ្រាវ ត្រូវបានប្រើប្រាស់សម្រាប់ទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្ស។
- ☐ ទិន្នន័យនៃអំពើជួញដូរមនុស្សបែងចែកតាម GEDSI ត្រូវបានប្រមូល វិភាគ និងចែករំលែកជាមួយនឹងអ្នកពាក់ព័ន្ធ។
- ☐ លទ្ធផលរកឃើញនៃការស្រាវជ្រាវ និងការវិភាគទិន្នន័យអំពើជួញដូរមនុស្ស ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំច្បាប់ គោលនយោបាយ និងអាចផ្លាស់ប្តូរការអនុវត្តការងារ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ភស្តុតាងត្រូវបានប្រើប្រាស់ដើម្បីដាក់ចេញនូវវិធានការផ្អែកលើភស្តុតាង ដើម្បីប្រយុទ្ធប្រឆាំងនឹងការផ្គត់ផ្គង់ និងតម្រូវការនៃអំពើជួញដូរមនុស្ស។ | ការស្រាវជ្រាវ និងការរាយការណ៍អំពីអំពើជួញដូរមនុស្ស នាំឱ្យប្រេវ៉ាឡង់នៃអំពើជួញដូរមនុស្សមានការថយចុះ និងមានការឆ្លើយតបកាន់តែប្រសើរ។ |

## ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី

| | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ការបង្កើនការយល់ដឹង និងការទប់ស្កាត់ អំពើជួញដូរមនុស្ស

៤

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

រដ្ឋាភិបាល និងស្ថាប័ននានា មានច្បាប់ និងគោលនយោបាយ ផែនការ កម្មវិធី ធនធាន កិច្ចព្រមព្រៀង និងគោលការណ៍ណែនាំពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៤.២, ៤.៨, ៤.១៦។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៩។
- អនុសញ្ញា ACTIP មាត្រា ១១(៤)។

### សេចក្តីអធិប្បាយ និងការពន្យល់

រដ្ឋជាសមាជិកអាស៊ាន ដាក់ឱ្យអនុវត្តច្បាប់ គោលនយោបាយ ផែនការ យុទ្ធសាស្ត្រ កម្មវិធី និងគំនិតផ្តួចផ្តើមពាក់ព័ន្ធអំពើជួញដូរមនុស្ស នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយមានការទឹកដល់នៅធនធានសម្រាប់ការអនុវត្តនិងមានការលើកកម្ពស់ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការរវាងរដ្ឋជាសមាជិកអាស៊ាន។

ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានពង្រឹង ដើម្បីវាយតម្លៃ និងពិនិត្យលើច្បាប់ ផែនការ កម្មវិធី ឬគំនិតផ្តួចផ្តើមប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

### វិសាលភាព

លទ្ធផលនេះ រួមមាន ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ៖

- ប្រទេសនានាធ្វើការវាយតម្លៃ (ឡើងវិញ) និងកែសម្រួលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដើម្បីការពារកម្មករនិយោជិតនៅក្នុងវិស័យដែលការកេងប្រវ័ញ្ចតែងកើតមានឡើង និងធានាឱ្យមានការធ្វើទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព ដោយធ្វើការពិចារណាពីឱ្យផលប៉ះពាល់ ដែលច្បាប់ ដែលមានចរិតរើសអើងមានលើក្រុមងាយរងគ្រោះនានា ដូចជា ស្ត្រី កុមារ និងជនមានពិការភាព។
- រចនាសម្ព័ន្ធ ឬយន្តការនានា ដូចជា ក្រុមការងារ ឬអង្គភាពប្រឆាំងអំពើជួញដូរមនុស្ស នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើង។

លទ្ធផលនេះ រួមមាន គំនិតផ្តួចផ្តើមកាត់បន្ថយភាពងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស៖

- វិធានការនានា ឆ្លើយតបចំពោះកត្តា ដែលធ្វើឱ្យបុគ្គល ជាពិសេសស្ត្រី និងកុមារងាយត្រូវបានគេជួញដូរ។ វិធានការទាំងនេះ មានបញ្ចូលកត្តានានា ដែលជួបប្រសព្វគ្នា ដូចជា ភាពក្រីក្រ ការអភិវឌ្ឍតិចតួច វិសមភាពយេនឌ័រ និងការពុំមានឱកាសស្មើភាពគ្នា។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ប្រទេសនានា ធ្វើការកំណត់ កែសម្រួល និងដាក់ឱ្យអនុវត្តនូវច្បាប់ គោលនយោបាយប្រឆាំងអំពើជួញដូរមនុស្ស។
- ☐ កម្មវិធីលើកកម្ពស់មុខរបរចិញ្ចឹមជីវិត ត្រូវបានអនុវត្តសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ ស្ថាប័ននានា សហការ និងសម្របសម្រួលជាមួយគ្នាក្នុងការផ្តល់សេវាថែទាំ និងការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ កិច្ចព្រមព្រៀងប្រយុទ្ធប្រឆាំងអំពើជួញដូរទ្វេភាគីត្រូវបានរៀបចំឡើង និង/ឬត្រូវបានពង្រឹង ការអនុវត្ត និងមានធនធានគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការអនុវត្ត។

## វិសាលភាព

- កម្មវិធីអប់រំ( ឧទាហរណ៍អក្ខរកម្ម)និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅមធ្យោបាយប្រកបរបរចិញ្ចឹមជីវិត និងបង្ការមិនឱ្យធ្លាក់ចូលទៅក្នុងស្ថានភាពជួញដូរមនុស្សធម៌ជាថ្មី។

លទ្ធផលនេះ រួមមាន ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការៈ

- ការផ្តល់ និងការបង្កលក្ខណៈងាយស្រួល ដើម្បីឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចទទួលបានសេវាថែទាំ និងសេវាគាំទ្រនានាត្រូវបានជំរុញដោយ
- រដ្ឋាភិបាល ក្រសួងស្ថាប័ន និងទីភ្នាក់ងារនៅថ្នាក់ជាតិ ខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការអន្តរស្ថាប័ន ក្នុងគោលបំណងបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈអនុស្សរណៈជាលក្ខណៈទ្វេភាគី ក្នុងករណីអាចធ្វើទៅបាន។
- កិច្ចព្រមព្រៀង ការសហការ និងការសម្របសម្រួលថ្នាក់តំបន់ បានទទួលធនធានគ្រប់គ្រាន់ និងគាំទ្រដល់ការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ករណីជួញដូរមនុស្ស រួមនឹងការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆ្លងដែននានា។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| រដ្ឋាភិបាល ក្រសួងស្ថាប័ន និងហេតុទីភ្នាក់ងារនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រៀបចំ និងអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងកម្មវិធីដែលចាំបាច់នានា។ | ច្បាប់ និងគោលនយោបាយប្រឆាំងអំពើជួញដូរមនុស្ស មានលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវបានពង្រឹងបន្ថែម និងកាត់បន្ថយប្រេវ៉ាឡង់នៃអំពើជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការបង្កើនការយល់ដឹង និងការទប់ស្កាត់ អំពើជួញដូរមនុស្ស



## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ច្បាប់ និងគោលនយោបាយនានា ត្រូវបានអនុវត្ត ដើម្បីស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសករណីជួញដូរមនុស្ស លើកកម្ពស់សិទ្ធិរបស់ជនដែលត្រូវបានគេជួញដូរ ជាពិសេសសិទ្ធិទទួលបានដំណោះស្រាយ និងសំណងបដិទាន និង/ឬសំណងជំងឺចិត្ត និងបង្ការទប់ស្កាត់ករណីជួញដូរមនុស្ស។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៣.៦.២។
- អនុសញ្ញា ACTIP មាត្រា ១២(h), ១៦(៩)។

## សេចក្តីអធិប្បាយ និងការពន្យល់

អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងជនល្មើស រាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាល ដែលចូលរួមប្រព្រឹត្តអំពើជួញដូរមនុស្សផងដែរ ត្រូវបានគេស៊ើបអង្កេត និងចោទប្រកាន់ទោស ស្របតាមអនុសញ្ញា ACTIP។ លទ្ធផលនេះ គឺមានគោលបំណងធានាឱ្យមានការពង្រឹងការអនុវត្តសិទ្ធិរបស់ជនរងគ្រោះ ជាពិសេសសិទ្ធិទទួលបានដំណោះស្រាយនានា ដូចជា សំណងបដិទាន និង/ឬសំណងជំងឺចិត្ត និងការដាក់ទោសឱ្យបានសមស្រប ដើម្បីការទប់ស្កាត់មិនឱ្យករណីបែបនេះកើតឡើងបន្តទៀត។

## វិសាលភាព

លទ្ធផលនេះ រួមមាន វិធានការសម្រាប់ទប់ស្កាត់អំពើជួញដូរមនុស្ស៖

- ការស៊ើបអង្កេត ការរឹតត្បិតលើការធ្វើដំណើរ ការជំនុំជម្រះ និងការចោទប្រកាន់ទោស អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងជនផ្សេងទៀត ស្របតាមច្បាប់ជាតិ និងធានាថាជនដែលប្រព្រឹត្ត ឬគាំទ្រដល់ការប្រព្រឹត្តអំពើជួញដូរមនុស្ស ត្រូវបាននាំមកទទួលទោសចំពោះមុខច្បាប់។
- ការជំរុញ ការចូលរួមរបស់សហគមន៍ក្នុងការអប់រំផ្សព្វផ្សាយ ការបង្ការទប់ស្កាត់ ករណីជួញដូរមនុស្ស និងការរាយការណ៍ពីបទល្មើសជួញដូរមនុស្ស។
- រដ្ឋជាសមាជិកអាស៊ាន លើកកម្ពស់កិច្ចខិតខំប្រឹងប្រែង ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស រាយការណ៍ពីការស៊ើបអង្កេត ការឃាត់ខ្លួន ការចោទប្រកាន់ជាសាធារណៈ ព្រមទាំងពីចំនួនសំណងបដិទាន និង/ឬសំណងជំងឺចិត្ត ដែលត្រូវបានផ្តល់ដោយជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ច្បាប់ជាតិ ត្រូវបានដាក់ឱ្យអនុវត្ត ដែលបង្គលក្ខណៈឱ្យគេអាចធ្វើការស៊ើបអង្កេតលើអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងជនផ្សេងទៀត ព្រមទាំងបទល្មើសពាក់ព័ន្ធ។
- ☐ ច្បាប់ជាតិ ត្រូវបានដាក់អនុវត្ត ដើម្បីបង្គលក្ខណៈឱ្យមានការចោទប្រកាន់ និងការជំនុំជម្រះលើអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងបុគ្គលផ្សេងទៀត។
- ☐ ច្បាប់ជាតិត្រូវបានអនុវត្តដើម្បីអាចឱ្យគេផ្តល់សំណងបដិទាន និង/ឬសំណងជំងឺចិត្តដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ សហគមន៍ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការអប់រំផ្សព្វផ្សាយ ការទប់ស្កាត់ និងការរាយការណ៍ពីករណីជួញដូរមនុស្ស។
- ☐ ព័ត៌មានអំពីការចោទប្រកាន់ទោសពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើជួញដូរមនុស្ស ងាយស្រួលយល់សម្រាប់សាធារណជន ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សមិនឱ្យកើតមានឡើង។

| លទ្ធផលរយៈពេលមធ្យម ( ២ ទៅ ៥ ឆ្នាំ ) | លទ្ធផលរយៈពេលវែង ( ចាប់ពី ៥ ឆ្នាំឡើងទៅ ) |
|---|---|
| អ្នកប្រព្រឹត្តអំពើជួញដូរមនុស្ស និងបុគ្គលផ្សេងទៀត ដែលចូលរួមប្រព្រឹត្តអំពើជួញដូរមនុស្ស ត្រូវបានស៊ើបអង្កេត និងចោទប្រកាន់ទោសជាទៀងទាត់។ | ការស៊ើបអង្កេត និងការចោទប្រកាន់ទោសករណីអំពើជួញដូរមនុស្សកាន់តែច្រើន បង្កការរំខានដល់ការប្រព្រឹត្តអំពើជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ការបង្កើនការយល់ដឹង និងការទប់ស្កាត់ អំពើជួញដូរមនុស្ស

៦

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ទីភ្នាក់ងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស មានការយល់ដឹងអំពីជាតុផ្សំនៃអំពើជួញដូរមនុស្ស ជំនាញផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ និងមានធនធាន ដើម្បីអនុវត្តសកម្មភាពទប់ស្កាត់អំពើជួញដូរមនុស្ស។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៤.១.១។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៤.១០, ៤.១៦។
- អនុសញ្ញា ACTIP មាត្រា ១៣(២), ១៦(១), ១៦(៦)។

## សេចក្តីអធិប្បាយ និងការពន្យល់

ទីភ្នាក់ងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស អាជ្ញាធរពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកដឹកនាំសហគមន៍មានសមត្ថភាព ចំណេះដឹង ជំនាញផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ដែលអាចប្រើប្រាស់ក្នុងការអនុវត្តវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស។

## វិសាលភាព

មានការផ្តល់ធនធានដល់ទីភ្នាក់ងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាជ្ញាធរពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ព្រមទាំងអ្នកដឹកនាំសហគមន៍ ក្នុងការរៀបចំការបណ្តុះបណ្តាល ដើម្បី៖

- ពង្រឹងសមត្ថភាពរបស់អ្នកជំនាញ ក្នុងការស្រាវជ្រាវ និងទប់ស្កាត់អំពើជួញដូរមនុស្សឱ្យបានទាន់ពេលវេលា
- លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារ និងកិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់
- ពង្រឹងការត្រួតពិនិត្យព្រំដែន ជាមួយនឹងការយល់ដឹងកាន់តែច្បាស់ពីករណីជួញដូរមនុស្ស
- ធានាឱ្យមានការចេញឯកសារសម្គាល់អត្តសញ្ញាណ និងឯកសារសម្រាប់ការធ្វើដំណើរ
- វិធានការប្រឆាំងការក្លែងបន្លំឯកសារ និងការប្រើប្រាស់ឯកសារក្លែងបន្លំ និង
- អនុវត្តសកម្មភាពទប់ស្កាត់ និងអប់រំផ្សព្វផ្សាយ ដោយមានការផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ការត្រួតពិនិត្យព្រំដែនយ៉ាងតឹងរ៉ឹងត្រូវបានអនុវត្ត និងមានការបង្កើនការយល់ដឹងអំពីករណីជួញដូរមនុស្សដើម្បីគាំទ្រដល់ការអនុវត្តវិធានការទាំងនេះ។
- ☐ ធនធាននានាត្រូវបានបែងចែកសម្រាប់អនុវត្ត និងពង្រឹងសមត្ថភាព អ្នកដែលអនុវត្តការងារប្រឆាំងអំពើជួញដូរមនុស្ស ដូចជាអ្នកឆ្លើយតបជួរមុខ ក្នុងការធ្វើសកម្មភាពទប់ស្កាត់ និងអប់រំផ្សព្វផ្សាយដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្តោតលើជនរងគ្រោះ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ទីភ្នាក់ងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានជំនាញ ដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ ព្រមទាំងសមត្ថភាពអាចកំណត់ដឹង និងទប់ស្កាត់បទល្មើសជួញដូរមនុស្សឱ្យបានទាន់ពេលវេលា។ | វិធានការអប់រំផ្សព្វផ្សាយ និងទប់ស្កាត់អំពើជួញដូរមនុស្ស កាត់បន្ថយករណីជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការបង្កើនការយល់ដឹង និងការទប់ស្កាត់ អំពើជួញដូរមនុស្ស

៧

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយស្តីពីការសង្គ្រោះ និងការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងស្ថានភាពអាសន្នមានបញ្ចូលការទប់ស្កាត់អំពើជួញដូរមនុស្ស។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៣.៨.១.២, ៣.៨.១.៣។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ញាបសិទ្ធិជនមានពិការភាព APSC ៩, ១២, ១៣, ១៤។

### សេចក្តីអធិប្បាយ និងការពន្យល់

គ្រោះមហន្តរាយ និងស្ថានភាពអាសន្ននានា រួមមានគ្រោះមហន្តរាយធម្មជាតិជាអាទិ៍ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ រលកយក្សស៊ូណាមិ គ្រោះរញ្ជួយដី និងការផ្ទុះភ្នំភ្លើង ។ល។ ស្ថានភាពទាំងនេះ ក៏រាប់បញ្ចូលទាំងវិបត្តិមនុស្សធម៌ដូចជា គ្រោះទុរ្ភិក្ស ការចំណាកស្រុកទាំងបង្ខំ និងជម្លោះផងដែរ។ ការសង្គ្រោះនៅពេលដែលមានគ្រោះមហន្តរាយ និងការឆ្លើយតបចំពោះស្ថានភាពអាសន្នមិនអាស្រ័យថាត្រូវតែមានការប្រកាសដាក់ប្រទេសស្ថិតក្នុងស្ថានភាពអាសន្ននោះឡើយ។

អំពើជួញដូរមនុស្ស គឺជាផលវិបាកដែលកើតចេញដោយផ្ទាល់ពីវិបត្តិអ្វីមួយ។ ស្ថានភាពវិបត្តិនាំឱ្យមានកត្តា ហានិភ័យជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សកើតមានឡើង ការបំពានគោលការណ៍នីតិរដ្ឋ និងស្ថាប័ន និងការខ្វះឱកាសសេដ្ឋកិច្ច ធ្វើឱ្យក្រុមប្រជាពលរដ្ឋដែលរងផលប៉ះពាល់ កាន់តែងាយត្រូវបានគេជួញដូរ និងធ្វើឱ្យបណ្តាញឧក្រិដ្ឋជនដែលប្រតិបត្តិការរបស់ពួកគេទទួលរងការបង្អាក់ ត្រូវសម្របខ្លួនទៅនឹងស្ថានភាពថ្មីៗ។ ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស អាចផ្តោតលើទីតាំងថ្មីៗ ដូចជា ជំរុំជនភៀសខ្លួន និងជំរុំជនដែលបាត់បង់ទីលំនៅ ទីកន្លែងឆ្លងកាត់ ឬប្រជាពលរដ្ឋនៅមូលដ្ឋានដែលទទួលយកជនចំណាកស្រុកឱ្យស្នាក់នៅជាដើម។ ការអនុវត្តបែបប្រពៃណី និងវប្បធម៌ដែលអាចនាំមកនូវគ្រោះថ្នាក់ អាចកាន់តែមានការកើនឡើង ក្នុងអំឡុងពេលដែលមានវិបត្តិ ហើយការពុំបាន ផ្តល់ការការពារ និងការមិនមានដំណោះស្រាយចំពោះបញ្ហាចំពោះមុខ ជាកត្តាធ្វើឱ្យប្រជាពលរដ្ឋកាន់តែប្រឈម និងងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស។[៣៦]

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយស្តីពីការសង្គ្រោះនៅពេលដែលមានគ្រោះមហអន្តរាយ និងការឆ្លើយតបចំពោះស្ថានភាពអាសន្ន បានបញ្ចូលការបង្កើនការយល់ដឹង និងការទប់ស្កាត់អំពើជួញដូរមនុស្ស។
- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយស្តីពីការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងវិបត្តិនានា បានបញ្ចូលវិធានការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្សដែលមានការយក ចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្តោតលើជនរងគ្រោះ។
- ☐ អ្នកពាក់ព័ន្ធដែលធ្វើការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងឆ្លើយតបចំពោះស្ថានភាពអាសន្ន បានសម្របសម្រួល និងសហការជាមួយអ្នកពាក់ព័ន្ធដែលធ្វើការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស នៅពេលដែលមានវិបត្តិ និងស្ថានភាពអាសន្នកើតមានឡើង។
- ☐ អ្នកឆ្លើយតបជួរមុខចំពោះស្ថានភាពអាសន្ន បានទទួលការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់គោលការណ៍ណែនាំថ្នាក់ជាតិ ឬនីតិវិធីប្រតិបត្តិការស្តង់ដារពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះឱ្យបានទាន់ពេលវេលា។
- ☐ យុទ្ធនាការអប់រំផ្សព្វផ្សាយអំពីអំពើជួញដូរមនុស្សនិងអំពីច្រកសម្រាប់បញ្ជូនជនរងគ្រោះ ត្រូវបានធ្វើឡើងនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេល ដែលគ្រោះមហន្តរាយកើតមានឡើង។

---

៣៦ International Organization for Migration Addressing Human Traffcking and Exploitation in Times of Crisis ( IOM ) 2015.

## វិសាលភាព

លទ្ធផលនេះស្នើឱ្យមានការបញ្ចូលកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ទៅក្នុងការសង្គ្រោះជនរងគ្រោះពីគ្រោះមហន្តរាយ និងការឆ្លើយតបចំពោះស្ថានភាពអាសន្ន។ តួអង្គដែលធ្វើការងារឆ្លើយតបនឹងអំពើជួញដូរមនុស្ស ចាំបាច់ត្រូវសម្របសម្រួលជាមួយនឹងតួអង្គដែលឆ្លើយតបចំពោះស្ថានភាពអាសន្ន និងគ្រោះមហន្តរាយ ដោយសហការ និងភាពជាដៃគូនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ទាំងរវាង និងនៅក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន។

នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយស្តីពីការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងវិបាកនានា អាចទទួលបានការគាំទ្រដោយ៖

- ផែនការស្តីពីការបង្កើនភាពធន់ចំពោះគ្រោះមហន្តរាយប្រកបដោយបរិយាបន្ន ដោយមានការវិភាជន៍ថវិកា ការផ្តល់ជាឧបករណ៍ជំនួយ ការព្យាបាល ការបង្កភាពងាយស្រួលសម្រាប់ការទទួលបានសេវាថែទាំសុខភាព ការត្រៀមឆ្លើយតបនឹងស្ថានភាពអាសន្ន យុទ្ធសាស្ត្រឆ្លើយតបផែនការសង្គ្រោះ និងយន្តការសម្រាប់ពិនិត្យតាមដាន។
- បណ្តាញអ្នកជំនាញខាងពិការភាព និងសិទ្ធិមនុស្ស ក្នុងហេដ្ឋារចនាសម្ព័ន្ធឆ្លើយតបចំពោះស្ថានភាពអាសន្ន ដោយមានការចូលរួមពីអង្គការជនមានពិការភាព ក្នុងការរៀបចំផែនការ ការអនុវត្ត និងការវាយតម្លៃលើគោលនយោបាយឆ្លើយតបចំពោះគ្រោះមហន្តរាយ និងគ្រោះអាសន្ននានា។
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរបស់អាស៊ាន ព្រមទាំងគោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌពិការភាព និងសិទ្ធិមនុស្ស នៅថ្នាក់អន្តរជាតិ និងថ្នាក់តំបន់។
- ក្របខ័ណ្ឌពិការភាព និងសិទ្ធិមនុស្ស ត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាពស្តីពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងស្ថាប័ន តាមវិស័យនានា ដែលធ្វើការងារពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឆ្លងដែន។
- យុទ្ធនាការអប់រំផ្សព្វផ្សាយអំពីអំពើជួញដូរមនុស្ស និងការបញ្ជូន ផ្តោតលើសាធារណជនទូទៅ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារវិបត្តិ និងប្រជាពលរដ្ឋដែលប្រឈមនឹងហានិភ័យ រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងកងកម្លាំងរក្សាសន្តិភាព ក្នុងគោលបំណងភ្ជាប់គម្លាតចំណេះដឹង មុនពេល ក្នុងអំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយ។[៣៧]
- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកឆ្លើយតបជាមុខ ដើម្បីឱ្យពួកគេគោរពតាមគោលការណ៍ណែនាំ ថ្នាក់ជាតិ ឬនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយស្តីពីការជួយសង្គ្រោះជនរងគ្រោះពីគ្រោះមហន្តរាយ និងការឆ្លើយតបចំពោះស្ថានភាពអាសន្ន ត្រូវបានអនុវត្ត និងមានការកែលម្អជាបន្តបន្ទាប់។ | នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយត្រូវបានធ្វើស្ថាបនីយកម្ម និងបានបញ្ជៀប។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

៣៧ International Organization for Migration Addressing Human Traffcking and Exploitation in Times of Crisis ( IOM ) 2015. p 4.

# ឧទាហរណ៍អំពីការអនុវត្តល្អពាក់ព័ន្ធនឹងការបង្កើនការយល់ដឹង និងការទប់ស្កាត់អំពើជួញដូរមនុស្ស

**យុទ្ធនាការអប់រំផ្សព្វផ្សាយផ្ដោតការយកចិត្តទុកដាក់លើហានិភ័យ ទោស និងផលវិបាកនៃអំពើជួញដូរមនុស្ស**

នៅក្នុងប្រទេសវៀតណាម អង្គការដែលធ្វើការងារនៅក្នុងវិស័យសង្គមកិច្ច បានអនុវត្តសកម្មភាពការពារកុមារ និងពិនិត្យតាមដានលើសកម្មភាពទាំងនេះ តាមរយៈការរៀបចំជាសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងយុទ្ធនាការអប់រំផ្សព្វផ្សាយ។ អង្គការទាំងនេះ ភាគច្រើនជួយផ្ដល់ការគាំទ្រដល់ករណីរំលោភបំពានផ្លូវភេទលើកុមារ តាមរយៈការផ្ដល់ការគាំទ្រ និងដំបូន្មានដោយស្ម័គ្រចិត្ត។

មេធាវីការពារសិទ្ធិកុមារស្ម័គ្រចិត្តជួយដល់អង្គការទាំងនេះ តាមរយៈការរៀបចំការបង្ហាញជាសាធារណៈពីសាលាក្ដីសាកល្បង ដោយប្រើប្រាស់មេធាវីល្បីឈ្មោះ។ គម្រោងនេះ បានទទួលការស្វាគមន៍យ៉ាងខ្លាំងពីប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលមានការអនុវត្តបង្ហាញបែបនេះដ្បិតគំរូបែបនេះផ្ដោតលើអ្នកសិក្សារៀនសូត្រ ងាយស្រួលយល់ និងអាចឱ្យគេចែករំលែកបទពិសោធពាក់ព័ន្ធនឹងការការពារកុមារ អំពើហិង្សាក្នុងគ្រួសារ និងការទប់ស្កាត់ការជួញដូរមនុស្ស។

**ការចាប់ខ្លួនអតិថិជនដែលប្រើប្រាស់សេវា នៃការជួញដូរមនុស្ស**

ការចោទប្រកាន់ករណីជួញដូរមនុស្សនៅក្នុងប្រទេសថៃ ដែលបានទទួលការចាប់អារម្មណ៍យ៉ាងច្រើនពីប្រព័ន្ធផ្សព្វផ្សាយ ផ្ដោតលើការចោទប្រកាន់ទោស បុគ្គលល្បីឈ្មោះម្នាក់ ដែលជាអតិថិជនប្រើប្រាស់សេវាពេស្យាចាររបស់កុមារអាយុក្រោម ១៨ ឆ្នាំ។ អតិថិជនរូបនេះ ត្រូវបានស៊ើបអង្កេតចោទប្រកាន់ទោស និង ផ្ដន្ទាទោសពីបទល្មើសសច្ចារកម្មលើកុមារអាយុក្រោម ១៥ ឆ្នាំ។ គាត់បាត់បង់ការងារដោយពុំទទួលបានប្រាក់សោធន ដ្បិតគាត់ប្រព្រឹត្តបទល្មើសគួរឱ្យស្អប់ខ្ពើម។ ករណីនេះ ធ្វើឱ្យសាធារណជនកាន់តែមានការយល់ដឹង និងជាវិធានការ ដើម្បីទប់ស្កាត់មិនឱ្យគេចូលរួមប្រព្រឹត្តអំពើជួញដូរមនុស្ស ឬប្រើប្រាស់សេវាពេស្យាចារដោយបង្ខំ។

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

## ៨

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ច្បាប់ គោលនយោបាយ និងនីតិវិធីនានា បានបញ្ចូលនិយមន័យនៃអំពើជួញដូរមនុស្ស ដូចដែលមានចែងនៅក្នុងអនុសញ្ញា ACTIP។
- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស ប្រើប្រាស់និយមន័យយ៉ាងសុក្រិតនៃអំពើជួញដូរមនុស្ស ដែលមានចែងនៅក្នុងអនុសញ្ញា ACTIP រួមទាំងធាតុផ្សំនានា ដែលត្រូវញែកឱ្យដាច់ក្នុងករណីដែលជនរងគ្រោះជាមនុស្សពេញវ័យ និងក្នុងករណីដែលជនរងគ្រោះជាកុមារ។
- ☐ កុមារត្រូវបានគេឱ្យនិយមន័យថាជាអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- ☐ វាក្យសព្ទសំខាន់ៗនៅក្នុងនិយមន័យតាមច្បាប់ជាតិស្តីពីអំពើជួញដូរមនុស្ស ត្រូវបានកំណត់ស្របតាមអនុសញ្ញា ACTIP និង/ឬលិខិតុបករណ៍ច្បាប់ ឬគោលការណ៍ណែនាំអន្តរជាតិដែលពាក់ព័ន្ធ។
- ☐ មានការផ្តល់ការបណ្តុះបណ្តាលដល់អ្នកជំនាញ ដើម្បីជួយឱ្យពួកគេយល់ និងអាចយកនិយមន័យនៃ "អំពើជួញដូរមនុស្ស" ទៅប្រើប្រាស់បាន។
- ☐ ច្បាប់ គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធអំពើជួញដូរមនុស្ស ត្រូវបានពិនិត្យ វាយតម្លៃ និងពង្រឹងជាប្រចាំ។

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

រដ្ឋជាសមាជិកអាស៊ានអនុម័ត និងអនុវត្តនិយមន័យ "អំពើជួញដូរមនុស្ស" ដែលមានចែងក្នុងអនុសញ្ញា ACTIP។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ផ្នែក ១.១.១, ១.១.២, ១.១.៣, ៤.១.១។
- អនុសញ្ញា ACTIP មាត្រា ២(ក)-(ង), ១៤(២)។

### សេចក្តីអធិប្បាយ និងការពន្យល់

ពិធីសារបស់អង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ បង្រ្កាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលអាចជាឯកសារបំពេញបន្ថែមឱ្យអនុសញ្ញាប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំងរបស់អង្គការសហប្រជាជាតិ[៣៨] ត្រូវបានចាត់ទុកថាជា "ឧបករណ៍ចងកាតព្វកិច្ចផ្លូវច្បាប់ដ៏សំខាន់របស់សកលលោក ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស" ជាពិសេស ពិធីសារនេះបានឱ្យនិយមន័យតាមច្បាប់អន្តរជាតិ ជាលើកដំបូងដល់ពាក្យថា "ការជួញដូរមនុស្ស"។ ពិធីសារស្តីពីអំពើជួញដូរមនុស្សឆ្នាំ២០០០នេះ ត្រូវបានរដ្ឋ និងសហគមន៍អន្តរជាតិនានា ទទួលយកយ៉ាងទូលំទូលាយ ហើយលិខិតុបករណ៍ច្បាប់ និងគោលនយោបាយសំខាន់ៗស្តីពីអំពើជួញដូរមនុស្សរបស់អន្តរជាតិ បានយកនិយមន័យដែលមានចែងនៅក្នុងពិធីសារនេះទៅប្រើប្រាស់ ក្នុងនោះមានទាំងអនុសញ្ញា ACTIP ផងដែរ។

និយមន័យនៃអំពើជួញដូរមនុស្ស ត្រូវបានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងមាត្រា ៣ នៃពិធីសារនេះ ដោយមានបញ្ចូលធាតុផ្សំចំនួន ៣ ( សកម្មភាព មធ្យោបាយ និងគោលបំណង ) ដែលចាំបាច់ត្រូវមាន ទើបចាត់ទុកថាជាអំពើជួញដូរមនុស្ស លើកលែងតែពាក់ព័ន្ធនឹងករណីជួញដូរកុមារ ដែលមិនតម្រូវឱ្យមានធាតុផ្សំមធ្យោបាយនោះឡើយ។ ការយល់ព្រមរបស់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សត្រូវបានប្រកាសថាមិនមានភាពពាក់ព័ន្ធឡើយ នៅពេលដែលមធ្យោបាយណាមួយ ដូចដែលត្រូវបានកំណត់នៅក្នុងនិយមន័យនេះ ត្រូវបានប្រើប្រាស់។គេឱ្យនិយមន័យកុមារ ថាជាមនុស្សអាយុក្រោម ១៨ ឆ្នាំ ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធកុមារ។

សង្គតិភាពនៃការប្រើប្រាស់និយមន័យអំពើជួញដូរមនុស្សមានសារៈសំខាន់និងចាំបាច់ដើម្បីអាចកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្សឱ្យបានត្រឹមត្រូវ។ ការទទួលស្គាល់ទៅវិញទៅមក លើការកំណត់អត្តសញ្ញាណជនរងគ្រោះសម្រាប់ករណីដែលអំពើជួញដូរមនុស្សកើតមាននៅក្នុងប្រទេសលើសពីមួយ ដូចដែលតម្រូវនៅក្នុងមាត្រា ១៤(២) នៃអនុសញ្ញា ACTIP អាចអនុវត្តទៅបាន តែប្រសិនបើរដ្ឋជាសមាជិកទាំងអស់របស់អាស៊ាន ទទួលស្គាល់និយមន័យនៃអំពើជួញដូរមនុស្សដូចៗគ្នា ក្នុងក្របខណ្ឌច្បាប់ជាតិរបស់ខ្លួន ដូចជា ក្នុងគោលការណ៍ណែនាំ និងក្នុងនីតិវិធីប្រតិបត្តិការស្តង់ដារស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះជាដើម។

៣៨ United Nations Protocol to Prevent, Suppress and Punish Traffcking in Persons Especially Women and Children ( The TIP Protocol ), 2000; United Nations Convention against Transnational Organised Crime ( UNTOC ) 2001. p 4.

## វិសាលភាព

លទ្ធផលនេះ រាប់បញ្ចូល៖

- ច្បាប់ គោលនយោបាយ និងនីតិវិធីនានា អនុម័ត និងអនុវត្តនិយមន័យនៃអំពើជួញដូរមនុស្ស ដូចមានចែងក្នុងអនុសញ្ញា ACTIP រាប់បញ្ចូលទាំងនិយមន័យដែលអនុវត្តចំពោះការជួញដូរកុមារ និងគោលការណ៍នៃភាពមិនពាក់ព័ន្ធនៃការយល់ព្រម។
- វាក្យសព្ទគន្លឹះ នៅក្នុងនិយមន័យនៃពាក្យពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដែលមានចែងនៅក្នុងច្បាប់ជាតិ ដូចជា "ពលកម្មដោយបង្ខំ" ឬ "ការប្រើបំពានស្ថានភាពងាយរងគ្រោះ" និង "កុមារ" ត្រូវបានកំណត់ស្របតាមលិខិតុបករណ៍ច្បាប់អន្តរជាតិ ឬគោលការណ៍ណែនាំដែលពាក់ព័ន្ធនានា។
- និយមន័យការជួញដូរកុមារ ត្រូវបានបញ្ចូលទៅក្នុងច្បាប់ និងគោលនយោបាយក្នុងស្រុក ស្តីពីអំពើជួញដូរមនុស្ស ហើយធាតុផ្សំនៃអំពើជួញដូរមនុស្ស (ទង្វើ និងគោលបំណង) ត្រូវបានកំណត់យ៉ាងជាក់ច្បាស់ នៅក្នុងគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដារស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។
- មានការផ្តល់ការបណ្តុះបណ្តាលដល់អ្នកជំនាញ ដើម្បីជួយឱ្យពួកគេយល់ និងអាចយកនិយមន័យអំពើជួញដូរមនុស្សទៅប្រើប្រាស់បាន។
- ច្បាប់ គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធអំពើជួញដូរមនុស្ស ត្រូវបានពិនិត្យ វាយតម្លៃ និងពង្រឹងជាប្រចាំ ដើម្បីបញ្ចូលសកម្មភាពអំពើជួញដូរមនុស្ស ដែលលេចចេញថ្មីៗ ដូចជា ការបង្ខំឱ្យប្រព្រឹត្តបទល្មើសជាដើម។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| នីតិវិធីប្រតិបត្តិការស្តង់ដារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនិយមន័យ និងគោលនយោបាយដែលមានបញ្ចូលនិយមន័យ "អំពើជួញដូរមនុស្ស" ត្រូវបានអនុវត្ត និងកែលម្អជាប់ជាប្រចាំ ឱ្យស្របតាមអនុសញ្ញាជាតិ អន្តរជាតិដែលពាក់ព័ន្ធ បញ្ហា និងនិន្នាការថ្មីៗ។ | ច្បាប់ និងគោលនយោបាយស្តីពីអំពើជួញដូរមនុស្ស ត្រូវបានពិនិត្យជាប្រចាំ ដើម្បីធានាឱ្យមានការអនុវត្តតាមកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញា ACTIP និងកាត់បន្ថយប្រេវ៉ាឡង់នៃអំពើជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

៩

## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការធ្វើអត្តសញ្ញាណជនរងគ្រោះ ស្របតាមអនុសញ្ញា ACTIP។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ផ្នែក ១.៣.៨, ២.២.៦, ១.២.៤, ២.៤.១០. ៤.២.៩. ៤.៣.១០។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ២.៦.២, ៣.២.១, ៣.២.៤, ៣.២.៥, ៣.២.៧, ៣.៣.៣, ៣.៥.៦។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ១៥, ១៦, ២៤, ២៥, ២៩, ៣២។
- អនុសញ្ញា ACTIP មាត្រា ១(ខ), ១៤(១), ១៤(២), ១៤(៧), ១៤(១០), ១៤(១២)។

## សេចក្តីអធិប្បាយ និងការពន្យល់

ការខកខានពុំបានទទួលស្គាល់ បុគ្គលដែលអាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស គឺជាការបំពានសិទ្ធិរបស់បុគ្គល ដែលបង្កឱ្យមានគ្រោះថ្នាក់បន្ថែមទៀត និងធ្វើឱ្យបាត់បង់ឱកាស អនុវត្តក្របខ័ណ្ឌច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស។ ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឱ្យបានត្រឹមត្រូវ និងឱ្យបានឆាប់រហ័សគឺជាមូលដ្ឋានគ្រឹះសម្រាប់ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងធានាថាជនរងគ្រោះនៃអំពើជួញដូរមនុស្សបានទទួលជំនួយ ការគាំទ្រ និងការការពារនានា។ ចាំបាច់ត្រូវតែអនុវត្តនូវយន្តការ និងនីតិវិធីនានា ដើម្បីសម្រួលឱ្យមានការជួយគាំទ្រ និងផ្តល់ការការពារដល់ជនរងគ្រោះ។

អនុសញ្ញា ACTIP អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ាន រៀបចំជាគោលការណ៍ណែនាំរួមមួយ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ព្រមទាំងនីតិវិធីប្រតិបត្តិការស្តង់ដារ សម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្សឱ្យបានត្រឹមត្រូវ និងក្នុងករណីដែលចាំបាច់ ត្រូវសហការជាមួយអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ។ ឧបករណ៍ និងគោលការណ៍ណែនាំទាំងនេះ ត្រូវផ្តល់ការការពារដល់សុខមាលភាពជនរងគ្រោះទាំងអស់ និងអ្នកដែលអាចក្លាយជាជនរងគ្រោះ ជាពិសេសឆ្លើយតបចំពោះតម្រូវការពិសេសរបស់កុមារ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានអនុវត្តស្របតាមកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញា ACTIP។
- ☐ រដ្ឋជាសមាជិកអាស៊ាន ប្រើប្រាស់និយមន័យ អំពើជួញដូរមនុស្សតែមួយ និងទទួលស្គាល់គ្នាទៅវិញទៅមកនូវលទ្ធផលនៃការកំណត់អត្តសញ្ញាណនៅពេលដែលអំពើជួញដូរមនុស្ស កើតមាននៅក្នុងប្រទេសលើសពីមួយ។
- ☐ រដ្ឋជាសមាជិកអាស៊ាន កំពុងធ្វើការកែសម្រួលច្បាប់លិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយនានាជាប្រចាំ ដើម្បីធានាឱ្យមានការអនុវត្តស្របតាមអនុសញ្ញា ACTIP ព្រមទាំងស្តង់ដារអន្តរជាតិដទៃទៀតស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។
- ☐ ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺជាផ្នែកមួយនៃសិទ្ធិរបស់ជនរងគ្រោះ រាល់បុគ្គលដែលគេសន្មតថាជាជនរងគ្រោះទាំងអស់គួរទទួលបានព័ត៌មាន និងទទួលបានការកំណត់អត្តសញ្ញាណ។
- ☐ មានការស្នើសុំការយល់ព្រម ផ្អែកតាមព័ត៌មានត្រឹមត្រូវ និងការយល់ព្រមពីអនីតិជន។
- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានធ្វើការពិចារណាពីយេនឌ័រ អាយុ និងតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេសកុមារ។
- ☐ មានបុគ្គលិក ដើម្បីជួយផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើ ជួញដូរមនុស្ស។
- ☐ ជានិច្ចកាល មានអ្នកបកប្រែដែលមានសមត្ថភាព ដើម្បីជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ប្រសិនបើចាំបាច់។
- ☐ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស តែងទទួលបានព័ត៌មានជាភាសា និងក្នុងទម្រង់ដែលពួកគេអាចយល់បាន។
- ☐ ជនរងគ្រោះនៃអំពើជួញដូរមនុស្សបានចូលរួមក្នុងការធ្វើផែនការ និងការអនុវត្តការផ្តល់ជំនួយដល់ពួកគេ។

## វិសាលភាព

រដ្ឋជាសមាជិកអាស៊ាន៖

- បានបង្កើត ផ្តល់ការគាំទ្រ និងអនុវត្ត ឯកសារណែនាំថ្នាក់ជាតិ និងថ្នាក់តំបន់ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ស្របតាមកាតព្វកិច្ចមានចែងក្នុងអនុសញ្ញា ACTIP។
- នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងការធ្វើសេចក្តីសម្រេចចិត្តនានា មានភាពច្បាស់លាស់ ត្រូវបានចងក្រងជាឯកសារបានត្រឹមត្រូវ ផ្អែកលើគំរូនៃការអនុវត្តល្អ ដើម្បីបង្កើនល្បឿន និងឯកភាពសុក្រឹតនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ។
- នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំនានា ត្រូវបានរៀបចំឡើង ដោយធានាឱ្យមានការទទួលស្គាល់គ្នាទៅវិញទៅមក ក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន ក៏ដូចជា ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិ និងអន្តរជាតិ។
- កែសម្រួលជាប់ជាប្រចាំនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដើម្បីធានាឱ្យមានភាពអនុលោមតាមអនុសញ្ញា ACTIP ព្រមទាំងស្តង់ដារអន្តរជាតិដទៃទៀតស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។
- ប្រមូលទិន្នន័យឱ្យបានសមស្រប និងមានសង្គតិភាពសម្រាប់ធ្វើសេចក្តីសម្រេចចិត្តចងក្រងឯកសារ និងរៀបចំរបាយការណ៍។
- ផ្សព្វផ្សាយព័ត៌មានដល់អ្នកអនុវត្តន៍ការងារនានារួមទាំងរៀបចំឱ្យមានជាវគ្គបណ្តុះបណ្តាលនិងរៀបចំឯកសារផ្អែកលើភ័ស្តុតាង។

ផ្តល់ការការពារដល់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាព តាមរយៈការអនុវត្តអភិក្រមបែបកុមារមេត្រី៖

- បុគ្គលិក អ្នកបកប្រែ និងព័ត៌មាន សម្រាប់ជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានលក្ខណៈកុមារមេត្រី និងមានជាភាសា និងទម្រង់ចម្រុះ ដូចជា ភាសាសញ្ញា និងអាចយល់បានសម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ដូចជា កុមារ ក្រុមងាយរងគ្រោះ និងជនមានពិការភាព។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស គួរអាចកំណត់ពីយេនឌ័រនៃបុគ្គលិក ដែលត្រូវផ្តល់ការគាំទ្រដល់ពួកគេ។
- ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ បានទទួលការយកចិត្តទុកដាក់ ស្របតាមអាយុ យេនឌ័រ និងតម្រូវការរបស់ពួកគេ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានចូលរួមនៅក្នុងគ្រប់ផ្នែកទាំងអស់នៃការធ្វើផែនការ និងការអនុវត្ត ការផ្តល់ជំនួយ ដោយមានការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ ឬការយល់ព្រមពីអនីតិជន (ក្នុងករណីជនរងគ្រោះជាកុមារ)។
- បន្ទាប់ពីបានចូលរួមនៅក្នុងដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះរួច គេគួរបញ្ជូនជនរងគ្រោះទៅរកសេវាគាំទ្រ ឬជំនួយនានា ប្រសិនបើជនរងគ្រោះសម្រេចចិត្តមិនចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវបានអនុវត្ត និងកែលម្អជាប់ជាប្រចាំ។ | នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅស្របតាមអនុសញ្ញា ACTIP ដោយមានការគោរព និងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

១០

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនបង្គោលទទួលបន្ទុកករណីជួញដូរមនុស្សនៅថ្នាក់កណ្តាល ឬរចនាសម្ព័ន្ធសម្របសម្រួលស្រដៀងគ្នានេះ ត្រូវបានបង្កើតឡើង និង/ឬពង្រឹងនៅតាមរដ្ឋជាសមាជិកអាស៊ាននីមួយៗ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ផ្នែក ១.៣.៩, ១.៤.១០, ៦.១.៣។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៣.១.១, ៣.២.៨, ៣.៤.១, ៣.៤.២, ៣.៤.៤។
- អនុសញ្ញា ACTIP មាត្រា ១២(ខ)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ១៩។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនបង្គោលនៅថ្នាក់កណ្តាល ឬរចនាសម្ពន្ធសម្របសម្រួលស្រដៀងគ្នានេះ ដូចជា ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសឥណ្ឌូនេស៊ី ក្រុមប្រឹក្សាសម្របសម្រួលនៅក្នុងប្រទេសហ្វីលីពីន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមប្រទេសក្នុងតំបន់មេគង្គ បានរៀបចំគោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដារស្តីពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ។

ដើម្បីធានាឱ្យមានការកំណត់អត្តសញ្ញាណជនរងគ្រោះ ឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស ស្ថាប័នសម្របសម្រួល គួរតែងតាំងទីភ្នាក់ងារពិសេសណាមួយឱ្យទទួលខុសត្រូវ លើការកំណត់អត្តសញ្ញាណជនរងគ្រោះ ការគាំទ្រដល់ជនរងគ្រោះ និងការបញ្ជូនទៅរកសេវាការពារជាដើម។ ស្ថាប័នសម្របសម្រួលទាំងនេះ គួរលើកទឹកចិត្តឱ្យអង្គការសង្គមស៊ីវិល អ្នកដឹកនាំសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត បានចូលរួមក្នុងការស្វែងរក និងការកំណត់អត្តសញ្ញាណជាមុន លើបុគ្គលដែលអាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឱ្យបានទាន់ពេលវេលា ចូលរួមក្នុងដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ។

ស្ថាប័នសម្របសម្រួលនៅថ្នាក់ជាតិ ក៏គួរលើកទឹកចិត្តឱ្យមានការបង្កើតអនុក្រុមការងារនៅថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះផងដែរ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ គោលនយោបាយស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនិងមាគ៌ាសម្រាប់បញ្ជូនជនរងគ្រោះត្រូវបានបង្កើតឡើង។
- ☐ ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្តោតលើជនរងគ្រោះ ត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារនានា ដែលមានភារកិច្ចធ្វើការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ។
- ☐ ឧបករណ៍ និងគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវបានពិនិត្យ និងកែសម្រួលតាមកាលកំណត់ ទៅតាមការចាំបាច់។
- ☐ ស្ថានទូតអាចតែងតាំងជនបង្គោលម្នាក់ ដើម្បីធ្វើការសហការជាមួយនឹងស្ថាប័ននានារបស់រដ្ឋាភិបាល។
- ☐ ក្រុមការងារ/ក្រុមប្រឹក្សា/គណៈកម្មាធិការនៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើង ដើម្បីជួយដល់ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះនៅថ្នាក់មូលដ្ឋាន។
- ☐ អង្គការសង្គមស៊ីវិល អ្នកដឹកនាំសហគមន៍ និងទីភ្នាក់ងារមិនមែនរដ្ឋាភិបាលដទៃទៀត បានចូលរួមផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង/ឬបុគ្គលដែលអាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស នៅក្នុងដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ។
- ☐ ជនបង្គោលទទួលបន្ទុកករណីជួញដូរមនុស្ស នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ដូចជា ក្រុមការងារ/ក្រុមប្រឹក្សា/គណៈកម្មាធិការ) បានទទួលធនធានគ្រប់គ្រាន់សម្រាប់អនុវត្តយន្តការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ (ធនធានថវិកា ធនធានមនុស្ស និងបច្ចេកវិទ្យា)។

## វិសាលភាព

ជនបង្គោលទទួលបន្ទុកករណីជួញដូរមនុស្សនៅថ្នាក់កណ្តាល (ក្រុមការងារ/ក្រុមប្រឹក្សា/គណៈកម្មាធិការ) គួរ៖

- រៀបចំឱ្យមានជាគោលនយោបាយស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ រួមទាំងមាគ៌ាសម្រាប់ធ្វើការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ។
- រៀបចំឯកសារណែនាំស្តីពីការអនុវត្តអភិក្រមជួយដល់ជនរងគ្រោះ ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ (ការគាំទ្រដល់ជនរងគ្រោះមានចាប់ពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស្តារឡើងវិញ ការផ្តល់ជម្រកសុវត្ថិភាព ការធ្វើមាតុភូមិនិវត្តន៍ រហូតដល់ការធ្វើសមាហរណកម្ម)។
- តាមដាន និងវាយតម្លៃការអនុវត្ត និងការប្រើប្រាស់គោលការណ៍ណែនាំ និងឧបករណ៍ទាំងនេះ ប្រសិនបើចាំបាច់ ដោយធ្វើការកែសម្រួលឯកសារទាំងនេះ ជាទៀងទាត់ ដើម្បីឆ្លើយតបនឹងនិន្នាការថ្មីៗ នៃអំពើជួញដូរមនុស្ស ក៏ដូចជា អភិក្រមដែលត្រូវបានដាក់ឱ្យអនុវត្តថ្មីៗ។
- បង្កើតយន្តការបញ្ជូននៅថ្នាក់ជាតិ សម្រាប់ផ្តល់ការគាំទ្រ និងការការពារដល់ជនរងគ្រោះ តាមរយៈការសហការជាមួយស្ថាប័នតាមវិស័យពាក់ព័ន្ធរបស់អាស៊ាន។
- ផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ ដើម្បីពង្រឹងការងារកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះ។

លទ្ធផលនេះរួមមាន ការសម្របសម្រួល និងការសហការ៖

- ជនបង្គោលនៅថ្នាក់កណ្តាល ដែលទទួលបានការចាត់តាំង ត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិកអាស៊ានដទៃទៀត ក្នុងការទទួលសំណើបញ្ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ស្ថានទូតអាចចាប់តាំងជនបង្គោលឱ្យសហការជាមួយនឹងទីភ្នាក់ងារនានារបស់រដ្ឋាភិបាល ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលត្រូវបានជួញដូរ មិនថាពួកគេមានឯកសារផ្លូវការ ឬអត់នោះឡើយ។
- ប្រកទំនាក់ទំនងជាមួយរដ្ឋជាសមាជិកអាស៊ានដទៃទៀត ត្រូវបានពង្រឹង ដើម្បីផ្លាស់ប្តូរព័ត៌មានអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលជាជនបរទេស តាមរយៈការប្រើប្រាស់មន្ត្រីកុងស៊ុល នៅក្នុងករណីសមស្រប។
- អ្នកផ្តល់សេវា (ដូចជា សេវាផ្លូវច្បាប់ ជម្រកសុវត្ថិភាព និងកន្លែងស្នាក់នៅ សេវាវេជ្ជសាស្ត្រ និងសេវាសង្គម) បានទទួលការយល់ព្រមត្រឹមត្រូវជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដោយមានការថតទុកពីជនរងគ្រោះ ឬការយល់ព្រមពីអនីតិជន សម្រាប់អ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីចែករំលែកព័ត៌មានដែលពាក់ព័ន្ធអំពីករណីនេះ ទៅជនបង្គោលនៅថ្នាក់កណ្តាល ឬស្ថាប័នសម្របសម្រួល និងអ្នកផ្តល់សេវាស្រដៀងគ្នានេះនៅតាមប្រទេសគោលដៅ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនបង្គោលទទួលបន្ទុកករណីជួញដូរមនុស្សនៅថ្នាក់កណ្តាល ជួយសម្រួលដល់ការសហការ និងការសម្របសម្រួលរវាងទីភ្នាក់ងារនានា ដើម្បីធានាឱ្យមានការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ទៅរកសេវាគាំទ្រនានា។ | ការកំណត់អត្តសញ្ញាណ ការការពារ ការគាំទ្រ និងការបញ្ជូនជនរងគ្រោះត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

១១

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ពុំត្រូវបានតម្រូវឱ្យទទួលខុសត្រូវលើអំពើខុសច្បាប់ ដែលត្រូវបានប្រព្រឹត្តដែលជាផលវិបាកផ្ទាល់ កើតចេញពីការដែលពួកគេត្រូវបានជួញដូរនោះឡើយ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ផ្នែក ២.៦.១៤, ៣.៦.១, ៤.៣.១០។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ៣.៦.១។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ ទំព័រ ២១។
- អនុសញ្ញា ACTIP មាត្រា ១៤(៧)។

## សេចក្តីអធិប្បាយ និងការពន្យល់

អនុសញ្ញា ACTIP គឺជាការប្តេជ្ញាចិត្តដ៏សំខាន់មួយរបស់រដ្ឋជាសមាជិកអាស៊ានក្នុងការធានាសុវត្ថិភាពជនរងគ្រោះ ការការពារឯកជនភាព និងការការពារជនរងគ្រោះពីការឃុំឃាំង និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។ អនុសញ្ញា ACTIP បញ្ជាក់យ៉ាងច្បាស់ថា ការចោទប្រកាន់ទោសព្រហ្មទណ្ឌ ឬទោសរដ្ឋបាលលើជនរងគ្រោះចំពោះការប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ពួកគេ[៣៩] និងការឃុំខ្លួនឱ្យជនរងគ្រោះ ពុំស្របតាមស្មារតីនៃអនុសញ្ញានេះ ឬខ្លឹមសារនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សឡើយ។[៤០]

ការផ្តន្ទាទោសព្រហ្មទណ្ឌ ជារឿយៗ កើតឡើងដោយសារការពុំបានកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ដែលធ្វើឱ្យជនរងគ្រោះពុំបានទទួលសិទ្ធិរបស់ពួកគេ សូម្បីតែមានបញ្ញត្តិស្តីពីការមិនដាក់ទោសនៅក្នុងច្បាប់ នៅក្នុងប្រទេសក៏ដោយ។ ជាជាងត្រូវបានកំណត់អត្តសញ្ញាណ និងបញ្ជូនទៅរកជម្រកសុវត្ថិភាពឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ជនរងគ្រោះនៃអំពើជួញដូរមនុស្សបែរជាត្រូវបានគេឃុំខ្លួន ឬនិរទេសទៅវិញ ជាពិសេសនៅពេលដែលអាជ្ញាធរពាក់ព័ន្ធ ជឿថាជនរងគ្រោះ គឺជាអ្នកសមគំនិតក្នុងករណីជួញដូររបស់ពួកគេ ដ្បិតពួកគេបានចូលរួមក្នុងសកម្មភាពខុសច្បាប់ ដូចជាបម្រើសេវាពេស្យាចារ ការឆបោក ល្បែងស៊ីសង ការចូលដោយខុសច្បាប់ ឬការធ្វើការដោយខុសច្បាប់ជាដើម។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ច្បាប់ និងគោលនយោបាយនានា ត្រូវបានរៀបចំឡើង និងធ្វើវិសោធនកម្ម ដើម្បីការពារមិនឱ្យមានការចោទប្រកាន់ជនរងគ្រោះនៃអំពើជួញដូរមនុស្សពីបទល្មើសខុសច្បាប់ ដែលជនរងគ្រោះប្រព្រឹត្ត ដោយសារតែត្រូវបានគេជួញដូរ។
- ☐ ច្បាប់ និងគោលនយោបាយនានា ត្រូវបានអនុវត្តដើម្បីការពារមិនឱ្យមានការចោទប្រកាន់ជនរងគ្រោះនៃអំពើជួញដូរមនុស្សពីបទល្មើសខុសច្បាប់ ដែលជនរងគ្រោះប្រព្រឹត្ត ដោយសារតែត្រូវបានគេជួញដូរ។
- ☐ ច្បាប់ គោលនយោបាយ និងនីតិវិធីនានា ត្រូវបានដាក់ចេញ និងធ្វើវិសោធនកម្ម ដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ពីការឃុំឃាំង ឬការជាប់ពន្ធនាគារដោយគ្មានហេតុផលសមស្រប នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេល ការអនុវត្តនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាល លើសំណុំរឿងជួញដូរមនុស្ស។
- ☐ ច្បាប់ និងគោលនយោបាយនានា ត្រូវបានអនុវត្តដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ពីការឃុំឃាំង ឬការជាប់ពន្ធនាគារដោយគ្មានហេតុផលសមស្រប នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេល ការអនុវត្តនីតិវិធីរដ្ឋប្បវេណីព្រហ្មទណ្ឌ ឬរដ្ឋបាល លើសំណុំរឿងជួញដូរមនុស្ស។

---

៣៩ See also ASEAN, Criminal Justice Responses to Traffcking in Persons: ASEAN Practitioner Guidelines, June 2007, Part 1(c), para. 2.

៤០ United Nations High Commissioner for Human Rights (UNHCHR) Recommended Principles and Guidelines on Human Rights and Human Trafficking, 2002: Commentary. OHCHR, New York and Geneva, 2010, Principle 7 and related guidelines, pp 129–140.

## វិសាលភាព

ច្បាប់ គោលនយោបាយ ត្រូវបានរៀបចំ ពិនិត្យ វាយតម្លៃ និងពង្រឹងជាទៀងទាត់ ដើម្បីធានាថាជនរងគ្រោះនៃអំពើជួញដូរមនុស្ស រាប់បញ្ចូលទាំងកុមារ ដែលត្រូវបាន៖

- កំណត់អត្តសញ្ញាណរួចរាល់ ឬកំណត់អត្តសញ្ញាណជាបណ្តោះអាសន្ន ពុំត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬបទល្មើសរដ្ឋបាល ចំពោះអំពើខុសច្បាប់ដែលពួកគេប្រព្រឹត្តក្នុងករណីដែលអំពើទាំងនេះមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងអំពើជួញដូរមនុស្ស។
- ឃុំខ្លួនជាបណ្តោះអាសន្ន ឬដាក់ឱ្យជាប់ពន្ធនាគារ ដោយពុំមានហេតុផល សមស្រប មុនពេល ក្នុងអំឡុងពេល ឬក្រោយពេលការអនុវត្តនីតិវិធីរដ្ឋប្បវេណីព្រហ្មទណ្ឌ ឬរដ្ឋបាលលើករណីជួញដូរមនុស្ស។

បញ្ញត្តិស្តីពីការមិនដាក់ទោសលើជនរងគ្រោះ មានចែងនៅក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា នៃរដ្ឋជាសមាជិកអាស៊ាន ក៏ដូចជា នៅក្នុងគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដារ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានកែសម្រួល ដើម្បីបញ្ចូលបញ្ញត្តិការការពារជនរងគ្រោះមិនឱ្យទទួលទោសលើអំពើខុសច្បាប់ និងឆ្លើយតបចំពោះបញ្ហា និងនិន្នាការថ្មីៗ។ | គោលការណ៍ស្តីពីការមិនដាក់ទោស ត្រូវបានធ្វើស្ថាបនីកម្ម និងអនុវត្តជាទូទៅ ស្របតាមស្មារតីនៃអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

១២

### លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

សិទ្ធិឯកជនភាព និងទិន្នន័យផ្ទាល់ខ្លួនរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ ត្រូវបានការពារ។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ផ្នែក ២.៣.៧, ២.៣.៨។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ២.៣.១។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ ទំព័រ ១៦។
- អនុសញ្ញា ACTIP មាត្រា ១៤(៦), ១៦(៦)។

### សេចក្តីអធិប្បាយ និងការពន្យល់

ដូចដែលត្រូវបានដាក់ចេញនូវអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ាន ត្រូវការពារឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស រួមទាំងគ្រួសាររបស់ពួកគេ តាមរយៈការរក្សាការសម្ងាត់ សម្រាប់នីតិវិធីច្បាប់ដែលកំពុងអនុវត្តពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស។

ការបង្ការមិនឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សរងគ្រោះជាលើកទី ២ គួរជាអាទិភាពនៅក្នុងសកម្មភាព របស់អ្នកជំនាញទាំងអស់។ អនុសញ្ញា ACTIP បន្តតម្រូវឱ្យរដ្ឋជាសមាជិកអាស៊ាន ពង្រឹងកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីពាក់ព័ន្ធក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស រួមទាំងមន្ត្រីដែលទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណ ការស៊ើបអង្កេត ការជំនុំជម្រះ និងការចោទប្រកាន់ជនរងគ្រោះផងដែរ។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ច្បាប់ត្រូវបានរៀបចំឡើង ដើម្បីការពារសិទ្ធិឯកជនភាព របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ និងហាមប្រាមមិនឱ្យមានការផ្សព្វផ្សាយព័ត៌មានលម្អិតទាំងឡាយណា ដែលអាចឱ្យគេដឹងអត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ ច្បាប់ត្រូវបានអនុវត្ត ដើម្បីឃាមការពារសិទ្ធឯកជនភាព និងគ្រួសាររបស់ពួកគេ និងហាមប្រាមមិនឱ្យមានការផ្សព្វផ្សាយព័ត៌មានលម្អិតទាំងឡាយណាដែលអាចឱ្យគេដឹងអត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ គោលនយោបាយត្រូវបានដាក់ចេញ ដើម្បីការពារសិទ្ធិឯកជនភាព របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ និងហាមប្រាមមិនឱ្យមានការផ្សព្វផ្សាយព័ត៌មានលម្អិតទាំងឡាយណាដែលអាចឱ្យគេដឹងអត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ គោលនយោបាយត្រូវបានអនុវត្ត ដើម្បីការពារសិទ្ធិឯកជនភាព របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ និងហាមប្រាមមិនឱ្យមានការផ្សព្វផ្សាយព័ត៌មានលម្អិតទាំងឡាយណា ដែលអាចឱ្យគេដឹងអត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ គោលនយោបាយ និងការអនុវត្តច្បាប់ ផ្តល់ការការពារដល់ឯកជនភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។
- ☐ របនាសម្ព័ន្ធនានាត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាថា សំណុំរឿងនានា ត្រូវបានរក្សាការសម្ងាត់ ដូចជាការរក្សាអនាមិកភាព សម្រាប់ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានរបស់ជនរងគ្រោះ ក៏ដូចជាព័ត៌មានអំពីគ្រួសាររបស់ពួកគេ។
- ☐ ច្បាប់ គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនឹងសិទ្ធឯកជនភាព និងការរក្សាការសម្ងាត់របស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ត្រូវបានពិនិត្យ វាយតម្លៃ និងកែសម្រួលជាប់ជាប្រចាំ។

## វិសាលភាព

លទ្ធផលនេះ រួមមានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដើម្បី៖

- ធានាថាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេមានសិទ្ធិក្សាឯកជនភាព និងការសម្ងាត់ ចាប់ពីពេលដែលពួកគេត្រូវបានកំណត់អត្តសញ្ញាណ ឬសន្មតថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ហាមប្រាមមិនឱ្យមានការផ្សព្វផ្សាយព័ត៌មានលម្អិតនានា ដែលអាចនាំឱ្យមានការដឹងអត្តសញ្ញាណរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ លើកលែងតែជនរងគ្រោះ ផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានថតសំឡេងទុក។ ក្នុងករណីកុមារ គេត្រូវទទួលបានការយល់ព្រម (affirmative assent) ពីកុមារសិន បន្ថែមលើការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេឱ្យបង្ហាញព័ត៌មាននេះទៅអ្នកដទៃ ឬតែក្នុងករណីដែលការបង្ហាញព័ត៌មានត្រូវបានចាត់ទុកថាចាំបាច់សម្រាប់ហេតុផលដទៃទៀត ដូចជាសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាដើម។ កុមារដែលជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស គួរមានការតែងតាំងអាណាព្យាបាលស្របច្បាប់ សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ នៅពេលដែលឪពុកម្តាយរបស់ពួកគេពុំអាច ពុំមានឆន្ទៈ ឬមិនសមស្របក្នុងការអនុវត្តសិទ្ធិមេបារបស់ពួកគេជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន។
- ធានាថាមានការដកចេញព័ត៌មានសម្គាល់អត្តសញ្ញាណពីគ្រប់ឯកសារទាំងអស់ និងមានការរៀបចំជាគោលការណ៍ណែនាំ ដើម្បីការមិនឱ្យមានការលេចធ្លាយដាក់ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងព័ត៌មានឯកជនដទៃទៀត ដែលអាចធ្វើឱ្យគេដឹងថាពីអត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស គ្រួសារ ឬសាក្សី។
- ច្បាប់គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធនឹងឯកជនភាព និងការរក្សាការសម្ងាត់ ត្រូវបានពិនិត្យឡើងវិញ វាយតម្លៃ និងកែសម្រួលជាប្រចាំ។
- ពង្រឹងសមត្ថភាពបុគ្គលិកការពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការគោរពសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ ព្រមទាំងគ្រួសាររបស់ពួកគេ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ការការពារឯកជនភាព អត្តសញ្ញាណ និងការរក្សាការសម្ងាត់ដល់ជនរងគ្រោះ គឺជាការអនុវត្តដែលមានលក្ខណៈស្តង់ដារ។ | សិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារ តាមរយៈការអនុវត្តយន្តការបញ្ជូន និងប្រមូលទិន្នន័យ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

១៣

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះជាកុមារ ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៤.១.១-៣, ៤.១.៨។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្សដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក៣.២.៣, ៣.២.៩។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៣២។
- អនុសញ្ញា ACTIP មាត្រា ១៤(១២)។

## សេចក្តីអធិប្បាយ និងការពន្យល់

ស្ថាប័នពាក់ព័ន្ធ បានរៀបចំនូវនីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំ ស្តីពីដំណើរការបញ្ជូនជនរងគ្រោះជាកុមារ ស្របតាមអនុសញ្ញាស្តីពីសិទ្ធកុមារ។[៤១]

អនុសញ្ញា ACTIP អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទទួលស្គាល់ពីប្រេកផ្សេងៗគ្នាសម្រាប់បញ្ជូនកុមារទៅតាមអាយុ យេនឌ័រ និងតម្រូវការពិសេស ជាពិសេសតម្រូវការពិសេសរបស់កុមារ នៅគ្រប់ដំណាក់កាលទាំងអស់នៃការផ្តល់ការគាំទ្រ និងការការពារដល់ជនរងគ្រោះ រួមទាំងក្នុងការបញ្ជូនផងដែរ។ ពុំមានអភិក្រមតែមួយគត់សម្រាប់ឆ្លើយតបទៅនឹងស្ថានភាព និងកាលៈទេសៈជាក់លាក់ផ្សេងៗគ្នារបស់កុមារនោះឡើយ។ គេត្រូវរៀបចំកែសម្រួលសេវានានា ឱ្យស្របតាមតម្រូវការជាក់លាក់របស់កុមារម្នាក់ៗ និងត្រូវអនុវត្តតាមបែបកុមារមេត្រី។

ត្រូវប្រើប្រាស់កែវឆ្លុះលើភាពប្រសព្វគ្នា (intersectionality lens) ដើម្បីជួយដល់អាជ្ញាធរ និងទីភ្នាក់ងារពាក់ព័ន្ធ ឱ្យអាចទទួលស្គាល់ថាជនរងគ្រោះរាប់បញ្ចូលទាំងកុមារ មានអត្តសញ្ញាណចម្រុះ ទៅតាមប្រទេស អាយុ ជាតិពន្ធុ និងដើមកំណើតសង្គម ពិការភាព និងកត្តាដទៃទៀត ដូចជា វប្បធម៌ និងសាសនាជាដើម។

ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែជាចំណុចកណ្តាលនៃកម្មវិធី/សកម្មភាពនានា និងត្រូវយកមកធ្វើការពិចារណាជាសំខាន់ នៅពេលដែលមានការអនុវត្តវិធានការនានា ដែលប៉ះពាល់ដល់កុមារ ដូចជា នៅក្នុងដំណើរការបញ្ជូនជាដើម។ កុមារគួរទទួលបានព័ត៌មានពេញលេញ និងគួរអាចចូលរួមក្នុងរាល់ការសម្រេចចិត្ត និងការអនុវត្តអន្តរាគមន៍នានា តាមរយៈការផ្តល់ការយល់ព្រមពីកុមារ។

រាល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ត្រូវធ្វើឡើងឱ្យស្របតាមអនុសញ្ញាស្តីពីសិទ្ធកុមារ និងគួរមានការតែងតាំង អាណាព្យាបាលស្របច្បាប់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ នៅពេលដែលឪពុកម្តាយរបស់ពួកគេពុំមានសមត្ថភាព ពុំមានធនធានៈ ឬពុំមានភាពសមស្របក្នុងការអនុវត្តសិទ្ធិមេបារបស់ខ្លួន ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ បុគ្គលិកដែលធ្វើការងារជាមួយកុមារដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស បានទទួលការបណ្តុះបណ្តាលសមស្រប និងមានសមត្ថភាព។
- ☐ កែវឆ្លុះលើភាពស្របគ្នា ត្រូវបានប្រើប្រាស់នៅពេលធ្វើការប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះជាកុមារ។
- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ សម្រាប់អនុវត្តដំណើរការបញ្ជូនកុមារដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស ត្រូវបានរៀបចំ។
- ☐ នីតិវិធីប្រតិបត្តិការស្តង់ដារ សម្រាប់អនុវត្តដំណើរការបញ្ជូនកុមារដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស ត្រូវបានអនុវត្ត។
- ☐ មានការសុំការយល់ព្រមពីកុមារ។
- ☐ មានការគោរព និងពិចារណា លើទស្សនៈយល់ឃើញរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ នៅពេលរៀបចំផែនការ និងអនុវត្តកម្មវិធីផ្តល់ជំនួយដល់ពួកគេ ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ។
- ☐ ជនរងគ្រោះនៃអំពើជនរងគ្រោះជាកុមារ តែងទទួលបានព័ត៌មានជាភាសា និងក្នុងទម្រង់ដែលពួកគេអាចយល់បាន។
- ☐ រដ្ឋជាសមាជិកអាស៊ាន តែងពិនិត្យ និងកែសម្រួលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា តាមកាលកំណត់។

---

៤១ United Nations Convention on the rights of the child, 1989..

## វិសាលភាព

លទ្ធផលនេះ រួមមាន កត្តាដែលត្រូវធ្វើការពិចារណាដូចខាងក្រោម នៅពេលអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ សម្រាប់កុមារគ្រប់រូប រួមទាំងកុមារដែលពុំមានឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ដោយត្រូវមានការយល់ព្រមពីកុមារ នៅពេលសមស្រប៖

- ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ មានសិទ្ធិផ្តល់ ឬដកយកការយល់ព្រមជុំវិញបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងពួកគេ។
- ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ ត្រូវទទួលបានព័ត៌មាន និងអាចចូលរួមយ៉ាងពេញលេញ នៅក្នុងរាល់ការធ្វើសេចក្តីសម្រេចចិត្តទាំងអស់ រួមទាំងក្នុងការយុត្តិធម៌ព្រហ្មទណ្ឌផងដែរពីសំណាក់បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលសមស្រប និងមានសមត្ថភាព។
- មានការគោរពដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ ហើយការយល់ឃើញរបស់ពួកគេត្រូវយកទៅធ្វើការពិចារណា ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ រាប់បញ្ចូលទាំងការគាំទ្រដែលពួកគេចង់ទទួលបានផងដែរ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ បានទទួលព័ត៌មានពាក់ព័ន្ធអំពីស្ថានភាព និងសិទ្ធិរបស់ពួកគេយ៉ាងសមស្របក្នុងទម្រង់ដែលពួកគេអាចយល់បាន។
- ពួកគេនៅបន្តទទួលបានព័ត៌មានអំពីភាពជឿនលឿននៃសំណុំរឿងរបស់ពួកគេ។
- ការវិលត្រឡប់ទៅជួបជុំគ្រួសារ គឺជាជម្រើសដំបូង និងជាជម្រើសអាទិភាព នៅពេលឆ្លើយតបចំពោះសំណុំរឿងរបស់កុមារ។ ជម្រើសនេះ គួរអនុវត្តនៅក្នុងគ្រប់ស្ថានភាពទាំងអស់ ដែលគេចាត់ទុកថាមានសុវត្ថិភាពនិងមានភាពល្អប្រសើរសម្រាប់កុមារ។

លទ្ធផលនេះ រាប់បញ្ចូលការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរក្នុងស្រុក និងអាជ្ញាធរអន្តរជាតិ។

រដ្ឋជាសមាជិកអាស៊ាន ធ្វើការកែសម្រួល វាយតម្លៃ និងពិនិត្យឡើងវិញ លើច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានាជាប្រចាំ ដើម្បីធានាឱ្យមានការការពារសិទ្ធិកុមារ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| នីតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះជាកុមារ ត្រូវបានអនុវត្ត និងកែលម្អជាបន្តបន្ទាប់ស្របតាមអនុសញ្ញាស្តីពីសិទ្ធកុមារ (CRC)។ | អភិក្រមផ្តល់សិទ្ធិដល់កុមារ និងការការពារសុវត្ថិភាពកុមារ ត្រូវបានធ្វើស្ថាបនីកម្ម និងអនុវត្តជាទូទៅស្របតាមអនុសញ្ញាស្តីពីសិទ្ធកុមារ (CRC) និងឧត្តមានុវត្តន៍អន្តរជាតិដទៃទៀត។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ



### លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានបញ្ជូនទៅកាន់ស្ថាប័នពាក់ព័ន្ធទាន់ពេលវេលា ផ្អែកតាមតម្រូវការជាក់លាក់របស់ពួកគេ។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្អែក ២.២.៤, ២.៣.៨, ២.៦.១៥។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្អែក ២.២.១, ២.៧.១, ២.៧.២, ៣.២.២, ៣.២.៦, ៣.៣.៤។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ២៦, ៣២, ៣៤។
- អនុសញ្ញា ACTIP មាត្រា ១៤(៥), ១៤(១០)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៣, APSC ១១។

### សេចក្តីអធិប្បាយ និងការពន្យល់

ដំណើរការបញ្ជូន មានគោលដៅគោរព និងការពារសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងបញ្ជូនថាពួកគេទៅកាន់ស្ថាប័នសមស្រប ដើម្បីផ្តល់ជំនួយ និងសេវានានាដល់ពួកគេ។[៤២] ការបញ្ជូនប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការឱ្យបានល្អ រវាងស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការអន្តរជាតិ ព្រមទាំងជាមួយទីភ្នាក់ងារពហុជំនាញដទៃទៀត។ នៅពេលជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណ ឬនៅពេលដែលបុគ្គលណាម្នាក់ ត្រូវបានគេសន្មតថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ហើយពួកគេចូលទៅក្នុងយន្តការបញ្ជូននៅថ្នាក់ជាតិ ត្រូវមានការរក្សាការសម្ងាត់ និងគោរពឯកជនភាពរបស់ពួកគេ។ នេះរួមមាន ការផ្តល់ការគាំទ្រ ការថែទាំ និងការផ្តល់ជំនួយឱ្យបានទាន់ពេលវេលា និងមានការរក្សាការសម្ងាត់។ សេវានានាមានជាអាទិ៍ សេវាថែទាំសុខភាព (វេជ្ជសាស្ត្រ និងផ្លូវចិត្ត) សេវាផ្លូវច្បាប់ កន្លែងស្នាក់នៅ សេវាជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ គោលការណ៍ណែនាំស្តីពីរបៀបកំណត់អត្តសញ្ញាណ និងផ្តល់ការយកចិត្តទុកដាក់ឱ្យបានសមស្របដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង/ឬបុគ្គលដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ ត្រូវបានរៀបចំឡើង។
- ☐ តម្រូវការសុខភាពរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានវាយតម្លៃបានទាន់ពេលវេលា ហើយការបញ្ជូនពួកគេត្រូវបានចាត់ទុកជាអាទិភាព។
- ☐ មាគ៌ាសម្រាប់បញ្ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានរៀបចំឡើង ដើម្បីបញ្ជូនជនរងគ្រោះទៅកាន់ស្ថាប័នផ្សេងៗ ជាអាទិ៍ ជម្រកសុវត្ថិភាព សេវាវេជ្ជសាស្ត្រ និងសេវាសុខភាពផ្លូវចិត្ត និងសេវាផ្លូវច្បាប់។
- ☐ ដំណើរការបញ្ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្សធានាឯកជនភាព និងការសម្ងាត់ជូនព័ត៌មានរបស់ជនរងគ្រោះ។
- ☐ ទិន្នន័យនានាត្រូវបានរក្សាជាការសម្ងាត់ និងពុំមានព័ត៌មានដែលអាចឱ្យគេសម្គាល់ដឹងពីអត្តសញ្ញាណ។
- ☐ យន្តការបញ្ជូនឆ្លងដែន ត្រូវបានដាក់ឱ្យអនុវត្ត។
- ☐ មាគ៌ា និងនីតិវិធីសម្រាប់បញ្ជូនជនរងគ្រោះ ត្រូវបានពិនិត្យ និងកែសម្រួលតាមកាលកំណត់។

---

៤២ International Organisation for Migration (IOM), National Referral Mechanisms for Victims of Human Traffcking: Defciencies and Future Development, 2017.

## វិសាលភាព

លទ្ធផលនេះ និងធានាថាការបញ្ជូនគួរបញ្ចូល៖

- ការណែនាំអំពីរបៀបកំណត់អត្តសញ្ញាណ និងផ្ដល់ការយកចិត្តទុកដាក់ឱ្យបានសមស្រប ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង/ឬបុគ្គលដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ ហើយទន្ទឹមគ្នា មានការគោរពសិទ្ធិរបស់ពួកគេ រួមទាំងសិទ្ធិធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវផងដែរ។
- តម្រូវការសុខភាពរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានវាយតម្លៃទាន់ពេលវេលា និងមានការផ្ដល់អាទិភាពដល់ការបញ្ជូនជនរងគ្រោះ ដូចជា ទៅរកសេវាជម្រកសុវត្ថិភាព សេវាថែទាំសុខភាពឯកទេស និងសេវាគាំទ្រផ្លូវចិត្តជាដើម។
- សេវាជំនួយផ្លូវច្បាប់ បណ្ដាញ និងព័ត៌មាននានា មានលក្ខណៈកុមារមេត្រី ច្រើនភាសា និងក្នុងទម្រង់នានា ដូចជា ភាសាសញ្ញា និងមានសម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងកុមារ ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពជាដើម។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលបដិសេធមិនទទួលយកសេវា ហើយក្រោយមកយល់ព្រមទទួលសេវាវិញ បានទទួលព័ត៌មានដែលអាចឱ្យពួកគេយកទៅប្រើប្រាស់នាពេលអនាគត។

លទ្ធផលនេះ រាប់បញ្ចូលការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្ដល់សេវានានា៖

- យន្តការបញ្ជូនឆ្លងដែន ត្រូវបានដាក់អនុវត្ត។
- មាគ៌ាបញ្ជូនទៅរកអង្គការផ្ដល់សេវាដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្ដោតការយកចិត្តទុកដាក់លើជនរងគ្រោះ ក៏ដូចជា មានការរក្សាការសម្ងាត់ ត្រូវបានបង្កើតឡើង ដូចជា អង្គការដែលធ្វើការងារជាមួយជនមានពិការភាព អង្គការដែលផ្ដល់សេវាឯកទេសដល់ស្ត្រី និងកុមារ អ្នកផ្ដល់ការថែទាំកុមារ សេវាសម្រាប់ពលករទេសន្តប្រវេសន៍ជាដើម។
- ទិន្នន័យត្រូវបានរក្សាការសម្ងាត់ និងពុំមានបញ្ចូលព័ត៌មានដែលអាចឱ្យគេដឹងពីអត្តសញ្ញាណ។
- ទីភ្នាក់ងារពាក់ព័ន្ធ ខិតខំពិនិត្យឡើងវិញ វាយតម្លៃ និងកែសម្រួលលើមាគ៌ា និងនីតិវិធីបញ្ជូនជាប់ជាប្រចាំ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| នីតិវិធីប្រតិបត្តិការស្ដង់ដារស្ដីពីការបញ្ជូនជនរងគ្រោះ ដើម្បីធានាឱ្យមានការទទួលសេវា ត្រូវបានអនុវត្ត និងកែលម្អជាប្រចាំ។ | ការការពារ ការគាំទ្រ និងការបញ្ជូនជនរងគ្រោះ ត្រូវបានធ្វើស្ថាប័ននីតិកម្ម និងអនុវត្តជាទូទៅ ស្របតាមខ្លឹមសារនៃអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

១៥

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

នៅពេលដែលឪពុកម្ដាយមិនអាចពុំមានឆន្ទៈ ឬពុំមានភាពសមស្រប ក្នុងការអនុវត្តសិទ្ធិជាមេបារបស់ពួកគេ ជាបណ្ដោះអាសន្នក្ដី ឬជាអចិន្ត្រៃយ៍ក្ដី ត្រូវមានការតែងតាំងអាណាព្យាបាលម្នាក់ ដើម្បីធានាឱ្យមានការគោរពឧត្ដមប្រយោជន៍របស់កុមារ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៤.២.៥, ៤.៤.១៤, ៤.៤.១៥។
- មគ្គុទេសក៍ស្ដីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ១៦, ៩៣។

## សេចក្ដីអធិប្បាយ និងការពន្យល់

ដោយសារកុមារងាយរងគ្រោះ ដោយសារការកេងប្រវ័ញ្ច ចាំបាច់ត្រូវមានការផ្ដល់ការការពារ និងការគាំទ្របន្ថែមទៀត នៅពេលដែលកុមារត្រូវបានគេកំណត់អត្តសញ្ញាណ ថាអាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។[៤៣] សម្រាប់កុមារដែលជាជនរងគ្រោះនៃអំពើជួញដូរមនុស្សចាប់ពីពេលដែលកុមារត្រូវបានអាជ្ញាធរកំណត់អត្តសញ្ញាណដឹង ហើយនៅពេលដែលឪពុកម្ដាយរបស់ពួកគេពុំមានសមត្ថភាព ពុំមានឆន្ទៈ ឬក៏មានភាពសមស្របក្នុងការអនុវត្តសិទ្ធិជាមេបាជាបណ្ដោះអាសន្ន គឺជាអចិន្ត្រៃយ៍ គួរមានការតែងតាំងអាណាព្យាបាល ឬតំណាងឱ្យកុមាររូបនោះ សម្រាប់ចូលរួមក្នុងដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូន ដើម្បីផ្ដល់ជម្រកសុវត្ថិភាព និងការពារឧត្ដមប្រយោជន៍របស់កុមារ។[៤៤]

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ នៅពេលដែលអាណាព្យាបាលរបស់កុមារ ដែលរងគ្រោះដោយសារអំពើជួញដូរមនុស្សត្រូវបានតែងតាំង មានការពិគ្រោះយោបល់ជាមួយនឹងកុមារ និងផ្ដល់ព័ត៌មានដល់កុមារ ដោយប្រើប្រាស់ភាសា និងក្នុងទម្រង់ដែលពួកគេអាចយល់បាន ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ។
- ☐ ទៅតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ មានការសុំការយល់ព្រមពីកុមារ បន្ថែមលើការយល់ព្រមដែលផ្ដល់ដោយអាណាព្យាបាល។
- ☐ អាណាព្យាបាលមានសមត្ថភាពក្នុងការបំពេញ តួនាទី និងផ្ដល់អាទិភាពដល់ឧត្ដមប្រយោជន៍របស់កុមារ។
- ☐ អាណាព្យាបាលត្រូវមានវត្តមាន និងចូលរួមក្នុងអន្តរាគមន៍នៅគ្រប់ដំណាក់កាលទាំងអស់ (ចាប់ពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ ការអនុវត្តនីតិវិធីច្បាប់ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម)។

---

៤៣ United Nations High Commissioner for Human Rights (UNHCHR) Recommended Principles and Guidelines on Human Rights and Human Traffcking, 2002, p 161.

៤៤ Committee on the Rights of the Children, General Comments No 6, 2005, para 21; United Nations Protocol to Prevent, Suppress and Punish Traffcking in Persons Especially Women and Children (The TIP Protocol), 2000: Supplementing the UN Convention against Transnational Organised Crimes, 2002, para 224

## វិសាលភាព

អ្វីដែលត្រូវបានបញ្ចូលទៅក្នុងលទ្ធផលនេះ រួមមាន វិធានការការពារឧត្តមប្រយោជន៍របស់ជនរងគ្រោះនៃអំពើជួញដូរជាកុមារ នៅពេលដែលឳពុកម្តាយមិនអាច ពុំមានឆន្ទៈ ឬពុំមានភាពសមស្រប ក្នុងការអនុវត្តសិទ្ធិជាមេបារបស់ពួកគេ៖

- ការតែងតាំងអាណាព្យាបាលដែលមានសមត្ថភាព ដូចជា សាច់ញាតិ ភ្នាក់ងារសង្គមកិច្ច ឬបុគ្គល ដើម្បីផ្តល់ការគាំទ្រដទៃទៀត នៅពេលដែលចាំបាច់ ដើម្បីផ្តល់ការការពារដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ ឬពួកគេអាចនៅតែបន្តមានវត្តមាន (ក្នុងអំឡុងពេលអនុវត្តដំណើរការនេះ រួមទាំងក្នុងអំឡុងពេលធ្វើដំណើរ ក្រោយពេលដែលពួកគេរួចផុតពីការជួញដូរមនុស្ស ការអនុវត្តនីតិវិធីច្បាប់ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម)។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលជាកុមារ ត្រូវបានត្រូវបានប្រាប់ឱ្យដឹងពីសិទ្ធិរបស់ពួកគេ ជាភាសា និងក្នុងទម្រង់ដែលពួកគាត់អាចយល់បាន ហើយការប្រាស្រ័យទាក់ទងត្រូវបានធ្វើឡើងជាមួយនឹងកុមារ ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ
- ពោលគឺមិនមែនប្រាស្រ័យទាក់ទងតែជាមួយឳពុកម្តាយ អ្នកផ្តល់ការថែទាំ ឬអាណាព្យាបាលនោះឡើយ។ អាណាព្យាបាល ឬតំណាងកុមារ ត្រូវមានវត្តមានក្នុងអំឡុងពេលដែលមានការអនុវត្តដំណើរការជាមួយនឹងកុមារ ដូចជា ដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះជាដើម។
- ការជ្រើសរើសបុគ្គលដែលសមស្រប ត្រូវបានធ្វើឡើងដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ដោយមានការថតសំឡេងទុករបស់កុមារ ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ។
- អាណាព្យាបាលរបស់កុមារ ធ្វើការពិចារណាលើការយល់ឃើញរបស់កុមារ ដែលជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងធានាឱ្យមានការការពារឧត្តមប្រយោជន៍របស់កុមារ ស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| សិទ្ធិរបស់កុមារដែលជាជនរងគ្រោះ ត្រូវបានគោរព និងការពារតាមរយៈការតែងតាំងអាណាព្យាបាលដោយមានការពិគ្រោះយោបល់ជាមួយនឹងកុមារ ស្របតាមអាយុ ភាពចាស់ទុំ និងសុវត្ថិភាពរបស់ពួកគេ។ | ការការពារ និងការគាំទ្រដល់ជនរងគ្រោះជាកុមារ ត្រូវបានធ្វើស្ថាប័ននីតិកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

## ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ

១៦

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ និងមន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធ។
- ☐ សកម្មភាពបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធ បានបញ្ចូលការពង្រឹងការគាំទ្រដល់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាព។
- ☐ វគ្គបណ្តុះបណ្តាលបានបញ្ចូលស្វ័យវាយតម្លៃលើភាពលម្អៀងផ្ទាល់ខ្លួន និងរបៀបជម្នះភាពលម្អៀងទាំងនេះ។

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

មន្ត្រី និងទីភ្នាក់ងារជួរមុខដែលពាក់ព័ន្ធ បានទទួលការបណ្តុះបណ្តាល និងព័ត៌មានអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ១.២.៥, ១.២.៦, ៤.១.១, ២.១.២, ៣.៤.៥។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ២.១.១, ៣.៣.១, ៣.៥.១, ៣.៥.២, ៣.៥.៣, ៣.៥.៤, ៣.៥.៥។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ១៥, ២៤, ៣០, ៣៤។
- អនុសញ្ញា ACTIP មាត្រា ២(ក), ១២(ឆ), ១៤(១), ១៤(៥)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៤, ASCC ៣។

### សេចក្តីអធិប្បាយ និងការពន្យល់

ការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្សត្រឹមត្រូវ និងទាន់ពេលវេលា គឺជាមូលដ្ឋាន សម្រាប់ឱ្យវិស័យយុត្តិធម៌ធ្វើការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនិងធានាថាជនរងគ្រោះបានទទួលការគាំទ្រនិងការការពារ។បន្ថែមលើយន្តការ និងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលត្រូវបានដាក់អនុវត្ត ចាំបាច់ត្រូវមានការពង្រឹងសមត្ថភាព ដូចជា ការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ ដែលទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីគាំទ្រដល់ដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះរបស់ពួកគេ។

ការយល់ច្រឡំរវាងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស និង/ឬទេសន្តរប្រវេសន៍ខុសច្បាប់ ក៏ដូចជា ភាពលំអៀងផ្អែកតាមយេនឌ័រ ធ្វើឱ្យរាំងស្ទះដល់ប្រសិទ្ធភាពនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលពុំត្រូវបានកំណត់អត្តសញ្ញាណឱ្យបានជាក់ច្បាស់ ឬដែលត្រូវបានគេច្រឡំថាជាជនចំណាកស្រុកខុសច្បាប់ អាចនាំឱ្យមានការនិរទេស ឬចាត់ទុកពួកគេថាជាជនល្មើស ដោយពួកគេពុំបានទទួលសិទ្ធិដែលពួកគេត្រូវទទួលបាននោះឡើយ។ ការខកខានពុំបានកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានត្រឹមត្រូវ អាចនាំឱ្យមានការបន្តការប្រព្រឹត្តអំពើកេងប្រវ័ញ្ច ឬការលេចចេញនូវការកេងប្រវ័ញ្ចក្នុងទម្រង់ថ្មីៗបន្ថែមទៀត។

លទ្ធផលនេះ រួមមាន ការផ្តល់ការបណ្តុះបណ្តាលដល់ក្រុមដូចតទៅ៖ ស្ថាប័ន និងមន្ត្រីជួរមុខ ជាអាទិ៍ អ្នកជំនាញផ្នែកច្បាប់ មន្ត្រីសុខមាលភាពសង្គម អ្នកសម្ភាស មន្ត្រីអនុវត្តច្បាប់ និងអ្នកផ្តល់សេវាថែទាំសុខភាព។

## វិសាលភាព

ការបណ្តុះបណ្តាល និងធនធាននានា មានបញ្ចូល៖

- អភិក្រមលើកកម្ពស់បរិយាបន្ន ដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្តោតលើជនរងគ្រោះ ការផ្លាស់ប្តូរបទដ្ឋានសង្គម កិច្ចខិតខំប្រឹងប្រែងប្រឆាំងការមាក់ងាយ និងភាពលម្អៀងយេនឌ័រ។
- មានការយកចិត្តទុកដាក់ជាពិសេសលើក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពជាដើម។
- ម៉ូឌុលជាក់លាក់អំពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ មានបញ្ចូលជាតុផ្សំនៃអំពើជួញដូរមនុស្ស ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ជាមួយនឹងម៉ូឌុលស្តីពីការជួញដូរកុមារ ការទប់ស្កាត់ និងការបង្កើនការយល់ដឹងអំពីអំពើជួញដូរមនុស្ស។
- វគ្គបណ្តុះបណ្តាល ផ្តោតការយកចិត្តទុកដាក់លើការកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលជាមនុស្សពេញវ័យ និងជាកុមារ ស្របតាមអនុសញ្ញា ACTIP។
- ការការពារជនរងគ្រោះពីការតបតសងសឹកនានា។
- ការសម្ភាសជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងស្វ័យវាយតម្លៃលើភាពលម្អៀងផ្ទាល់ខ្លួន ត្រូវបានធ្វើឡើងដោយប្រើប្រាស់អភិក្រម ផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចប៉ះទង្គិចផ្លូវចិត្ត។
- ផលវិបាកប្រកបដោយគ្រោះថ្នាក់ ដោយសារការមិនកំណត់អត្តសញ្ញាណ ឬការកំណត់អត្តសញ្ញាណពុំបានត្រឹមត្រូវ ធ្វើឱ្យជនរងគ្រោះត្រូវទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មី។
- ដោយហេតុថាជនរងគ្រោះត្រូវបានគេចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬត្រូវបានគេឃុំឃាំង។
- ប្រើប្រាស់កែវឆ្លុះនៃភាពប្រសព្វគ្នា ក្នុងដំណើរការ និងការសម្រេចចិត្តអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។
- ការផ្តល់ធនធានបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់។

លទ្ធផលនេះ រួមមាន កិច្ចសហប្រតិបត្តិការបច្ចេកទេស ព្រមទាំងកិច្ចប្រជុំសម្របសម្រួលនៅថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីបន្តកសាងសមត្ថភាពកំណត់អត្តសញ្ញាណជនរងគ្រោះ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| មន្ត្រី និងអ្នកឆ្លើយតបជួរមុខ ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះត្រឹមត្រូវ និងទាន់ពេលវេលា និងបញ្ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទៅស្ថាប័នសមស្រប ដើម្បីទទួលបានការការពារ និងការគាំទ្រនានា។ | ការកំណត់និយមន័យ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |



# ឧទាហរណ៍បង្ហាញពីការអនុវត្តល្អ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ និង ការបញ្ជូនជនរងគ្រោះ

**ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ពុំត្រូវបានគេចោទប្រកាន់ឱ្យទទួលខុសត្រូវលើសកម្មភាពខុសច្បាប់ ដែលត្រូវបានប្រព្រឹត្តដោយសារតែពួកគេត្រូវបានគេជួញដូរនោះឡើយ**

បុរសជនជាតិវៀតណាមម្នាក់ ត្រូវបានគេបោកបញ្ឆោត នាំទៅក្រៅប្រទេស ហើយបន្ទាប់មកលក់ទៅឱ្យក្រុមហ៊ុនប្រកបអាជីវកម្មតាមប្រព័ន្ធអនឡាញមួយ។ គាត់ត្រូវបានគេឃុំឃាំង និងបង្ខំឱ្យធ្វើការក្នុងអាជីវកម្មឆបោកតាមប្រព័ន្ធអនឡាញ។ ជារៀងរាល់ថ្ងៃ គេដាក់ការងារឱ្យគាត់ធ្វើ ហើយគាត់ត្រូវឆបោកមនុស្ស ២ ទៅ ៣ នាក់។ នៅពេលដែលគាត់ពុំបានសម្រេចតាមគោលដៅការងារនេះ ជនជាតិវៀតណាមរូបនេះត្រូវបានគេរំលោភបំពានផ្លូវកាយ និងរំលោភបំពានជាពាក្យសម្ដី។

បុរសជនជាតិវៀតណាមនេះ បានរត់គេចខ្លួនពីអ្នកដែលឃុំឃាំងគាត់ ក្រោយពេលដែលគាត់មកដល់ព្រំដែនជាមួយនឹងប្រទេសវៀតណាម គាត់បានរាយការណ៍ទៅមន្ត្រីដែលយាមច្រកព្រំដែនអំពីការជាប់ឃុំឃាំង និងពីទុក្ខលំបាករបស់គាត់។ មន្ត្រីយាមច្រកព្រំដែនបានធ្វើការស៊ើបអង្កេត និងផ្ទៀងផ្ទាត់អ្វីដែលជនរងគ្រោះបានរាយការណ៍ប្រាប់ និងការធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះ ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងចេញជាលិខិតបញ្ជាក់។ នៅច្រកព្រំដែនជនរងគ្រោះបានទទួលជំនួយ កន្លែងស្នាក់នៅ និងការការពារទៅតាមតម្រូវការរបស់គាត់។ ជនរងគ្រោះនៃអំពើជួញដូរមនុស្សរូបនេះ បានទទួលការគាំទ្រផ្លូវចិត្ត សេវាថែទាំសុខភាព និងការឧបត្ថម្ភ និងពុំត្រូវបានគេចោទប្រកាន់ពីបទល្មើសចូល ឬចេញពីប្រទេសមួយដោយខុសច្បាប់ ក៏ដូចជា សកម្មភាពខុសច្បាប់ដែលគាត់បានធ្វើ នៅពេលដែលគាត់នៅជាជនរងគ្រោះនៃអំពើជួញដូរមនុស្សឡើយ។

# ការស្តារឡើងវិញ ការឆ្លុះបញ្ចាំង និងជម្រកសុវត្ថិភាព

១៧

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចទទួលបានជម្រកសុវត្ថិភាព/កន្លែងស្នាក់នៅ ដែលមានសុវត្ថិភាព ឈរលើគោលការណ៍ស្ម័គ្រចិត្ត ដើម្បីឱ្យពួកគេអាចមានឱកាសស្តារឡើងវិញ និងឆ្លុះបញ្ចាំង ស្របតាមតម្រូវការរបស់ពួកគេ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ២.៤.១២, ៣.១.៣។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៣៦-៥០។
- អនុសញ្ញា ACTIP មាត្រា ១៤(៤), ១៤(៥), ១៤(១០)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៣។

## សេចក្តីអធិប្បាយ និងការពន្យល់

ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ត្រូវបានអនុវត្ត ឬពង្រឹង ដើម្បីធានាយ៉ាងណាឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងបុគ្គលដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ អាចទទួលបានដោយឥតលក្ខខណ្ឌនៅពេលវេលាដែលមានភាពបត់បែន ដើម្បីឱ្យពួកគេអាចស្តារឡើងវិញ និងធ្វើការឆ្លុះបញ្ចាំងក្នុងអំឡុងពេលដែលពួកគេកំពុងទទួលបានសេវានានាស្របតាមតម្រូវការរបស់ពួកគេ ក៏ដូចជា ទទួលបាននូវជម្រកសុវត្ថិភាពជាបណ្តោះអាសន្ន។ នេះអាចរួមមាន ការផ្តល់ឱ្យជនរងគ្រោះនៅប្រាក់លើកទឹកចិត្ត កន្លែងស្នាក់នៅជាបណ្តោះអាសន្ន និង/ឬប័ណ្ណអនុញ្ញាតការងារជាបណ្តោះអាសន្ន ដោយឈរលើហេតុផលសង្គម សមានចិត្ត និងមនុស្សធម៌។

សេវាបកប្រែដែលផ្តល់ជូនជនរងគ្រោះ មានលក្ខណៈកុមារមេត្រី និងផ្តល់ជូនជាភាសា ឬភាសាសញ្ញា ដែលមនុស្សគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គមអាចយល់បាន រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពផងដែរ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ គោលនយោបាយ ឬនីតិវិធី ដែលមានបញ្ចូលខ្លឹមសារស្តីពីការផ្តល់កន្លែងស្នាក់នៅ និងកម្មវិធី ជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចស្តារឡើងវិញ ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ សមស្របទៅតាមវប្បធម៌ និងអាយុ និងមានលក្ខណៈកុមារមេត្រី។
- ☐ រយៈពេលឆ្លុះបញ្ចាំង និងស្តារឡើងវិញ ដែលមានភាពបត់បែន និងការផ្តល់ជម្រកសុវត្ថិភាពពុំមានចងលក្ខខណ្ឌ ដែលតម្រូវឱ្យជនរងគ្រោះ ត្រូវតែចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌឡើយ។
- ☐ ក្នុងរយៈពេលឆ្លុះបញ្ចាំង និងស្តារឡើងវិញនេះ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទទួលបានសេវានានាទៅតាមតម្រូវការរបស់ពួកគេ និងមានការគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការដកខ្លួនចេញ ឬបដិសេធមិនទទួលសេវា។
- ☐ ព័ត៌មាននានា ត្រូវបានផ្តល់ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាភាសា និងក្នុងទម្រង់ដែលពួកគេអាចយល់បាន ។
- ☐ ជនរងគ្រោះនៅបន្តទទួលបានព័ត៌មានអំពីភាពជឿនលឿននៃសំណុំរឿងដែលពួកគេចូលរួមពាក់ព័ន្ធ និងអាចស្នើសុំព័ត៌មាននៅពេលណាក៏បាន។
- ☐ កម្មវិធីផ្តល់ជម្រកសុវត្ថិភាព និងស្តារឡើងវិញ ពុំបានពង្រឹងបន្ថែមលើការប្រកាន់ផ្នត់គំនិតយេនឌ័រ ឬធ្វើឱ្យខូចខាតដល់សិទ្ធិឯកជនភាព ឬបូរណភាពរាងកាយរបស់ជនរងគ្រោះឡើយ។
- ☐ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស នៅតែអាចបន្តស្នាក់នៅទីកន្លែង ឬប្រទេសគោលដៅ ក្នុងរយៈពេលស្តារឡើងវិញ និងឆ្លុះបញ្ចាំងនេះ។

## វិសាលភាព

លទ្ធផលនេះ រាប់បញ្ចូលវិធានការស្តារឡើងវិញ ដែលត្រូវបានអនុវត្តសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬបុគ្គលដែលត្រូវបានសន្មតថាជាជនរងគ្រោះដែលក្នុងនោះ៖

- វិធានការច្បាប់ ឬវិធានការដទៃទៀត ត្រូវបានអនុវត្ត ដើម្បីជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស បន្តស្នាក់នៅទីកន្លែងគោលដៅក្នុងអំឡុងពេលអនុវត្តកម្មវិធីស្តារឡើងវិញ និងការអនុវត្តនីតិវិធីច្បាប់នានា។
- អ្នកផ្តល់សេវា ផ្តល់ពេលឱ្យជនរងគ្រោះអាចស្តារស្ថានភាពខ្លួនឯងឡើងវិញ ប្រកបដោយភាពបត់បែន ទៅតាមអាយុ យេនឌ័រ និងតម្រូវការជាក់លាក់របស់ពួកគេ រួមទាំងផ្តល់ពេលវេលាបន្ថែមដល់ជនរងគ្រោះជាកុមារ និងជនដែលងាយរងគ្រោះផងដែរ។

## វិសាលភាព

- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទទួលបានសេវាទៅតាមអាយុ យេនឌ័រ និងតម្រូវការជាក់លាក់របស់ពួកគេ។ នេះអាចមានជាអាទិ៍ ការផ្តល់ជំនួយវេជ្ជសាស្ត្រ និងជំនួយផ្លូវចិត្ត ជំនួយផ្លូវច្បាប់ ការផ្តល់ប្រឹក្សា ជំនួយជាស្មារតី និងសម្ភារៈ ក៏ដូចជា ភាសាសញ្ញា និងសេវាបកប្រែជាដើម ដើម្បីឱ្យពួកគេអាចប្រាស្រ័យទាក់ទងជាមួយគ្រួសារបាន ឬនៅពេលដែលពួកគេចង់ស្វែងរកឱកាសទទួលបានការងារ ការអប់រំ និងការបណ្តុះបណ្តាលជាដើម។
- កម្មវិធីស្តារឡើងវិញ ត្រូវបានអនុវត្តដល់ជនរងគ្រោះដែលមានបំណងចង់ស្នាក់នៅក្នុងផ្ទះសុវត្ថិភាព និង/ឬជម្រកសុវត្ថិភាព ដែលផ្តល់ដោយរដ្ឋាភិបាល ក៏ដូចជា ដល់ជនរងគ្រោះ ដែលជ្រើសរើសស្នាក់នៅក្នុងជម្រកសុវត្ថិភាពដទៃទៀត ដូចជា ជម្រកសុវត្ថិភាពតាមសហគមន៍ ឬផ្ទះផ្ទាល់ខ្លួនរបស់ពួកគេជាដើម។ កម្មវិធីស្តារឡើងវិញ ត្រូវបានផ្តល់ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ ឬអ្នកដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ ដោយមិនមានភ្ជាប់លក្ខខណ្ឌ ថាជនរងគ្រោះត្រូវតែចូលរួមក្នុងការអនុវត្តនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនោះឡើយ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចដកយកការយល់ព្រមរបស់ពួកគេនៅពេលណាក៏បាន ហើយអ្នកផ្តល់សេវាស្តារឡើងវិញនេះ ត្រូវធ្វើការពិនិត្យជាទៀងទាត់ ថាតើជនរងគ្រោះនៅបន្តយល់ព្រមទទួលសេវាគាំទ្រនានាដែរឬទេ។
- ជនរងគ្រោះបានទទួលការគាំទ្រ ដើម្បីឱ្យពួកគេមានស្ថានភាពនឹងនរ បង្ការមិនឱ្យមានការបង្កគ្រោះថ្នាក់បន្ថែមទៀតដល់ជនរងគ្រោះ និងជួយឱ្យពួកគេអាចស្តារស្ថានភាពឡើងវិញជាអតិបរមា។ មានការផ្តល់ការថែទាំជាបន្តបន្ទាប់ និងមានការគ្រប់គ្រងករណីស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចស្តារស្ថានភាពខ្លួនឯងឡើងវិញ ចេញពីអ្វីដែលពួកគេធ្លាប់ជួបប្រទះ ទទួលបានយុត្តិធម៌ពីការឈឺចាប់របស់ពួកគេ ទ្រទ្រង់ជីវភាពខ្លួនឯងជាបន្តបន្ទាប់ និងអាចចូលរួមយ៉ាងពេញលេញនៅក្នុងជីវភាពសេដ្ឋកិច្ច និងសង្គម។

លទ្ធផលនេះរាប់បញ្ចូលរយៈពេលឆ្លុះបញ្ចាំង ដែលក្នុងនោះ៖

- ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ បានទទួលរយៈពេលឆ្លុះបញ្ចាំង ដែលមិនភ្ជាប់លក្ខខណ្ឌតម្រូវឱ្យពួកគេចូលរួម ឬសហការក្នុងដំណើរការយុត្តិធម៌នោះឡើយ។
- រយៈពេលឆ្លុះបញ្ចាំង គឺជារយៈពេលដែលផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេអាចឆ្លុះបញ្ចាំងលើរាល់ព័ត៌មានទាំងអស់ដែលមាន ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវអំពីជម្រើសរបស់ពួកគេ ដូចជា ការកំណត់អត្តសញ្ញាណ ការទទួលជំនួយ និងការផ្តល់កិច្ចសហប្រតិបត្តិការដល់ទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌជាដើម។
- ជនដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ អាចទទួលបានសេវាគាំទ្រជាច្រើន នៅពេលដែលមានមូលហេតុសមស្រប ក្នុងការជឿជាក់ថាបុគ្គលនេះ អាចជាជនរងគ្រោះ។
- គេមិនអាចបណ្តេញជនរងគ្រោះនៃអំពើជួញដូរមនុស្សពីទីកន្លែង ឬប្រទេសគោលដៅក្នុងអំឡុងរយៈពេលនេះឡើយ ហើយអាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់ការអនុញ្ញាតឱ្យពួកគេបន្តស្នាក់នៅក្នុងប្រទេសគោលដៅ។

លទ្ធផលនេះ តម្រូវឱ្យអ្នកផ្តល់សេវាជម្រកសុវត្ថិភាព៖

- គោរពសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការបដិសេធមិនអាចចូលមក ឬស្នាក់នៅក្នុងជម្រកសុវត្ថិភាព។
- ផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស នូវបរិយាកាសរស់នៅប្រកបដោយសុវត្ថិភាព និងទទួលបានការការពារ ដោយមិនបន្ទច់បង្អាក់ដល់សិទ្ធិសេរីភាពដើរហើររបស់ពួកគេ (ក្នុងករណីដែលការធ្វើបែបនេះ មានសុវត្ថិភាពសម្រាប់ពួកគេ) និងគោលការណ៍ស្តីពីការមិនដាក់ទោស។
- ផ្តល់ជម្រកសុវត្ថិភាពជាជម្រើស(ជម្រកសុវត្ថិភាពនៅក្នុងសហគមន៍ ការជួលបន្ទប់ស្នាក់នៅបណ្តោះអាសន្ន) នៅពេលដែលពុំមានជម្រកសុវត្ថិភាពពិសេសសម្រាប់ពួកគេ។
- ធ្វើការពិចារណាពិសេស នៅពេលផ្តល់កន្លែងស្នាក់នៅដល់អនីតិជន ដូចជា ពិចារណាពីអាយុ យេនឌ័រ ពិការភាព និង/ឬភាពចាស់ទុំរបស់ពួកគេ ស្របតាមគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ។

## វិសាលភាព

- កន្លែងស្នាក់នៅ និងសកម្មភាពនានា មានការយកចិត្តទុកដាក់ចំពោះយេនឌ័រ រៀបចំឱ្យសមស្របទៅតាមវប្បធម៌ អាយុ និងមានលក្ខណៈកុមារមេត្រី កម្មវិធីផ្តល់ជម្រកសុវត្ថិភាព និងស្តារឡើងវិញ មិនជំរុញឱ្យមានការប្រកាន់ផ្នត់គំនិតយេនឌ័រ ឬបង្កផលប៉ះពាល់ដល់សិទ្ធិក្សាឯកជនភាព ឬបូរណភាពរាងកាយរបស់ជនរងគ្រោះឡើយ (ឧទាហរណ៍ ជនរងគ្រោះពុំត្រូវបានគេឆែកឆេររាងកាយ ឬបង្ខំឱ្យទៅពិនិត្យសុខភាពនោះឡើយ)។
- ការបង្កលក្ខណៈឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចធ្វើការប្រាស្រ័យទាក់ទងការជាមួយនឹងក្រុមគ្រួសារ។
- ស្តង់ដារជាតិស្តីពីការផ្តល់ផាសុកវត្ថុសម្រាប់ជនមានពិការភាព សេវាបកប្រែ និងភាសាសញ្ញា ដែលផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាព។
- ផ្តល់ព័ត៌មានក្នុងទម្រង់ដែលមានភាពងាយស្រួលសម្រាប់ពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ដូចជា ព័ត៌មានអំពីឱកាសការងារ ឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលជាដើម។
- ផ្តល់ព័ត៌មានអំពី និងពិភាក្សាពីជម្រើសសំណងបដិទាន និង/ឬសំណងជំងឺចិត្តនានា។
- ជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចប្រើប្រាស់បណ្តាញអ្នកជំនាញផ្តល់ជំនួយផ្លូវច្បាប់ អង្គការដែលធ្វើការងារផ្នែកពិការភាព និងអង្គការសិទ្ធិមនុស្ស។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| រដ្ឋជាសមាជិកអាស៊ាន ផ្តល់ជម្រកសុវត្ថិភាព និងរយៈពេលផ្ទះបញ្ជាំង និងស្តារឡើងវិញ យ៉ាងសមស្របដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្របតាមអនុសញ្ញា ACTIP។ | ការការពារ និងការគាំទ្រដល់ជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីតិកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការស្តារឡើងវិញ ការឆ្លុះបញ្ចាំង និងជម្រកសុវត្ថិភាព

១៨

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ជនរងគ្រោះនៃអំពើជួញដូរមនុស្សបានទទួលព័ត៌មាននិងផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដែលមានថតសំឡេងទុក និងផ្តល់ការយល់ព្រមពីកុមារ បន្ថែមលើការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ ដើម្បីឱ្យពួកគេអាចទទួលបាន ជម្រកសុវត្ថិភាព/កន្លែងស្នាក់នៅដែលជួយពួកគេអាចស្តារឡើងវិញ និងទទួលបានសេវាសមស្របតាមតម្រូវការរបស់ពួកគេ។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ២.៦.១៦។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្សដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ២.២.១, ២.៧.១, ២.៧.២, ៣.៣.៤។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ២១. ៤០, ៤២, ៩២។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៨, ASCC ១៣។

### សេចក្តីអធិប្បាយ និងការពន្យល់

រាល់ជំនួយទាំងអស់ រាប់បញ្ចូលទាំងកម្មវិធីស្តារឡើងវិញ និងការផ្តល់ជម្រកសុវត្ថិភាពផង គួរផ្តល់ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង/ឬបុគ្គលដែលត្រូវបានគេសន្មតថាជាជនរងគ្រោះផ្អែកតាមការយល់ព្រមពេញលេញផ្អែកតាមព័ត៌មានត្រឹមត្រូវរបស់ពួកគេ។[៤៦] មុនពេលសុំការយល់ព្រមលើសកម្មភាពណាមួយ ជនរងគ្រោះគួរទទួលបានព័ត៌មានឱ្យបានពេញលេញ អំពីគោលនយោបាយ នីតិវិធី និងកម្មវិធីដែលមានសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាភាសា និងក្នុងទម្រង់ដែលពួកគេអាចយល់បាន។ ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីជនរងគ្រោះដែលអាចសរសេរបាន ហើយការយល់ព្រមដោយផ្ទាល់មាត់ អាចស្នើសុំពីជនរងគ្រោះ ដែលមិនអាចផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ។ ត្រូវផ្តល់អ្នកបកប្រែភាសានិង/ឬអ្នកបកប្រែភាសាសញ្ញា ដើម្បីជួយសម្រួលដល់ការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ក្នុងករណីជនរងគ្រោះជាកុមារ គួរមានការសាកសួរជនរងគ្រោះអំពីការយល់ឃើញ និងបំណងប្រាថ្នារបស់ពួកគេ សមស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ។ កុមារអាចផ្តល់ការយល់ព្រម តែក៏ចាំបាច់ដែលត្រូវសុំការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេផងដែរ។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ នីតិវិធី ដើម្បីសុំការយល់ព្រមពីកុមារ និងនីតិវិធី ដើម្បីឱ្យជនរងគ្រោះដកយកការយល់ព្រមឱ្យគេជួយគាំទ្រ និងផ្តល់ជំនួយដល់ពួកគេ ត្រូវបានដាក់ឱ្យអនុវត្ត។
- ☐ ព័ត៌មានត្រូវបានផ្តល់ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាភាសា និងក្នុងទម្រង់ដែលពួកគេអាចយល់បាន។
- ☐ មានការរៀបចំផ្តល់ការបណ្តុះបណ្តាលអំពីរបៀបសុំការយល់ព្រម ផ្អែកលើព័ត៌មានត្រឹមត្រូវពីជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយប្រើប្រាស់អភិក្រមបែបកុមារមេត្រី យកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តោតលើជនរងគ្រោះ និងផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ។
- ☐ កុមារបានចូលរួមក្នុងរាល់ការសម្រេចចិត្តទាំងអស់អំពីសេវា និងការគាំទ្រដែលផ្តល់ឱ្យពួកគេ។

៤៦ International Organisation for Migration ( IOM ), Handbook on Direct Victim Assistance for Victims of Traffcking, 2007, p 57-58.

## វិសាលភាព

លទ្ធផលនេះ សំដៅលើការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដោយមានការថតជាសំឡេងទុក ឬការផ្តល់ការយល់ព្រមពីកុមារដែលជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ពាក់ព័ន្ធនឹងការស្តារឡើងវិញ ជម្រកសុវត្ថិភាព និងសេវានានា៖

- ត្រូវសុំការផ្តល់ការយល់ព្រមផ្អែកលើព័ត៌មានត្រឹមត្រូវ សម្រាប់ជនរងគ្រោះជាមនុស្សពេញវ័យ និងការយល់ព្រមពីជនរងគ្រោះជាកុមារ បន្ថែមលើការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ នៅដំណាក់កាលដំបូងនៃដំណើរការ
- ផ្តល់ការគាំទ្រដល់ជនរងគ្រោះ រួមទាំងក្នុងអំឡុងពេលផ្តល់សេវាស្តារឡើងវិញ និងសេវាជម្រកសុវត្ថិភាពផងដែរ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង/ឬបុគ្គលដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ អាចដកការយល់ព្រមរបស់ខ្លួន នៅពេលណាក៏បាន ហើយអ្នកផ្តល់សេវាត្រូវធ្វើការពិនិត្យឱ្យបានជាប្រចាំ ថាតើជនរងគ្រោះនៅតែបន្តយល់ព្រមទទួលយកសេវា/ការគាំទ្រពាក់ព័ន្ធនានា ដែលត្រូវបានផ្តល់ដល់ពួកគេដែរឬទេ។
- មានការផ្តល់អ្នកបកប្រែ ភាសាសញ្ញា បច្ចេកវិទ្យា និងឧបករណ៍ផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះផ្តល់ការយល់ព្រម ផ្អែកលើព័ត៌មានពេញលេញ។
- នៅពេលសុំការយល់ព្រម ផ្អែកលើព័ត៌មានត្រឹមត្រូវពីជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានការប្រើប្រាស់អភិក្រមបែបកុមារមេត្រី យកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តោតលើជនរងគ្រោះ និងផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្ម័គ្រចិត្តប្រើប្រាស់ជម្រកសុវត្ថិភាព/កន្លែងស្នាក់នៅ សេវានានា និងការគាំទ្រផ្សេងៗស្របតាមឧត្តមានុវត្តន៍។ | ការការពារ និងការគាំទ្រដោយជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការស្តារឡើងវិញ ការឆ្លុះបញ្ចាំង និងជម្រកសុវត្ថិភាព

១៩

## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ ត្រូវបានដាក់ឱ្យស្នាក់នៅនៅក្នុងជម្រកសុវត្ថិភាព/កន្លែងស្នាក់នៅសមស្រប ដើម្បីឱ្យពួកគេអាចស្តារឡើងវិញ និងការធ្វើការឆ្លុះបញ្ចាំង ស្របតាមតម្រូវការរបស់ពួកគេ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៤.២.៧, ៤.២.៩, ៤.៣.១១, ៤.៣.១២, ៤.៣.១១-១៣។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ២១, ៣៩។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៨, ASCC ១៣។

## សេចក្តីអធិប្បាយ និងការពន្យល់

កន្លែងស្នាក់នៅដែលសមស្រប និងមានសុវត្ថិភាព គឺជាកន្លែងស្នាក់នៅជាមួយនឹងក្រុមគ្រួសារ លើកលែងតែគ្រួសារ ត្រូវបានគេចាត់ទុកថាមិនមានភាពសមស្រប។ រាប់បញ្ចូលទាំងក្មេងប្រុស ឬក្មេងស្រី ដែលមានពិការភាពផង ត្រូវទទួលបានការថែទាំ និងការព្យាបាលឱ្យបានត្រឹមត្រូវ សមស្របតាមយេនឌ័រ វប្បធម៌ សុខភាពផ្លូវចិត្ត និងសុខភាពផ្លូវកាយ តម្រូវការភាសា និងតម្រូវការស្មារតីរបស់ពួកគេ នៅពេលដែលមានការរៀបចំកន្លែងស្នាក់នៅ ឬកម្មវិធីស្តារឡើងវិញដល់ជនរងគ្រោះជាកុមារ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ការជួយឱ្យគ្រួសាររស់នៅបានជុំគ្នា គឺជាជម្រើសអាទិភាពដំបូង ក្នុងការបំពេញតម្រូវការរបស់កុមារ។ ជម្រើសនេះ គួរអនុវត្តនៅក្នុងស្ថានភាពដែលមានសុវត្ថិភាព និងល្អប្រសើរសម្រាប់កុមារ។
- ☐ កុមារបានទទួលការគាំទ្រ ស្របតាមតម្រូវការរបស់ពួកគេ។
- ☐ ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ បានទទួលពេលវេលា ដើម្បីធ្វើការឆ្លុះបញ្ចាំងឡើងវិញ។
- ☐ មានការគោរពសិទ្ធិ ការយល់ឃើញ និងសេចក្តីសម្រេចចិត្តរបស់កុមារដែលរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ☐ ក្នុងរាល់ការធ្វើសេចក្តីសម្រេចចិត្តទាំងអស់ ដែលប៉ះពាល់លើពួកគេ រដ្ឋជាសមាជិកអាស៊ាន ផ្តល់ការសម្របសម្រួលសមស្របសម្រាប់កុមារដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស។
- ☐ ការផ្តល់ការសម្របសម្រួលដល់កុមារដែលរងគ្រោះដោយអំពើជួញដូរមនុស្ស សមស្របតាមតម្រូវការរបស់ពួកគេ និងមានការយកចិត្តទុកដាក់លើអាយុ ភាពចាស់ទុំ សមត្ថភាព និងបណ្តាញគាំទ្ររបស់ពួកគេ។
- ☐ កុមារមានសិទ្ធិទៅរៀន ក្នុងអំឡុងពេលដែលពួកគេស្នាក់នៅ នៅពេលដែលការទៅរៀនមានសុវត្ថិភាពសម្រាប់កុមារ។

## វិសាលភាព

លទ្ធផលនេះ សំដៅជាក់លាក់លើ**ការស្តារឡើងវិញ**៖

- ការរស់នៅជួបជុំជាមួយនឹងក្រុមគ្រួសារ គឺជាជម្រើសអាទិភាពដំបូងនៃការផ្តល់កន្លែងស្នាក់នៅដល់កុមារ។ ជម្រើសនេះ គួរអនុវត្តក្នុងស្ថានភាពដែលវាមានសុវត្ថិភាព និងល្អប្រសើរសម្រាប់កុមារ។
- ការថែទាំ និងការព្យាបាល ត្រូវបានផ្តល់ស្របតាមតម្រូវការរបស់កុមារ និងមិនអាចភ្ជាប់ជាលក្ខខណ្ឌដែលតម្រូវឱ្យកុមារត្រូវតែចូលរួមសហការជាមួយអាជ្ញាធរ ឬក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌនោះឡើយ។
- កុមារគួរចូលរួមក្នុងរាល់ការសម្រេចចិត្តទាំងអស់ដែលប៉ះពាល់លើពួកគេ។
- កុមារមានសិទ្ធិទៅរៀន ក្នុងអំឡុងពេលស្នាក់នៅ នៅពេលដែលការទៅរៀនបែបនេះមានសុវត្ថិភាពសម្រាប់កុមារ។

លទ្ធផលនេះ សំដៅជាក់លាក់លើ**ការឆ្លុះបញ្ចាំង**៖

- ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ បានទទួលរយៈពេលឆ្លុះបញ្ចាំងស្របតាមអាយុ ភាពចាស់ទុំ សមត្ថភាព និងបណ្តាញគាំទ្ររបស់ពួកគេ។
- មានការគោរពសិទ្ធិ ការយល់ឃើញ និងការសម្រេចចិត្តរបស់កុមារ។

លទ្ធផលនេះ សំដៅជាក់លាក់លើ**ជម្រកសុវត្ថិភាព**៖

- កន្លែងស្នាក់នៅសមស្រប ដែលផ្តល់សេរីភាពក្នុងការដើរហើរ ត្រូវបានផ្តល់ដល់កុមារ ក្មេងជំទង់ និងកុមារមានពិការភាព។
- ជម្រកសុវត្ថិភាព/កន្លែងស្នាក់នៅសមស្របទៅតាមវប្បធម៌ ជំនឿ យេនឌ័រ និងអាយុ និងបង្ការមិនឱ្យមានការប៉ះទង្គិចផ្លូវចិត្តជាថ្មី។
- កុមារត្រូវបានដាក់នៅកន្លែងឃុំឃាំង។
- ប្រសិនបើចាំបាច់ត្រូវដាក់កុមារឱ្យរស់នៅក្នុងជម្រកសុវត្ថិភាព ការស្នាក់នៅរបស់ពួកគេត្រូវមានរយៈពេលខ្លីបំផុត តាមដែលអាចធ្វើទៅបាន និងអាចត្រូវមានការវាយតម្លៃដោយឯករាជ្យ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| កុមារដែលរងគ្រោះដោយសារការជួញដូរមនុស្ស បានទទួលជម្រកសុវត្ថិភាព កន្លែងស្នាក់នៅ ព្រមទាំងសេវា ការគាំទ្រ និងការស្តារឡើងវិញ។ | ការការពារ និងការគាំទ្រដល់ជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានដឹកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានដឹក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានដឹក |

# ការស្តារឡើងវិញ ការឆ្លុះបញ្ចាំង និងជម្រកសុវត្ថិភាព

## ២០

### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

រយៈពេលស្តារឡើងវិញ និងឆ្លុះបញ្ចាំង ព្រមទាំងសេវាជម្រកសុវត្ថិភាព/កន្លែងស្នាក់នៅ ផ្អែកតាមព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ ទំព័រ ៤៩
- អនុសញ្ញា ACTIP មាត្រា ១៤(១០)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ច្រាបសិទ្ធិជនមានពិការភាព APSC ៨, ASCC ១៣។

### សេចក្តីអធិប្បាយ និងការពន្យល់

អភិក្រមផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ទទួលស្គាល់ពីការប៉ះទង្គិចផ្លូវចិត្ត និងប្រវាំឡង់នៃការប៉ះទង្គិចផ្លូវចិត្ត ក្នុងចំណោមជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ អ្នកផ្តល់សេវាជួរមុខ រាប់បញ្ចូលទាំងបុគ្គលិក ដែលបំពេញការងារនៅជម្រកសុវត្ថិភាព គួរដឹង និងចេះសម្គាល់ដឹង ពីសញ្ញាដែលបង្ហាញអ្នកពីការប៉ះទង្គិចផ្លូវចិត្ត និងផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត លើជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ។ អភិក្រមផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ចាប់ផ្តើមជាមួយនឹងការយល់ដឹងពីផលប៉ះពាល់ផ្លូវកាយចិត្ត សង្គម និងផ្លូវចិត្ត ដែលការប៉ះទង្គិចផ្លូវចិត្តមានលើបុគ្គល និងគ្រួសាររបស់ពួកគេ ព្រមទាំងអ្នកជំនាញដែលអាចជួយពួកគេបាន។ អភិក្រមបែបនេះ ផ្តល់នូវយុទ្ធសាស្ត្រ និងឧបករណ៍សម្រាប់ជួយគាំទ្រដល់ជនរងគ្រោះ ដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត បញ្ចៀសមិនឱ្យមានការប៉ះទង្គិចផ្លូវចិត្តជាថ្មី និងការបញ្ជូនជនរងគ្រោះទៅរកសេវាផ្តល់ជំនួយពីអ្នកជំនាញនៅពេលដែលចាំបាច់។

### វិសាលភាព

លទ្ធផលនេះ សំដៅជាក់លាក់លើ៖

- បុគ្គលិកទាំងអស់ ដែលអនុវត្តកម្មវិធីស្តារឡើងវិញ និងកំពុងបំពេញការងារនៅក្នុងជម្រកសុវត្ថិភាព(អ្នកគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច សន្តិសុខអ្នកដាំស្ល និងអ្នកសម្អាត) ត្រូវទទួលបានជំនាញ និងការបណ្តុះបណ្តាលអំពីចំណេះដឹង ដើម្បីឱ្យពួកគេយល់ពីតួនាទីរបស់ខ្លួន ក្នុងការជួយគាំទ្រ និងផ្តល់ការថែទាំដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងត្រៀមរៀបចំពួកគេ ដើម្បីទទួលបានសេវាគាំទ្រ ក្រោយពេលចាកចេញពីជម្រកសុវត្ថិភាព។
- គោលការណ៍ណែនាំ និងនីតិវិធីនានា ប្រើប្រាស់គោលការណ៍ផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្តដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះក្នុងអំឡុងពេលនៃការស្តារឡើងវិញ និងការស្នាក់នៅក្នុងជម្រកសុវត្ថិភាព។
- ការគាំទ្រ និងជំនួយនានា ត្រូវបានផ្តល់ផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ទៅតាមតម្រូវការ និងបំណងប្រាថ្នារបស់ជនរងគ្រោះ។
- ការផ្តល់ប្រឹក្សា ឬការគាំទ្រផ្លូវចិត្ត ត្រូវបានផ្តល់ដោយអ្នកជំនាញឯកទេស ឬដោយជាក់បុគ្គលិករបស់អ្នកផ្តល់សេវាតែម្តង។
- បណ្តាញមិត្តជួយមិត្តសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានបង្កើតឡើង។
- មានការទទួលស្គាល់សិទ្ធិជនមានពិការភាព ក្នុងការរស់នៅប្រកប ដោយសេចក្តីថ្លៃថ្នូរ ទៅតាមការសម្រេចចិត្តរបស់ពួកគេ។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ រាល់អ្នកផ្តល់សេវាទាំងអស់ បានទទួលការបណ្តុះបណ្តាល ដែលផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត យកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តោតលើជនរងគ្រោះ និងឈរលើគោលការណ៍សិទ្ធិមនុស្ស។
- ☐ ការគាំទ្រ និងការផ្តល់ជំនួយ ផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ត្រូវបានផ្តល់ទៅតាមតម្រូវការ និងបំណងប្រាថ្នារបស់ជនរងគ្រោះ។
- ☐ សេវាដែលផ្តល់នៅក្នុងអង្គការ ឬស្ថាប័ន រួមមានយ៉ាងហោចណាស់ ការផ្តល់ប្រឹក្សា ឬការគាំទ្រផ្លូវចិត្ត។
- ☐ មានការផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក។

| លទ្ធផលរយៈពេលមធ្យម ( ២ ទៅ ៥ ឆ្នាំ ) | លទ្ធផលរយៈពេលវែង ( ចាប់ពី ៥ ឆ្នាំឡើងទៅ ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្ម័គ្រចិត្ត ប្រើប្រាស់សេវាចម្រុះសុវត្ថិភាព/កន្លែងស្នាក់នៅ និងការគាំទ្រនានាស្របតាមឧត្តមានុវត្តន៍។ | ការការពារ និងការគាំទ្រដល់ជនរងគ្រោះ ផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ត្រូវបានធ្វើស្ថាប័ននីតិកម្ម និងអនុវត្តជាទូទៅ ស្របតាមខ្លឹមសារនៃអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ឧទាហរណ៍ បង្ហាញពីការអនុវត្តល្អ ពាក់ព័ន្ធនឹងការស្តារឡើងវិញ ការ ស្តារឡើងវិញ ការ ផ្ទះបញ្ជាំង និងជម្រកសុវត្ថិភាព

**ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលមានកូនតូច ត្រូវបានផ្តល់ជូននូវកន្លែងស្នាក់នៅបណ្តោះអាសន្ន នៅជម្រកសុវត្ថិភាព ផ្ទះសន្តិភាព ប្រទេសវៀតណាម**

កាលពីឆ្នាំ ២០២១ ក្នុងអំឡុងពេលដែលមានផ្ទុះជំងឺកូវីដ ១៩ ជម្រកសុវត្ថិភាពមួយកន្លែងនៅក្នុងប្រទេសវៀតណាម បានទទួលទារក ៤ នាក់ (ដែលពុំមានអាណាព្យាបាល) និងស្ត្រីមានផ្ទៃពោះ ១ នាក់ឱ្យស្នាក់នៅ។ ជម្រកសុវត្ថិភាពនេះ បានសម្របសម្រួល និងកៀរគរធនធានផ្សេងៗ ដើម្បីផ្តល់ការថែទាំ ជាអាទិភាពដល់ទារក និងស្ត្រីជាម្តាយរូបនេះ។ គេត្រូវការបុគ្គលិកអ្នកមើលការខុសត្រូវក្នុងជម្រកសុវត្ថិភាព សន្តិសុខ និងភ្នាក់ងារសង្គមកិច្ច ដើម្បីអាចជួយផ្តល់ការថែទាំដល់ទារកដែលទើបកើតទាំងនេះ។

នៅពេលដែលស្ថាប័នរដ្ឋដឹងអំពីស្ថានភាពនេះ ពេលនោះជម្រកសុវត្ថិភាពនេះបានទទួលកញ្ចប់សេវាគាំទ្រ ផ្អែកតាមតម្រូវការរបស់កុមារ ដូចជា ម្សៅទឹកដោះគោទារក និងសម្លៀកបំពាក់ជាដើម។ មានការផ្តល់សេវាថែទាំសុខភាព និងការព្យាបាលសម្រាប់កុមារ និងម្តាយ ហើយបុគ្គលិកបានទទួលការណែនាំ និងការបណ្តុះបណ្តាលអំពីរបៀបផ្តល់ការថែទាំដល់ទារក។ ស្ត្រីមានផ្ទៃពោះរូបនេះ បានសម្រាលកូនប្រកបដោយសុវត្ថិភាព ក្នុងអំឡុងពេលដែលគាត់ស្នាក់នៅក្នុងជម្រកសុវត្ថិភាពនេះ។

នៅពេលដែលជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ត្រូវបានចាប់ខ្លួន ប៉ូលិសបានរកឃើញម្តាយរបស់កុមារទាំងនេះ ដែលត្រូវបានបញ្ជូនមកជម្រកសុវត្ថិភាព ហើយស្ត្រីទាំងនេះ បានយកកូនរបស់ពួកគេត្រឡប់ទៅវិញ។

**ការគាំទ្រ និងការផ្តល់ជំនួយនៅក្នុងជម្រកសុវត្ថិភាព ធ្វើឡើងផ្អែកតាមព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត**

ជារឿយៗ ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលជាជនជាតិវៀតណាម តែងត្រូវបានគេជួញដូរសម្រាប់ការធ្វើអាជីវកម្មផ្លូវភេទ នៅក្នុងប្រទេសម៉ាឡេស៊ី។ មន្ត្រីដែលផ្តល់ការគាំទ្រផ្លូវចិត្ត ផ្អែកតាមព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ជួបជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងជួយឱ្យពួកគេផ្តល់សក្ខីកម្មនិងចូលរួមក្នុងសវនាការ។ បុគ្គលិកដែលផ្តល់សេវាគាំទ្រផ្លូវចិត្តបានទទួលការបណ្តុះបណ្តាលឯកទេស និងកសាងការជឿទុកចិត្ត និងផ្តល់ភាពកក់ក្តៅដល់ជនរងគ្រោះ ជាមួយនឹងការគាំទ្រទាំងនេះ ជនរងគ្រោះកាន់តែមានទំនុកចិត្ត និងកាន់តែមានភាពកក់ក្តៅក្នុងចិត្ត និងយល់ព្រមចែករំលែកព័ត៌មានបន្ថែមទៀត មានភាពក្លាហានក្នុងការធ្វើជាសាក្សីនៅក្នុងតុលាការ និងកាន់មានទំនុកចិត្តអំពីខ្លួនឯង និងគ្រួសាររបស់ពួកគេ។

# ការធ្វើមាតុភូមិនិវត្តន៍ និង ការធ្វើសមាហរណកម្ម

## ២១

### លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មទៅតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ត្រូវបានរៀបចំឡើង។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៥៤, ៥៩។
- អនុសញ្ញា ACTIP មាត្រា ១៤(១០)-(១២)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព ASCC ១៣។

### សេចក្តីអធិប្បាយ និងការពន្យល់

ការផ្តល់ជំនួយ ដើម្បីឱ្យជនរងគ្រោះ បានធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញ គួរខិតខំធានាការធ្វើដំណើរប្រកបដោយសុវត្ថិភាព និង/ឬការផ្ទេរជនរងគ្រោះពីការទីកន្លែង ឬប្រទេសគោលដៅទៅប្រភពដើមរបស់ពួកគេវិញ។ គេមិនគួរបង្ខំឱ្យជនរងគ្រោះត្រឡប់ទៅកន្លែងដើមកំណើតរបស់ពួកគេវិញឡើយ នៅពេលដែលការវិលត្រឡប់បែបនេះបង្កជាហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់ជនរងគ្រោះ គេគួរពិនិត្យលទ្ធភាពផ្តល់នូវជម្រើសណាផ្សេងទៀត ដូចជា ការស្នាក់នៅក្នុងប្រទេស/សហគមន៍គោលដៅ ឬផ្លាស់ទៅប្រទេសទី ៣ ឬសហគមន៍ផ្សេងទៀតជាដើម។ ក្នុងករណីដែលការវិលត្រឡប់មកទីកន្លែងប្រភពដើមវិញ ជាជម្រើសតែមួយគត់ គេគួរផ្តោតការយកចិត្តទុកដាក់លើអ្វីដែលអាចផ្តល់ឱ្យបានដើម្បីជួយជនរងគ្រោះក្នុងពេលអន្តរកាល និងសម្របសម្រួលជាមួយកន្លែងប្រភពដើម និង/ឬប្រទេសដែលជាប្រភពដើមរបស់ជនរងគ្រោះ ដើម្បីធានាឱ្យមានការបន្តផ្តល់ការថែទាំដល់ជនរងគ្រោះ។

ការធ្វើសមាហរណកម្ម គឺជាសមាសភាគមួយដ៏សំខាន់ នៃការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលបានទទួលជំនួយសម្រាប់ការធ្វើសមាហរណកម្ម អាចត្រូវបានគេជួញដូរសាជាថ្មី ក្នុងកម្រិតមួយតិចតួចបំផុត។ គោលការណ៍ណែនាំរបស់ UNHCR ត្រង់ចំណុច ៦.៨ ស្នើសុំឱ្យរដ្ឋជាសមាជិកអាស៊ាន ធានាឱ្យមានការកសាងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ដើម្បីឱ្យ បុគ្គលដែលវិលត្រឡប់ទៅទីកន្លែងដែលជាប្រភពដើមរបស់ពួកគេវិញ បានទទួលជំនួយ និងការគាំទ្រដែលចាំបាច់ ដើម្បីលើកកម្ពស់សុខមាលភាពរបស់ពួកគេ។ គួរមានការចាត់វិធានការ ដើម្បីធានាឱ្យមានការផ្តល់ការថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្ត លំនៅឋាន សេវាអប់រំ និងសេវាស្វែងរកការងារឱ្យបានសមស្រប សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍។[៤៧] អនុសញ្ញា ACTIP អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីជួយដល់ការធ្វើសមារណកម្មជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយសហការជាមួយអង្គការសង្គមស៊ីវិលដែលពាកក់ព័ន្ធ។

គួរមានការពិចារណាពីឧត្តមប្រយោជន៍របស់កុមារ នៅពេលផ្តល់ការគាំទ្រដល់កុមារ ដែលធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្ម ដូចជា ការសុំការយល់ព្រមពីកុមារ ការវាយតម្លៃលើគ្រួសារ និងការរៀបចំផែនការសមាហរណកម្មជាដើម។ ការរៀបចំផែនការត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះនៃអំពើជួញដូរមនុស្ស គ្រួសាររបស់ពួកគេ និងភាគីទទួលកុមារឱ្យស្នាក់នៅ។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ការរៀបចំផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម ទៅតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស គ្រួសាររបស់ពួកគេ និងភាគីទទួល។
- ☐ វិធានការពិសេសនានាត្រូវបានអនុវត្ត ស្របតាមតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ មានការតែងតាំងភ្នាក់ងារសង្គមកិច្ច ឬជនបង្គោលសម្រាប់ផ្តល់ការគាំទ្រដល់ជនរងគ្រោះ។
- ☐ រដ្ឋជាសមាជិកអាស៊ានកំពុងរៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីឱ្យជនរងគ្រោះអាចធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព និងធ្វើសមាហរណកម្ម តាមរយៈកិច្ចសហប្រតិបត្តិការរវាងស្ថានទូត និងប្រកការទូតនានា។
- ☐ គោលនយោបាយ និងនីតិវិធីនានា ត្រូវបានដាក់អនុវត្តសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ដើម្បីធានាឱ្យជនរងគ្រោះអាចធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត និងទទួលបានជំនួយសម្រាប់ការធ្វើសមាហរណកម្ម។
- ☐ មានការផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក ដែលពាក់ព័ន្ធរបស់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនរដ្ឋាភិបាល ដូចជាភ្នាក់ងារសង្គមកិច្ច ដែលមានភារៈកិច្ចផ្តល់សេវាគាំទ្រសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម។ ប្រធាននៃការបណ្តុះបណ្តាលរួមមានរបៀបអនុវត្តអភិក្រមផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ និងស្ថានភាពរបស់កុមារ។

---

៤៧ United Nations High Commissioner for Human Rights (UNHCHR) Recommended Principles and Guidelines on Human Rights and Human Traffcking, 2002. Para 8.

## វិសាលភាព

លទ្ធផលនេះ មានគោលបំណងធានាថា៖

- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មិនថាពួកគេជាពលរដ្ឋ ឬមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ បានទទួលជំនួយទាន់ពេលវេលា ដើម្បីអាចវិលត្រឡប់ទៅទីកន្លែងដែលជាប្រភពដើមរបស់ពួកគេវិញ។
- ផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម ស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយភាគីទទួលជនរងគ្រោះ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ។ ផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មនេះ រៀបចំទៅតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ឆ្លើយតបចំពោះតម្រូវការរបស់ពួកគេ និងត្រូវបានអនុវត្តសមស្របទៅតាមយេនឌ័រ អាយុ និងវប្បធម៌របស់ជនរងគ្រោះ។
- អ្នកគ្រប់គ្រងករណី ឬភ្នាក់ងារសង្គមកិច្ច ត្រូវបានតែងតាំងឱ្យសហការជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីរៀបចំផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម ដែលឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ជនរងគ្រោះ។ ឧទាហរណ៍ ស្តីពីការធ្វើសមាហរណកម្ម និងការផ្តល់ជំនួយ រួមមាន សេវាថែទាំវេជ្ជសាស្ត្រ/សុខភាព រាប់បញ្ចូលទាំងសេវាផ្តល់ប្រឹក្សា ការផ្តល់ជំនួយហិរញ្ញវត្ថុ ការផ្តល់កម្ចីខ្នាតតូច ជំនួយផ្លូវច្បាប់ ការទទួលបានសេវាអប់រំ ការអប់រំវិជ្ជាជីវៈ សេវាស្វែងរកការងារ សេវាលំនៅឋាន និងការផ្តល់កន្លែងស្នាក់នៅ។
- អាយុ យេនឌ័រ និងតម្រូវការពិសេសរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេសកុមារ និងជនមានពិការភាព ត្រូវបានពិចារណា និងមានការអនុវត្តវិធានការនានា។
- មានការពិចារណាពីការវិលត្រឡប់ប្រកបដោយសុវត្ថិភាព ហើយជនរងគ្រោះ មិនគួរត្រូវបានគេបង្ខំឱ្យវិលត្រឡប់ទៅកន្លែងដែលជាប្រភពដើមរបស់ពួកគេឡើយ។ ការធ្វើមាតុភូមិនិវត្តន៍អាចជាការពិបាកសម្រាប់ ជនរងគ្រោះដែលត្រូវបានគេជួញដូរនៅក្នុងប្រទេស។ ដោយសារតែមនុស្សម្នាក់ មានប្រភពពីប្រទេសដែលជាកន្លែងដែលពួកគេត្រូវបានជួញដូរ មិនមានន័យថាពួកគេអាចវិលត្រឡប់ទៅកាន់សហគមន៍ ដែលជាស្រុកកំណើតរបស់ពួកគេវិញបានឡើយ។ អាស្រ័យទៅតាមកត្តាសុវត្ថិភាព ការវិលត្រឡប់ទៅរកសហគមន៍ផ្សេង ឬប្រទេសផ្សេងទៀត អាចជាជម្រើសដែលល្អបំផុតក៏ថាបាន។
- ជនរងគ្រោះត្រូវបានអមដំណើរដោយភ្នាក់ងារសង្គមកិច្ច ឬអ្នកផ្តល់ការគាំទ្រ ដើម្បីឱ្យពួកគេទទួលបានសុវត្ថិភាព និងទទួលបានការគាំទ្រដើម្បីបំពេញបំណងប្រាថ្នារបស់ជនរងគ្រោះ និងការមានការពិចារណាពីហានិភ័យដែលអាចកើតមាននៅក្នុងសហគមន៍របស់ពួកគេ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលព័ត៌មាន អំពីអ្វីដែលគេរំពឹងថានឹងកើតមានឡើង ក្នុងអំឡុងពេលដែលពួកគេធ្វើមាតុភូមិនិវត្តន៍ ត្រូវផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅប្រាក់ឧបត្ថម្ភ សម្រាប់ការធ្វើដំណើរ និងចំណាយលើអាហារ នៅពេលដែលពួកគេវិលត្រឡប់ទៅទីកន្លែងដែលជាប្រភពដើមរបស់ពួកគេវិញតែឯង។
- ផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ត្រូវបានធ្វើឡើងជាមួយនឹងជនរងគ្រោះ និង/ឬជនដែលត្រូវបានគេសន្មតថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងពុំត្រូវបានភ្ជាប់លក្ខខណ្ឌ ថាទាល់តែជនរងគ្រោះចូលរួមក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌឡើយ។
- រដ្ឋជាសមាជិកអាស៊ាន កំពុងខិតខំរៀបចំជានីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីឱ្យជនរងគ្រោះអាចវិលត្រឡប់ និងធ្វើសមាហរណកម្មប្រកបដោយសុវត្ថិភាព ដែលមានការសហការរវាងស្ថានទូត និងប្រកការទូតនានា។
- មានការផ្តល់ជំនួយសម្រាប់ការធ្វើសមាហរណកម្ម។ នេះអាចមាន ដូចជា សេវាថែទាំវេជ្ជសាស្ត្រ/សុខភាព រាប់បញ្ចូលទាំងការផ្តល់ប្រឹក្សា ជំនួយផ្នែកហិរញ្ញវត្ថុ កម្ចីខ្នាតតូច សេវាជំនួយផ្លូវច្បាប់ ការទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ សេវាស្វែងរកការងារ លំនៅដ្ឋាន និងកន្លែងស្នាក់នៅជាដើម។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម ស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ត្រូវបានរៀបចំឡើង ស្របតាមការអនុវត្តជាស្តង់ដារ។ | ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានដឹកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានដឹក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានដឹក |

# ការធ្វើមាតុភូមិនិវត្តន៍ និង ការធ្វើសមាហរណកម្ម

២២

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្សម្នាក់ៗ បានទទួលការវាយតម្លៃហានិភ័យទៅតាមស្ថានភាពរបស់ពួកគេរៀងៗខ្លួន ដើម្បីរៀបចំជាផែនការស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មរបស់ពួកគេ សំដៅឱ្យពួកគេអាចធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៤.៥.១៧, ៦.១.១, ៦.១.២, ៦.១.៤។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៥៤, ៥៦។
- អនុសញ្ញា ACTIP មាត្រា ១៤(១១), ១៥(១)-(៥)។

## សេចក្តីអធិប្បាយ និងការពន្យល់

ហានិភ័យពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស មានច្រើនបែបច្រើនយ៉ាង ដោយសារតែការជួញដូរមនុស្សមានការបង្ខិតបង្ខំ និងការកេងប្រវ័ញ្ច។ វាបង្កជាហានិភ័យមកលើសន្តិសុខ សុខភាព និងហានិភ័យពាក់ព័ន្ធដទៃទៀត។ ចាំបាច់ត្រូវមានការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយលើហានិភ័យ ដោយធ្វើការពិចារណាពីឥរិយាបថរបស់អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស៖

- តើឥរិយាបថរបស់ជនរងគ្រោះបង្ហាញពីមូលហេតុ
- ដែលធ្វើឱ្យពួកគេភ័យខ្លាចទទួលរងការសងសឹកក្នុងកម្រិតណា
- ស្ថានភាពដល់សន្តិសុខ នៅទីកន្លែងដែលជនរងគ្រោះត្រូវវិលត្រឡប់ និងធ្វើសមារណកម្ម និង
- ថាតើអាជ្ញាធរនៅទីកន្លែង/ប្រទេសដែលជាប្រភពដើម អាចនឹងមានឆន្ទៈកម្រិតណា ក្នុងការផ្តល់ការការពារដល់សុវត្ថិភាព និងបូរណភាពរាងកាយរបស់ជនរងគ្រោះ។

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ទៅកាន់ទីកន្លែងដែលជាប្រភពដើមរបស់ពួកគេ ត្រូវប្រឈមនឹងហានិភ័យ អាចត្រូវបានគេមាក់ងាយ។ ពួកគេអាចត្រឡប់ទៅរកស្ថានភាពដដែល ដែលនាំឱ្យពួកគេត្រូវបានគេជួញដូរ ឬធ្លាក់ចូលទៅក្នុងស្ថានភាព ដែលពួកគេទទួលបានការគាំទ្រតិចតួច។ ស្របតាមអនុសញ្ញា ACTIP គួរមានការវាយតម្លៃលើហានិភ័យឱ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ក្រោយពេលដែលជនរងគ្រោះ ត្រូវបានគេទទួលស្គាល់ និងត្រូវបានធ្វើបច្ចុប្បន្នភាពដែលជាទៀងទាត់ ដើម្បីធានាសុវត្ថិភាពដល់ជនរងគ្រោះ។

ការវាយតម្លៃលើហានិភ័យរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាមនុស្សពេញវ័យ និងជាកុមារ គួរធ្វើឡើង ដើម្បីកំណត់ពីលទ្ធភាព អាចឱ្យពួកគេធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមារណកម្មប្រកបដោយសុវត្ថិភាព ទៅកាន់គ្រួសារ និងសហគមន៍របស់ពួកគេវិញ ដោយមានការពិនិត្យលើជម្រើសផ្សេងៗ ដែលអាចមាន ប្រសិនបើចាំបាច់។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ការវាយតម្លៃហានិភ័យ ផ្អែកលើស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ត្រូវបានធ្វើឡើង។
- ☐ មានការសុំការយល់ព្រម ផ្អែកលើព័ត៌មានត្រឹមត្រូវពីជនរងគ្រោះ
- ☐ ការសម្រេចចិត្តពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះជាកុមារ បានផ្តល់អាទិភាពដល់តម្រូវការ និងឧត្តមប្រយោជន៍របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ ភាគីនានា បានសម្របសម្រួលជាមួយនឹងទីកន្លែងដែលជាប្រភពដើម និងសហគមន៍មូលដ្ឋាន ដើម្បីផ្តល់ការថែទាំជាប្រចាំដល់ជនរងគ្រោះ។
- ☐ មានការចាត់តាំងទីភ្នាក់ងារឱ្យការត្រួតពិនិត្យលើការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ។

## វិសាលភាព

លទ្ធផលនេះ ខិតខំធានាថា៖

- ច្បាប់ និងវិធានការនានា ត្រូវបានដាក់អនុវត្ត ដើម្បីធ្វើការវាយតម្លៃហានិភ័យឱ្យបានគ្រប់ជ្រុងជ្រោយ។ ការវាយតម្លៃហានិភ័យនេះ អាចមានការចូលរួមពីទីភ្នាក់ងារ ឬអង្គការសង្គមស៊ីវិលជាតិ ឬអន្តរជាតិដែលពាក់ព័ន្ធ។
- ការវាយតម្លៃគ្រប់ជ្រុងជ្រោយលើហានិភ័យ គួរធ្វើឡើងឱ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ក្រោយពេលកំណត់ដឹងពីជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង/ឬជនដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ រួមទាំងសមាជិកគ្រួសាររបស់ពួកគេផង គួរដឹងពីការវាយតម្លៃលើហានិភ័យ និងយល់ព្រមឱ្យគេវាយតម្លៃពីហានិភ័យរបស់ខ្លួន។
- ពុំមានរូបមន្តទូទៅ សម្រាប់វាយតម្លៃហានិភ័យពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឡើយ គេគួរពិចារណាលើករណីនីមួយៗ ទៅតាមស្ថានភាពជាក់ស្តែង ដ្បិតបុគ្គលម្នាក់ៗមានលក្ខណៈពិសេស និងអាចប្រឈមនឹងហានិភ័យខុសៗគ្នា ផ្អែកតាមបទពិសោធន៍កន្លងមករបស់អ្នក។
- អាយុ យេនឌ័រ និងតម្រូវការពិសេសរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេសកុមារ និងជនមានពិការភាព ត្រូវបានយកមកធ្វើការពិចារណា និងមានការអនុវត្តវិធានការ។
- មានការតែងតាំងទីភ្នាក់ងារណាមួយ ឱ្យធ្វើការត្រួតពិនិត្យលើការអនុវត្តការវាយតម្លៃហានិភ័យ ឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ការវាយតម្លៃលើហានិភ័យ ស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ធ្វើឡើងទៅតាមការអនុវត្តស្តង់ដារ។ | ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការធ្វើមាតុភូមិនិវត្តន៍ និង ការធ្វើសមាហរណកម្ម

២៣

## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ភាគីដែលទទួលខុសត្រូវ លើការធ្វើមាតុភូមិនិវត្តន៍ ទទួលជនរងគ្រោះ និង ទទួលខុសត្រូវលើកន្លែងឆ្លងកាត់របស់ជនរងគ្រោះ បានរៀបចំនូវនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់អនុវត្តរួមគ្នា។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៦.១.៥, ៦.២.៦។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៣.៤.៣។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៥៤, ៥៦។
- អនុសញ្ញា ACTIP មាត្រា ១៤(១១), ១៥(៥)។

## សេចក្តីអធិប្បាយ និងការពន្យល់

កិច្ចសហប្រតិបត្តិការ មានសារៈសំខាន់ និងចាំបាច់សម្រាប់ផ្តល់ការគាំទ្រ និង ការការពារដល់ជនរងគ្រោះ ដូចជា ការផ្តល់ជំនួយសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឯកជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ អនុសញ្ញា ACTIP បានចែងយ៉ាងជាក់ច្បាស់ ពីកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននានា នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ទាំងតួអង្គក្នុងប្រព័ន្ធយុត្តិធម៌ និងតួអង្គក្រៅប្រព័ន្ធយុត្តិធម៌ រួមទាំងអង្គការសង្គមស៊ីវិលផងដែរ គ្រប់បញ្ញត្តិដែលពាក់ព័ន្ធនឹងការការពារជនរងគ្រោះ និងការទប់ស្កាត់អំពើជួញដូរមនុស្ស។

អនុសញ្ញា ACTIP អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ាន ដាក់ចេញនូវនីតិវិធី និង យន្តការក្នុងចំណោមភាគី ដែលទទួលខុសត្រូវលើការធ្វើមាតុភូមិនិវត្តន៍ ការទទួល និងការឆ្លងកាត់របស់ជនរងគ្រោះ ដើម្បីធានា សុវត្ថិភាព សុខមាលភាព និងមានការផ្តល់ការថែទាំ និងការគាំទ្រជាប្រចាំដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

## វិសាលភាព

លទ្ធផលនេះ មានគោលបំណងធានាថាៈ

- នីតិវិធី និងយន្តការសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងរដ្ឋជាសមាជិកអាស៊ាន ត្រូវបានបង្កើតឡើង ដើម្បីធានាឱ្យមានការផ្តល់ជំនួយ និងការការពារជាបន្តឥតដាច់ដល់ជនរងគ្រោះនៃនៃអំពើជួញដូរមនុស្ស បង្កើនឱកាសឱ្យពួកគេអាចធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្ម ក៏ដូចជា តាមដានដំណើរការធ្វើមាតុភូមិនិវត្តន៍ និងលទ្ធផលសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- កម្មវិធីធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ត្រូវបានបង្កើតឡើង ជាមួយនឹងស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ដើម្បីជួយសម្រួលឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។
- ការបញ្ជាក់ផ្ទៀងផ្ទាត់លើសញ្ជាតិ ឬនិវាសនដ្ឋានអចិន្ត្រៃយ៍របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើឡើងស្របតាមការស្នើសុំរបស់ប្រទេសទទួល និងមានការផ្តល់ការអនុញ្ញាតឱ្យធ្វើដំណើរ សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលពុំមានឯកសារសម្គាល់ខ្លួន។

| បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម |
|---|
| ☐ នីតិវិធី និងយន្តការសហការរវាងរដ្ឋជាសមាជិកអាស៊ាន ត្រូវបានដាក់ឱ្យអនុវត្ត។ |
| ☐ កិច្ចសហប្រតិបត្តិការ និងនីតិវិធីស្តង់ដារត្រូវបានអនុវត្តដោយរដ្ឋជាសមាជិកអាស៊ាន។ |

| លទ្ធផលរយៈពេលមធ្យម ( ២ ទៅ ៥ ឆ្នាំ ) | លទ្ធផលរយៈពេលវែង ( ចាប់ពី ៥ ឆ្នាំឡើងទៅ ) |
|---|---|
| នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ធ្វើមាតុភូមិនិវត្តន៍ ទទួល និងការឆ្លងកាត់របស់ជនរងគ្រោះត្រូវបានអនុវត្ត និងកែលម្អជាប់ជាប្រចាំ។ | នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ធ្វើមាតុភូមិនិវត្តន៍ ទទួល និងការឆ្លងកាត់របស់ជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការធ្វើមាតុភូមិនិវត្តន៍ និង ការធ្វើសមាហរណកម្ម

២៤

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ទីកន្លែងដែលជាប្រភពដើម និងគោលដៅ ផ្តល់ការគាំទ្រ ដើម្បីឱ្យតែជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មប្រកបដោយនិរន្តរភាព។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៦.២.៧, ៦.២.៨, ៦.៣.៩, ៦.៣.១១។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្សដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក៣.៧.១, ៣.៧.៣។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៥៤, ៥៦, ៥៩, ៦៤។
- អនុសញ្ញា ACTIP មាត្រា ១៤(១០)-(១២), ១៥(៥), ១៥(៦)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព AEC ២៥។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ អ្នកគ្រប់គ្រងករណី ឬភ្នាក់ងារសង្គម ត្រូវបានតែងតាំងឱ្យផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ មានការផ្តល់ជំនួយជាច្រើនដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលបានធ្វើមាតុភូមិនិវត្តន៍ ដោយពុំមានភ្ជាប់លក្ខខណ្ឌតម្រូវថាជនរងគ្រោះត្រូវតែសហការចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ។
- ☐ សេវានានាត្រូវបានរៀបចំឡើងស្របតាមតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ☐ រដ្ឋជាសមាជិកអាស៊ានពិនិត្យតាមដាន និងវាយតម្លៃលើផលជះនៃការគាំទ្រដែលត្រូវបានផ្តល់ឱ្យ។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវការជំនួយ ក្នុងរយៈពេលវែង ដើម្បីឱ្យការវិលត្រឡប់ និងសមាហរណកម្មរបស់ពួកគេមានប្រសិទ្ធភាព។ គោលដៅសំខាន់នៃការធ្វើសមាហរណកម្ម គឺដើម្បីជួយឱ្យជនរងគ្រោះ អាចត្រឡប់ចូលទៅរស់នៅក្នុងសង្គមជាធម្មតា ប្រកបដោយសុវត្ថិភាព សេចក្តីថ្លៃថ្នូរ ជានិរន្តរ។

ជំនួយសម្រាប់ការធ្វើសមារណកម្ម អាចមានដូចជា សេវាថែទាំសុខភាព (រាប់បញ្ចូលទាំងការផ្តល់ប្រឹក្សា) ជំនួយហិរញ្ញវត្ថុ ការផ្តល់កម្ចីជាឥណទានខ្នាតតូច សេវាជំនួយផ្លូវច្បាប់ ការទទួលបានការអប់រំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ សេវាស្វែងរកការងារ លំនៅដ្ឋាន និងកន្លែងស្នាក់នៅជាដើម។

ទីកន្លែងដែលជាប្រភពដើម ត្រូវជួយសម្រួលដល់ការធ្វើសមាហរណកម្ម តាមរយៈការសហការឱ្យបានជិតស្និទ្ធ និងទាន់ពេលវេលាជាមួយប្រទេសគោលដៅ ដើម្បីជួយសម្រួលដល់ការធ្វើសមារណកម្មប្រកបដោយនិរន្តរភាព ការគាំទ្រ និងការតាមដានឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ ដើម្បីទប់ស្កាត់ការជួញដូរពួកគេជាថ្មី។ ការគាំទ្រដល់ការធ្វើសមារណកម្មភាគច្រើន ត្រូវបានផ្តល់ដោយ ទីភ្នាក់ងារទទួលជនរងគ្រោះនៅក្នុងប្រទេសប្រភពដើម ដោយសកម្មភាពជាច្រើនទំនងជានឹងត្រូវអនុវត្ត និងចាត់ចែងនៅទីកន្លែងដែលជនរងគ្រោះរស់នៅ។

អ្វីដែលសំខាន់ គឺទីភ្នាក់ងារទទួលជនរងគ្រោះនៅក្នុងប្រទេសប្រភពដើម ត្រូវជួយឱ្យជនរងគ្រោះក្នុងការកំណត់គោលដៅ ដែលមានលក្ខណៈប្រាកដនិយម មិនត្រឹមតែសមស្របទៅតាមតម្រូវការ ជំនាញ និងគុណវុឌ្ឍិផ្ទាល់របស់ជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងត្រូវស្របទៅតាមឱកាសដែលមាននៅក្នុងប្រទេស ក្នុងមូលដ្ឋាន និងនៅកន្លែងរស់នៅ ដែលការធ្វើសមារណកម្ម ត្រូវបានធ្វើឡើង ស្របតាមលទ្ធផលនៃការវាយតម្លៃលើសមាហរណកម្ម។ លើសពីនេះ ផែនការសមាហរណកម្ម ត្រូវធ្វើឡើងផ្អែកតាមសេវា ដែលអង្គការផ្តល់សេវា និង/ឬដៃគូ និងកម្មវិធីដែលខ្លួនកំពុងអនុវត្តនៅក្នុងប្រទេសប្រភពដើម អាចផ្តល់ឱ្យបាន។ នេះជាចំណុចដែលគេអាចគួរធ្វើការពិចារណា នៅក្នុងអំឡុងពេលការវាយតម្លៃលើសមាហរណកម្ម។

ប្រទេសបញ្ជូន ឬកន្លែងគោលដៅ ត្រូវធ្វើការវាយតម្លៃលើតម្រូវការ និងការចង់បានរបស់ជនរងគ្រោះម្នាក់ៗ និងបញ្ជូនលទ្ធផលនៃការវាយតម្លៃទៅកាន់ទីភ្នាក់ងារក្នុងប្រទេសទទួល តាមរយៈការជូនដំណឹងមុនពេលធ្វើដំណើរ ឬនៅពេលវិលត្រឡប់មកវិញ។

## វិសាលភាព

លទ្ធផលនេះ លើកស្ទើថា កន្លែងប្រភពដើម ត្រូវ៖

- ចាត់តាំងឱ្យមានអ្នកគ្រប់គ្រងករណី ឬភ្នាក់ងារសង្គមកិច្ច ដើម្បីជួយដល់ជនរងគ្រោះក្នុងការធ្វើសមាហរណកម្ម ទទួលបានសេវា ការងារ និងបណ្តាញសង្គមនានា។
- ឆ្លើយតបចំពោះតម្រូវការរបស់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាព។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ត្រូវបានផ្តល់ឱ្យនូវឱកាសទទួលបានជំនាញវិជ្ជាជីវៈ ដូចជា អក្ខរកម្ម ចំណេះដឹងអំពីប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា ចំណេះដឹងហិរញ្ញវត្ថុ ការសង្គ្រោះបឋម សុខភាព និងសុវត្ថិភាព និងការធ្វើផែនការគ្រួសារ ស្របតាមតម្រូវការ និងផលប្រយោជន៍របស់ពួកគេ។
- ការគាំទ្រនេះ មិនភ្ជាប់លក្ខខណ្ឌតម្រូវ ថាជនរងគ្រោះត្រូវតែសហការ ការដែលបានចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌនោះឡើយ។
- ផ្តល់សេវាគាំទ្រនានា ដែលឆ្លើយតបទៅនឹងស្ថានភាពរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ ដោយគោរពតាមគោលការណ៍សិទ្ធិកុមារ និងពិធីសារដែលត្រូវអនុវត្តចំពោះកុមារ។
- ជនមានពិការភាព ត្រូវបានផ្តល់ឱកាសប្រកបដោយសមធម៌ ក្នុងការទទួលបានការងារ សហគ្រិនភាព និងសមាហរណកម្មសេដ្ឋកិច្ច។
- តាមដានវឌ្ឍនភាពរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលត្រូវបានធ្វើសមារណកម្ម ជាមួយនឹងយន្តការវាយតម្លៃលើហេតុផលជះនៃការគាំទ្រ ដែលត្រូវបានផ្តល់ដល់ជនរងគ្រោះ។

លទ្ធផលនេះ លើកស្ទើថាកន្លែងគោលដៅ ត្រូវ៖

- ធានាថាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្ម័គ្រចិត្តធ្វើមាតុភូមិនិវត្តន៍ និងផ្តល់ការយល់ព្រម ផ្អែកតាមព័ត៌មានត្រឹមត្រូវ ឬផ្តល់ការយល់ព្រមពីអនីតិជន សម្រាប់ជនដែលមានអាយុក្រោម ១៨ ឆ្នាំ។
- ដំណើរការធ្វើសមាហរណកម្ម ត្រូវបានរៀបចំឡើងស្របតាមស្ថានភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្សម្នាក់ៗ និងត្រូវបានអនុវត្តសមស្របតាមយេនឌ័រ តាមអាយុ និងវប្បធម៌របស់ពួកគេ។
- ធានាថាជនរងគ្រោះនៃអំពើជួញដូរមនុស្ស មិនថាពួកគេជាពលរដ្ឋ ឬមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ បានទទួលជំនួយទាន់ពេលវេលា ដើម្បីឱ្យពួកគេអាចវិលត្រឡប់ទៅទីកន្លែង ដែលជាប្រភពដើមរបស់ពួកគេវិញ។
- រៀបចំឱ្យមានភ្នាក់ងារសង្គមកិច្ច ឬអ្នកផ្តល់ការគាំទ្រណាម្នាក់ អមដំណើរជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីធានាសុវត្ថិភាព និងជួយជនរងគ្រោះ ក្នុងការបំពេញបំណងប្រាថ្នារបស់ពួកគេ ដោយធ្វើការពិចារណាពីហានិភ័យដែលអាចកើតមាននៅក្នុងសហគមន៍របស់ពួកគេ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មក្នុងរយៈពេលវែងរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានធនធានដែលគាំទ្រគ្រប់គ្រាន់។ | ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP នៅទូទាំងរដ្ឋសមាជិកអាស៊ានទាំងអស់។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |



# ឧទាហរណ៍ ដែលបង្ហាញពីការអនុវត្តល្អ ពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម

**ការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស នៅក្នុងប្រទេសថៃ**

ច្បាប់ប្រឆាំងអំពើជួញដូរមនុស្សរបស់ប្រទេសថៃ ចែងថា ត្រូវមានការប្រតិបត្តិចំពោះជនរងគ្រោះដោយផ្តល់ឱ្យពួកគេនូវសេចក្តីថ្លៃថ្នូរ ដែលក្នុងនោះមានការពិចារណាលើភេទ អាយុ សញ្ជាតិ ជាតិសាសន៍ និងវប្បធម៌របស់ពួកគេ ព្រមទាំងទស្សនៈយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេ។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលជំនួយផ្សេងៗ ដូចជា ស្បៀងអាហារ ជម្រកសុវត្ថិភាព ការព្យាបាលសុខភាព ការស្តារលទ្ធភាពពលកម្ម និងផ្លូវចិត្ត ការអប់រំ ការបណ្តុះបណ្តាល ជំនួយផ្លូវច្បាប់ និងការឱ្យវិលត្រឡប់ទៅកាន់ទីកន្លែងដែលជាប្រភពដើមរបស់ពួកគេវិញ។ ជនរងគ្រោះបានទទួលការគាំទ្រ ក្នុងការអនុវត្តនីតិវិធីច្បាប់ ដើម្បីទាមទារសំណងនានា។

# ការថែទាំវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត ២៥

## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលព័ត៌មានអំពីសេវាសុខភាព ជាភាសា និងក្នុងទម្រង់ ដែលពួកគេអាចយល់បាន។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ២.២.៤, ២.២.៥។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ២.៤.១, ៣.១.២, ២.៦.១, ៣.១.១។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៧៣
- អនុសញ្ញា ACTIP មាត្រា ១៤( ៥ ), ( ១០ )។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានសិទ្ធិទទួលបានសេវាថែទាំសុខភាព។ ការធ្លាប់ត្រូវបានគេជួញដូរ អាចបង្កផលប៉ះពាល់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ ក្នុងរយៈពេលខ្លី និងរយៈពេលវែង។ ស្របតាមមាត្រា ១៤( ១០ ) នៃអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ានមានកាតព្វកិច្ច បន្តរៀបចំឱ្យមានការថែទាំ ការការពារ និងការគាំទ្រឱ្យបានសមស្រប ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយមានការទទួលស្គាល់ និងឆ្លើយតបចំពោះតម្រូវការសេវាថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ ដែលមានលក្ខណៈចម្រុះ និងភាពស្មុគស្មាញខុសៗគ្នា។ ការជួញដូរមនុស្ស បង្កផលប៉ះពាល់ជាច្រើនប្រភេទផ្សេងៗគ្នា លើសុខភាពរបស់បុគ្គល (ផ្លូវកាយ ផ្លូវចិត្ត និងសង្គម) ដូច្នេះ ការស្តារជនរងគ្រោះឡើងវិញ ត្រូវប្រើប្រាស់អភិក្រមផ្តល់សេវាពហុជំនាញ។[៤៨]

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ឯកសារព័ត៌មានដែលពុំមានភ្ជាប់លក្ខខណ្ឌ ត្រូវបានផ្តល់ក្នុងទម្រង់ និងក្នុងប្រភេទណាផ្សេងៗគ្នា។
- ☐ មានការគោរពសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការទទួលយក ឬបដិសេធមិនទទួលយកជំនួយ។
- ☐ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដោយមានការថតសំឡេងទុក ហើយជនរងគ្រោះអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីកុមារ សម្រាប់ជនរងគ្រោះអាយុក្រោម ១៨ ឆ្នាំ និងមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ដើម្បីឱ្យពួកគេអាចទទួលបានសេវាសុខភាព។
- ☐ ផែនការផ្តល់ការព្យាបាលដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ ជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស បុគ្គលិកផ្នែកវេជ្ជសាស្ត្រ គ្រួសារ និង/ឬអ្នកពាក់ព័ន្ធដទៃទៀត។
- ☐ ឯកសារនានាត្រូវបានដកចេញនូវព័ត៌មានដែលអាចឱ្យគេសម្គាល់ដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះ។

## វិសាលភាព

លទ្ធផលនេះពាក់ព័ន្ធនឹងការរៀបចំព័ត៌មានឱ្យងាយស្រួលយល់ សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្សដើម្បីធានាថា៖

- ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ បានទទួលព័ត៌មាន និងទទួលសេវាសុខភាព ដោយមិនភ្ជាប់លក្ខខណ្ឌតម្រូវថា ពួកគេត្រូវចូលរួមសហការជាមួយអាជ្ញាធរ ឬក្នុងនីតិវិធីព្រហ្មទណ្ឌឡើយ។
- ព័ត៌មាននានាត្រូវបានផ្តល់ក្នុងទម្រង់ និងប្រភេទដែលជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចប្រើប្រាស់ និងយល់បាន និងត្រូវផ្តល់អ្នកបកប្រែក៏ដូចជា ភាសាសញ្ញា ទៅតាមតម្រូវការជាក់ស្តែង។
- មន្ត្រីផ្នែកវេជ្ជសាស្ត្រ និងអ្នកបកប្រែ បានទទួលការបំពាក់បំប៉ននូវចំណេះដឹង និងជំនាញ ដើម្បីពួកគេមានសមត្ថភាពធ្វើការងារជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានសិទ្ធិទទួលយក ឬ បដិសេធ មិនទទួលជំនួយ និងត្រូវមានការគោរព ការសម្រេចចិត្តរបស់ពួកគេ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដោយមានការថតសំឡេងទុក ឬផ្តល់ការយល់ព្រមពីអនីតិជន សម្រាប់ជនរងគ្រោះអាយុក្រោម ១៨ ឆ្នាំ រួមនឹងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។

៤៨ United Nations Protocol to Prevent, Suppress and Punish Traffcking in Persons Especially Women and Children ( The TIP Protocol ), 2000.

## វិសាលភាព

- មានការអនុវត្តអភិក្រមបែបកុមារមេត្រី ដើម្បីធានាឱ្យមានការរៀបចំ និងការសម្រេចចិត្តអំពីផែនការផ្តល់ការព្យាបាលដល់កុមារ ដោយមានការពិគ្រោះយោបល់ជាមួយឪពុកម្តាយ អ្នកផ្តល់ការថែទាំ ឬអាណាព្យាបាល និងកុមារស្របតាមអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់ពួកគេ។
- ផែនការព្យាបាលស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ត្រូវបានរៀបចំឡើង ដោយបុគ្គលិកផ្នែកវេជ្ជសាស្ត្រ ដោយមានការពិគ្រោះយោបល់ជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីជួយឱ្យពួកគេអាចទទួលបានសេវាសុខភាពបែបឯកទេស និងមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តផែនការផ្តល់ការព្យាបាលទាំងនេះ។
- ឯកសារនានា ត្រូវបានដកចេញនូវព័ត៌មានដែលអាចសម្គាល់ដឹងពីអត្តសញ្ញាណ និងមានការរៀបចំនូវគោលការណ៍ណែនាំច្បាស់ លាស់ ដើម្បីបង្ការការលេចធ្លាយព័ត៌មានអំពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងព័ត៌មានឯកជនដទៃទៀត ដែលអាចធ្វើឱ្យគេដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស គ្រួសារ ឬសាក្សី។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ក្រុមជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ បានទទួលសេវាព័ត៌មាន និងប្រើប្រាស់សេវាសុខភាពជាប្រចាំទៅតាមតម្រូវការរបស់ពួកគេ។ | សេវាវេជ្ជសាស្ត្រ និងសេវាថែទាំសុខភាពផ្លូវចិត្ត ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានដឹកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានដឹក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានដឹក |

# ការថែទាំវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត ២៦

## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទទួលបានសេវាថែទាំ និងព្យាបាលពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ និងថែទាំសុខភាព។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៦៨, ៧២, ៧៣។
- អនុសញ្ញា ACTIP មាត្រា ១៤(១០)(គ)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ញាបសិទ្ធិជនមានពិការភាព AEC ១៧, ASCC ៦។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវទទួលបានសេវាថែទាំសុខភាព ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សមស្រប និងមាននិរន្តរភាព ផ្តោតលើការជួយឱ្យជនរងគ្រោះ អាចទទួលបានសុខមាលភាពផ្លូវកាយ ផ្លូវចិត្ត និងសង្គម។ គួរមានការយកចិត្តទុកដាក់ជាពិសេស លើតម្រូវការសុខភាព និងតម្រូវការសុខភាពផ្លូវចិត្តរបស់កុមារ និងក្មេងជំទង់ ដែលត្រូវបានជួញដូរ។ គួរមានការផ្តល់ថែទាំសុខភាពនៅកន្លែងឯកជន ដែលផ្តល់ភាពកក់ក្តៅដល់ជនរងគ្រោះ ពីអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាល ដោយមានការផ្អែកលើព័ត៌មានត្រឹមត្រូវពីជនរងគ្រោះ។

ការអនុវត្តអន្តរាគមន៍នៅដំណាក់កាលផ្សេងៗគ្នា ត្រូវមានការចាត់អាទិភាពផ្សេងៗគ្នាដែរ ពាក់ព័ន្ធនឹងការផ្តល់សេវាថែទាំសុខភាពដល់ជនរងគ្រោះ នៅក្នុងដំណាក់កាលសង្គ្រោះជនរងគ្រោះដំបូងជាពេលដែលជនរងគ្រោះជួបនឹងអ្នកជំនាញផ្តល់សេវាសុខភាព ការផ្តល់ការថែទាំនៅពេលនោះ គួរផ្តោតលើការព្យាបាលស្នាមរបួស និងការប៉ះទង្គិចផ្លូវចិត្ត តាមរយៈការអនុវត្តអន្តរាគមន៍ឆ្លើយតបចំពោះវិបត្តិ និងការផ្តល់សេវាថែទាំសុខភាពកម្រិតមូលដ្ឋាន (រួមទាំងការផ្តល់ប្រឹក្សា)។ នៅដំណាក់កាលស្តារនីតិសម្បទា ការផ្តល់ការថែទាំត្រូវផ្តោតលើតម្រូវការសុខភាពក្នុងរយៈពេលវែង និងការធ្វើសមាហរណកម្មជនរងគ្រោះ។ ជនរងគ្រោះគួរទទួលបានសេវាថែទាំសុខភាព ស្របតាមតម្រូវការ និងកាលៈទេសៈរបស់ពួកគេម្នាក់ៗ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ វេជ្ជជាសមាជិកអាស៊ាន ផ្តល់សេវាវេជ្ជសាស្ត្រ និងជំនួយនានាដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់។
- ☐ ផែនការផ្តល់ការព្យាបាលត្រូវបានរៀបចំឡើង ជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្របតាមស្ថានភាពរបស់ពួកគេ។
- ☐ អ្នកជំនាញនិងបុគ្គលិកផ្នែកវេជ្ជសាស្ត្របានទទួលការបណ្តុះបណ្តាល និងការចែករំលែកបទពិសោធ ដើម្បីអាចផ្តល់សេវាថែទាំវេជ្ជសាស្ត្រ ផ្តោតលើជនរងគ្រោះ និងដែលមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ និងដោយពុំមានការមាក់ងាយ។
- ☐ កិច្ចពិគ្រោះយោបល់ និងការពិនិត្យជំងឺ ធ្វើឡើងនៅទីកន្លែងឯកជនដែលផ្តល់នូវភាពកក់ក្តៅដល់ជនរងគ្រោះ។
- ☐ អ្នកបកប្រែដែលបានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាពផ្តល់ព័ត៌មានច្បាស់លាស់អំពីដំណើរការ និងការរំពឹងទុកនានា។
- ☐ មានការសុំការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ដោយមានការថតសំឡេងទុក ឬការផ្តល់ការយល់ព្រមពីជនអាយុក្រោម ១៨ ឆ្នាំ ឬការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ សម្រាប់ការពិនិត្យកាយសម្បទា និងការអនុវត្តនីតិវិធីនានា។
- ☐ ការធ្វើតេស្តមេរោគអេដស៍និងជំងឺកាមរោគព្រមទាំងត្រូវបានផ្តល់ជូនជនរងគ្រោះទាំងអស់ ប្រសិនបើចាំបាច់។
- ☐ ការពិនិត្យផ្ទៃពោះ ការពន្យារកំណើតបន្ទាន់ សេវាព្យាបាល និងការផ្តល់ប្រឹក្សា សមស្របមានផ្តល់ជូនដល់ជនរងគ្រោះប្រសិនបើចាំបាច់។
- ☐ នៅពេលដែលជនរងគ្រោះនៃអំពើជួញដូរមនុស្ស វិលត្រឡប់ទៅទីកន្លែងដែលជាប្រភពដើមរបស់ពួកគេវិញ មានការបញ្ជូនឯកសារវេជ្ជសាស្ត្រ ដោយមានការយល់ព្រមពីជនរងគ្រោះ ដើម្បីរៀបចំឱ្យមានការផ្តល់សេវាថែទាំសុខភាពជាបន្តដល់ជនរងគ្រោះ។
- ☐ ទិន្នន័យវេជ្ជសាស្ត្រត្រូវបានចែករំលែក ជាមួយនឹងការធានាឱ្យមានការរក្សាការសម្ងាត់ និងការការពារព័ត៌មានក្នុងកម្រិតអតិបរមា។
- ☐ ឯកសារភស្តុតាងនានា ត្រូវបានផ្តល់ទៅតាមសំណើរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬតំណាងស្របច្បាប់របស់ពួកគេ។
- ☐ ពុំមានការបដិសេធមិនផ្តល់សេវាថែទាំសុខភាព ដោយសារតែការមាក់ងាយ ថវិកា ឬធនធានមានកម្រិតនៅឡើយ។
- ☐ ស្តង់ដារអប្បបរមាស្តីពីការការផ្តល់សេវាថែទាំវេជ្ជសាស្ត្រជូនដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានដាក់ឱ្យអនុវត្ត។

## វិសាលភាព

លទ្ធផលនេះ ធានាថា សេវាវេជ្ជសាស្ត្រ៖

- ផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ នៅសេវាថែទាំវេជ្ជសាស្ត្រ ដែលពុំមានភ្ជាប់លក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះ ត្រូវសហការជាមួយអាជ្ញាធរ ឬចូលរួមក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌឡើយ។
- រៀបចំផែនការផ្តល់ការព្យាបាលដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយពិចារណាពីយេនឌ័រ ជំនឿសាសនា ទម្លាប់វប្បធម៌ អាយុ និងសុវត្ថិភាពរបស់ពួកគេ។
- គោរពសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការទទួលយក ឬបដិសេធមិនទទួលយកជំនួយនានា។ ជនរងគ្រោះអាចដកខ្លួន ឬវិលត្រឡប់ទៅវិញនៅពេលណាក៏បាន។
- ផ្តល់អ្នកជំនាញ និងបុគ្គលិក ដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធ ក្នុងការផ្តល់ការថែទាំវេជ្ជសាស្ត្រ ផ្តោតលើជនរងគ្រោះ ដោយមានការយកចិត្តទុកដាក់ពីយេនឌ័រ ដោយពុំមានការមាក់ងាយ។
- រៀបចំការពិគ្រោះយោបល់ និងការពិនិត្យនៅទីកន្លែងដែលអាចរក្សាបាននូវឯកជនភាព និងផ្តល់ភាពកក់ក្តៅ ដោយមានផ្តល់អ្នកបកប្រែដែលបានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាព ប្រសិនបើចាំបាច់ ដើម្បីធានាឱ្យមានការផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ អំពីដំណើរការ និងនីតិវិធីនានា។
- សុំការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានការថតទុកពីជនរងគ្រោះ ឬការយល់ព្រមពី អនីតិជន ពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ ដើម្បីឱ្យជនរងគ្រោះអាចទទួលបានការពិនិត្យកាយសម្បទា និងការអនុវត្តនីតិវិធីនានា ដោយគោរពសិទ្ធិរបស់ជនរងគ្រោះ ក្នុងការបដិសេធមិនទទួលយកសេវាទាំងនេះ។
- ផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស រាប់បញ្ចូលទាំងជនមានពិការភាព នូវសារព័ត៌មានងាយស្រួលយល់ ផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ដែលលើកទឹកចិត្តឱ្យមានការធ្វើតេស្តមេរោគអេដស៍ និងជំងឺកាមរោគ ក៏ដូចជា ផ្តល់នូវការព្យាបាលវេជ្ជសាស្ត្រឱ្យបានសមស្រប ប្រសិនបើជនរងគ្រោះត្រូវការ។
- បានផ្តល់ឱ្យស្ត្រី និងក្មេងស្រី រាប់បញ្ចូលទាំងជនមានពិការភាពនៅសេវាពិនិត្យផ្ទៃពោះ ពន្យារកំណើតបន្ទាន់ សេវាព្យាបាល និងសេវាផ្តល់ប្រឹក្សាទៅតាមការចាំបាច់។
- ផ្ទេរឯកសារវេជ្ជសាស្ត្ររបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទៅកាន់ទីកន្លែងដែលជាប្រភពដើម ដោយសុំការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានការថតទុកពីជនរងគ្រោះ ឬការយល់ព្រមពីអនីតិជន ពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ ការធ្វើបែបនេះ គឺដើម្បីធានាឱ្យជនរងគ្រោះនៅតែបន្តទទួលបានសេវាថែទាំវេជ្ជសាស្ត្រ ប្រសិនបើចាំបាច់។
- ចែករំលែកទិន្នន័យវេជ្ជសាស្ត្រ តែនៅក្នុងករណីដែលមានការធានាថាមានការរក្សាការសម្ងាត់ និងការការពារព័ត៌មានក្នុងកម្រិតអតិបរមា និងមានការយល់ព្រមពីជនរងគ្រោះនៃអំពើជួញដូរមនុស្សតែប៉ុណ្ណោះ។
- ផ្តល់ឯកសារបញ្ជាក់ភ័ស្តុតាង (ការពិនិត្យកាយសម្បទា និងការពិនិត្យសុខភាពផ្លូវចិត្ត សម្រាប់គោលបំណងផ្លូវច្បាប់) ទៅតាមការស្នើសុំរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងអំឡុងពេលអនុវត្តដំណើរការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- សម្របសម្រួលជាមួយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីធានាថាពុំមានដីកាបដិសេធ មិនផ្តល់សេវាថែទាំសុខភាព ដោយសារតែថវិកា និងធនធានមានកំណត់នោះឡើយ។

## វិសាលភាព

លទ្ធផលនេះតម្រូវឱ្យរដ្ឋាភិបាល៖

- ដាក់ចេញនូវស្តង់ដារអប្បបរមា សម្រាប់ផ្តល់សេវាថែទាំវេជ្ជសាស្ត្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ស្តង់ដារនានា គួររៀបចំឡើងដោយមានការសហការជាមួយរដ្ឋាភិបាល ស្ថាប័នក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវនានា និងគួរធ្វើឡើងផ្អែកលើលទ្ធផលនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងការអនុវត្តល្អ។
- បង្កើនកិច្ចសហប្រតិបត្តិការ ក្នុងចំណោមស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងការសហការរវាងប្រទេសមួយ និងប្រទេសមួយទៀត តាមរយៈការសម្របសម្រួល និងការធ្វើសមាហរណកម្មសេវាថែទាំវេជ្ជសាស្ត្រ ដែលផ្តល់នៅក្នុងប្រទេសគោលដៅ ប្រទេសដែលជាប្រភពដើម និងប្រទេសឆ្លងកាត់។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ បានទទួលព័ត៌មាន និងសេវាសុខភាពជាប្រចាំ ទៅតាមតម្រូវការជាក់ស្តែងរបស់ពួកគេ។ | សេវាថែទាំវេជ្ជសាស្ត្រ និងសេវាថែទាំសុខភាពផ្លូវចិត្ត ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្រុមឧបត្ថម្ភ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ការថែទាំវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត ២៧

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទទួលបានសេវាថែទាំ និងព្យាបាលសុខភាពផ្លូវចិត្ត។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៦៩, ៧២, ៧៣។
- អនុសញ្ញា ACTIP មាត្រា ១៤(១០)(គ)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព AEC ១៧, ASCC ៦។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានតម្រូវការសុខភាពផ្លូវចិត្តស្មុគស្មាញផ្សេងៗគ្នា។ ដូច្នេះ ជនរងគ្រោះ គួរអាចទទួលបានសេវាថែទាំសុខភាពផ្លូវចិត្តនានា ឱ្យបានទាន់ពេលវេលា ដោយមានការយកចិត្តទុកដាក់ចំពោះស្ថានភាពវប្បធម៌ និងផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ស្របតាមតម្រូវការជាក់ស្តែងរបស់ពួកគេ។ គួរមានការយកចិត្តទុកដាក់ ជាពិសេសចំពោះតម្រូវការសុខភាពផ្លូវចិត្តរបស់កុមារ និងក្មេងជំទង់។

ចាំបាច់ត្រូវមានការយល់ព្រមពីជនរងគ្រោះ និងការយល់ព្រមពីអនីតិជន ពីកុមារ និងការយល់ព្រមពីឪពុកម្តាយ/អាណាព្យាបាលរបស់ពួកគេ សម្រាប់គ្រប់អន្តរាគមន៍សុខភាពផ្លូវចិត្តទាំងអស់។

## វិសាលភាព

លទ្ធផលនេះ ធានាថាសេវាសុខភាពផ្លូវចិត្ត៖

- ផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ នូវសេវាថែទាំសុខភាពផ្លូវចិត្ត ដោយពុំមានភ្ជាប់លក្ខខណ្ឌ ថាពួកគេត្រូវតែចូលរួមសហការជាមួយអាជ្ញាធរ ឬក្នុងនីតិវិធីព្រហ្មទណ្ឌនោះឡើយ។
- គោរពសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការទទួលយក ឬបដិសេធមិនទទួលយកជំនួយនានា។ ជនរងគ្រោះអាចដកខ្លួនចេញ ឬត្រឡប់មកវិញនៅពេលណាក៏បាន។
- រៀបចំផែនការផ្តល់ការព្យាបាលដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយធ្វើការពិចារណាពីយេនឌ័រ ជំនឿសាសនា ការអនុវត្តវប្បធម៌ អាយុ និងសមត្ថភាពរបស់ពួកគេ។
- ផ្តល់អ្នកជំនាញខាងវិកលវិទ្យា និង/ឬអ្នកជំនាញខាងសុខភាពផ្លូវចិត្ត ដែលបានទទួលការបណ្តុះបណ្តាល ហើយអ្នកផ្តល់សេវាថែទាំសុខភាពផ្លូវចិត្ត បានទទួលការបណ្តុះបណ្តាលអំពីរបៀបផ្តល់សេវាថែទាំសុខភាពផ្លូវចិត្ត ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ ដោយពុំមានការមាក់ងាយ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ភាគីនានា ផ្តល់សេវា និងជំនួយសុខភាពផ្លូវចិត្តដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់។
- ☐ មានការគោរពសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការទទួលយក ឬបដិសេធមិនទទួលយកជំនួយនានា។
- ☐ ផែនការផ្តល់ការព្យាបាល ត្រូវបានរៀបចំឡើង រួមជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្របតាមស្ថានភាពជាក់ស្តែងរបស់ពួកគេ។
- ☐ អ្នកជំនាញខាងសុខភាពផ្លូវចិត្ត បានទទួលការបណ្តុះបណ្តាល ក្នុងការផ្តល់សេវាថែទាំសុខាភាពផ្លូវចិត្ត ដែលមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ និងផ្តោតលើជនរងគ្រោះដោយពុំមានការមាក់ងាយ។
- ☐ សុំការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានការថតទុកពីជនរងគ្រោះ ឬការយល់ព្រមពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ សម្រាប់ការពិនិត្យលើស្ថានភាពផ្លូវចិត្តរបស់ជនរងគ្រោះ។
- ☐ ការពិគ្រោះយោបល់ និងការផ្តល់ប្រឹក្សា ធ្វើឡើងនៅទីកន្លែងដែលអាចរក្សាបាននូវឯកជនភាព និងផ្តល់ភាពកក់ក្តៅដល់ជនរងគ្រោះ ឬធ្វើ "នៅក្នុងទីតាំងផ្ទាល់" របស់អ្នកផ្តល់សេវា។
- ☐ អ្នកបកប្រែដែលបានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាព ផ្តល់ព័ត៌មានច្បាស់លាស់ អំពីដំណើរការ និងការរំពឹងទុកនានា។
- ☐ ពុំមានការបដិសេធមិនផ្តល់សេវាថែទាំសុខភាពផ្លូវចិត្ត ដោយសារតែការមាក់ងាយ ថវិកា ឬធនធានមានកំណត់នោះឡើយ។
- ☐ មានការចែករំលែកទិន្នន័យវេជ្ជសាស្ត្រ ដោយមានការធានាថា មានការរក្សាការសម្ងាត់ និងការការពារព័ត៌មានក្នុងកម្រិតអតិបរមា។
- ☐ ឯកសារបញ្ជាក់ពីភ័ស្តុតាងត្រូវបានផ្តល់ជូនស្របតាមការស្នើសុំរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬតំណាងស្របច្បាប់របស់ពួកគេ។
- ☐ ស្តង់ដារអប្បបរមាសម្រាប់សេវាថែទាំសុខភាពផ្លូវចិត្ត ដែលត្រូវផ្តល់ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានដាក់អនុវត្ត។

### វិសាលភាព

- រៀបចំការពិគ្រោះយោបល់ និងការផ្តល់ប្រឹក្សានៅទីកន្លែងដែលគេអាចរក្សាបាននូវឯកជនភាព និងផ្តល់ភាពកក់ក្តៅដល់ជនរងគ្រោះ រួមទាំងនៅក្នុងទីតាំងផ្ទាល់របស់អ្នកផ្តល់សេវាផងដែរ ប្រសិនបើសមស្រប នឹងត្រូវមានអ្នកបកប្រែដែលបានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាព ប្រសិនបើចាំបាច់ ដើម្បីធានាឱ្យមានការផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ អំពីដំណើរការ និងការរំពឹងទុកនានា។
- សុំការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានការថតទុកពីជនរងគ្រោះ ឬការយល់ព្រមពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ សម្រាប់ការអនុវត្តនីតិវិធីពិនិត្យលើស្ថានភាពសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ ដោយត្រូវគោរពដល់សិទ្ធិឯកជនរងគ្រោះ ក្នុងការបដិសេធមិនឱ្យគេអនុវត្តនីតិវិធីបែបនេះចំពោះខ្លួន។
- ចែករំលែកទិន្នន័យវេជ្ជសាស្ត្រតែនៅពេលដែលមានការធានាថា មានការរក្សាការសម្ងាត់ និងការការពារព័ត៌មាន ជូនជនរងគ្រោះក្នុងកម្រិតអតិបរមា និងត្រូវមានការយល់ព្រមពីជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ផ្តល់ឯកសារភស្តុតាង (ការពិនិត្យកាយសម្បទា និងការពិនិត្យស្ថានភាពសុខភាពផ្លូវចិត្ត សម្រាប់គោលបំណងផ្លូវច្បាប់) ទៅតាមការស្នើសុំរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬតំណាងស្របច្បាប់របស់ពួកគេ ក្នុងអំឡុងពេលអនុវត្តដំណើរការយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- សម្របសម្រួលជាមួយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីធានាថា ពុំមានការបដិសេធមិនផ្តល់សេវាថែទាំសុខភាពផ្លូវចិត្ត ដោយសារតែថវិកា ឬធនធានមានកម្រិតនោះឡើយ។

លទ្ធផលនេះ តម្រូវឱ្យរដ្ឋាភិបាល៖

- រៀបចំស្តង់ដារអប្បបរមាស្តីពីសេវាថែទាំវេជ្ជសាស្ត្រ ដែលត្រូវផ្តល់ជម្រកដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ស្តង់ដារទាំងនេះ គួររៀបចំឡើងដោយមានការសហការជាមួយរដ្ឋាភិបាល ស្ថាប័នអន្តររដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវនានា និងគួរធ្វើឡើងផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវគ្រប់ជ្រុងជ្រោយ និងការអនុវត្តល្អ។
- បង្កើនកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ស្ថាប័នអន្តររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងកិច្ចសហប្រតិបត្តិការឆ្លងដែនតាមរយៈការសម្របសម្រួល និងការធ្វើសមាហរណកម្មសេវាថែទាំវេជ្ជសាស្ត្រ ដែលផ្តល់នៅប្រទេសគោលដៅ ប្រទេសប្រភពដើម និងប្រទេសឆ្លងកាត់។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ទទួលបានព័ត៌មាន និងសេវាសុខភាព ជាទៀងទាត់ស្របតាមតម្រូវការរបស់ពួកគេ។ | សេវាថែទាំវេជ្ជសាស្ត្រ និងសេវាថែទាំសុខភាពផ្លូវចិត្ត ត្រូវបានធ្វើស្ថាប័ននីតិកម្ម និងអនុវត្តជាទូទៅ ស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |



# ឧទាហរណ៍ អំពីការអនុវត្តល្អពាក់ព័ន្ធនឹងការថែទាំវេជ្ជសាស្ត្រ និងសេវាថែទាំសុខភាពផ្លូវចិត្ត

**ជនរងគ្រោះនៃអំពើជួញដូរមនុស្សទទួលបានព័ត៌មានដើម្បីធ្វើការសម្រេចចិត្តត្រឹមត្រូវអំពីសុខភាពរបស់ពួកគេ**

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលត្រូវបានគេដកហូតសេរីភាព ត្រូវបានបញ្ជូនទៅផ្ទះសុវត្ថិភាព ៣ ទៅ ៥ ថ្ងៃ ក្រោយពេលដែលគ្រលៀនរបស់គាត់ត្រូវបានគេដកហូត។ នៅផ្ទះសុវត្ថិភាពនេះ ជនរងគ្រោះ បានជួបជាមួយនឹងភ្នាក់ងារសុខភាព។

ភ្នាក់ងារសុខភាពនេះបានផ្តល់ព័ត៌មានអំពីដំណាក់កាលបន្ទាប់ នៃការជួយសង្គ្រោះជនរងគ្រោះ។ ភ្នាក់ងារសុខភាពបានប្រាប់ជនរងគ្រោះថា ចាំបាច់ត្រូវមានការសម្ភាស និងឱ្យការពិនិត្យកាយសម្បទា (ក្រៅខ្លួន) ជាមួយនឹងគ្រូពេទ្យព្យាបាលជំងឺទូទៅ ក្នុងនោះក៏មានការថតរូបត្រង់កន្លែងដែលមានស្នាមរបួសផងដែរ។ គ្រូពេទ្យទូទៅនេះនឹងពិនិត្យមើលស្នាមរបួសថាតើចាំបាច់ត្រូវមានការពិនិត្យឬការធ្វើអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្របន្ថែមទៀតដែរឬទេ។ វេជ្ជបណ្ឌិត ក៏ទំនងជាតម្រូវឱ្យជនរងគ្រោះចូលស្កែនស៊ីធី (CT) ដើម្បីប្រមូលភស្តុតាងទុកសម្រាប់ប្រើប្រាស់នៅក្នុងតុលាការ ហើយដើម្បីអនុវត្តទម្រង់ការទាំងនេះបាន គេចាំបាច់ត្រូវនាំជនរងគ្រោះទៅកាន់មន្ទីរពេទ្យ។

ដំបូងឡើយជនរងគ្រោះបដិសេធមិនព្រមឱ្យគេពិនិត្យកាយសម្បទា និងព្យាបាលឡើយ ភ្នាក់ងារសុខភាពរូបនេះ គោរពតាមការសម្រេចចិត្តរបស់គាត់។ ប៉ុន្តែគាត់គិតថាជនរងគ្រោះត្រូវការព័ត៌មានបន្ថែមទៀត ភ្នាក់ងារសុខភាពបានពន្យល់ពីអត្ថប្រយោជន៍ តម្រូវការជាក់លាក់របស់គាត់ ព្រមទាំងជម្រើសដែលគាត់អាចមាន។ ជនរងគ្រោះយល់កាន់តែច្បាស់ និងបានផ្តល់ការយល់ព្រម។ គ្រួសារជនរងគ្រោះ ក៏ត្រូវបានអញ្ជើញឱ្យអមដំណើរជនរងគ្រោះទៅកាន់មន្ទីរពេទ្យ ដែលនៅទីនោះគាត់ទទួលការពិនិត្យ និងការព្យាបាល។

**ធ្វើការជាមួយជនមានពិការភាព**

នៅក្នុងប្រទេសឥណ្ឌូនេស៊ី មជ្ឈមណ្ឌលព័ត៌មានមួយ ត្រូវបានដំណើរការ ដោយអង្គការសង្គមស៊ីវិល ដែលស្វែងរកការគាំទ្រសម្រាប់ជនមានពិការភាព។ អង្គការសង្គមស៊ីវិលនេះ ជ្រើសរើសអ្នកអមដំណើរម្នាក់ ដើម្បីជួយក្នុងករណីដែលអាចធ្វើទៅបាន នៅពេលដែលមានការបញ្ជូនជនរងគ្រោះ ឬបុគ្គលដែលអាចជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស មកកាន់មជ្ឈមណ្ឌលនេះ ដើម្បីទទួលបានការគាំទ្រ។

អ្នកអមដំណើរនេះ យល់ពីស្ថានភាពពិការភាព និងសេវាដែលជនរងគ្រោះនៃអំពើជួញដូរមនុស្ស កំពុងប្រើប្រាស់។ អ្នកអមដំណើរនេះបានទទួលការបណ្តុះបណ្តាលអំពីរបៀបធ្វើការជាមួយជនរងគ្រោះ និងជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលមានពិការភាព ក្នុងការទទួលបានសេវានានាឱ្យបានល្អបំផុតតាមដែលអាចធ្វើទៅបាន ដូចជា សេវាព្យាបាល និងសេវាថែទាំជាដើម។

# ដំណើរការយុត្តិធម៌

២៨

## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ត្រូវបានអនុវត្ត ដើម្បីស៊ើបអង្កេត ចោទប្រកាន់ និងជំនុំជម្រះជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងបក្សពួកដទៃទៀត ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ៣.៦.២។
- អនុសញ្ញា ACTIP មាត្រា ១(១)(ក), ៥, ១២(ជ)។

## សេចក្តីអធិប្បាយ និងការពន្យល់

បញ្ញត្តិដែលចាត់ទុកការជួញដូរមនុស្សជាបទល្មើសព្រហ្មទណ្ឌ អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ាន អនុម័តច្បាប់ និងវិធានការដែលចាំបាច់ដទៃទៀតឱ្យបានសមស្រប ដើម្បីចាត់ទុកអំពើជួញដូរមនុស្ស ថាជាបទល្មើសព្រហ្មទណ្ឌរាប់បញ្ចូលទាំងជាតុផ្សំ និងទង្វើដែលពាក់ព័ន្ធផងដែរ។ ការចាត់ទុកបទល្មើសជួញដូរមនុស្ស ជាបទល្មើសព្រហ្មទណ្ឌ ជាជំហានដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ចប់និទណ្ឌភាពរបស់ជន ដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។ គោលដៅចុងក្រោយ គឺដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងដើម្បីធានាឱ្យមានការផ្តន្ទាទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ឱ្យមានប្រសិទ្ធភាព និងប្រកបដោយយុត្តិធម៌។

ប្រទេសនានា ដែលខកខានពុំបានចាត់ទុកអំពើជួញដូរមនុស្ស ថាជាបទល្មើសព្រហ្មទណ្ឌ គឺពុំបានបំពេញកាតព្វកិច្ចការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងទប់ស្កាត់ការជួញដូរមិនឱ្យកើតមានជាថ្មីនាពេលអនាគតនោះឡើយ។ ពួកគេក៏ខកខានពុំបានរៀបចំឱ្យមានជារចនាសម្ព័ន្ធចាំបាច់ ដើម្បីឱ្យស្ថាប័នរដ្ឋធ្វើការស៊ើបអង្កេត ចោទប្រកាន់ទោស និងផ្តន្ទាទោស ករណីជួញដូរមនុស្សទៅតាមស្តង់ដារ ធានាភាពត្រឹមត្រូវ ដែលចាំបាច់ត្រូវអនុវត្តតាម។ បន្ថែមលើក្របខ័ណ្ឌច្បាប់រឹងមាំ រដ្ឋក៏ត្រូវការមន្ត្រីដែលមានសមត្ថភាព ដូចជា ភ្នាក់ងារអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម ដែលត្រូវមានអំណាច និងមធ្យោបាយគ្រប់គ្រាន់ សម្រាប់ការធ្វើការស៊ើបអង្កេត ចោទប្រកាន់ទោស និងផ្តន្ទាទោសជនល្មើសប្រកបដោយប្រសិទ្ធភាព។

លើសពីនេះ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ត្រូវតែអនុវត្តដោយមានការពិចារណាពីតម្រូវការរបស់ជនរងគ្រោះ ក៏ដូចជា ការអនុវត្តតាមគោលការណ៍ដែលពាក់ព័ន្ធមួយចំនួន ដូចជា គោលការណ៍មិន ផ្តន្ទាទោសជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ ការមិនឃុំខ្លួន និងគោលការណ៍មិនបង្គ្រោះថ្នាក់ជាដើម។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយផ្តន្ទាទោសករណីជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធជាបទល្មើសព្រហ្មទណ្ឌ ត្រូវបានអនុវត្ត។
- ☐ អាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរតុលាការដែលពាក់ព័ន្ធបានទទួលធនធាននិងមធ្យោបាយដែលចាំបាច់ដើម្បីធ្វើការស៊ើបអង្កេត ចោទប្រកាន់ទោស និងជំនុំជម្រះករណីជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។
- ☐ មានការផ្តល់ការបណ្តុះបណ្តាលជាទៀងទាត់ដល់មន្ត្រីអនុវត្តច្បាប់ដែលធ្វើការស៊ើបអង្កេតលើករណីជួញដូរមនុស្ស ដូចជាមន្ត្រីអន្តោប្រវេសន៍ អធិការការងារ និងមន្ត្រីស្លៀកឯកសណ្ឋានដទៃទៀត ដែលមានអំណាចស៊ើបអង្កេត និងសមត្ថកិច្ចចាត់ចែងសំណុំរឿងជួញដូរមនុស្ស។
- ☐ មានការផ្តល់ការបណ្តុះបណ្តាលជាទៀងទាត់ ដល់ព្រះរាជអាជ្ញា និងចៅក្រម ដែលចាត់ការ លើសំណុំរឿងជួញដូរមនុស្ស។
- ☐ ការបណ្តុះបណ្តាល ប្រើប្រាស់អភិក្រម ដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តោតលើជនរងគ្រោះ មានលក្ខណៈកុមារមេត្រី និងផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត ដោយធ្វើការពិចារណា ផ្តល់ឱកាសឱ្យអង្គការសង្គមស៊ីវិលពាក់ព័ន្ធបានចូលរួម ជាពិសេសអង្គការដែលជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងអំឡុងពេលដែលជនរងគ្រោះ ចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ☐ វគ្គបណ្តុះបណ្តាលជួយពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេត ចោទប្រកាន់ និងជំនុំជម្រះលើករណីជួញដូរមនុស្ស ក្នុងប្រទេស និងឆ្លងដែន។
- ☐ អង្គភាពស៊ើបអង្កេតពិសេស ត្រូវបានបង្កើតឡើង។
- ☐ ព្រះរាជអាជ្ញាពិសេស ត្រូវបានតែងតាំង។
- ☐ អង្គភាព ឬក្រុមការងារអយ្យការឯកទេស ត្រូវបានបង្កើតឡើង។
- ☐ ចៅក្រមឯកទេសត្រូវបានតែងតាំង។
- ☐ តុលាការឯកទេស ទទួលបន្ទុកសំណុំរឿងជួញដូរមនុស្ស ត្រូវបានបង្កើតឡើង។

## វិសាលភាព

លទ្ធផលនេះ រួមបញ្ចូលៈ

- ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដែលចាត់ទុកអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធ ថាជាបទល្មើសព្រហ្មទណ្ឌ ស្របតាមអនុសញ្ញា ACTIP និងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធដទៃទៀត។
- ការកសាងសមត្ថភាពស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ និងស្ថាប័នដទៃទៀតនៃប្រព័ន្ធយុត្តិធម៌ ដូចជា អធិការការងារ ដើម្បីពង្រឹងការស៊ើបអង្កេត ការចោទប្រកាន់ និងការជំនុំជម្រះលើករណីជួញដូរមនុស្ស រួមទាំងករណីជួញដូរមនុស្សឆ្លងដែន។
- រដ្ឋជាសមាជិកអាស៊ានបង្កើត និង/ឬតែងតាំងអង្គភាពស៊ើបអង្កេត ព្រះរាជអាជ្ញា អង្គភាព ឬក្រុមការងារអយ្យការ ចៅក្រម និងតុលាការឯកទេស ដើម្បីស៊ើបអង្កេត ចោទប្រកាន់ និងជំនុំជម្រះលើករណីជួញដូរមនុស្ស។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ស្ថាប័នយុត្តិធម៌ មានចំណេះដឹង ជំនាញ ធនធាន និងមធ្យោបាយ ដើម្បីធ្វើការស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោស អំពើជួញដូរមនុស្សឱ្យគ្រប់រូបភាពទាំងក្នុងប្រទេស ទាំងឆ្លងដែន ប្រកបដោយប្រសិទ្ធភាព។ | ការបង្កើនការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស ធ្វើឱ្យអាក់ខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានត្រឹមត្រូវ ថាតើពួកគេសម្រេចចិត្តចង់ចូលរួមក្នុងនីតិវិធីចោទប្រកាន់ទោស អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សដែរឬទេ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.១.១។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៤២, ៧៧, ៨៥, ៩២។
- អនុសញ្ញា ACTIP មាត្រា ១៦(៥)។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស គឺជាក្រុមដែលទទួលបានប្រយោជន៍ច្រើនជាងគេ នៅពេលដែលមានការផ្តន្ទាទោសលើជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សប្រកបដោយជោគជ័យ។ ជាការសំខាន់ណាស់ ដែលគេត្រូវប្រាប់ជនរងគ្រោះឱ្យដឹងពីសិទ្ធិ តាមច្បាប់របស់ពួកគេ ក៏ដូចជា ជំនួយ ដែលមានសម្រាប់ពួកគេ និងពីអ្វីដែលកើតមានឡើង ក៏ដូចជា មូលហេតុផ្សេងៗ។ ការគោរពតម្រូវការ សិទ្ធិ និងជម្រើសរបស់ជនរងគ្រោះ នៅក្នុងរយៈពេលវែង អាចផ្តល់ប្រយោជន៍ មិនត្រឹមតែដល់ជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងដល់ដំណើរការយុត្តិធម៌ និងសង្គមទាំងមូលផងដែរ។

ជាការសំខាន់ណាស់ ដែលអ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះ ធ្វើការប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ និងសាក្សី ប្រកបដោយប្រសិទ្ធភាព ដូចជា ផ្តល់ឱ្យពួកគេនូវព័ត៌មានដែលចាំបាច់ក្នុងភាសា ឬទម្រង់ដែលងាយស្រួលយល់ ដើម្បីឱ្យជនរងគ្រោះអាចយល់ពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ព្រមទាំងការគាំទ្រនានា ដែលដែលមានសម្រាប់ពួកគេ ដើម្បីឱ្យពួកគេអាចធ្វើការសម្រេចចិត្ត ឱ្យបានត្រឹមត្រូវ។ អាជ្ញាធរ ក៏ច្រើនតែទទួលបានព័ត៌មានជាសាច់រឿងពេញលេញ និងស៊ីសង្វាក់គ្នា ពីជនរងគ្រោះផងដែរ នៅពេលដែលជនរងគ្រោះមានអារម្មណ៍កក់ក្តៅ និងបានទទួលការគាំទ្រ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការពន្យល់យ៉ាងច្បាស់លាស់អំពីបទល្មើសជួញដូរមនុស្ស ការផ្តន្ទាទោសជនដែលប្រព្រឹត្ត និងការទទួលបានយុត្តិធម៌ និងសំណងនានា។
- ☐ មានការពន្យល់យ៉ាងច្បាស់លាស់ អំពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ
- ☐ ជនរងគ្រោះបានដឹងពីសិទ្ធិរបស់ពួកគេ ក្នុងការចូលរួមក្នុងនីតិវិធីតាមផ្លូវច្បាប់នានា និងអាចបញ្ចប់ការចូលរួមរបស់ពួកគេនៅពេលណាក៏បាន។
- ☐ មានការផ្តល់ព័ត៌មានអំពីជំនួយផ្លូវច្បាប់ការរៀបចំនៅក្នុងបន្ទប់តុលាការ ការរំពឹងទុក និងនីតិវិធីនានា។
- ☐ មានការផ្តល់ព័ត៌មានអំពីតួនាទីរបស់ចៅក្រមបុគ្គលិកតុលាការ ព្រះរាជអាជ្ញា និងមេធាវី ព្រមទាំងសំណួរដែលគេអាចសួរ។
- ☐ ព័ត៌មានដែលផ្តល់ឱ្យ បានយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្តោតលើជនរងគ្រោះ និងងាយស្រួលយល់សម្រាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជាស្ត្រី កុមារ និងជនមានពិការភាពផងដែរ។
- ☐ មានការផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ផ្អែកលើព័ត៌មានត្រឹមត្រូវ ផ្តល់ជូនជាមុន ដោយសេរី និងស្ម័គ្រចិត្ត ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានការថតសំឡេងទុក ឬការផ្តល់ការយល់ព្រមពីអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។
- ☐ មានការគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការបដិសេធមិនទទួលយកជំនួយ និងការគាំទ្រផ្សេងៗ នៅគ្រប់ពេលទាំងអស់។
- ☐ ការការពារ ការគាំទ្រ និងជំនួយគ្រប់គ្រាន់ ដូចដែលតម្រូវដោយច្បាប់ ពុំត្រូវបានភ្ជាប់លក្ខខណ្ឌថា ទាល់តែជនរងគ្រោះនៃអំពើជួញដូរមនុស្ស សហការក្នុងដំណើរការយុត្តិធម៌នោះឡើយ។
- ☐ មានការតែងតាំងមេធាវី អ្នកផ្តល់ជំនួយផ្លូវច្បាប់ ឬបុគ្គលដែលផ្តល់ការគាំទ្រដទៃទៀត។
- ☐ ពុំមានការគំរាមជនរងគ្រោះ ថានឹងមានការចោទប្រកាន់ទោសពួកគេពីបទល្មើសព្រហ្មទណ្ឌប្រសិនបើពួកគេបដិសេធមិនសហការ ក្នុងការអនុវត្តនីតិវិធីច្បាប់នោះឡើយ។

## វិសាលភាព

លទ្ធផលនេះរាប់បញ្ចូលការផ្តល់ព័ត៌មានផ្សេងៗ ដែលជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចធ្វើការសម្រេចចិត្តបាន។

- មានការពន្យល់យ៉ាងច្បាស់លាស់អំពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដូចជា ស្ថានភាពស្របច្បាប់របស់ជនរងគ្រោះ សិទ្ធិ ជម្រើស សេវាដែលមានសម្រាប់ពួកគេ និងដំណើរការជនុំជម្រះជាដើម។ ព័ត៌មានមានជាអាទិ៍ (ការផ្តន្ទាទោសជនដែលប្រព្រឹត្ត) ដំណោះស្រាយដែលអាចមានសម្រាប់ជនរងគ្រោះ សំណងបជិទាន និង/ឬសំណងជំងឺចិត្ត នីតិវិធីអនុវត្ត លទ្ធភាពដែលជនរងគ្រោះអាចត្រូវបានផ្តន្ទាទោស និងរយៈពេលនៃការអនុវត្តនីតិវិធីក្នុងតុលាការ។
- មានការផ្តល់ព័ត៌មានផ្តោតលើជនរងគ្រោះ និងមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងសាក្សី អំពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល ដូចជា ការរំពឹងទុកនៅក្នុងបន្ទប់តុលាការ ការអនុវត្តនីតិវិធី និងសំណួរដែលគេអាចសួរដោយប្រើប្រាស់ភាសាចម្រុះ ទម្រង់ផ្សេងៗ ឬជាភាសាសញ្ញា ដែលប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គមអាចយល់បាន រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពផងដែរ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្សបានទទួលសេវាជំនួយផ្លូវច្បាប់ ដើម្បីផ្តល់អាទិភាពឱ្យពួកគេអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ថាតើពួកគេចង់ចូលរួមក្នុងការអនុវត្តនីតិវិធីចោទប្រកាន់លើជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សដែរឬទេ។
- ជនរងគ្រោះបានទទួលការការពារ ការគាំទ្រ និងជំនួយគ្រប់គ្រាន់ទៅតាមការតម្រូវនៅក្នុងច្បាប់ សម្រាប់រយៈពេលដែលពួកគេចូលរួម នៅក្នុងការអនុវត្តនីតិវិធីច្បាប់។ មានការផ្តល់ការគាំទ្រដល់ជនរងគ្រោះ និង/ឬបុគ្គល ដែលសន្មតថាជាជនរងគ្រោះ ដោយមិនភ្ជាប់លក្ខខណ្ឌតម្រូវថាជនរងគ្រោះនៃអំពើជួញដូរមនុស្សត្រូវចូលរួមសហការក្នុងដំណើរការយុត្តិធម៌នោះឡើយ។
- មានការផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ផ្អែកលើព័ត៌មានត្រឹមត្រូវ ផ្តល់ជូនជាមុន ដោយសេរី និងស្ម័គ្រចិត្ត ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានការថតសំឡេងទុក ឬការផ្តល់ការយល់ព្រមអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ ដើម្បីឱ្យពួកគេចូលរួមនៅក្នុងដំណើរការផ្លូវច្បាប់។ មានការគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការបដិសេធមិនទទួលយកជំនួយ និងការគាំទ្រនានា នៅពេលណាក៏បាន។
- កុមារមានភាពងាយរងគ្រោះ ជាពិសេសដោយសារគ្រោះថ្នាក់ ឬអាចទទួលរងគ្រោះ (ជាថ្មី) នៅពេលដែលឱ្យពួកគេមានទំនាក់ទំនងជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលចាំបាច់ត្រូវមានការឆ្លើយតប ស្របតាមអាយុ វប្បធម៌ និងយេនឌ័ររបស់ពួកគេ។
- មានការចាត់តាំងមេធាវី អ្នកផ្តល់សេវាជំនួយផ្លូវច្បាប់ និងអ្នកជួយគាំទ្រដទៃទៀត ឱ្យគាំទ្រ និងផ្តល់ បច្ចុប្បន្នភាពដោយជនរងគ្រោះ ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល ក៏ដូចជា អមដំណើរដល់ជនរងគ្រោះក្នុងអំឡុងពេលផ្តល់ចម្លើយ។ ការផ្តល់មេធាវីពុំភ្ជាប់លក្ខខណ្ឌតម្រូវថាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬសាក្សីត្រូវតែសហការជាមួយអាជ្ញាធរ ឬចូលរួមក្នុងដំណើរការយុត្តិធម៌នោះឡើយ។
- ពុំមានការគំរាមចោទប្រកាន់ជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ ប្រសិនបើពួកគេបដិសេធមិនសហការចូលរួមក្នុងការអនុវត្តនីតិវិធីតាមផ្លូវច្បាប់ឡើយ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| អត្រាជនរងគ្រោះដែលស្ម័គ្រចិត្តចូលរួមក្នុងនីតិវិធីចោទប្រកាន់ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សមានការកើន | កំណើននៃការស៊ើបអង្កេត និងការចោទប្រកាន់បទល្មើសជួញដូរមនុស្សធ្វើឱ្យអាក់ខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ដំណើរការយុត្តិធម៌



## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចបន្តស្ថិតនៅក្នុងប្រទេសគោលដៅ ពេលដែលពួកគេកំពុងស្តារឡើងវិញ និងពេលកំពុងអនុវត្តនីតិវិធីនៅតុលាការ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ២.៥.១៣, ៣.១.៣, ៥.៣.៨។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ ទំព័រ ២១, ៥៤, ៩២។
- អនុសញ្ញា ACTIP មាត្រា ១៤(៤), ១៦(៥)។

## សេចក្តីអធិប្បាយ និងការពន្យល់

ក្រោមអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ាន មានកាតព្វកិច្ច ដាក់ចេញនូវវិធានការច្បាប់ ឬវិធានការសមស្របដទៃទៀត ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស បន្តស្ថិតនៅក្នុងដែនដីរបស់ខ្លួន ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ទៅតាមករណីជាក់ស្តែង រហូតដល់ពេលមានការដោះស្រាយសំណុំរឿងរបស់ពួកគេបានចប់សព្វគ្រប់ ឬនៅពេលដែលជនរងគ្រោះ បានទទួលសំណង។ រដ្ឋជាសមាជិកអាស៊ានមានកាតព្វកិច្ច ធ្វើការពិចារណាពីកត្តាមនុស្សធម៌ និងកត្តាសមានចិត្តនានា ដើម្បីសម្រេចគោលបំណងនេះ។ ប្រទេសដែលទទួលឱ្យជនរងគ្រោះ អាចលើកទឹកចិត្តឱ្យជនរងគ្រោះស្ម័គ្រចិត្តបន្តស្នាក់នៅ ដើម្បីផ្តល់សក្ខីកម្ម ឬចូលរួមសហការក្នុងការអនុវត្តនីតិវិធីចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ប៉ុន្តែត្រូវមានការយកចិត្តទុកដាក់ចំពោះសុវត្ថិភាពរបស់ពួកគេ។

ករណីអនុញ្ញាតឱ្យស្នាក់នៅជាបក្សបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ត្រូវបានផ្តល់ដល់ជនរងគ្រោះ មិនថាជនរងគ្រោះចូលរួម ឬផ្តល់កស្តុតាងក្នុងនីតិវិធីច្បាប់ដែរឬអត់នោះឡើយ។ ជនរងគ្រោះនៃអំពើជួញដូរមនុស្សពុំត្រូវបាន ផ្តន្ទាទោសដោយសារតែពួកគេបំពានលើច្បាប់អន្តោប្រវេសន៍នៃប្រទេសគោលដៅ ក្រោយពេលដែលពួកគេត្រូវបានជួញដូរនោះឡើយ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការដាក់ចេញ និងអនុវត្តច្បាប់/គោលនយោបាយ ឬនីតិវិធី ដើម្បីធានាមិនឱ្យមានការបង្ខំជនរងគ្រោះ និងសាក្សីនៃអំពើជួញដូរមនុស្សចាកចេញ ឬបន្តស្នាក់នៅក្នុងប្រទេសគោលដៅ ដើម្បីចូលរួមក្នុងការអនុវត្តនីតិវិធីច្បាប់។
- ☐ ជនរងគ្រោះ និងសាក្សីនៃអំពើជួញដូរមនុស្ស ដែលបានទទួលស្ថានភាពស្របច្បាប់ និងឯកសារសម្គាល់ខ្លួន ដើម្បីឱ្យពួកគេអាចបន្តស្នាក់នៅក្នុងប្រទេស ក្នុងអំឡុងពេលដែលពួកគេស្តារឡើងវិញ និងចូលរួមក្នុងការអនុវត្តនីតិវិធីច្បាប់។
- ☐ ជនរងគ្រោះ និងសាក្សីនៃអំពើជួញដូរមនុស្ស បានទទួលសុវត្ថិភាព និងការការពារពីការបង្កប្លួសស្នាម ឬការបៀតបៀននានា។
- ☐ មានការផ្តល់ឱ្យជនរងគ្រោះនៅរយៈពេលស្តារឡើងវិញ ដោយពុំមានភ្ជាប់លក្ខខណ្ឌជាមួយនឹងពេលវេលានៃការអនុវត្តនីតិវិធីច្បាប់នោះឡើយ។
- ☐ ជនរងគ្រោះចូលរួមក្នុងការអនុវត្តនីតិវិធីច្បាប់ ទៅតាមការត្រៀមខ្លួនរបស់ពួកគេ។
- ☐ ការអនុវត្តនីតិវិធី អាចត្រូវបានផ្អាកជាបណ្តោះអាសន្ន ប្រសិនបើចាំបាច់ដោយមិនរំខានដល់រយៈពេលដែលកំណត់ពីដំបូងនោះឡើយ។
- ☐ ពុំមានការចោទប្រកាន់ទោសជនរងគ្រោះ ថាបានស្នាក់នៅខុសច្បាប់ឬមានស្ថានភាពខុសច្បាប់នៅក្នុងប្រទេសគោលដៅ ក្រោយពេលដែលពួកគេត្រូវបានជួញដូរនោះឡើយ។

## វិសាលភាព

អភិក្រមផ្តោតលើជនរងគ្រោះ យកចិត្តទុកដាក់ចំពោះយេនឌ័រ និងបែបកុមារមេត្រី ជានាថា៖

- មានការផ្តល់ជំនួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេទទួលបានស្ថានភាពស្របច្បាប់ ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ទៅតាមករណីជាក់ស្តែង។
- ជនរងគ្រោះ និងសាក្សីនៃអំពើជួញដូរមនុស្ស បានទទួលសុវត្ថិភាព និងការការពារពីការបង្ករបួសស្នាម ឬការបៀតបៀននានា។
- រយៈពេលស្តារឡើងវិញ ពុំត្រូវបានភ្ជាប់លក្ខខណ្ឌជាមួយនឹងការពេលវេលានៃការអនុវត្តនីតិវិធីលើសំណុំរឿងនោះឡើយ ប៉ុន្តែការអនុវត្តនីតិវិធីច្បាប់ ធ្វើឡើងទៅតាមការត្រៀមខ្លួនរបស់ជនរងគ្រោះ។
- តុលាការអាចផ្អាកការអនុវត្តនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើជនរងគ្រោះ ឬសាក្សី ពុំមានសមត្ថភាពផ្នែកសុខភាព ឬសតិបញ្ញាបន្តចូលរួម រហូតដល់ពេលដែលមានអ្នកជំនាញបញ្ជាក់ថាជនរងគ្រោះ មានភាពសមស្របក្នុងការបន្តចូលរួមក្នុងនីតិវិធីទៀត ហើយរយៈពេលនេះមិនត្រូវធ្វើឱ្យអាក់ខានរយៈពេលដែលកំណត់ពីដំបូងនោះឡើយ។
- រដ្ឋជាសមាជិកអាស៊ាន រៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារ ឬគោលការណ៍ណែនាំ ដើម្បីផ្តល់លទ្ធភាពឱ្យជនរងគ្រោះ និងសាក្សីនៃអំពើជួញដូរមនុស្សបានទទួលស្ថានភាព និងឯកសារស្របច្បាប់នានា ដើម្បីឱ្យពួកគេអាចបន្តស្នាក់នៅក្នុងប្រទេស ក្នុងអំឡុងពេលនៃការអនុវត្តនីតិវិធីច្បាប់។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬជនដែលត្រូវបានគេសន្មតថាជាជនរងគ្រោះ បានទទួលស្ថានភាពស្របច្បាប់ និងការការពារ ពីការឃុំខ្លួន និងការនិរទេស និងពុំត្រូវបានគេផ្តន្ទាទោស ឃុំខ្លួន ឬនិរទេសដោយសារបំពានច្បាប់អន្តោប្រវេសន៍ ដូចជា ការស្នាក់នៅហួសកាលកំណត់ ការធ្វើទេសន្តប្រវេសន៍ខុសច្បាប់ ការមិនបង់ថ្លៃសេវាអន្តោប្រវេសន៍ ឬធ្វើការងារដោយខុសច្បាប់ក្នុងប្រទេសគោលដៅ ដោយសារតែពួកគេត្រូវបានគេជួញដូរមនុស្សឡើយ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានស្តារកែសម្រួល ដើម្បីបញ្ចូលបញ្ញត្តិ ផ្តល់ការការពារដល់ជនរងគ្រោះ និងជួយសម្រួលឱ្យពួកគេស្នាក់នៅ និងស្តារឡើងវិញក្នុងប្រទេសដែលទទួលពួកគេឱ្យស្នាក់នៅ។ | ច្បាប់ និងបញ្ញត្តិ ពាក់ព័ន្ធនឹងយន្តការច្បាប់ ដើម្បីឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សបន្តស្នាក់នៅក្នុងប្រទេសគោលដៅ ត្រូវបានអនុម័តស្របតាមអនុសញ្ញា ACTIP។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តធម៌



## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលសេវាពាក់ព័ន្ធ ក្នុងអំឡុងពេលដែលពួកគេ ចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.១.៥។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ៣.៤.៦។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៩៣។
- អនុសញ្ញា ACTIP មាត្រា ១៤(១០), (១៣), ១៦(៥)។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៣។

## សេចក្តីអធិប្បាយ និងការពន្យល់

ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ត្រូវបានអនុវត្តដើម្បីអាចផ្តល់សេវាដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងអំឡុងពេលដែលពួកគេចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ សេវានានាមានជាអាទិ៍ លំនៅឋាន ការផ្តល់ប្រឹក្សា និងការផ្តល់ព័ត៌មានអំពីសិទ្ធិស្របច្បាប់របស់ជនរងគ្រោះជាភាសា និងក្នុងទម្រង់ដែលងាយស្រួលយល់ ក៏ដូចជា ជំនួយផ្នែកវេជ្ជសាស្ត្រ ការពិគ្រោះយោបល់ផ្លូវចិត្ត និងជំនួយជាសម្ភារៈ ការងារ ឱកាសអប់រំ និងបណ្តុះបណ្តាលជាដើម។ ជនរងគ្រោះមានសិទ្ធិទទួលបានសេវាច្បាប់ និងសេវាជំនួយផ្លូវច្បាប់ ដោយមិនគិតថ្លៃ ដើម្បីជួយឱ្យពួកគេអាចចូលរួមក្នុងដំណើរការយុត្តិធម៌ រួមទាំងទទួលបានសំណងបដិទាន និងសំណងជួសជុលការខូចខាតដែលពួកគេដែលទទួលរងកន្លងមក។

កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធានាឱ្យជនរងគ្រោះ អាចទទួលបានការថែទាំ និងការគាំទ្រពេញលេញ ដូចដែលមានចែងនៅក្នុងអនុសញ្ញា ACTIP។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការផ្តល់ការគាំទ្រជាច្រើនប្រភេទដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដូចជាសេវាជំនួយផ្លូវច្បាប់ដោយមិនគិតថ្លៃ ដែលពុំមានការភ្ជាប់លក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះ ត្រូវចូលរួមសហការក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ☐ បណ្តាញស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ផ្តល់នូវជំនួយផ្លូវច្បាប់ដោយមិនគិតថ្លៃ និងផ្តល់ភាពងាយស្រួលដល់ជនរងគ្រោះ។
- ☐ មេធាវី និងអ្នកផ្តល់សេវាជំនួយផ្លូវច្បាប់ មានជំនាញឯកទេស និងបទពិសោធ។
- ☐ ដំបូន្មានផ្នែកច្បាប់ត្រូវបានផ្តល់យ៉ាងច្បាស់លាស់ក្នុងទម្រង់ និងភាសា ដែលជនរងគ្រោះងាយស្រួលយល់។
- ☐ មានការតែងតាំងអាណាព្យាបាលស្របច្បាប់ នៅពេលដែលគេរកមិនឃើញឪពុកម្តាយ និង/ឬឪពុកម្តាយពុំអាចផ្តល់ការថែទាំដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ។

## វិសាលភាព

លទ្ធផលនេះ រាប់បញ្ចូលចំណុចដូចតទៅ៖

- ផ្តល់សេវា ឬការគាំទ្រផ្លូវច្បាប់ដោយមិនគិតថ្លៃ និងដែលផ្តល់នូវភាពងាយស្រួល ដើម្បីជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ស្របតាមច្បាប់ និងគោលនយោបាយជាតិ របស់រដ្ឋជាសមាជិកអាស៊ាននីមួយៗ។ ប្រសិនបើពុំមានការផ្តល់សេវាគាំទ្រផ្លូវច្បាប់ ក្រោមការឧបត្ថម្ភថវិកាពីរដ្ឋនោះទេ គេអាចរៀបចំឱ្យមានជាជម្រើសផ្សេងទៀត ដូចជា សេវាមេធាវីដោយមិនគិតថ្លៃ ឬមេធាវី ដែលផ្តល់ដោយអង្គការសង្គមស៊ីវិលជាដើម។
- បង្កើត ឬពង្រឹងបណ្តាញអ្នកជំនាញ ផ្តល់សេវាជំនួយផ្លូវច្បាប់ និងអង្គការដែលអ្នកឯកទេសជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងជនមានពិការភាព ដែលពុំមានលទ្ធភាពជួលមេធាវីតំណាងឱ្យពួកគេ។
- ផ្តល់មេធាវី ដែលមានជំនាញឯកទេស ផ្តល់ដំបូន្មានដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងតំណាងជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។ ផ្តល់ដំបូន្មានផ្លូវច្បាប់គ្រប់បែបយ៉ាងឱ្យបានច្បាស់លាស់ និងមានផ្តល់អ្នកបកប្រែភាសា ឬភាសាសញ្ញា ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាពជាដើម។
- ធានាថាតុលាការ និងដំណើរការនានា អនុវត្តបែបកុមារមេត្រី ដោយមានការតែងតាំងអាណាព្យាបាលស្របច្បាប់ដែលមានសមត្ថភាព សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលជាកុមារ ប្រសិនបើពួកគេពុំបានទទួលការថែទាំពីឪពុកម្តាយ ដើម្បីទប់ស្កាត់ការប៉ះទង្គិចផ្លូវចិត្តជាថ្មី ការពារឧត្តមប្រយោជន៍របស់ពួកគេ ក៏ដូចជា តំណាងឱ្យពួកគេនៅក្នុងនីតិវិធីច្បាប់។
- ធានាថាការផ្តល់សេវានានា ពុំមានការភ្ជាប់លក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះ ឬសាក្សីនៃអំពើជួញដូរមនុស្ស ត្រូវចូលរួមសហការជាមួយអាជ្ញាធរ ឬចូលរួមក្នុងដំណើរការច្បាប់នោះឡើយ។
- អនុវត្តអភិក្រមផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត និងគោលការណ៍មិនបង្កគ្រោះថ្នាក់នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ធានាឱ្យមានការរក្សាការសម្ងាត់ នៅពេលអនុវត្តចំណាត់ការលើសំណុំរឿងជួញដូរមនុស្ស (ឧទាហរណ៍ ផ្តល់បន្ទប់ឯកជនសម្រាប់ការសម្ភាសការស៊ើបអង្កេត/ជំនុំជម្រះបិទទ្វារជាដើម)។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| អត្រាជនរងគ្រោះស្ម័គ្រចិត្តចូលរួមនៅក្នុងនីតិវិធីចោទប្រកាន់ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស មានការកើនឡើង។ | ការការពារ និងការគាំទ្រដល់ជនរងគ្រោះ ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅស្របតាមអនុសញ្ញា ACTIP ដែលនាំឱ្យមានការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្សកាន់តែច្រើនជាងមុន ដែលបង្កការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តិធម៌



## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលបានធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្ម បានទទួលការគាំទ្រ ដើម្បីអាចចូលរួមក្នុងការស៊ើបអង្កេតឆ្លងដែន និងការចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរពួកគេ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.១.៤។
- អនុសញ្ញា ACTIP មាត្រា ១៥(១), (៤), (៧), ១៦(៥)។

## សេចក្តីអធិប្បាយ និងការពន្យល់

ក្រោមអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ាន មានកាតព្វកិច្ចដែលជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយពុំមានការពន្យារពេលដោយគ្មានហេតុផលសមស្របនោះឡើយ និងមានការគិតពិចារណាពីសុវត្ថិភាពរបស់ពលរដ្ឋ ឬរបស់អ្នកដែលមាននិវេសនដ្ឋានជាអចិន្ត្រៃយ៍នៅក្នុងប្រទេសរបស់ខ្លួន។ រដ្ឋជាសមាជិកអាស៊ាន ក៏មានកាតព្វកិច្ចចេញឯកសារធ្វើដំណើរ និង/ឬលិខិតអនុញ្ញាតនានា ដើម្បីផ្តល់លទ្ធភាពឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចធ្វើដំណើរ និងចូលមកដែនដីរបស់ពួកគេជាថ្មី។

នៅក្នុងករណីដែលមានការស៊ើបអង្កេត និងការចោទប្រកាន់ទោសឆ្លងដែន ដែលចាំបាច់ត្រូវមានការបង្ហាញខ្លួនជាក់ស្តែង មានការពិចារណាលើថ្លៃធ្វើដំណើរ អាហារនិងការស្នាក់នៅ សុវត្ថិភាព និងភាពងាយស្រួលរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដើម្បីឱ្យជួយឱ្យជនរងគ្រោះអាចចូលរួមក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។ នេះគឺអាស្រ័យលើកិច្ចព្រមព្រៀងផ្តល់ជំនួយផ្លូវច្បាប់ទៅវិញទៅមកជាលក្ខណៈទ្វេភាគីឬពហុភាគី ដែលកំពុងចូលជាធរមាន ឬការរៀបចំនានាពាក់ព័ន្ធនឹងការធ្វើអន្តោប្រវេសន៍ ដែលផ្តល់សិទ្ធិ និងបុព្វសិទ្ធិដល់ជនរងគ្រោះ។

ក្នុងករណីដែលការបង្ហាញខ្លួនជាក់ស្តែងមិនអាចធ្វើទៅបាន ត្រូវមានការពិនិត្យលើជម្រើសផ្សេងទៀត ដើម្បីឱ្យជនរងគ្រោះអាចផ្តល់ភស្តុតាងបាន។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការអនុវត្តយន្តការ ឬនីតិវិធី ដើម្បីឱ្យជនរងគ្រោះដែលបានធ្វើមាតុភូមិនិវត្តន៍ អាចចូលរួមក្នុងការស៊ើបអង្កេត និងចោទប្រកាន់ទោស លើអ្នកដែលប្រព្រឹត្តការជួញដូរមកលើពួកគេ ក្នុងករណីដែលការធ្វើបែបនេះ ផ្តល់នូវសុវត្ថិភាពសម្រាប់ជនរងគ្រោះ។
- ☐ មានការរៀបចំសវនាការតាមប្រព័ន្ធអេឡិចត្រូនិកនិងការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូអនឡាញ ពីកន្លែងដែលជាប្រភពដើមរបស់ជនរងគ្រោះ ដើម្បីជួយឱ្យជនរងគ្រោះផ្តល់សក្ខីកម្ម។
- ☐ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលការគាំទ្រដើម្បីផ្តល់សក្ខីកម្មឬថតវីដេអូទុកជាមុនសម្រាប់ប្រើប្រាស់ជាភស្តុតាង ក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។
- ☐ កិច្ចព្រមព្រៀងសហការគ្នាជាមួយប្រទេសប្រភពដើមត្រូវបានរៀបចំ ដើម្បីឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចធ្វើដំណើរប្រកបដោយសុវត្ថិភាព ទទួលបានអាហារ និងកន្លែងស្នាក់នៅរួមទាំងអ្នកអមដំណើរផងដែរ ប្រសិនបើចាំបាច់ ក្នុងអំឡុងពេលដែលពួកគេចូលរួមក្នុងដំណើរការយុត្តិធម៌។
- ☐ ការរៀបចំកិច្ចសហប្រតិបត្តិការរវាងប្រទេសនានាបែបនេះ បង្កភាពមិនងាយស្រួលតិចតួចបំផុតដល់ជនរងគ្រោះ និងមិនត្រូវឱ្យជនរងគ្រោះអស់ចំណាយអ្វីនោះឡើយ។

## វិសាលភាព

លទ្ធផលនេះ រាប់បញ្ចូលការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋជាសមាជិកអាស៊ាន ដើម្បីៈ

- រៀបចំឱ្យមានកិច្ចសហប្រតិបត្តិការរវាងប្រទេសគោលដៅ និងប្រទេសប្រភពដើម ដើម្បីជួយសម្រួលឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សអាចធ្វើដំណើរប្រកបដោយសុវត្ថិភាព និងមានអ្នកអមដំណើរនៅពេលផ្តល់សក្ខីកម្ម កាត់បន្ថយកត្តាដែលបង្កផលវិបាកឱ្យនៅតិចបំផុត និងមិនតម្រូវឱ្យជនរងគ្រោះត្រូវចំណាយអ្វីនោះឡើយ។
- បង្កើតយន្តការសហការគ្នារវាងរដ្ឋជាសមាជិកអាស៊ាន និងទីភ្នាក់ងារនានា ដើម្បីបង្កលក្ខណៈឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានចូលរួមក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត និងចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរពួកគេ។
- រៀបចំសវនាការតាមប្រព័ន្ធអេឡិចត្រូនិក ការផ្តល់សក្ខីកម្មតាមប្រព័ន្ធអនឡាញ និងវីដេអូ ពីទីកន្លែងប្រភពដើម ស្របតាមច្បាប់ជាតិ។
- ផ្តល់ជម្រើសថតវីដេអូទុកជាមុន ដើម្បីឱ្យជនរងគ្រោះអាចផ្តល់ភស្តុតាងបាន ។
- រៀបចំឱ្យជនរងគ្រោះអាចផ្តល់សក្ខីកម្មទុកជាមុន ដែលជាវិធីសាស្រ្តសម្រាប់អាចផ្តល់ជាភស្តុតាង។
- អនុញ្ញាតឱ្យអ្នកដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះ អមដំណើរជនរងគ្រោះ និង/ឬជនដែលត្រូវបានគេសន្មតថាជាជនរងគ្រោះក្នុងអំឡុងពេលស៊ើបអង្កេត ចោទប្រកាន់ទោស និងជំនុំជម្រះ។

អាជ្ញាធរ និងមន្ត្រីច្បាប់ទទួលស្គាល់ថាករណីជួញដូរមនុស្ស មិនអាចពឹងអាស្រ័យតែលើសក្ខីកម្មរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ចោទប្រកាន់ទោស និងជំនុំជម្រះលើឯកជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សឡើយ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| អត្រាជនរងគ្រោះស្ម័គ្រចិត្តចូលរួមនៅក្នុងនីតិវិធីចោទប្រកាន់ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស មានការកើនឡើង។ | ការកើនឡើងនៃការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស បង្ករការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តិធម៌



## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលសម្រេចចិត្តចូលរួមក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត និងចោទប្រកាន់លើជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស បានទទួលព័ត៌មានអំពីភាពជឿនលឿននៃសំណុំរឿងរបស់ខ្លួន។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.១.១។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៤២, ៧៣, ៨៥, ៩២។
- អនុសញ្ញា ACTIP មាត្រា ១៦(៥), ៩។

## សេចក្តីអធិប្បាយ និងការពន្យល់

ដើម្បីអាចការផ្តល់ឱ្យជនរងគ្រោះនូវព័ត៌មានបច្ចុប្បន្នភាព អំពីភាពជឿនលឿននៃសំណុំរឿងរបស់ពួកគេឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា រដ្ឋជាសមាជិកអាស៊ាន ចាំបាច់ត្រូវបង្កើត និងប្រើប្រាស់ប្រព័ន្ធទាក់ទងដែលមានស្រាប់ រវាង និងក្នុងចំណោមស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនៅថ្នាក់ជាតិ ឬរវាង ឬក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច ដែលកំពុងចូលរួមអនុវត្តនីតិវិធីក្នុងសំណុំរឿងឆ្លងដែន ដើម្បីជួយសម្រួលឱ្យមានការផ្លាស់ប្តូរព័ត៌មានប្រកបដោយសុវត្ថិភាព និងឆាប់រហ័ស និងបន្តទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីភាពជឿនលឿននៃការស៊ើបអង្កេត និងការចោទប្រកាន់ទោសក្នុងសំណុំរឿងនេះ។

អនុសញ្ញា ACTIP តម្រូវឱ្យរដ្ឋជាសមាជិកផ្តល់ព័ត៌មានអំពីលក្ខណៈនៃការការពារ ការផ្តល់ជំនួយ និងការគាំទ្រនានា ដែលពួកគេមានសិទ្ធិទទួលបាន ក្រោមច្បាប់ជាតិ និងក្រោមអនុសញ្ញានេះ។ ព័ត៌មាននានា ជាពិសេសព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិតាមផ្លូវច្បាប់ គួរផ្តល់ជាភាសា ភាសាសញ្ញា និងក្នុងទម្រង់ដែលជនរងគ្រោះអាចយល់បាន។

## វិសាលភាព

លទ្ធផលនេះ ធានាថា ជនរងគ្រោះ និងសាក្សីនៃអំពើជួញដូរមនុស្ស បានទទួលព័ត៌មានអំពីភាពជឿនលឿននៃសំណុំរឿង តាមរយៈមធ្យោបាយគ្រប់បែបយ៉ាងដែលមានភាពសមស្របក្នុងភាសា និងទម្រង់ដែលពួកគេអាចយល់បាន។

យន្តការនានាត្រូវបានអនុវត្ត ដើម្បីធានាឱ្យមានការផ្ទេរព័ត៌មានត្រឹមត្រូវប្រកបដោយសុវត្ថិភាពជាទៀងទាត់ អំពីសំណុំរឿងជួញដូរមនុស្ស ក្នុងចំណោមផ្នែកក្នុងទីភ្នាក់ងារនានា និងរវាងទីភ្នាក់ងារមួយ និងទីភ្នាក់ងារមួយទៀត។ ជនរងគ្រោះបានទទួលព័ត៌មានបច្ចុប្បន្នភាពជាទៀងទាត់ ពាក់ព័ន្ធនឹងសំណុំរឿងរបស់ពួកគេ ពីមន្ត្រីបង្គោល ឬពីទីភ្នាក់ងារដែលទទួលបន្ទុកសំណុំរឿង។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការពន្យល់យ៉ាងច្បាស់លាស់អំពីភាពជឿនលឿននៃសំណុំរឿង ក្នុងភាសា និងទម្រង់ដែលជនរងគ្រោះអាចយល់បាន។
- ☐ យន្តការសហប្រតិបត្តិការ និងសម្របសម្រួលយ៉ាងរឹងមាំ សម្រាប់ការចែករំលែកព័ត៌មាន ត្រូវបានដាក់អនុវត្ត។
- ☐ ប្រព័ន្ធប្រាស្រ័យទាក់ទងដែលមានស្រាប់ និងមានសុវត្ថិភាព ត្រូវបានបង្កើតឡើង និងប្រើប្រាស់ដោយរដ្ឋជាសមាជិកអាស៊ាន។
- ☐ អាចមានការចាត់តាំងជនបង្គោលផ្តល់ការគាំទ្រ ឬអ្នកសម្របសម្រួលជនរងគ្រោះជាសាក្សី ដើម្បីជួយដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីស្ថានភាព/ភាពជឿនលឿននៃសំណុំរឿង និងបញ្ហាដែលពាក់ព័ន្ធដទៃទៀត។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| អត្រាជនរងគ្រោះស្ម័គ្រចិត្តចូលរួមនៅក្នុងនីតិវិធីចោទប្រកាន់ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស មានការកើនឡើង។ | ការកើនឡើងនៃការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស បង្ការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

**ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី**

| | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |

# ដំណើរការយុត្តិធម៌



### លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ការវាយតម្លៃលើហានិភ័យរបស់ជនរងគ្រោះម្នាក់ៗ និងផែនការសុវត្ថិភាព ត្រូវបានរៀបចំឡើងសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្សទាំងអស់ ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.២.៧។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៧៧, ៨១, ៨៥។

### សេចក្តីអធិប្បាយ និងការពន្យល់

ការវាយតម្លៃលើហានិភ័យ និងការរៀបចំផែនការឆ្លើយតបចំពោះហានិភ័យ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សមស្របទៅតាមស្ថានភាពរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងសាក្សី ជាមនុស្សពេញវ័យ និងកុមារ ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងសមាជិកគ្រួសាររបស់ពួកគេ (ប្រសិនបើអាចធ្វើទៅបាន) ទីភ្នាក់ងារអនុវត្តច្បាប់ និងសេវាគាំទ្រដល់ជនរងគ្រោះ។ គោលបំណងនៃការវាយតម្លៃនេះ គឺដើម្បីវាយតម្លៃលើគ្រោះថ្នាក់ដែលអាចកើតមានឡើង នៅពេលដែលជនរងគ្រោះចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ព្រមទាំង ដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់ពួកគេ និងគ្រួសាររបស់ពួកគេ។

គ្រោះថ្នាក់ដែលអាចកើតមានឡើងចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគេដែលគួរឱ្យពិចារណា នៅពេលធ្វើការវាយតម្លៃលើហានិភ័យ និងរៀបចំផែនការ អាចមានដូចជា ការសម្លុតគំរាម ការបៀតបៀន ការគំរាមកំហែង ការបង្ខិតបង្ខំ និងអំពើហិង្សាក្នុងទម្រង់ផ្សេងទៀត ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ផ្លូវកាយ និងផ្លូវចិត្ត។ ការប្រកាន់ផ្តត់គំនិតអវិជ្ជមានពីគ្រួសាររបស់ជនរងគ្រោះ និងប្រតិកម្មអវិជ្ជមានដែលអាចកើតមាននៅក្នុងសហគមន៍ប្រភពដើម ក៏គួរត្រូវបានយកមកធ្វើការពិចារណា នៅក្នុងការវាយតម្លៃហានិភ័យផងដែរ។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ការវាយតម្លៃលើហានិភ័យស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ត្រូវបានរៀបចំឡើង និងអនុវត្ត។
- ☐ សកម្មភាពទាំងអស់ត្រូវការ និងបានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬការយល់ព្រមដោយផ្ទាល់មាត់ ដោយមានថតសំឡេងទុក ឬការយល់ព្រម affirmative assent ពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ ឬការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។
- ☐ ផែនការសុវត្ថិភាព ត្រូវបានអនុវត្ត និងអាចបញ្ចូលចំណុចដូចតទៅ៖
  - ☐ មានការការពារឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះ និងគ្រួសារ
  - ☐ ការស៊ើបអង្កេត និងការជំនុំជម្រះបិទទ្វារ
  - ☐ ជម្រើសផ្សេងៗសម្រាប់ផ្តល់ភ័ស្តុតាង
  - ☐ កម្មវិធីការពារសាក្សី
  - ☐ អាចមានការតែងតាំងបុគ្គលិកសន្តិសុខដើម្បីផ្តល់ការការពារដល់ជនរងគ្រោះនិង/ឬសាក្សី។

## វិសាលភាព

លទ្ធផលនេះ រួមមាន៖

- ការវាយតម្លៃហានិភ័យសមស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ ដើម្បីវាយតម្លៃលើគ្រោះថ្នាក់ដែលអាចកើតមានឡើង និង/ឬហានិភ័យ ដែលជនរងគ្រោះ និង/ឬសមាជិកគ្រួសាររបស់ពួកគេ អាចជួបប្រទះ ក្នុងអំឡុងពេលដែលពួកគេចូលរួមនៅក្នុងប្រព័ន្ធយុត្តិធម៌ (ក្នុងអំឡុងពេល និងក្រោយពេល)។
- ផែនការសុវត្ថិភាព និងសន្តិសុខត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងអំឡុងពេលនៃដំណើរការយុត្តិធម៌។ ផែនការនានា មានជាអាទិ៍៖
  - ឯកជនភាពរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស សាក្សី និងគ្រួសាររបស់ពួកគេត្រូវបានការពារ, ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន ស្ថានភាពផ្ទាល់ខ្លួន ឬព័ត៌មានលម្អិតដែលដទៃទៀត ដែលអាចឱ្យគេដឹងពីអត្តសញ្ញាណ ត្រូវបានដកចេញ ឬលុបចោល នៅពេលដែលចាំបាច់។
  - មានការស៊ើបអង្កេត និងការជំនុំជម្រះបិទទ្វារ។
  - ព័ត៌មានសម្គាល់អត្តសញ្ញាណត្រូវបានផ្សព្វផ្សាយដោយមានការផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដោយមានថតសំឡេងទុក ឬមានការយល់ព្រមពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ ព្រមទាំងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។
  - ជនរងគ្រោះអាចឱ្យផ្តល់ភស្តុតាង តាមរយៈមធ្យោបាយជាជម្រើសផ្សេងៗ។
  - កម្មវិធីការពារសាក្សី ដោយមានការផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដោយមានថតសំឡេងទុក ឬមានការយល់ព្រមពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ ព្រមទាំងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។
  - អាចមានការតែងតាំងបុគ្គលិកសន្តិសុខ ដើម្បីផ្តល់ការការពារដល់ជនរងគ្រោះនិង/ឬសាក្សី។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| អត្រាជនរងគ្រោះស្ម័គ្រចិត្តចូលរួមនៅក្នុងនីតិវិធីចោទប្រកាន់ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស មានការកើនឡើង។ | ការកើនឡើងនៃការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស បង្កការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តធម៌

## ៣៥

### លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ បានទទួលការការពារពីការសម្លុតគំរាម ការបង្ខិតបង្ខំ ការបៀតបៀន និង/ឬការសងសឹក ឬការបង្ខំឱ្យសាក្សីឱ្យផ្លាស់ប្តូរចម្លើយ។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.២.៧, ២.១.១។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ៣.៦.៥, ៤.១៦។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៧៧, ៨១។
- អនុសញ្ញា ACTIP មាត្រា ១៦(៥), (៧)។

### សេចក្តីអធិប្បាយ និងការពន្យល់

ការការពារបូរណភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទាមទារឱ្យមានការការពារភាគីដែលដែលរងផលប៉ះពាល់ ផ្តន្ទាទោសជនដែលប្រព្រឹត្តបទល្មើស តាមរយៈដំណើរការច្បាប់ដែលមានភាពត្រឹមត្រូវ។ ក្រោមអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ាន មានកាតព្វកិច្ចចាត់វិធានការដែលចាំបាច់ ដើម្បីធានាឱ្យមានការរក្សាបូរណភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលក្នុងនោះ រួមមាន ការការពារដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ពីការសម្លុតគំរាម និងការបៀតបៀន និងក្នុងករណីដែលចាំបាច់ ផ្តន្ទាទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។

ដើម្បីសម្រេចគោលដៅនេះ ចាំបាច់ត្រូវមានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងផែនការនានា ដើម្បីការពារជនរងគ្រោះ និងសាក្សីពីការសម្លុតគំរាម និងការសងសឹក។ ការការពារអាចមានជាអាទិ៍ ការរៀបចំឱ្យមានមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ឬបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលដើម្បីផ្តល់នូវការការពារដល់ជនរងគ្រោះ និងមានបុគ្គលិកសន្តិសុខអមដំណើរដូចជា បុគ្គលិកសន្តិសុខនៅក្នុងបន្ទប់តុលាការជាដើម ដើម្បីធានាមិនឱ្យមានហេតុការណ៍អ្វីមួយកើតមាន ចំពោះជនរងគ្រោះ ឬសាក្សី និងដើម្បីបង្ការមិនឱ្យមានការរំខានដល់ការអនុវត្តនីតិវិធីច្បាប់។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងវិធានការដ៏មានប្រសិទ្ធភាពនៃអង្គនីតិប្រតិបត្តិ និងតុលាការ ត្រូវបានអនុវត្ត ដើម្បីការពារជនរងគ្រោះ និងសាក្សី ពីការសម្លុតគំរាម និងការតបតសងសឹក។
- ☐ មានការផ្តល់ឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស សាក្សី និងសមាជិកគ្រួសារ ដែលប្រឈមនឹងហានិភ័យ នៅកន្លែងស្នាក់ប្រកបដោយសុវត្ថិភាព និងសមស្រប។
- ☐ កម្មវិធីការពារសាក្សីរបស់រដ្ឋាភិបាល ផ្តល់សេវាការពារពេញលេញដល់ជនរងគ្រោះ និងមានការសម្របសម្រួលបានល្អ ដើម្បីផ្តល់សេវាដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។
- ☐ កិច្ចព្រមព្រៀងរវាងតុលាការ និងអង្គការសង្គមស៊ីវិល លើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការផ្តល់សេវាការពារ និងការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស សាក្សី និងសមាជិកគ្រួសារដែលប្រឈមនឹងហានិភ័យ។
- ☐ ការផ្តល់ជំនួយនានាពុំមានការកំណត់លក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះ ត្រូវចូលរួមសហការជាមួយអាជ្ញាធរ ឬចូលរួមក្នុងការអនុវត្តនីតិវិធីច្បាប់នោះឡើយ។
- ☐ មានការគោរពសិទ្ធិជនរងគ្រោះក្នុងការបដិសេធ មិនទទួលយកការការពារ និងការផ្តល់ជំនួយនានា។

## វិសាលភាព

លទ្ធផលនេះ រាប់បញ្ចូលបញ្ញត្តិ ដើម្បីកាត់បន្ថយឱកាសបង្កជាការគំរាមកំហែង ឬការបង្ខំសាក្សីឱ្យផ្លាស់ប្តូរចម្លើយ តាមរយៈ៖

- ការរៀបចំឱ្យមានមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ មន្ត្រីនគរបាលអមដំណើរជនរងគ្រោះ និងបុគ្គលិកសន្តិសុខនៅក្នុងបន្ទប់តុលាការ ឬបុគ្គលិកសន្តិសុខផ្សេងទៀត ដើម្បីផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី។
- ការដកព័ត៌មានសម្គាល់អត្តសញ្ញាណចេញពីព័ត៌មានរបស់សាក្សី ជនរងគ្រោះ និងគ្រួសារ ដើម្បីធានាឯកជនភាព និងការរក្សាការសម្ងាត់។
- ផ្តល់កន្លែងស្នាក់នៅដែលមានសុវត្ថិភាព និងសមស្របដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស សាក្សី និងសមាជិកគ្រួសារ ដែលប្រឈមនឹងហានិភ័យ។
- ការសម្របសម្រួលជាមួយនឹងកម្មវិធីការពារសាក្សី និងផ្លាស់ប្តូរទីតាំងរបស់ជនរងគ្រោះ ដើម្បីផ្តល់សេវាការពារឱ្យបានពេញលេញដល់ជនរងគ្រោះ។
- រៀបចំឱ្យមានកិច្ចព្រមព្រៀងរវាងតុលាការ និងអង្គការសង្គមស៊ីវិល ដើម្បីលើកទឹកចិត្ត និងសម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងការបញ្ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្ស សាក្សី និងសមាជិកគ្រួសារដែលប្រឈមនឹងហានិភ័យ ទៅទទួលបានសេវាការពារ និងគាំទ្រនានា។

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អាចអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការបដិសេធមិនទទួលយកការការពារ និងជំនួយ (សម្រាប់មនុស្សពេញវ័យ) និងបង្ហាញពីការយល់ឃើញរបស់ខ្លួន (សម្រាប់កុមារ)។

សេវាការពារ រាប់បញ្ចូលទាំងការផ្តល់កន្លែងស្នាក់នៅដែលសមស្រប និងមានសុវត្ថិភាព ព្រមទាំងការផ្តល់ជំនួយផងដែរ មិនមានភ្ជាប់លក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះ ត្រូវសហការជាមួយអាជ្ញាធរ ឬចូលរួមក្នុងការអនុវត្តនីតិវិធីផ្លូវច្បាប់នោះឡើយ។

គេមិនអាចពឹងអាស្រ័យទាំងស្រុងលើការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស សម្រាប់ធ្វើជាភស្តុតាងក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ទោសជនដែលប្រព្រឹត្តអំពើជួញដូរមនុស្សឡើយ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| វិធានការការពារ និងសេវាដែលផ្តល់ដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ ត្រូវបានអនុវត្ត និងមានធនធានគ្រប់គ្រាន់។ | ការកើនឡើងនៃការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស បង្កការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានដឹកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានដឹក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានដឹក |

# ដំណើរការយុត្តធម៌



### លទ្ធផលរយៈពេលខ្លី (0 ទៅ ២ ឆ្នាំ)

មានការការពារឯកជនភាព និងទិន្នន័យផ្ទាល់ខ្លួនរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេ ក្នុងអំឡុងពេលអនុវត្តនីតិវិធីច្បាប់។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.២.៦, ៤.២.៤។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ៣.៦.៦។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ,ទំព័រ៧៩, ៨៩។
- អនុសញ្ញា ACTIP មាត្រា ១៤(៦)។

### សេចក្តីអធិប្បាយ និងការពន្យល់

រដ្ឋស្លាករដ្ឋជាសមាជិកអាស៊ាន មានកាតព្វកិច្ចការពារឯកជនភាព និងកំណត់អត្តសញ្ញាណជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ដែលក្នុងនោះមានដូចជាការរក្សាការសម្ងាត់នៃនីតិវិធីច្បាប់ ដែលអនុវត្តចំពោះករណីជួញដូរមនុស្ស។

ដើម្បីសម្រេចគោលដៅនេះ ជាការសំខាន់ ដែលរដ្ឋជាសមាជិកអាស៊ាន ត្រូវមានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដែលផ្តល់ឱ្យជនរងគ្រោះនៅសិទ្ធិរក្សាឯកជនភាព និងការសម្ងាត់ និងត្រូវធានាឱ្យមានការអនុវត្តក្របខ័ណ្ឌគតិយុត្ត ដើម្បីការពាររងគ្រោះនៃអំពើជួញដូរមនុស្ស និងគ្រួសាររបស់ពួកគេពីគ្រោះថ្នាក់មកលើរាងកាយ និងផ្លូវចិត្ត នៅពេលដែលពួកគេអាចឆ្លងកាត់ដំណើរការយុត្តិធម៌។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ រាល់វិធានការដែលចាំបាច់ទាំងអស់ ត្រូវបានអនុវត្តដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះ/សាក្សី និងបុគ្គលដែលអាចធ្វើជាសាក្សីបាន ព្រមទាំងគ្រួសាររបស់ពួកគេ។
- ☐ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន ស្ថានភាពផ្ទាល់ខ្លួននិងព័ត៌មានលម្អិតដែលអាចឱ្យគេដឹងអត្តសញ្ញាណដទៃទៀត ត្រូវបានដកចេញ ឬលុបចោល នៅពេលដែលចាំបាច់។
- ☐ មានការការពារឯកជនភាពដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ។
- ☐ នីតិវិធីតុលាការត្រូវបានធ្វើឡើងដោយបិទទ្វារ។
- ☐ ការស៊ើបអង្កេតត្រូវបានធ្វើឡើងជាលក្ខណៈបិទទ្វារ។
- ☐ មានការរក្សាការសម្ងាត់ និងមានការសុំការអនុញ្ញាតពីជនរងគ្រោះនៃអំពើជួញដូរមនុស្ស មុនពេលធ្វើការចែករំលែកសារព័ត៌មាននានារបស់ជនរងគ្រោះ។
- ☐ មានការរៀបចំនូវគោលការណ៍ណែនាំច្បាស់លាស់ស្តីពីការរក្សាអនាមិកភាព/ការបិទបាំងព័ត៌មានសម្គាល់អត្តសញ្ញាណជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។
- ☐ មានការរៀបចំគោលការណ៍ណែនាំច្បាស់លាស់ ស្តីពីការផ្សព្វផ្សាយ និងការចែករំលែកឯកសារនានា។
- ☐ វិធានការការពារត្រូវបានអនុវត្តនៅក្នុងតុលាការ។
- ☐ ការបំពានលើការរក្សាការសម្ងាត់ និងសិទ្ធឯកជនភាពត្រូវបានការស៊ើបអង្កេត និងការចោទប្រកាន់។
- ☐ អ្នកជំនាញក្នុងវិស័យយុត្តិធម៌របស់តុលាការ បានទទួលការបណ្តុះបណ្តាល ផ្តោតលើជនរងគ្រោះ និងមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ដោយមានបញ្ចូលប្រធានបទឯកជនភាព និងការរក្សាការសម្ងាត់។

## វិសាលភាព

លទ្ធផលនេះធានាថា៖

- មានការអនុវត្តរាល់ជំហានដែលចាំបាច់ទាំងអស់ ដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះ/សាក្សី ព្រមទាំងគ្រួសាររបស់ពួកគេ ដូចជា ការរក្សាអនាមិកភាព ឬការបិទបាំងព័ត៌មានអំពីឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត និង/ឬស្ថានភាពផ្ទាល់ខ្លួន ឬព័ត៌មានលម្អិតដែលអាចឱ្យគេដឹងអត្តសញ្ញាណជនរងគ្រោះ ចាប់ពីការស៊ើបអង្កេត រហូតដល់ការជំនុំជម្រះក្នុងតុលាការ ស្របតាមច្បាប់ និងលិខិតបទដ្ឋានដែលកំពុងចូលជាធរមានរបស់ប្រទេស។
- មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ និងអ្នកផ្តល់ការគាំទ្រ រួមទាំងភាគីទាំងអស់ដែលពាក់ព័ន្ធនឹងសំណុំរឿង ត្រូវទទួលខុសត្រូវការពារឯកជនភាពរបស់ជនរងគ្រោះ។
- មានការការពារឯកជនភាព សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្សជាកុមារ និងមានការហាមប្រាមមិនឱ្យបង្ហាញអត្តសញ្ញាណ ឬព័ត៌មានលម្អិតរបស់ពួកគេ ដោយពុំមានការអនុញ្ញាត។
- មានការរក្សាការសម្ងាត់ និងត្រូវសុំការអនុញ្ញាតពីភាគីដែលជាម្ចាស់សិទ្ធិ មុនពេលអាចធ្វើការចែករំលែកសារព័ត៌មាននានាអំពីជនរងគ្រោះដែលអាចធ្វើឱ្យគេដឹងពីអត្តសញ្ញាណ ឬអាសយដ្ឋានរបស់ពួកគេ។
- វិធានការការពារនានា ត្រូវបានអនុវត្តនៅក្នុងតុលាការ ដើម្បីធានាឯកជនភាព សុវត្ថិភាព និងអនាមិកភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ដូចជា ការអនុវត្តនីតិវិធីតុលាការបិទទ្វារ ការស៊ើបអង្កេតបិទទ្វារ ការរៀបចំបន្ទប់រង់ចាំដាច់ដោយឡែក ការកត់ត្រា ការផ្តល់សក្ខីកម្ម និងការប្រើប្រាស់ជម្រើសផ្សេងៗ ដើម្បីផ្តល់ភស្តុតាង។
- ឯកសារ និងសេចក្តីសម្រេចរបស់តុលាការ ត្រូវបានរក្សាអនាមិកភាព និងមានការដាក់ចេញនូវគោលការណ៍ណែនាំច្បាស់លាស់ ដើម្បីការពារមិនឱ្យលេចធ្លាយឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងព័ត៌មានឯកជនដទៃទៀត ដែលអាចធ្វើឱ្យដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស គ្រួសារ ឬសាក្សី។
- ការបំពានឯកជនភាពដោយបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានរាយការណ៍ និងមានការចាត់វិធានការដោយអាជ្ញាធរ ក៏ដូចជា អាចមានការចោទប្រកាន់ទោសអ្នកទាំងនេះ។
- ដោយសហការជាមួយអង្គការ ដែលធ្វើការងារផ្តោតលើជនរងគ្រោះ និងយេនឌ័រ មានការរៀបចំជាការបណ្តុះបណ្តាលអំពីច្បាប់សិទ្ធិមនុស្ស និងការប្រកាន់ផ្នត់គំនិតយេនឌ័រ ដល់អ្នកជំនាញក្នុងវិស័យយុត្តិធម៌។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ការការពារឯកជនភាពអត្តសញ្ញាណ និងការសម្ងាត់របស់ជនរងគ្រោះ គឺជាការអនុវត្តដែលមានលក្ខណៈស្តង់ដារ។ | ការកើនឡើងនៃការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស បង្កការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តិធម៌



## លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

មានការអនុវត្តវិធានការជាក់លាក់ ដើម្បីជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងសាក្សី អាចចូលរួមក្នុងនីតិវិធីតុលាការយ៉ាងមានប្រសិទ្ធភាព។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ២.២.៦, ៣.៣.៨, ៣.៣.៩, ២.៤.១០, ២.៤.១១។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ ផ្នែក ៣.៣.៣, ៣.៦.៦, ៣.៦.៧។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ៤២, ៨១, ៨៥, ៩២។
- អនុសញ្ញា ACTIP មាត្រា ១៤(៦), (៧)។

## សេចក្តីអធិប្បាយ និងការពន្យល់

ចាប់ដែលជនរងគ្រោះចូលមកក្នុងប្រព័ន្ធយុត្តិធម៌ ជាលើកដំបូង រហូតដល់ពេលបញ្ចប់ដំណើរការ ពួកគេត្រូវប្រឈមនឹងការទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មី។ ជារឿយៗជនរងគ្រោះត្រូវឆ្លងកាត់ការសម្ភាសជាច្រើនដង ដោយពួកគេត្រូវរៀបរាប់ដដែលៗឡើងវិញលម្អិតអំពីអ្វីដែលពួកគេជួបប្រទះ ក្នុងអំឡុងពេលដែលត្រូវបានគេជួញដូរ។ អាចមានការសម្តែងនូវកាយវិការ ឬភាសា និងការលើកដាក់សំឡេង ដែលមិនខ្វល់ពីស្ថានភាពរបស់ជនរងគ្រោះ ធ្វើឱ្យពួកគេគិតថា ពួកគេគឺជាអ្នកខុស ឬជាអ្នកត្រូវទទួលខុសត្រូវចំពោះស្ថានភាពដែលកើតឡើងចំពោះពួកគេ។ ស្ថានភាពនេះរឹតតែធ្ងន់ធ្ងរទៅទៀត ដោយហេតុថាអាជ្ញាធរមួយចំនួន ច្រើនតែប្រកាន់ផ្នត់គំនិតចំពោះជនរងគ្រោះ ដោយសារតែភាពលម្អៀងនៅក្នុងវប្បធម៌ ដែលកើតឡើងដោយគេមិនទាំងដឹងផង ដែលអាចប៉ះពាល់ដល់ការវិនិច្ឆ័យ និងការយល់ដឹងរបស់ពួកគេអំពីផលប៉ះពាល់ដែលការប៉ះទង្គិចផ្លូវចិត្ត អាចមានលើជនរងគ្រោះ។ ជនរងគ្រោះដែលជួបប្រទះនឹងជំងឺបាក់ស្បាត អាចទទួលរងគ្រោះថ្នាក់បន្ថែមទៀត នៅពេលដែលពួកគេទំនាក់ទំនងជាមួយនឹងអាជ្ញាធរ ជាពិសេស ប្រសិនបើគេចាត់ទុកសញ្ញាដែលបង្ហាញពីការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះ ថាជាការមិនចង់សហការជាមួយនឹងសមត្ថកិច្ច។

ដូច្នេះជាការចាំបាច់ដែលត្រូវមានការផ្តល់ការការពារជាក់លាក់ ស្របតាមស្ថានភាពរបស់ជនរងគ្រោះ ដល់ជនរងគ្រោះ ដើម្បីកាត់បន្ថយហានិភ័យនៃការទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មី។ វិធានការពិសេសអាចមានជាអាទិ៍ ការរៀបចំសវនាការតាមប្រព័ន្ធអេឡិចត្រូនិក និងតាមប្រព័ន្ធវីដេអូខនហ្វឺរិន ការបំពាក់អេក្រង់ធំៗ ការរៀបចំឱ្យមានជាបន្ទប់រង់ចាំដាច់ដោយឡែក ប្រកចូលសម្រាប់តែជនរងគ្រោះ ការរក្សាអនាមិកភាព ដូចជា ការប្រើប្រាស់ឈ្មោះហៅក្រៅ និងការបំផ្លែងវីដេអូ/សំឡេងខុសពីទម្រង់ដើម ដើម្បីការពារជនរងគ្រោះក្នុងអំឡុងពេលអនុវត្តនីតិវិធី។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានការផ្តល់ការការពារជាក់លាក់ ដល់ជនរងគ្រោះ និង/ឬសាក្សី ដែលប្រឈមនឹងហានិភ័យ ស្របតាមស្ថានភាពរបស់ពួកគេ។
- ☐ នីតិវិធីរបស់តុលាការអនុញ្ញាតឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្សផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូខនហ្វឺរិន និងការការរៀបចំសវនាការតាមប្រព័ន្ធអេឡិចត្រូនិក ការថតវីដេអូទុកជាមុន ការប្រើប្រាស់តំណភ្ជាប់ផ្សាយផ្ទាល់ឬការរៀបចំបន្ទប់ដោយឡែកឬការយកសក្ខីកម្មជាមុនជាដើម។
- ☐ មានការគោរពសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ក្នុងការដកខ្លួនចេញពីដំណើរការយុត្តិធម៌។
- ☐ មានការផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដោយមានថតសំឡេងទុក ឬមានការយល់ព្រមពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។
- ☐ ការផ្តល់សក្ខីកម្មមុនពេលជំនុំជម្រះ កាត់បន្ថយរយៈពេលដែលជនរងគ្រោះជាសាក្សីត្រូវរង់ចាំផ្តល់សក្ខីកម្ម។
- ☐ ការជំនុំជម្រះ និងការអនុវត្តនីតិវិធីនានា ចាប់ផ្តើម និងបញ្ចប់ដោយពុំមានការពន្យារពេលមិនសមហេតុសមផល។
- ☐ មានការគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការបដិសេធមិនទទួលយកជំនួយ និងការគាំទ្រនានា។
- ☐ មានការចាប់តាំងមេធាវី ឬបុគ្គលិកផ្តល់ការគាំទ្រដទៃទៀត ដើម្បីគាំទ្រ និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ជនរងគ្រោះ ក្នុងដំណើរការយុត្តិធម៌ទាំងមូល និងអមដំណើរជនរងគ្រោះ ក្នុងអំឡុងពេលផ្តល់ចម្លើយ។
- ☐ បុគ្គលិកដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះ បានទទួលការបណ្តុះបណ្តាល និងផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

## វិសាលភាព

លទ្ធផលនេះ អាចរួមមាន ការរៀបចំដើម្បីៈ

- ជួយឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស ផ្តល់ភស្តុតាងក្នុងការអនុវត្តនីតិវិធីច្បាប់ តាមរយៈតំណភ្ជាប់ផ្សាយផ្ទាល់ បន្ទប់ដាច់ដោយឡែក ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ប្រព័ន្ធអនឡាញ ឬប្រព័ន្ធវីដេអូខនហ្វឺរិនស៍ ការថតវីដេអូទុកជាមុន ឬការផ្តល់សក្ខីកម្មទុកជាមុន។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានសិទ្ធិដកខ្លួនចេញពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌនៅពេលណាក៏បាន។
- ការផ្តល់សក្ខីកម្មមុនពេលជំនុំជម្រះ ដើម្បីកាត់បន្ថយរយៈពេលដែលជនរងគ្រោះជាសាក្សី ត្រូវរង់ចាំផ្តល់សក្ខីកម្ម។
- ការជំនុំជម្រះ និងនីតិវិធីនានា ចាប់ផ្តើម និងបញ្ចប់ទៅដោយពុំមានការពន្យារពេលមិនសមស្រប ជាពិសេសក្នុងករណីដែលមានពាក់ព័ន្ធនឹងកុមារ។
- ការអនុវត្តពិធីសារ ដើម្បីហាមប្រាមមិនឱ្យមន្ត្រី ឬអ្នកផ្តល់សេវាបង្ខំជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឱ្យចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្សត្រូវទទួលបានព័ត៌មានអំពីសិទ្ធិ ទទួលបានការការពារ ឬជំនួយជាបន្ទាន់ដោយពុំមានលក្ខខណ្ឌ។
- មានការផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដោយមានថតសំឡេងទុក ឬមានការយល់ព្រមពីជនដែលមានអាយុក្រោម ១៨ ឆ្នាំ និងការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។
- មានការចាត់តាំងមេធាវី ឬអ្នកផ្តល់ការគាំទ្រដទៃទៀត ឱ្យជួយគាំទ្រ និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ជនរងគ្រោះ ក្នុងដំណើរការយុត្តិធម៌ទាំងមូល និងអមដំណើរជនរងគ្រោះក្នុងអំឡុងពេលផ្តល់ចម្លើយ។
- រក្សាអនាមិកភាព ឬបិទបាំងព័ត៌មាន ដែលអាចឱ្យគេដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះ ឬគ្រួសាររបស់ពួកគេ ដូចជា ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត និងស្ថានភាពរបស់ខ្លួនដទៃទៀត ដែលអាចធ្វើឱ្យគេដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះ។
- ប្រើប្រាស់អន្តរការី ឬអ្នកផ្តល់ការគាំទ្រ។

មានសេវាផ្តល់ជំនួយដល់ជនរងគ្រោះ សម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលមានបំណងចង់ចូលរួម។ អ្នកផ្តល់ការគាំទ្រ និងអ្នកគ្រប់គ្រងករណី បានទទួលការបណ្តុះបណ្តាល ដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដូចជា ការសម្របសម្រួលជាមួយនឹងស្ថាប័នអយ្យការ ផ្តល់ព័ត៌មាន និង បច្ចុប្បន្នភាពនានា ជូនដំណើរជនរងគ្រោះទៅកាន់តុលាការ និងធានាឱ្យមានការទទួលបានសេវាសមស្រប។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| អត្រាជនរងគ្រោះស្ម័គ្រចិត្តចូលរួមនៅក្នុងនីតិវិធីចោទប្រកាន់ជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស មានការកើនឡើង។ | ការកើនឡើងនៃការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស បង្កការរំខានដល់ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តធម៌



### លទ្ធផលរយៈពេលខ្លី (០ ទៅ ២ ឆ្នាំ)

នីតិវិធីច្បាប់ តម្រូវឱ្យព្រះរាជអាជ្ញា ឬអាជ្ញាធរពាក់ព័ន្ធ ខិតខំទាមទារសំណង បដិទាន និង/ឬសំណងជំងឺចិត្តពីបុគ្គលដែលត្រូវបានផ្តន្ទាទោសពីបទជួញដូរមនុស្ស រួមទាំងសំណងបដិទាន និង/ឬសំណងជំងឺចិត្តពីរដ្ឋផងដែរ ដោយមានការពិគ្រោះយោបល់ជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

### ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៥.២.៣, ៥.២.៥, ៥.២.៦។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ២.៥.១, ៣.៦.៩, ៤.១៥។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៩២។
- អនុសញ្ញា ACTIP មាត្រា ១៤(១៣), ១៤។
- ផែនការមេស្តីពីការបង្កលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៣។

### សេចក្តីអធិប្បាយ និងការពន្យល់

ព្រះរាជអាជ្ញា និងអាជ្ញាធរពាក់ព័ន្ធ អាចជួយឱ្យជនរងគ្រោះទទួលបានសំណងបដិទាន និង/ឬសំណងជំងឺចិត្ត ចំពោះការខូចខាតដែលពួកគេទទួលរង។ ដើម្បីធានាថាជនរងគ្រោះអាចទទួលបានសំណងបដិទាន និង/ឬសំណងជំងឺចិត្ត ជាការសំខាន់ណាស់ដែលព្រះរាជអាជ្ញា និងអាជ្ញាធរពាក់ព័ន្ធ អាចកំណត់អត្តសញ្ញាណ តាមដានដឹង បង្កក ដកហូត រឹបអូសផលនៃបទល្មើស ដែលកើតចេញពីការជួញដូរមនុស្ស រួមទាំងទ្រព្យសម្បត្តិ បរិក្ខារ ឬមធ្យោបាយដទៃទៀត ដែលត្រូវបានប្រើប្រាស់ ឬគ្រោងនឹងត្រូវប្រើប្រាស់ ក្នុងបទល្មើសជួញដូរមនុស្ស។ លើសពីនេះ ចំណុចសំខាន់ដូចគ្នាដែរ ព្រះរាជអាជ្ញា និងអាជ្ញាធរពាក់ព័ន្ធ ត្រូវទទួលបានការបំពាក់បំប៉ន ចំណេះដឹង និងជំនាញ ក្នុងការគណនាតួលេខនៃសំណងបដិទាន និង/ឬសំណងជំងឺចិត្ត សម្រាប់ជនរងគ្រោះក្នុងអំឡុងពេលអនុវត្តនីតិវិធីរបស់តុលាការ។ ការទាមទារសំណងជំងឺចិត្ត (សំណងជំងឺចិត្តដែលផ្តល់ថវិកាដោយរដ្ឋ) មិនគួរពឹងអាស្រ័យតែលើលទ្ធផលនៃការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌតែមួយគត់នោះឡើយ។ ក្រោមអនុសញ្ញា ACTIP រដ្ឋជាសមាជិកអាស៊ាន មានកាតព្វកិច្ច រៀបចំឱ្យមានការវិភាជន៍ថវិកាសមស្រប បង្កើតមូលនិធិបរធនបាលថ្នាក់ជាតិ សម្រាប់ផ្តល់ការថែទាំ និងការគាំទ្រដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ថវិកាសម្រាប់មូលនិធិបរធនបាលថ្នាក់ជាតិនេះ មិនមែនមានប្រភពតែពីផលនៃបទល្មើស និងការវិភាជន៍ធនធានពីរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានប្រភពពីអ្នកផ្តល់ជំនួយអន្តរជាតិផងដែរ។

### បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ រដ្ឋជាសមាជិកអាស៊ាន ផ្តល់សំណងបដិទាន និង/ឬសំណងជំងឺចិត្តដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស តាមរយៈការបញ្ចូលទៅក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ។
- ☐ រដ្ឋជាសមាជិកអាស៊ាន បង្កើតមូលនិធិបរធនបាលសម្រាប់ផ្តល់សំណងដល់ជនរងគ្រោះ ស្របតាមអនុសញ្ញា ACTIP។
- ☐ រដ្ឋជាសមាជិកអាស៊ាន ដាក់ចេញ និងអនុវត្តវិធានការដើម្បីទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្តដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដោយប្រើប្រាស់វិធីសាមញ្ញ ដែលងាយស្រួលសម្រាប់ជនរងគ្រោះ។
- ☐ ទីភ្នាក់ងារ និងអាជ្ញាធរពាក់ព័ន្ធ ជួយដល់ជនរងគ្រោះក្នុងការទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្ត។
- ☐ បណ្តឹងទាមទារសំណងបដិទាននិង/ឬសំណងជំងឺចិត្តរដ្ឋប្បវេណី និង/ឬព្រហ្មទណ្ឌ ត្រូវបានដាក់ ដោយមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬអាជ្ញាធរពាក់ព័ន្ធ។
- ☐ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ឬគោលការណ៍ណែនាំនានា ផ្តល់ឱ្យព្រះរាជអាជ្ញា និងអាជ្ញាធរពាក់ព័ន្ធនៅមូលដ្ឋាន ឬការណែនាំអំពីរបៀប៖
  - ☐ កំណត់អត្តសញ្ញាណ តាមរកប្រភព បង្កក ចាប់យកឬដកហូតផលនៃបទល្មើសដែលកើតចេញអំពីអំពើជួញដូរមនុស្សដូចជាទ្រព្យសម្បត្តិបរិក្ខារ ឬមធ្យោបាយដទៃទៀតដែលត្រូវបានប្រើប្រាស់ ឬគ្រោងនឹងប្រើប្រាស់ដើម្បីប្រព្រឹត្តអំពើជួញដូរមនុស្ស។
  - ☐ គណនាតួលេខសំណងបដិទាន និង/ឬសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះឱ្យបានសមស្រប។
  - ☐ តុលាការចេញដីកាបង្គាប់ឱ្យជនល្មើសដែលត្រូវបានផ្តន្ទាទោសពីបទល្មើសជួញដូរមនុស្ស ឱ្យផ្តល់សំណងបដិទាននិង/ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ។

## វិសាលភាព

លទ្ធផលនេះ រួមមាន៖

- ច្បាប់ ដើម្បីធានាឱ្យមានការផ្តន្ទាទោសអំពើជួញដូរមនុស្សជាបទល្មើសព្រហ្មទណ្ឌ និងផ្តល់សិទ្ធិឱ្យជនរងគ្រោះទទួលបានសំណងបជិទាន និង/ឬសំណងជំងឺចិត្ត ត្រូវបានពង្រឹង និងអនុវត្ត។ ព្រះរាជអាជ្ញា និងអាជ្ញាធរពាក់ព័ន្ធទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬបុគ្គលដែលត្រូវបានសន្មតថាជាជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានសំណងបជិទាន និង/ឬសំណងជំងឺចិត្ត ក្នុងភាសា និងទម្រង់ដែលពួកគេអាចយល់បាន។
- រដ្ឋជាសមាជិកអាស៊ាន បង្កើតមូលនិធិបរធនបាលសម្រាប់ជនរងគ្រោះ ស្របតាមអនុសញ្ញា ACTIP។
- រដ្ឋជាសមាជិកអាស៊ាន បង្កើត និងអនុវត្តយន្តការ ដើម្បីទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្តដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។
- ច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស និងច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធនានា ដូចជា ក្រមព្រហ្មទណ្ឌ គោលការណ៍ណែនាំសម្រាប់អង្គនីតិប្រតិបត្តិ និងតុលាការ ផ្តល់លទ្ធភាពឱ្យតុលាការ ផ្តល់សំណងខូចខាត និងចេញបញ្ជាឱ្យជនល្មើសដែលត្រូវបានផ្តន្ទាទោសពីបទល្មើសជួញដូរមនុស្ស។
- ផ្តល់សំណងបជិទាន និង/ឬសំណងជំងឺចិត្ត រួមទាំងការដកហូតទ្រព្យសម្បត្តិពីជនល្មើសផងដែរ បណ្តឹងទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្តរដ្ឋប្បវេណី និង/ឬព្រហ្មទណ្ឌ ត្រូវបានដាក់ ដោយមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកពាក់ព័ន្ធនានា។
- មានការដកហូតឯកសារធនាគារ ហិរញ្ញវត្ថុ ឬពាណិជ្ជកម្ម និងទ្រព្យសម្បត្តិនានា ពីជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ដោយប្រើប្រាស់ច្រកផ្តល់ជំនួយផ្លូវការ និងក្រៅផ្លូវការរវាងទីភ្នាក់ងារនានា។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលសំណង ជួសជុលការខូចខាត ដែលបង្កឡើងដោយបទល្មើសជួញដូរមនុស្ស។ | ការផ្តល់សំណងដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើស្ថាបនីយកម្ម និងមានការអនុវត្តជាទូទៅ។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានដឹកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានដឹក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានដឹក |

# ដំណើរការយុត្តធម៌



## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទទួលបានព័ត៌មានអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្ត ព្រមទាំងនីតិវិធីនានា ដែលពាក់ព័ន្ធនឹងការផ្ដល់សំណងទាំងនេះ។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៥.១.១, ៥.១.២, ៥.៣.៩។
- មគ្គុទេសក៍ស្ដីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៧៧, ៩២។
- អនុសញ្ញា ACTIP មាត្រា ១៤( ៩ )។

## សេចក្ដីអធិប្បាយ និងការពន្យល់

នៅក្នុងការទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្ត ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវការព័ត៌មានជាក់លាក់អំពីរបៀបទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្ត ព្រមទាំងគោលបំណង និងប្រភពព័ត៌មាននានា ក៏ដូចជាអំពីសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្តប្រសិនបើមាន។

ព័ត៌មានទាំងនេះគួរផ្ដល់ក្នុងភាសានិងក្នុងទម្រង់តែងាយស្រួលយល់រួមទាំងត្រូវមានការកំណត់ជាលក្ខខណ្ឌ និងវិធីសាស្ត្រ ដើម្បីទទួលបានសំណង រយៈពេលរំពឹងទុក ដើម្បីបញ្ចប់នីតិវិធីច្បាប់ និងលទ្ធភាពក្នុងការទទួលបានសំណងទាំងនេះ។ ព័ត៌មាននេះនឹងជួយឱ្យជនរងគ្រោះធ្វើការសម្រេចចិត្តត្រឹមត្រូវ ថាតើត្រូវបន្តចូលរួមក្នុងនីតិវិធីច្បាប់ ដើម្បីទាមទារសំណងជំងឺចិត្ត ឬសំណងបដិទានទៀតដែរឬទេ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- [ ] ច្បាប់ គោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធីនានា មានបញ្ចូលខ្លឹមសារអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទាមទារសំណងបដិទាន និង/ឬសំណងជំងឺចិត្ត។
- [ ] ច្បាប់ គោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធីនានា មានបញ្ចូលខ្លឹមសារស្ដីពីការកាតព្វកិច្ចរបស់សមត្ថកិច្ច ក្នុងការជូនដំណឹងដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អំពីសិទ្ធិស្របច្បាប់របស់ពួកគេ ជាពិសេសសិទ្ធិទទួលបានសំណងបដិទាន និង/ឬសំណងជំងឺចិត្ត។
- [ ] មានការផ្ដល់ព័ត៌មានអំពីវិធាន និងនីតិវិធី សម្រាប់ផ្ដល់សំណងជំងឺចិត្តដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈក្នុងសង្គម រួមទាំងក្រុមងាយរងគ្រោះ ដូចជាស្ត្រី កុមារ និងជនមានពិការភាព។
- [ ] ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលធ្វើការទាមទារសំណង ហើយដែលបានវិលត្រឡប់ទៅកន្លែងដើមរបស់ពួកគេ ឬកំពុងឋិតនៅក្នុងប្រទេសទី ៣ បានទទួលព័ត៌មាន ឬដំបូន្មានដែលចាំបាច់ ក៏ដូចជាការគាំទ្រ ដើម្បីឱ្យពួកគេអាចឆ្លងកាត់ដំណើរការនេះបាន។
- [ ] មានការចាប់តាំងតំណាងផ្លូវច្បាប់ និងអ្នកដែលមានតួនាទីផ្ដល់ការគាំទ្រដល់ជនរងគ្រោះ ឱ្យផ្ដល់ព័ត៌មាន និងការគាំទ្រដល់ជនរងគ្រោះអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេអាចទទួលបានសំណងបដិទាន និង/ឬសំណងជំងឺចិត្ត។

## វិសាលភាព

លទ្ធផលនេះ មានភាពពាក់ព័ន្ធនឹងព័ត៌មានសម្រាប់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដូចជាៈ

- ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធីអំពីការផ្តល់សំណងជំងឺចិត្ត និង/ឬសំណងបជិទានដល់ជនរងគ្រោះ ព្រមទាំងការអនុវត្តលិខិតបទដ្ឋានទាំងនេះ ត្រូវបានដាក់ចេញនិងអនុវត្ត។
- ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធី ស្តីពីការកំណត់អត្តសញ្ញាណ ការបញ្ជូន ការផ្តល់ជំនួយ ការការពារផ្លូវច្បាប់ដល់ជនរងគ្រោះ និងការគាំទ្រនានា ដែលបានលើកឡើងយ៉ាងជាក់ច្បាស់ពីភាពចាំបាច់ក្នុងការផ្តល់ព័ត៌មានដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្សអំពីសិទ្ធិស្របច្បាប់របស់ពួកគេ ក្នុងការទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្ត តាមរយៈប្រកគុលាការរដ្ឋបាល និងប្រកដទៃទៀត។
- ឯកសារព័ត៌មានស្តីពីសំណងបជិទាន និង/ឬសំណងជំងឺចិត្ត គោលបំណង វិធាន និងនីតិវិធី មូលដ្ឋានច្បាប់ ត្រូវបានរៀបចំ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជាភាសា និងក្នុងទម្រង់ដែលងាយស្រួលយល់សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ និងជនមានពិការភាពផងដែរ។
- ព័ត៌មានអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងបជិទាន និង/ឬសំណងជំងឺចិត្ត លក្ខណៈវិនិច្ឆ័យ ដំណើរការដាក់ពាក្យបណ្តឹងដែលមានភាពងាយស្រួល ឯកសារដែលត្រូវមាន ការិយាល័យទទួលបន្ទុករបស់រដ្ឋាភិបាល និងរយៈពេលសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយជាភាសា និងក្នុងទម្រង់ដែលងាយស្រួលយល់ សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ និងជនមានពិការភាពផងដែរ។
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលបានវិលត្រឡប់ទៅកាន់កន្លែងប្រភពដើមរបស់ពួកគេ ឬស្ថិតនៅក្នុងប្រទេសទី ៣ បានទទួលការគាំទ្រ ដើម្បីឱ្យពួកគេអាចទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្ត និងអាចដាក់បណ្តឹងទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្ត នៅទីកន្លែងដែលមានការអនុវត្តនីតិវិធីចោទប្រកាន់សំណុំរឿងជួញដូរមនុស្ស។ ពួកគេបានទទួលដំបូន្មាន និងការគាំទ្រដែលចាំបាច់នានា ក្នុងដំណើរការទាំងមូល។
- មានការផ្តល់សេវាតំណាងផ្លូវច្បាប់ រួមទាំងអ្នកជួយជនរងគ្រោះ ក្នុងដំណើរការយុត្តិធម៌ទាំងមូល ទាំងរដ្ឋប្បវេណី ទាំងព្រហ្មទណ្ឌ ដើម្បីជួយជនរងគ្រោះនៃអំពើជួញដូរមនុស្សក្នុងការទាមទារសិទ្ធិ ទទួលបានសំណងបជិទាន និង/ឬសំណងជំងឺចិត្តនានា។
- ការគាំទ្រដល់ជនរងគ្រោះ ក្នុងការទាមទារសំណងបជិទាន និង/ឬសំណងជំងឺចិត្ត មិនភ្ជាប់លក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះ ត្រូវចូលរួមក្នុងដំណើរការយុត្តិធម៌នោះឡើយ។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលសំណងជួសជុលការខូចខាត ដែលបង្កឡើងដោយបទល្មើសជួញដូរមនុស្ស។ | ការផ្តល់សំណងដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានជីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានជីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានជីក |

# ដំណើរការយុត្តធម៌



## លទ្ធផលរយៈពេលខ្លី ( ០ ទៅ ២ ឆ្នាំ )

មន្ត្រីនានា បានទទួលការបណ្តុះបណ្តាល និងធនធាន ដើម្បីអាចបង្ការមិនឱ្យជនរងគ្រោះនៃអំពើជួញដូរមនុស្ស ទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មី ក្នុងអំឡុងពេលអនុវត្តនីតិវិធីច្បាប់។

## ឯកសារដើមដែលបង្ហាញពីខ្លឹមសារពាក់ព័ន្ធ

- គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ផ្នែក ៣.៣.១២, ៣.៣.១៥។
- គោលការណ៍ណែនាំស្តីពីការធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយមានការយកចិត្តទុកដាក់ចំពោះយេនឌ័រផ្នែក ៣.៥.៧, ៣.៦.៣, ៣.៦.៨។
- មគ្គុទេសក៍ស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់អ្នកឆ្លើយតបជួរមុខ, ទំព័រ ៨៥, ៨៩។
- អនុសញ្ញា ACTIP មាត្រា ១៦(១), (៦)។
- ផែនការមេស្តីពីការបង្គលក្ខណៈអំណោយផលរបស់អាស៊ាន ឆ្នាំ ២០២៥៖ បញ្ជ្រាបសិទ្ធិជនមានពិការភាព APSC ៤។

## សេចក្តីអធិប្បាយ និងការពន្យល់

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ងាយនឹងទទួលរងការប៉ះទង្គិចផ្លូវចិត្ត ដោយមានការបង្ហាញរោគសញ្ញាលើរាងកាយ និងស្ថានភាពផ្លូវចិត្ត នៅពេលដែលពួកគេទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ច ក្នុងរយៈពេលវែងដដែលៗ។ ក្រោយពេលត្រូវបានសង្គ្រោះ ពួកគេអាចអាចទទួលរងការប៉ះទង្គិចផ្លូវចិត្ត និងរងគ្រោះម្តងទៀត នៅក្នុងអំឡុងពេលដែលពួកគេស្វែងរកការការពារ និងទទួលបានយុត្តិធម៌។ ការបណ្តុះបណ្តាលបង្កើនការយល់ដឹង គួរមានការរៀបចំការបណ្តុះបណ្តាលបង្កើនការយល់ដឹងដល់អ្នកឆ្លើយតបចំពោះមុខ មន្ត្រីអនុវត្តច្បាប់ អ្នកផ្តល់សេវា និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យពួកគេចេះសម្គាល់ដឹងពីការប៉ះទង្គិចផ្លូវចិត្ត ដែលជនរងគ្រោះអាចទទួលរងក្នុងអំឡុងពេលដែលពួកគេត្រូវបានគេជួញដូរ។

អនុសញ្ញា ACTIP អំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ាន រៀបចំ និងពង្រឹងកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធអំពីអាការទប់ស្កាត់ និងការឆ្លើយតបចំពោះករណីជួញដូរមនុស្សនិងដោយផ្តោតការយកចិត្តទុកដាក់លើ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស ធ្វើការស៊ើបអង្កេត ចោទប្រកាន់ និងជំនុំជម្រះ អ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ក៏ដូចជា ការពារជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។

## បញ្ជីត្រួតពិនិត្យដែលបង្ហាញពីលទ្ធផលរយៈពេលមធ្យម

- ☐ មានធនធានសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល ដល់ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធដទៃទៀត។
- ☐ មានការផ្តល់ការបណ្តុះបណ្តាល និងរៀបចំសកម្មភាពកសាងសមត្ថភាពដទៃទៀត អំពីទស្សនវិស័យ និងអភិក្រមដែលពាក់ព័ន្ធនឹងពិការភាព។
- ☐ មានការផ្តល់ការបណ្តុះបណ្តាល និងអនុវត្តសកម្មភាពកសាងសមត្ថភាពដទៃទៀតអំពី អភិក្រមដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ។
- ☐ មានការរៀបចំការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពអំពីអភិក្រមសិទ្ធិមនុស្ស។
- ☐ មានការរៀបចំការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព អំពីការប៉ះទង្គិចផ្លូវចិត្ត។
- ☐ មានការរៀបចំការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព អំពីអភិក្រមកុមារមេត្រី។
- ☐ មានការរៀបចំការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព អំពីភស្តុតាងរូបវន្ត និងភ័ស្តុតាងកោសល្យវិច័យ (វេជ្ជសាស្ត្រ និងឌីជីថល)។
- ☐ ចៅក្រម ព្រះរាជអាជ្ញា អ្នកអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធដទៃទៀត បានទទួលការបណ្តុះបណ្តាលអំពីរបៀបការឆ្លើយតបចំពោះជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងជួយគាំទ្រដល់ការបំពេញតម្រូវការរបស់ពួកគេ។

## វិសាលភាព

លទ្ធផលនេះ រាប់បញ្ចូលការរៀបចំជាវគ្គបណ្តុះបណ្តាល និងការផ្តល់ធនធាននានា ដើម្បីធានា៖

- ដើម្បីធានាថា ទីភ្នាក់ងារ ស្ថាប័នបណ្តុះបណ្តាល និងស្ថាប័នសិក្សាស្រាវជ្រាវនានា រៀបចំអនុវត្តកម្មវិធីបណ្តុះបណ្តាលជាទៀងទាត់ដល់មន្ត្រីដែលធ្វើការងារពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស។
- មានធនធានសម្រាប់រៀបចំការបណ្តុះបណ្តាលសម្រាប់ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធដទៃទៀត។
- មានការផ្តល់ការបណ្តុះបណ្តាលអំពីចំណុចខ្លាំង និងចំណុចការខ្វះខាត ពាក់ព័ន្ធនឹងការប្រមូលភស្តុតាងរូបវន្ត និងភស្តុតាងកោសល្យវិច័យ (វេជ្ជសាស្ត្រ និងឌីជីថល) សម្រាប់ករណីជួញដូរមនុស្ស ដើម្បីធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការដកហូតសរីរាង្គ និងការជួញដូរក្នុងទម្រង់ផ្សេងទៀត ដូចជា ការបង្ខំឱ្យប្រព្រឹត្តបទល្មើសជាដើម។

ដើម្បីធានាការគោរពសិទ្ធិដែលជនរងគ្រោះ ត្រូវមានការរៀបចំការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពដទៃទៀត អំពីស្តង់ដារឥរិយាបថរំពឹងទុក និងផលវិបាកនានា ដែលពាក់ព័ន្ធនឹងការអនុវត្តចំណាត់ការ លើករណីជួញដូរមនុស្ស និងគួរបញ្ចូលប្រធានបទ ដូចតទៅ៖

- ទស្សនៈយល់ឃើញ និងអភិក្រមពាក់ព័ន្ធពិការភាព
- អភិក្រមយកចិត្តទុកដាក់ចំពោះយេនឌ័រ
- អភិក្រមសិទ្ធិមនុស្ស
- អភិក្រមផ្អែកលើព័ត៌មានស្តីពីការប៉ះទង្គិចផ្លូវចិត្ត
- អភិក្រមបែបកុមារមេត្រី

ការបណ្តុះបណ្តាល មានគោលបំណងធានាថា៖

- ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធដទៃទៀត បានទទួលការបណ្តុះបណ្តាលអំពីរបៀបអនុវត្តចំណាត់ការចំពោះករណីជួញដូរមនុស្សប្រកបដោយសុក្រឹតភាព។
- ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធដទៃទៀត ទំនាក់ទំនងជាមួយនឹងជនរងគ្រោះនៃអំពើជួញដូរមនុស្សប្រកបដោយសុក្រឹតភាព និងការផ្តល់ការគាំទ្រ។
- ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធដទៃទៀត ការពារជនរងគ្រោះពីការរងគ្រោះជាថ្មី ដូចជា ការសម្ភាសដដែលៗដោយមិនចាំបាច់ ឬការសាកសួរពីភាគីម្ខាងទៀត ដែលបង្កការគំរាមកំហែងដល់ជនរងគ្រោះជាដើម។

| លទ្ធផលរយៈពេលមធ្យម (២ ទៅ ៥ ឆ្នាំ) | លទ្ធផលរយៈពេលវែង (ចាប់ពី ៥ ឆ្នាំឡើងទៅ) |
|---|---|
| ជនរងគ្រោះនៃអំពើជួញដូរមនុស្ស បានទទួលសំណងជួសជុលការខូចខាត ដែលបង្កឡើងដោយបទល្មើសជួញដូរមនុស្ស។ | ការផ្តល់សំណងដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ត្រូវបានធ្វើស្ថាបនីយកម្ម និងអនុវត្តជាទូទៅ។ |

| ក្របខ័ណ្ឌ Building Block Maturity សម្រាប់លទ្ធផលរយៈពេលខ្លី | | |
|---|---|---|
| ☐ | NA | មិនពាក់ព័ន្ធ |
| ☐ | មិនទាន់សម្រេចបានវឌ្ឍនភាព | ពុំមានចំណុចណាមួយត្រូវបានធីកនោះឡើយ |
| ☐ | សម្រេចបានវឌ្ឍនភាពខ្លះៗ | ចំណុចខ្លះត្រូវបានធីក |
| ☐ | សម្រេចបានវឌ្ឍនភាពទាំងស្រុង | ចំណុចទាំងអស់ត្រូវបានធីក |



# ឧទាហរណ៍ បង្ហាញពីការអនុវត្តល្អ ពាក់ព័ន្ធនឹងដំណើរការយុត្តិធម៌

| | |
|---|---|
| **ការការពារពីការសម្លុតគំរាម និងការតបតសងសឹក** | ស្ត្រីជាម្តាយម្នាក់ ខ្ចីលុយពីថៅកែរបស់គាត់ និងទុកកូនស្រីឱ្យសងបំណុលនេះ។ ថៅកែរបស់គាត់មានប្តីជាមន្ត្រីប៉ូលិស។<br><br>កូនស្រីនេះ ត្រូវបានគេបង្ខំឱ្យធ្វើការនៅហាងអ៊ុតសក់របស់គ្រួសារនេះនៅពេលថ្ងៃ នាងមិនបានទៅរៀនឡើយ។ នាងត្រូវបានគេបង្ខំឱ្យគេងជាមួយនឹងបុរសជាប្តី ហើយលើសពីនេះទៅទៀត នាងត្រូវបានកូនប្រុសរបស់គ្រួសារនេះរំលោភសេពសន្ថវៈ។<br><br>ក្មេងស្រីរូបនេះ បានរាយការណ៍ពីស្ថានភាពរបស់នាងទៅកាន់មនុស្សម្នាក់ ដែលនាងជឿទុកចិត្ត ដែលយករឿងនេះ ទៅរាយការណ៍ប្រាប់អង្គការសង្គមស៊ីវិលមួយ។ នាងត្រូវបានគេសង្គ្រោះ ហើយករណីរបស់នាងត្រូវបានទទួលចំណាត់ការ តាមរយៈដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ក្មេងស្រីរូបនេះ ត្រូវបានគេជួយឱ្យរកយុត្តិធម៌ និងទទួលបានការការពារក្នុងនាមជាសាក្សី។<br><br>គ្រួសារដែលប្រព្រឹត្តបទល្មើសនេះ ត្រូវបានចោទប្រកាន់ទោស និងកាត់ទោសឱ្យជាប់ពន្ធនាគារ។ ក្មេងស្រីរូបនេះ អាចត្រឡប់ទៅរៀនវិញ និងទទួលបានសំណងជំងឺចិត្ត។ |
| **ការបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌** | នៅក្នុងប្រទេសឥណ្ឌូនេស៊ី អង្គការទេសន្តប្រវេសន៍អន្តរជាតិ បានរៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាលជាមួយអង្គការសង្គមស៊ីវិល ស្ថាប័នរដ្ឋាភិបាល និងទីភ្នាក់ងារអនុវត្តច្បាប់ដែលពាក់ព័ន្ធ។ ម៉ូឌុលនៃវគ្គបណ្តុះបណ្តាលនេះ រួមមានការកំណត់អត្តសញ្ញាណជនរងគ្រោះ យន្តការបញ្ជូន និងរបៀបញែកភាពខុសគ្នារវាងអំពើជួញដូរមនុស្ស និងបទល្មើសព្រហ្មទណ្ឌដទៃទៀត។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ គេក៏បានរៀបចំម៉ូឌុលជាមួយនឹងតុលាការកំពូល ពាក់ព័ន្ធនឹងការទទួលបានយុត្តិធម៌ សម្រាប់ករណីជួញដូរមនុស្សផងដែរ។ |
| **ការសង្គ្រោះជនរងគ្រោះនៃករណីពលកម្មដោយបង្ខំដោយមន្ត្រីម៉ាឡេស៊ី** | នៅក្នុងឧទាហរណ៍ដែលបង្ហាញពីការអនុវត្ត ដែលផ្តោតលើជនរងគ្រោះ និងយកចិត្តទុកដាក់ចំពោះយេនឌ័រ នីតិវិធីចោទប្រកាន់លើជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ដែលគ្រោងនឹងធ្វើឡើងនៅក្នុងប្រទេសម៉ាឡេស៊ី ត្រូវបានពន្យារពេល ដើម្បីធានាឱ្យមានការផ្តល់ការគាំទ្រឱ្យបានសមស្របដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ជនរងគ្រោះនៃករណីពលកម្មដោយបង្ខំនេះ បានវិលត្រឡប់ទៅទីកន្លែងប្រភពដើមរបស់ពួកគេវិញ ដើម្បីចូលរួមក្នុងនីតិវិធីជំនុំជម្រះ។ ទោះជាយ៉ាងនេះក្តី មុនការជំនុំជម្រះ ភ្នាក់ងារសង្គមកិច្ច បានសម្គាល់ដឹងថាជនរងគ្រោះនេះ ទទួលរងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងប្រឈមនឹងការប៉ះទង្គិចផ្លូវចិត្តជាថ្មី។ ដើម្បីជួយដល់ជនរងគ្រោះ ពួកគេបានសុំឱ្យមានការកាត់បន្ថយចំនួនមន្ត្រី និងរៀបចំឱ្យមានកន្លែងសុវត្ថិភាព និងដែលមានការការពារឯកជនភាព សម្រាប់សម្ភាសជាមួយនឹងជនរងគ្រោះ។ ការស្នើសុំនេះ ត្រូវបានគេផ្តល់ឱ្យ ហើយការសម្ភាសធ្វើឡើងនៅក្នុងសណ្ឋាគារឯកជនមួយកន្លែង បើទោះជាការធ្វើបែបនេះនាំឱ្យមានការពន្យារពេលការអនុវត្តនីតិវិធីជំនុំជម្រះបន្តិចបន្តួចក៏ដោយ។ |

# ឧបសម្ព័ន្ធទី ១៖
# សូចនាករធាតុចេញ

| ល.រ | ធាតុចេញ (សូចនាករ) | ផ្នែកគន្លឹះ |
|---|---|---|
| ១ | ចំនួនយុទ្ធនាការបង្កើនការយល់ដឹងអំពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បែងចែកតាមប្រភេទយុទ្ធនាការ និងក្រុមគោលដៅ ដូចជា អាយុ យេនឌ័រ ដែលជនមានពិការភាព និងកម្រិតអក្ខរកម្ម ឬក្រុមងាយរងគ្រោះដទៃទៀត | ១ |
| ២ | ចំនួនសំណើសុំផ្តល់ព័ត៌មាន និងកិច្ចសហប្រតិបត្តិការជាផ្លូវការ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងរដ្ឋជាសមាជិកអាស៊ាន | ២ |
| ៣ | ចំនួនករណីជួញដូរមនុស្ស បែងចែកតាម GEDSI | ២ |
| ៤ | ចំនួនថ្ងៃគិតជាមធ្យមដែលគេត្រូវការ ដើម្បីបញ្ជាក់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស បែងចែកតាម GEDSI | ២ |
| ៥ | ចំនួន និងភាគរយជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលជាជនមានពិការភាព ដែលមានការចាត់តាំង អាណាព្យាបាលជូន | ២ |
| ៦ | ចំនួន និងភាគរយ ដែលជនរងគ្រោះដែលមានការចាត់តាំងអាណាព្យាបាល បែងចែកតាមប្រភេទ (គ្រួសារ ស្ថាប័ន ។ល។) | ២ |
| ៧ | ភាគរយជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលទទួលបានការអនុញ្ញាត ឱ្យស្នាក់នៅជាបណ្តោះអាសន្ន ដោយឈរលើមូលហេតុសង្គម ឬមូលហេតុមនុស្សធម៌ | ៣ |
| ៨ | ចំនួន និងភាគរយ ជនរងគ្រោះដែលត្រូវបានដាក់ឱ្យស្នាក់នៅទីកន្លែងសមស្រប តាមតម្រូវការរបស់ពួកគេ បែងចែកតាមប្រភេទនៃកន្លែងស្នាក់នៅ (ការថែទាំដោយគ្រួសារធំ ឬការដាក់ឱ្យស្នាក់នៅជាមួយនឹងសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ ផ្ទះស្នាក់នៅជាក្រុមតូច ជម្រកសុវត្ថិភាព ឬមណ្ឌលសុខមាលភាព) | ៣ |
| ៩ | ចំនួន និងភាគរយជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលបានទទួលការវាយតម្លៃលើហានិភ័យសមស្របទៅតាមស្ថានភាពរបស់ពួកគេ ដើម្បីឱ្យពួកគេអាចវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព បែងចែកតាម GEDSI | ៤ |
| ១០ | ចំនួន និងភាគរយជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលត្រូវបានបញ្ជូនទៅរកសេវាថែទាំសុខភាព | ៥ |
| ១១ | ចំនួន និងភាគរយជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលត្រូវបានបញ្ជូនទៅរកសេវាថែទាំសុខភាពផ្លូវចិត្ត | ៥ |
| ១២ | ចំនួនករណីជួញដូរមនុស្ស ដែលត្រូវបានប្តឹង នៅក្នុងឆ្នាំរាយការណ៍ | ៦ |

| | | |
|---|---|---|
| ១៣ | ចំនួន និងរយភាគរយនៃសេចក្ដីសម្រេចរបស់តុលាការ ក្នុងសំណុំរឿងជួញដូរមនុស្ស ដែលត្រូវបានដកចេញនូវព័ត៌មាន ដែលគេអាចសម្គាល់ដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះ និងបញ្ចូលទៅក្នុងប្រព័ន្ធអនឡាញ ក៏ដូចជា ទៅក្នុងប្រព័ន្ធទិន្នន័យយុទ្ធិសាស្ត្រ Sherlock របស់ UNODC | ៦ |
| ១៤ | រយៈពេលជាមធ្យមសម្រាប់ការអនុវត្តចំណាត់ការលើករណីជួញដូរមនុស្ស ដែលជាប់ពាក់ព័ន្ធនឹងកុមារ | ៦ |
| ១៥ | ចំនួនដងគិតជាមធ្យមដែលជនរងគ្រោះនៃអំពើជួញដូរមនុស្ស រាយការណ៍ដោយខ្លួនឯងថាត្រូវបានសម្ភាសដោយស្ថាប័នពាក់ព័ន្ធ | ៦ |
| ១៦ | ចំនួន និងភាគរយ ករណីជួញដូរមនុស្ស ដែលត្រូវបានបញ្ចប់នីតិវិធី និងមានការបង្គាប់ឱ្យផ្ដល់សំណងជំងឺចិត្ត/សំណងបដិទាន និងសំណងជួសជុលការខូចខាតនានា | ៦ |
| ១៧ | ចំនួន និងភាគរយ ករណីការជួញដូរមនុស្ស ដែលត្រូវបានបញ្ចប់ការអនុវត្តនីតិវិធី ហើយជនរងគ្រោះបានទទួលសំណងជំងឺចិត្ត | ៦ |
| ១៨ | ចំនួនសាក្សីនៃករណីជួញដូរមនុស្ស ដែលមានការវាយតម្លៃហានិភ័យទៅតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ និងបែងចែកប្រភេទតាម GEDSI | ៦ |
| ១៩ | ចំនួនសាក្សីក្នុងករណីជួញដូរមនុស្ស ដែលបានទទួលផែនការសុវត្ថិភាព បែងចែកតាម GEDSI | ៦ |
| ២០ | ចំនួនករណីដែលប្រើប្រាស់សេវារបស់អ្នកសម្របសម្រួលជនរងគ្រោះជាសាក្សី | ៦ |

# ឧបសម្ព័ន្ធទី ២៖ ការប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្ស ផ្អែកតាមយេនឌ័រ ពិការភាព និងបរិយាបន្ន នៃមនុស្សពេញវ័យដែលងាយរងគ្រោះ

រដ្ឋជាសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបញ្ចូលព័ត៌មាន គោលការណ៍ និងការអនុវត្ត ដូចខាងក្រោម ទៅក្នុងឧបករណ៍កំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដំណើរការ និងការប្រមូលទិន្នន័យ។

**ការយកចិត្តទុកដាក់ចំពោះភេទ និងយេនឌ័រ**

នៅពេលប្រមូលទិន្នន័យអំពីភេទ យេនឌ័រ ធ្វើការបែងចែកភាពខុសគ្នារវាងភេទ និងយេនឌ័រ។ ភេទ និងយេនឌ័រ មិនដូចគ្នាឡើយ។ សំណួរមួយចំនួនប្រហែលជាមិនសមស្របសម្រាប់កុមារ និងក្មេងជំទង់ឡើយ។ អាស្រ័យលើកម្រិតចាស់ទុំរបស់ក្មេងជំទង់ ពួកគេប្រហែលជាបង្ហាញយេនឌ័ររបស់ខ្លួនថាមិនមែនជាបុរស ហើយក៏មិនមែនជាស្ត្រីនោះដែរ។

- ☐ នៅពេលសាកសួរអំពីភេទ តើអ្នកប្រើប្រាស់ពាក្យ៖ ភេទប្រុស ភេទស្រី ឬអន្តរភាពដែរឬទេ?
- ☐ នៅពេលសាកសួរអំពីយេនឌ័រ តើអ្នកប្រើពាក្យជាអាទិ៍៖ ស្ត្រី បុរស ស្ត្រីប្តូរភេទ បុរសប្តូរភេទដែរឬទេ?
- ☐ នៅពេលសាកសួរអំពីភេទ និងយេនឌ័រ តើអ្នកផ្តល់ជម្រើសឱ្យអ្នកឆ្លើយបង្ហាញពីប្រភេទយេនឌ័ររបស់ពួកគេដែរឬទេ?
- ☐ នៅពេលសាកសួរអំពីភេទ និងយេនឌ័រ តើអ្នកគោរពសិទ្ធិរបស់បុគ្គលដែលជាអ្នកឆ្លើយ ក្នុងការមិននិយាយ ឬមិនបង្ហាញពីភេទ ឬយេនឌ័ររបស់ពួកគេដែរឬទេ?
- ☐ តើអ្នកប្រមូលទិន្នន័យបែងចែកតាមភេទដែរឬទេ?
- ☐ តើអ្នកបែងចែកទិន្នន័យរបស់អ្នក ទៅតាមយេនឌ័រដែរឬទេ?

**ពិការភាព**

ក្រុមវ៉ាស៊ីនតោន បញ្ជាក់ថា៖

> *និយមពិការភាពមានការប្រែប្រួលជាបន្តបន្ទាប់ ហើយបច្ចុប្បន្ននេះត្រូវបានគេឱ្យនិយមន័យថាជាលទ្ធផលនៃអន្តរកម្មរវាងបុគ្គល ដែលមានសមត្ថភាពបំពេញមុខងារនៅមានកម្រិត (ពិបាកបំពេញសកម្មភាព ជាមូលដ្ឋានមួយចំនួន) និងបរិយាកាសដែលមិនបង្កភាពងាយស្រួលដល់ពួកគេ ធ្វើឱ្យពួកគេមិនអាចចូលរួមឱ្យបានពេញលេញនៅក្នុងសង្គម។*[៤៩]

៤៩ Washington Group on Disability Statistics. 2020. The Data Collection Tools Developed by the Washington Group on Disability Statistics and their Recommended Use. Available from: www.washingtongroup-disability.com

ក្រុមវ៉ាស៊ីនតោនមានកម្រងសំណួរមួយចំនួនសម្រាប់មនុស្សពេញវ័យ កុមារ និងក្មេងជំទង់ គេអាចបញ្ចូលកម្រងសំណួរទាំងនេះ ទៅក្នុងប្រព័ន្ធប្រមូលទិន្នន័យរបស់ជាតិ ការអង្កេតតាមប្រធានបទ ការអនុវត្តកម្មវិធីការស្រាវជ្រាវ និងការប្រមូលទិន្នន័យវាយតម្លៃ។ កម្រងសំណួរទាំងនេះ គួរប្រើប្រាស់ស្របតាមគោលការណ៍ណែនាំ ដែលផ្តល់ដោយក្រុមវ៉ាស៊ីនតោន។

- ☐ ប្រព័ន្ធពិនិត្យតាមដាន និងការប្រមូលទិន្នន័យរបស់អ្នក ទទួលស្គាល់ពីរាល់ទម្រង់ទាំងអស់នៃពិការភាព ដូចជា „ស្ថានភាពដែលគេមើលមិនឃើញ" ឧទាហរណ៍ពិការភាពប្រព័ន្ធប្រសាទជាដើម ដែរឬទេ?
- ☐ តើអ្នកធ្វើការប្រមូលទិន្នន័យ ដោយបែងចែកតាមពិការភាពដែរឬទេ?

**ភាពឆ្លើយតប និងការគិតគូរពីវប្បធម៌**

ភាពងាយរងគ្រោះត្រូវបានកំណត់ដោយដំណើរការប្រវត្តិសាស្ត្រ នយោបាយ វប្បធម៌ ស្ថាប័ន និងបរិស្ថាន។ ដំណើរការទាំងនេះ ជាកត្តាកំណត់ពីលក្ខខណ្ឌសង្គម និងបរិស្ថាន ដែលមនុស្សរស់នៅ។ កត្តាវប្បធម៌ ភាសា សេដ្ឋកិច្ច និងសង្គម អាចធ្វើឱ្យមនុស្សកាន់តែងាយរងគ្រោះ ដោយសារករណីជួញដូរមនុស្ស។

- ☐ តើគេយល់យ៉ាងដូចម្តេចខ្លះអំពីប្រវត្តិវប្បធម៌របស់ទីកន្លែងនិងមនុស្សដែលមានការប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្ស?
- ☐ តើគេនិយាយភាសាអ្វីខ្លះ នៅពេលដែលគេប្រមូលទិន្នន័យករណីជួញដូរមនុស្ស?
- ☐ តើមានក្រុមជាតិពន្ធុអ្វីខ្លះ ដែលគេកំពុងប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្សនេះ?
- ☐ តើមានការអនុវត្តនិងការប្រតិបត្តិជំនឿសាសនាអ្វីខ្លះនៅទីកន្លែងដែលគេប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្ស?
- ☐ តើទីតាំងភូមិសាស្ត្រមានឥទ្ធិពលអ្វីខ្លះទៅលើវប្បធម៌នៅទីកន្លែងដែលគេប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្ស?
- ☐ តើសំឡេងរបស់នរណាខ្លះ ដែលគេឮកាន់តែខ្លាំង និងសំឡេងរបស់នរណាខ្លះ ដែលគេឮកាន់តែតិច និងតើអ្នកឆ្លើយតបចំពោះបញ្ហាអតុល្យភាពអំណាចរវាងបុគ្គលម្នាក់ៗ សហគមន៍ ឬស្ថាប័ននានាយ៉ាងដូចម្តេច នៅទីកន្លែងដែលគេប្រមូលទិន្នន័យអំពីករណីជួញដូរមនុស្ស?
- ☐ នៅពេលដែលគេនិយាយអំពីអាយុ តើអ្នកផ្តល់ជម្រើសអ្វីខ្លះ ដល់បុគ្គលនានា ក្នុងការបង្ហាញពីអាយុរបស់ពួកគេ តាមបែបផែនដែលគោរពឯកជនភាពរបស់ពួកគេ?
- ☐ នៅពេលសាកសួរអំពីការអប់រំ តើអ្នកផ្តល់ឱ្យបុគ្គលម្នាក់ៗនូវជម្រើសយ៉ាងដូចម្តេច ដើម្បីបង្ហាញពីកម្រិតនៃការអប់រំរបស់ពួកគេ តាមបែបផែនដែលមិនធ្វើឱ្យពួកគេទទួលរងភាពអាម៉ាស់ ឬកាន់តែទទួលរងភាពអាម៉ាស់?
- ☐ តើវណ្ណៈ និងចំណូល (ស្ថានភាពសង្គម និងសេដ្ឋកិច្ច) មានឥទ្ធិពលអ្វីខ្លះ លើទិន្នន័យករណីជួញដូរមនុស្សដែលកំពុងត្រូវបានប្រមូល?